ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពផែនដី

កម្រងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពី ការពិនិត្យធម្មនុញ្ញភាព និងការបកស្រាយរដ្ឋធម្មនុញ្ញ

ខែមករា ឆ្នាំ២០១៨

មាតិកា

ទំព័រ

១-សេចក្តីសម្រេចលេខ:០១ កបជ.សសរ.ច ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១, ១២,១៣,១៨,២២,២៤,២៦,២៨,៣០,៣៤,៥១ និងមាត្រាទាំងឡាយ នៃជំពូកទី៧ ដល់ជំពូកទី១៤.....1-3

២-សេចក្តីសម្រេចលេខ:០៤ កបជ.សសរ.ច ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ សុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា.....3-4

៣-សេចក្តីសម្រេចលេខ:០៦ កបជ.សសរ.ច ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៩ សុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាព នៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា.....4-5

៤-សេចក្តីសម្រេចលេខ:០៧ កបជ.សសរ.ច ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់.....6

៥-សេចក្តីសម្រេចលេខ:០៨ កបជ.សសរ.ច ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម.....6-7

៦-សេចក្តីសម្រេចលេខ:០៩ កបជ.សសរ.ច ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន.....7-8

៧-សេចក្តីសម្រេចលេខ:១០ កបជ.សសរ.ច ចុះថ្ងៃទី២៨ ឧសភា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញនៃច្បាប់ស្តីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច.....9

៨-សេចក្តីសម្រេចលេខ:១១ កបធ.សសរ.ច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩ សំណើសុំឲ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ.....10-11

៩-សេចក្តីសម្រេចលេខ:១២ កបធ.សសរ.ច ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន.....11-12

១០-សេចក្តីសម្រេចលេខ:១៣ កបធ.សសរ.ច ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៩ ស្នើសុំឲ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន.....12-13

១១-សេចក្តីសម្រេចលេខ:១៤ កបធ.សសរ.ច ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ.....13-14

១២-សេចក្តីសម្រេចលេខ:០៣៥/០០១/២០០០ កបធ.ច ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០០ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា.....14-15

១៣-សេចក្តីសម្រេចលេខ:០៣៧/០០៣/២០០០ កបធ.ច ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា.....15-16

១៤-សេចក្តីសម្រេចលេខ:០៣៩/០០១/២០០១ កបធ.ច ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០១ ស្នើសុំពិនិត្យធម្មនុញ្ញភាពស្តីពីច្បាប់អគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា.....17-18

១៥-សេចក្តីសម្រេចលេខ:០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ស្នើសុំពិនិត្យឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ.....19-22

១៦-សេចក្តីសម្រេចលេខ:០៤១/០០៣/២០០១ កបធ.ច ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់.....22-23

១៧-សេចក្តីសម្រេចលេខ:០៤២/០០៤/២០០១ កបធ.ច ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០១ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់.....23-24

១៨-សេចក្តីសម្រេចលេខ:០៤៣/០០៥/២០០១ កបធ.ច ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០១ ស្នើឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃការធ្វើនិយតកម្មមាត្រា៣ នៃច្បាប់ស្តីពីបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តិឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ.....24-25

១៩-សេចក្តីសម្រេចលេខ:០៤៧/០០២/២០០២ កបធ.ច ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.....25-26

២០-សេចក្តីសម្រេចលេខ:០៥២/០០៣/២០០៣ កបធ.ច ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០១ ស្នើឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ៣៦ និងប្រការ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា.....27-28

២១-សេចក្តីសម្រេចលេខ:០៥៨/០០១/២០០៤ កបធ.ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា.....28-29

២២-សេចក្តីសម្រេចលេខ:០៦០/០០២/២០០៤ កបធ.ច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៤ ស្នើសុំពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ..... 29-30

២៣-សេចក្តីសម្រេចលេខ:០៦២/០០៤/២០០៤ កបធ.ច ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម.....30-31

២៤-សេចក្តីសម្រេចលេខ:០៦៣/០០៥/២០០៤ កបធ.ច ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃមាត្រា៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល.....32-33

២៥-សេចក្តីសម្រេចលេខ:០៦៤/០០៦/២០០៤ កបធ.ច ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ.....33-35

២៦-សេចក្តីសម្រេចលេខ: ០៦៥/០០៧/២០០៤ កបធ.ច ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញភាពនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា៣ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៧ មាត្រា១៨ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ មាត្រា២៤ មាត្រា២៧ មាត្រា២៩ មាត្រា៣១ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា ៣៩ មាត្រា៤០ មាត្រា៤២ មាត្រា៤៣ មាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ មាត្រា និងមាត្រា៤៧ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ.....35-37

២៧-សេចក្តីសម្រេចលេខ:០៦៦/០០៨/២០០៤ កបធ.ច ចុះថ្ងៃ០៣ ខែធ្នូ ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.....38

២៨-សេចក្តីសម្រេចលេខ:០៦៧/០០៩/២០០៤ កបធ.ច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញភាពនៃច្បាប់ស្តីការបង្កើតក្រសួងកិច្ចការនារី.....39

២៩-សេចក្តីសម្រេចលេខ:០៦៨/០១០/២០០៤ កបធ.ច ចុះថ្ងៃទី០៣ ខែធ្នូ២០០៤ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា.....39-40

៣០-សេចក្តីសម្រេចលេខ:០៦៩/០០១/២០០៥ កបធ.ច ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ២,៣,៤,៥,៦,៧,៩,១០,១៤,១៥,១៧,២២,៣១ថ្មី,៣៣,៤០,៤១,៤៨,៥១,៥៥, ៥៦,៥៨,៥៩,៦០ និងប្រការ៨៣ នៃបញ្ញាផ្ទៃក្នុងនៃរដ្ឋសភា.....40-41

៣១-សេចក្តីសម្រេចលេខ:០៧០/០០២/២០០៥ កបធ.ច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតាំងសមាជិកព្រឹទ្ធសភា.....42

៣២-សេចក្តីសម្រេចលេខ:០៧១/០០៣/២០០៥ កបធ.ច ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៥ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពប្រការ៤៧ថ្មី(ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា.....43

៣៣-សេចក្តីសម្រេចលេខ:០៧២/០០៤/២០០៥ កបធ.ច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពប្រការ៤៤ថ្មី នៃ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា.....43-44

៣៤- សេចក្តីសម្រេចលេខ:០៧៤/០០១/២០០៦ កបធ.ច ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ៦ថ្មី ៥ថ្មី ១០ថ្មី ៣៥,៤៧ថ្មី (ពីរ) និងប្រការ៨២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា..... 44-45

៣៥-សេចក្តីសម្រេចលេខ:០៧៥/០០២/២០០៦ កបធ.ច ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម..... 45-46

៣៦-សេចក្តីសម្រេចលេខ:០៧៦/០០៣/២០០៦ កបធ.ច ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្ម ប្រការ១៥ថ្មី និងប្រការ៤៨ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា..... 46-47

៣៧-សេចក្តីសម្រេចលេខ:០៧៧/០០៤/២០០៦ កបធ.ច ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា.....47-49

៣៨-សេចក្តីសម្រេចលេខ:០៧៨/០០៥/២០០៦ កបធ.ច ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់..... 49-50

៣៩-សេចក្តីសម្រេចលេខ:០៧៩/០០៦/២០០៦ កបធ.ច ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព អត្ថបទច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.....50-51

៤០-សេចក្តីសម្រេចលេខ:០៨០/០០៧/២០០៦ កបធ.ច ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា.....51-52

៤១-សេចក្តីសម្រេចលេខ:០៨១/០០៨/២០០៦ កបធ.ច ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា.....52-53

៤២-សេចក្តីសម្រេចលេខ: ០៨២/០០៩/២០០៦ កបធ.ច ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា៥ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ.....53-54

៤៣-សេចក្តីសម្រេចលេខ:០៨៨/០១៥/២០០៦ កបធ.ច ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០០៦ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិ នៃកម្ពុជា.....54-55

៤៤-សេចក្តីសម្រេចលេខ:០៨៩/០១៦/២០០៦ កបធ.ច ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ ស្នើសូមពិនិត្យមាត្រា៤ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ ដើម្បីធ្វើការប្រកាសថាមិនស្របនឹងរដ្ឋធម្មនុញ្ញ.....55-56

៤៥-សេចក្តីសម្រេចលេខ:០៩០/០០១/២០០៧ កធច.ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ.....57

៤៦-សេចក្តីសម្រេចលេខ:០៩១/០០២/២០០៧ កបធ.ច ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ស្នើសុំឲ្យក្រុមធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.....58-59

៤៧-សេចក្តីសម្រេចលេខ:០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ..... 59-60

៤៨-សេចក្តីសម្រេចលេខ:០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យលើអត្ថបទច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ..... 60-61

៤៩-សេចក្តីសម្រេចលេខ:០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ.....61-62

៥០-សេចក្តីសម្រេចលេខ:១០៨/០០១/២០១០ កបធ.ច ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីអស្សាមិករណ៍..... 63-65
៥១-សេចក្តីសម្រេចលេខ:១១០/០០៣/២០១០ កបធ.ច ចុះថ្ងៃទី០១ មេសា ឆ្នាំ២០១០
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញភាពនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ..... 65-67
៥២-សេចក្តីសម្រេចលេខ:១១៣/០០១ ២០១១ កបធ.ច ចុះថ្ងៃទី០១ ខែកុម្ភៈឆ្នាំ២០១១
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និងការ
ប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា..... 67-69
៥៣-សេចក្តីសម្រេចលេខ:១១៤/០០២/២០១១ កបធ.ច ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភា
និងព្រឹទ្ធសភា.....69-71
៥៤-សេចក្តីសម្រេចលេខ:១១៥/០០៣/២០១១ កបធ.ច ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្ម
ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ.....71-73
៥៥-សេចក្តីសម្រេចលេខ:១១៦/០០៤/២០១១ កបធ.ច ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្ម
ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ..... 73-77
៥៦-សេចក្តីសម្រេចលេខ:១១៧/០០៥/២០១១ កបធ.ច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្ម
ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់.....78-79
៥៧-សេចក្តីសម្រេចលេខ:១១៨/០០៦/២០១១ កបធ.ច ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី
ការប្រឆាំងអំពើពុករលួយ.....79-80
៥៨-សេចក្តីសម្រេចលេខ:១២២/០០៣/២០១២ កបធ.ច ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២
ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា....81-82

៥៩-សេចក្តីសម្រេចលេខ:០២ កបធ.សសរ.ច ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩ សុំឲ្យពិនិត្យបកស្រាយមាត្រាមួយចំនួននៃច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មលើមាត្រានិងជំពូកមួយចំនួន.....83-84

៦០-សេចក្តីសម្រេចលេខ:០៣ កបធ.សសរ.ច ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ សុំឲ្យពិនិត្យបកស្រាយមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញ.....84-85

៦១-សេចក្តីសម្រេចលេខ:០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី១៥ ខែមិថុនាឆ្នាំ២០០០ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា១១៣ថ្មី ជំពូកទី៨ នៃរដ្ឋធម្មនុញ្ញ.....85-89

៦២-សេចក្តីសម្រេចលេខ:០៣៨/០០៤/២០០១ កបធ.ច ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា១១២ថ្មី នៃរដ្ឋធម្មនុញ្ញ..... 89-90

៦៣-សេចក្តីសម្រេចលេខ:០៤៤/០០៦/២០០១ កបធ.ច ចុះថ្ងៃទី០៩ ខែតុលាឆ្នាំ២០០១ ប្តឹងពីការរំលោភរដ្ឋធម្មនុញ្ញ នៃក្រុមអ្នកតំណាងរាស្ត្រ០៦រូប ក្នុងគណៈកម្មការសាធារណការដឹកជញ្ជូន ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពលនិងពាណិជ្ជកម្ម នៃរដ្ឋសភា លើមាត្រាទាំងឡាយក្នុងជំពូកទី៣ ស្តីពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា..... 90-91

៦៤-សេចក្តីសម្រេចលេខ:០៤៨/០០៣/២០០២ កបធ.ច ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០០២ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ"មាត្រា១០១ថ្មី"និងពាក្យ "ការបោះឆ្នោតអសកល" ដែលមានក្នុងមាត្រា៩៩ថ្មី និងមាត្រា១០០ថ្មី នៃរដ្ឋធម្មនុញ្ញ.....91-92

៦៥-សេចក្តីសម្រេចលេខ:០៤៩/០០៤/២០០២ កបធ.ច ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា១១៣ថ្មីកថាខណ្ឌទី២ និងទី៥ នៃរដ្ឋធម្មនុញ្ញ.....93-95

៦៦-សេចក្តីសម្រេចលេខ:០៥៧/០០៥/២០០៣ កបធ.ច ចុះថ្ងៃទី២២ ខែកក្កដាឆ្នាំ២០០៣ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយវាក្យខ័ណ្ឌទី១ មាត្រា៧៦ និងមាត្រា៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ.....95-98

៦៧-សេចក្តីសម្រេចលេខ:០៦១/០០៣/២០០៤ កបធ.ច ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៤ សុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា៧ នៃរដ្ឋធម្មនុញ្ញ.....98-99

៦៨-សេចក្តីសម្រេចលេខ:១០៧/០០៣/២០០៩ កបធ.ច ចុះថ្ងៃទី២៣ ខែធ្នូ២០០៩ ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៤ និងមាត្រា៧៣ នៃរដ្ឋធម្មនុញ្ញ.....99-101

៦៩-សេចក្តីសម្រេចលេខ:១១២/០០៥/២០១០ កបធ.ច ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយអំពីសុពលភាព នៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ..... 101-102

៧០-សេចក្តីសម្រេចលេខ:០២ កបធ.សសរ.ច ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៩ ស្នើសុំបកស្រាយនូវមាត្រាមួយចំនួននៃច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មលើ មាត្រា និងជំពូកមួយចំនួនដែលត្រូវរដ្ឋសភាអនុម័តកាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ ១៩៩៩..... 105-106

៧១-សេចក្តីសម្រេចលេខ:០៣ កបធ.សសរ.ច ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ សុំបកស្រាយមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញ..... 108-109

៧២-សេចក្តីសម្រេចលេខ:០៣៦/០០២/២០០០ កបធ.សសរ.ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០ សំណើសុំបកស្រាយមាត្រា១១៣ថ្មី ជំពូកទី៨ថ្មី នៃរដ្ឋធម្មនុញ្ញ...115-116

៧៣-សេចក្តីសម្រេចលេខ:០៣៨/០០២/២០០០ កបធ.ច ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០០ សំណើសុំបកស្រាយមាត្រា១១២ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា....118-119

៧៤-សេចក្តីសម្រេចលេខ:០៤៨/០០៣/២០០២ កបធ.ច ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២ សំណើសុំបកស្រាយ មាត្រា១០១ថ្មី និងពាក្យ (បោះឆ្នោតអសកល) ដែលមានប្រើ ក្នុងមាត្រា៩៩ថ្មី និងមាត្រា១០០ថ្មី នៃរដ្ឋធម្មនុញ្ញ.....121-122

៧៥-សេចក្តីសម្រេចលេខ:០៤៩/០០៤/២០០២ កបធ.ច ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០២ សំណើសុំបកស្រាយ មាត្រា១១៣ថ្មី កថាខ័ណ្ឌទី២ និងទី៥ នៃរដ្ឋធម្មនុញ្ញ.....124-127

៧៦-សេចក្តីសម្រេចលេខ:០៥៤/០០៥/២០០៣ កបធ.ច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៣ សំណើសុំបកស្រាយវាយខ័ណ្ឌទី១ មាត្រា៧៦ និងមាត្រា៩៥ នៃរដ្ឋធម្មនុញ្ញ.....129-132

៧៧-សេចក្តីសម្រេចលេខ:០៦១/០០៣/២០០៤ កបធ.ច ចុះថ្ងៃទី០៧ខែកញ្ញា ឆ្នាំ២០០៤ សំណើសុំបកស្រាយ មាត្រា៧ នៃរដ្ឋធម្មនុញ្ញ.....134-135
៧៨-សេចក្តីសម្រេចលេខ:១០៧/០០៣/២០០៩ កបធ.ច ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ សំណើសុំបកស្រាយ មាត្រា៤ និងមាត្រា៤៣នៃរដ្ឋធម្មនុញ្ញ.....137-139
៧៩-សេចក្តីសម្រេចលេខ:១១២/០០៥/២០១០ កបធ.ច ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ សំណើសុំបកស្រាយសុពលភាពនៃចំណុចទី៤ មាត្រា១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ.....141-143
៨០-សេចក្តីសម្រេចលេខ:១៥៥/០០៣/២០១៥ កបធ.ច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ សំណើសុំបកស្រាយ មាត្រា៩១ថ្មី នៃរដ្ឋធម្មនុញ្ញ.....145-147
៨១-សេចក្តីសម្រេចលេខ:០៤៥/០០៧/២០០១ កបធ.ច ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ សំណើសុំបកស្រាយ មាត្រា១២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់.....150-151
៨២-សេចក្តីសម្រេចលេខ:០៤៦/០០១/២០០២ កបធ.ច ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០២ សំណើសុំបកស្រាយ មាត្រា៣៨ នៃព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ អំពីស្ថាប័នដែលមានសមត្ថកិច្ចផ្តន្ទាទោស.....154-155
៨៣-សេចក្តីសម្រេចលេខ:០៥០/០០១/២០០៣ កបធ.ច ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៣ សំណើសុំបកស្រាយ មាត្រា៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ដែលអនុម័ត ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១.....157-159
៨៤-សេចក្តីសម្រេចលេខ:០៥៣/០០៤/២០០៣ កបធ.ច ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៣ បណ្តឹងរបស់លោក គល់ បញ្ញា នាយកប្រតិបត្តិ នៃគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា សុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា ១៣៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.....163-165

៨៥-សេចក្តីសម្រេចលេខ:០៥៨/០០៩/២០០៣ កបធ.ច ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៣ សំណើសុំបកស្រាយ មាត្រា១២៤ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.....168-169

៨៦-សេចក្តីសម្រេចលេខ:១០៥/០០១/២០០៩ កបធ.ច ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ សំណើសុំបកស្រាយ មាត្រា១៧ និងមាត្រា១៨ នៃច្បាប់ស្តីពីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨.....171-173

៨៧-សេចក្តីសម្រេចលេខ:១០៦/០០១/២០០៩ កបធ.ច ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ សំណើសុំបកស្រាយ និងពិនិត្យធម្មនុញ្ញភាពនៃមាត្រា២៩ នៃច្បាប់ស្តីពីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងបកស្រាយមាត្រា១៦ នៃច្បាប់ស្តីពីគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់.....176-179

៨៨-សេចក្តីសម្រេចលេខ:១០៩/០០២/២០១០ កបធ.ច ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ សំណើសុំបកស្រាយ មាត្រា១៦ វាក្យខ័ណ្ឌទី៤ នៃច្បាប់ស្តីពីភូមិបាល.....181-182

៨៩-សេចក្តីសម្រេចលេខ:១១១/០០៤/២០១០ កបធ.ច ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១០ សំណើសុំបកស្រាយ មាត្រា៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ.....184-190

៩០-សេចក្តីសម្រេចលេខ:១៩២/០៣២/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ សំណើសុំពិនិត្យធម្មនុញ្ញភាព លើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ.....191-197

៩១-សេចក្តីសម្រេចលេខ:១៩០/០៣០/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ សំណើសុំពិនិត្យធម្មនុញ្ញភាព លើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា.....199-205

៩២-សេចក្តីសម្រេចលេខ:១៩១/០៣១/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ សំណើសុំពិនិត្យធម្មនុញ្ញភាព លើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់.....207-211

៩៣-សេចក្តីសម្រេចលេខ:១៨៩/០២៩/២០១៧ កបធ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧ សំណើសុំពិនិត្យធម្មនុញ្ញភាព លើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.....217-219

៩៤-សេចក្តីសម្រេចលេខ:១៨៧/០២៧/២០១៧ កបធ.ច ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ សំណើសុំពិនិត្យធម្មនុញ្ញភាព លើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ.....224-228

៩៥-សេចក្តីសម្រេចលេខ:១៨៦/០២៦/២០១៧ កបធ.ច ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ សំណើសុំពិនិត្យធម្មនុញ្ញភាព លើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា.....231-237

៩៦-សេចក្តីសម្រេចលេខ:១៨៥/០២៥/២០១៧ កបធ.ច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ សំណើសុំពិនិត្យធម្មនុញ្ញភាព លើច្បាប់ស្តីពីគណបក្សនយោបាយ.....243-252

៩៧-សេចក្តីសម្រេចលេខ:១១៣/០០១/២០១១ កបធ.ច ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ សំណើសុំពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា.....253-256

សេចក្តីសម្រេច លេខ : ០១ កបជ.សសរ.ច ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

.....

-បានឃើញសំណើរបស់ក្រុមអ្នកតំណាងរាស្ត្រ ១៩ នាក់ **ឱ្យពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ និង មាត្រាទាំងឡាយនៃជំពូកទី៧ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញដើម្បីបង្កើតព្រឹទ្ធសភាដែលជាអង្គការនីតិប្បញ្ញត្តិមួយទៀតដែលផ្តុំយកទាំងស្រុងទៅលើខ្នឹមសារនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ពិសេសមាត្រា ៥០ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៩៩** ដែលទទួលបាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ០៩ ខែ មីនា ឆ្នាំ១៩៩៩ និង **សំណើសុំពិនិត្យធម្មនុញ្ញភាពនៃមាត្រា ១០០ ថ្មី និង ១៥៧ ថ្មី នៃច្បាប់ធម្មនុញ្ញ** ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ១៩៩៩ ដែលទទួលបាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃទី ១៧ ខែ មីនា ឆ្នាំ១៩៩៩ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍
ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៥០ ៥១ ៥៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ គឺអនុលោមជាអាទិ៍ តាមមាត្រា ១៣២ នៃជំពូកទី ១៣ មិនប៉ះពាល់ដល់មាត្រា ១៣៣ និង មាត្រា ១៣៤ នៃជំពូកដដែលទេ

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ៥០ ត្រង់វាក្យខ័ណ្ឌទី១ ដែលបានចែងថា "រដ្ឋសភាជាអង្គការតែមួយគត់ដែលមានអំណាចនីតិប្បញ្ញត្តិ។ អំណាចនេះរដ្ឋសភាមិនអាចប្រគល់ឱ្យទៅអង្គការ ឬ បុគ្គលណាមួយបានឡើយ " ត្រូវបានជំនួសដោយមាត្រា ៥០ ថ្មី ត្រង់វាក្យខ័ណ្ឌទី១ ដែលចែងថា : " រដ្ឋសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន" និង ដោយមាត្រា ៥៩ ថ្មី ត្រង់វាក្យខ័ណ្ឌទី១ ដែលចែងថា : "ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញការកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន" រដ្ឋធម្មនុញ្ញមិនមានហាមឃាត់មិនឱ្យធ្វើវិសោធនកម្មមាត្រានេះទេ

-យល់ឃើញថា រដ្ឋធម្មនុញ្ញមិនតម្រូវឱ្យធ្វើប្រជាមតិទេ វាល់ករណីដែលធ្វើវិសោធនកម្ម

-យល់ឃើញថា ក្នុងប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្សក៏មានប្រើការបោះឆ្នោតអសកលក្នុងការជ្រើសតាំងសមាជិកព្រឹទ្ធសភាដែរ

-យល់ឃើញថា ល័ក្ខខ័ណ្ឌនៃការបោះឆ្នោតជ្រើសតាំងព្រឹទ្ធសភានឹងត្រូវកំណត់ដោយច្បាប់បោះឆ្នោតមួយដោយឡែក

-យល់ឃើញថា : មាត្រា ១៥៧ ថ្មី ជាមាត្រាមួយដែលនៅក្នុងអន្តរប្បញ្ញត្តិសម្រាប់តែអនុវត្តក្នុងនីតិកាលទី១ តែប៉ុណ្ណោះ ដូច្នេះមិនប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្សទេ។ អំពីល័ក្ខ័ណ្ឌទូទៅសម្រាប់ជ្រើសតាំងសមាជិកព្រឹទ្ធសភាសម្រាប់នីតិកាលក្រោយ ត្រូវអនុវត្តតាមមាត្រា ១០១ ថ្មី នៃច្បាប់ធម្មនុញ្ញដែលបានគោរពទៅតាមប្រព័ន្ធប្រជាធិបតេយ្យរួចហើយ

-យល់ឃើញថា ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៥០ ៥១ ៥៣ និង មាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី ១៤ ដើម្បីបង្កើតព្រឹទ្ធសភាមិនប៉ះពាល់ដល់ធម្មនុញ្ញភាពទេ។

សម្រេច

មាត្រា ១ : ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៥០ ៥១ ៥៣ និង មាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ០៤ កបធ. សសរ.ច ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញសំណើលេខ ០០៣/៤៩៩/ពស.រប ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ១៩៩៩ របស់សម្តេចប្រធានព្រឹទ្ធសភា **សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា** ដែលទទួលបាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ១២ ខែ មេសា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍រុបស់សមាជិការយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់កថាខ័ណ្ឌទី២ ឃ្លាទី១ ចែងថា " បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ។ " ការសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងដោយសម្តេចប្រធានព្រឹទ្ធសភា ជាការស្របតាមរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាការកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្អែកតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី២ ឃ្លាទី២ ដែលចែងថា : " ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ។"

-យល់ឃើញថា ឃ្លាដើមនៃប្រការ ៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាចែងថា : "ក្រោយពីព្រះមហាក្សត្រ និង សម្តេចព្រះរាជអគ្គមហេសី..." មានលក្ខណៈខុសនឹងប្រការ ២ ឃ្លាទី ២ ដែលចែងថា : "ព្រះមហាក្សត្រ សម្តេចព្រះរាជអគ្គមហេសី..." គឺឃ្លាក្រោយនេះពុំមានពាក្យ " និង " ទេ

-យល់ឃើញថា ប្រការ ៤៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ស្តីពីការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបឱ្យដឹកនាំការប្រជុំបន្ត ពុំមានចែងក្នុងរដ្ឋធម្មនុញ្ញទេ និង ជាប្រការមួយពិបាកនឹងអនុវត្តក្នុងការជាក់ស្តែង។

សម្រេច

មាត្រា ១ : បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាមាន ១៦ ជំពូក និង ៨០ មាត្រា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ៩ ខែ មេសា ឆ្នាំ១៩៩៩ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៤៨ ដែលមិនស្របនឹងមាត្រា ១១០ ថ្មី នៃរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ០៦ កបធ. សសរ.ច ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ២៩៥ រស ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ១៩៩៩ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា **សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា** ក្រោយពីបានទទួលយោបល់យល់ស្របពីព្រឹទ្ធសភា នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ហើយដែលទទួលបាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញត្រង់កថាខ័ណ្ឌទី២ ឃ្លាទី១ ចែងថា : "បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ។" និង មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ការសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ជាការស្របតាមរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ជាភារកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្អែកតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី២ ឃ្លាទី២ ដែលចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ។" និង មាត្រា ២២ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីការរៀបចំ និង ការព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-យល់ឃើញថា ការដែលព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់យល់ស្របនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ១៩៩៩ យោងតាមលិខិតលេខ ០១៨/៥៩៩/ពស/នវ ទៅលើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រោយពីរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ១៩៩៩ រួចបញ្ជូនទៅឱ្យព្រឹទ្ធសភានៅថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ១៩៩៩ ដើម្បីពិនិត្យ និង ឱ្យយោបល់ ដោយផ្អែកតាមមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី១ ដែលចែងថា : "ព្រឹទ្ធសភាពិនិត្យហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាដាក់ឱ្យពិនិត្យ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។" ជាការស្របនឹងរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដែលមាន ០៦ មាត្រា គ្មានចំណុចណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សាយភ្លាម ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ០៧ កបជ. សសរ.ច ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភា លេខ ២៥៣ រស ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ១៩៩៩ **ស្នើសុំពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការនេះ

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ ២ ៣ ៤ ៥ និង ៦ នៃច្បាប់រៀបចំអង្គការនេះឥតមានកន្លែងណាខុស ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ១៩៩៩ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ០៨ កបជ. សសរ.ច ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ២៥៤ រស ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ១៩៩៩ **ស្នើសុំពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការនេះ

-យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់រៀបចំអង្គការនេះឥតមានកន្លែងណាខុស ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់ហើយនោះ ត្រូវបានប្រកាសថា ស្របទាំងស្រុងនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២: សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ០៩ កបធ. សសរ.ច ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតរបស់ប្រធានរដ្ឋសភាលេខ ២៥៧ រស ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ១៩៩៩ **ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ១៩៩៩

-បានឃើញលិខិតរបស់អគ្គលេខាធិការរដ្ឋសភាលេខ ៣២២ អរស.នវ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ១៩៩៩ តបនឹងលិខិតរបស់អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៥/៩៩ អ.កបធ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ១៩៩៩ ដោយបានបញ្ជាក់ថា រដ្ឋសភាបានអនុម័តជាលើកទី ២ ដោយវិធីលើកដៃនូវច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន លើកលែងតែកថាខ័ណ្ឌទី ៧ នៃមាត្រា ១១៣ ថ្មី ដែលរដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ ហើយបែរជាធ្វើការអនុម័តដោយលើកដៃទៅវិញ។ ការខុសបែបបទនេះនាំឱ្យមានមោឃភាពដល់ច្បាប់នេះ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការនេះ

-យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់រៀបចំអង្គការនេះពុំមានខុសអ្វីនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ ២ ៤ ៥ និង ៦ នៃច្បាប់រៀបចំអង្គការនេះឥតមានកន្លែងណាខុស ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ៣ ដែលចែងថា " ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបជានារី ..." បានប៉ះពាល់ទៅលើគោលការណ៍ជាសារវ័ន្តនៃមាត្រា ៣១ កថាខ័ណ្ឌទី ២ ដែលចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និង ករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតមានប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ... " និង មាត្រា ៤៥ វាក្យខ័ណ្ឌទី ៣ ដែលចែងថា " បុរស និង ស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ... "។ ការតម្រូវឱ្យតែស្ត្រីទើបអាចធ្វើរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន គឺនាំឱ្យមានការរើសអើងពីរឿង " ភេទ " និង នាំឱ្យបាត់សមភាពក្នុងសិទ្ធិនយោបាយរវាងបុរស និង ស្ត្រី ដែលមាត្រា ៣១ និង ៤៥ នៃរដ្ឋធម្មនុញ្ញបានការពារ។ ដូច្នេះមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន មិនស្របនឹងរដ្ឋធម្មនុញ្ញ។

សម្រេច

មាត្រា ១: ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តលើកទី ២ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ១៩៩៩ នោះត្រូវបានប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២: សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ១០ កបធ. សសរ.ច ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ២៦២ រស ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ១៩៩៩ **ស្នើសុំពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះម្រូតតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើច្បាប់រៀបចំអង្គការនេះ

-យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់រៀបចំអង្គការនេះ ពុំមានខុសអ្វីនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ ២ ៣ ៤ ៥ និង ៦ នៃច្បាប់រៀបចំអង្គការនេះ ឥតមានកន្លែងណាខុស ឬផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំលើកទី ២ នីតិកាលទី ២ និងព្រឹទ្ធសភា បានពិនិត្យកាលពីថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ១១ កបជ. សសរ.ច ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញ**សំណើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាង ព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ១៩៩៩** របស់ក្រុមអ្នកតំណាងរាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបាននៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ១៩៩៩

-បានឃើញឯកសារនានាដែលបានទទួលពីរដ្ឋសភាទាក់ទងនឹងសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ប្រការ ១ ចំណុច ១ នៃសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ ដែលចែងថា " ... គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀង ... " មិនមានបញ្ហាពាក់ព័ន្ធនឹងការកាត់ក្តីហើយ ឬ មិនទាន់កាត់ក្តីហើយនោះទេ ហើយក៏មិនមានអ្វីផ្ទុយនឹងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញដែរ

-យល់ឃើញថា ទុកជាមិនទាន់មានការជំនុំជម្រះកាត់ក្តីក៏ដោយ ក៏គេអាចដឹងមុនទូវថៃរវេលានៃទណ្ឌកម្មក្នុងពេលដែលប្រទេសដាក់សំណើបត្យាប័នត្រូវបំពេញសំណុំបែបបទមួយចំនួនធំ។ ប្រការ ៧ ចំណុច ១ " គ " និង ចំណុច ១ " ឃ " នៃសន្ធិសញ្ញាបានតម្រូវឱ្យផ្តល់ឯកសារពាក់ព័ន្ធយ៉ាងហ្មត់ចត់ជាមុនស្រេចទៅហើយ។ ដូចនេះគ្មានឃើញសញ្ញាណាថា មិនស្របនឹងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញឡើយ

-យល់ឃើញថា ប្រការ ២ នៃសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ ដែលចែងថា " ... ហើយជនទាំងនោះ កំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជម្រះក្តី ឬ ដើម្បីឱ្យទទួលទោស ឬ អនុវត្តទណ្ឌកម្ម...." ក៏មិនប៉ះពាល់ដល់មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញដែរ ពីព្រោះបត្យាប័នអាចធ្វើបាននៅគ្រប់ដំណាក់កាលនៃនីតិវិធី

-យល់ឃើញថា ប្រការ ៣ ចំណុច ១ នៃសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជាណាចក្រថៃ (ដែលបានចែងថា "ភាគីទទួលយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័នដែលធ្វើឡើងដោយភាគីដាក់សំណើជាបទល្មើសនយោបាយ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវការធ្វើឃាត ឬ ប៉ុនប៉ង ធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិកនៃគ្រួសារជនទាំងនោះ។") បញ្ជាក់ដើម្បីទប់ស្កាត់កុំឱ្យពោលអាងលើលក្ខណៈនយោបាយសំដៅបញ្ឈៀសជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌចេញពីទណ្ឌកម្ម ដោយសំអាងលើតួនាទីអ្នករងគ្រោះជាប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ... យកជាលេស។ ដូច្នេះ ចំណុចនេះ មិនមានទំនាក់ទំនងជាមួយមាត្រា ៣១ និង មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ២ និង ព្រឹទ្ធសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ១២ កបធ. សសរ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតរបស់ប្រធានរដ្ឋសភាស្តីពី លេខ ៥៨២រស ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ **ស្នើសុំពិនិត្យធម្មនុញ្ញភាព នៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើនូវច្បាប់រៀបចំអង្គការនេះ

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ ២ ៣ ៤ ៥ និង ៦ នៃច្បាប់រៀបចំអង្គការនេះ គ្មានមានកន្លែងណាខុស ឬផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ១៩៩៩ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ១៩៩៩ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ១៣ កបធ. សសរ.ច ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញ**សំណើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ១៩៩៩** របស់ក្រុមអ្នកតំណាងរាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបាននៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃទី ១៩ ខែ សីហា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ពាក្យបណ្តឹងរបស់ក្រុមអ្នកតំណាងរាស្ត្រចំនួន ១៣ រូប ធ្វើបានត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែខុសនឹងគតិច្បាប់

-យល់ឃើញថា ព្រះរាជាណាចក្រកម្ពុជាបានប្រកាសសជូកម្មចូលអនុសញ្ញាស្តីពីការបង្ការ និង ផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ១៩ ខែ សីហា ឆ្នាំ១៩៥០ ដោយសម្តេច **សឺន សាន** រដ្ឋមន្ត្រីក្រសួងការបរទេស ហើយចូលជាធរមានថ្ងៃទី ១២ ខែ មករា ឆ្នាំ១៩៥១

-យល់ឃើញថា ក្រឹតច្បាប់លេខ ០១ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ១៩៧៩ ស្តីពីការបង្កើតតុលាការប្រជាជនបដិវត្តនៅទីក្រុងភ្នំពេញ ដើម្បីជំនុំជម្រះអំពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ពួក **ប៉ុល ពត អៀង សារី** ក៏បានកំណត់អំពីទោសនៃបទប្រល័យពូជសាសន៍នេះដែរ ត្រង់ចំណុច ១ មាត្រា ២

-យល់ឃើញថា ការឃុំខ្លួនជាបណ្តោះអាសន្ន ទោះជាមានរយៈពេលប៉ុន្មានក៏ដោយ ឱ្យតែមានកំណត់ក្នុងច្បាប់ ហើយអនុវត្តត្រឹមត្រូវតាមនីតិវិធីនៃការឃុំខ្លួនជាបណ្តោះអាសន្ន មិនត្រូវចាត់ទុកថា ជាមនុស្សមានទោសទេ ព្រោះក្នុងរយៈពេលនេះ តុលាការគ្រាន់តែធ្វើការស៊ើបអង្កេតឱ្យបានត្រប់ជ្រុងជ្រោយ មុនទីឈានដល់ការជំនុំជម្រះថា តើសាមីខ្លួនមាន ឬ គ្មានទោសប៉ុណ្ណោះ។ ដូច្នេះ មិនមានអ្វីប្រឆាំងនឹងវាក្យខ័ណ្ឌទី ៧ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីរយៈពេលនៃការឃុំខ្លួនជាបណ្តោះអាសន្ន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ២ និង ព្រឹទ្ធសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ១៤ កបធ. សសរ.ច ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ៧៨៨ រស ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ១៩៩៩ **ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ** ដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ១៩៩៩។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការអនុម័តច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

-យល់ឃើញថា ការដែលព្រឹទ្ធសភាពុំបានពិនិត្យច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដោយមូលហេតុពុំមានពេលវេលាគ្រប់គ្រាន់នោះ ពុំមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើនូវច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃជំពូកទាំង ២៤ និង មាត្រាទាំង ៧៦ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ពុំមានកន្លែងណាខុស ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង បរិវញ្ញវត្ថុ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៩ ខែ តុលា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេច លេខ : ០៣៥/០០១/២០០០ កបធ. ច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ៨៥ រស ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០០០ **ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០០០។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើនូវច្បាប់រៀបចំអង្គការនេះ

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា មាត្រា ៤០ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា: "គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងនាមរដ្ឋសភា មានសិទ្ធិជ្រើសរើសសវនករពិសេសដើម្បីពិនិត្យមើលឡើងវិញនូវសកម្មភាព និង កិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរសវនកម្ម" មិនស្របនឹងរដ្ឋធម្មនុញ្ញ ដោយហេតុថា ជាគោលការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាមិនអាចតំណាងឱ្យរដ្ឋសភាគ្រប់ពេលនោះទេ ដូចជាក្នុងសម័យប្រជុំពេញអង្គរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍មិនអាចជូនមុខឱ្យរដ្ឋសភាបានទេ ជាពិសេសក្នុងកិច្ចការដ៏មានសារសំខាន់ដូចជាការជ្រើសរើសសវនករពិសេសនេះ។ សូម្បីតែមាត្រា ៨៤ នៃរដ្ឋធម្មនុញ្ញក៏បានចែងថា នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាមានភារកិច្ចត្រឹមតែចាត់ចែងការងារធម្មតាតែប៉ុណ្ណោះ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០០ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយកាលពីថ្ងៃទី ២១ ខែ មករា ឆ្នាំ២០០០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា ៤០ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សាយតាំ ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៣៧/០០៣/២០០០ កបធ.ច ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ៧០១ រស ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០០ **ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០០០ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើនូវច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-យល់ឃើញថា មាត្រា ១៤២ ថ្មី នៃរដ្ឋធម្មនុញ្ញ បានចែងថា បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើ ឬ យកទៅអនុវត្តបានឡើយ

-យល់ឃើញថា មាត្រា ១៤២ ថ្មី នៃរដ្ឋធម្មនុញ្ញ មានន័យថា ទាំងលេខរៀងនៃមាត្រា ទាំងខ្លឹមសារនៃបទប្បញ្ញត្តិដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ ពុំអាចយកទៅប្រកាសឱ្យប្រើ ឬ យកទៅអនុវត្តបានឡើយ។ ដូច្នេះមាត្រា ៤០ នៅតែមានអត្ថភាពនៅក្នុងព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០

-យល់ឃើញថា អត្ថិភាពនៃមាត្រា ៤០ ទាំងមូលនៃព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ មិនត្រូវបំពេញបន្ថែមដោយច្បាប់ណាមួយបានឡើយ ពីព្រោះវាមិនស្របនឹងវាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤២ ថ្មី នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា សេចក្តីសម្រេចលេខ ០៣៥/០០១/២០០០ កបធ.ច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០០ នៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា " ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០០ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយកាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា ៤០ ។"

-យល់ឃើញថា មាត្រា ១ នៃច្បាប់បន្ថែម ដែលបង្គាប់ឱ្យប្រើលេខមាត្រា ៤០ អុននោះ មិនស្របនឹងវាក្យខ័ណ្ឌទី ១ នៃមាត្រា ១៤២ ថ្មី នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា លេខមាត្រា ៤០ នៃមាត្រា ១ នៃច្បាប់បន្ថែម ត្រូវនៅដាច់ដោយឡែក ពុំអាចបញ្ចូលទៅក្នុងច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ បានទេ

-យល់ឃើញថា ខ្លឹមសារនៃឃ្លាទី ១ នៃមាត្រា ១ នៃច្បាប់បន្ថែមដែលចែងថា " ត្រូវបានបំពេញបន្ថែមជាមាត្រា ៤០ ក្នុងជំពូកទី ៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ដូចតទៅ : " មិនស្របនឹងវាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤២ ថ្មី នៃរដ្ឋធម្មនុញ្ញ។

សម្រេច

មាត្រា ១ : ផ្អែកតាមមូលបទខាងលើ ច្បាប់ស្តីពីច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០០០ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយកាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទប្បញ្ញត្តិនៃឃ្លាទី ១ នៃមាត្រា ១។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៣៩/០០១/២០០១ កបធ.ច ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ១០៦៧ រស ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០០ **ស្នើសុំពិនិត្យធម្មនុញ្ញភាពស្តីពីច្បាប់អត្តិសនីនៃព្រះរាជាណាចក្រកម្ពុជា** ដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០០

-បានឃើញ លិខិតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ លេខ ៦១/០០ កបធ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០០ ស្នើសុំឱ្យរដ្ឋសភាឱ្យនិយមន័យពាក្យ បទបញ្ជាទូទៅ វិធាន និង បទប្បញ្ញត្តិ

-បានឃើញ លិខិតប្រធានរដ្ឋសភាលេខ ៣១ រស ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ២០០១ ស្តីពីការឱ្យនិយមន័យពាក្យ បទប្បញ្ញត្តិ បទបញ្ជា និង វិធាន ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីអត្តិសនីនៃព្រះរាជាណាចក្រកម្ពុជា

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើនូវច្បាប់ស្តីពីអត្តិសនីនៃព្រះរាជាណាចក្រកម្ពុជា

-យល់ឃើញថា ទម្រង់នៃការតាក់តែងសេចក្តីព្រាងនៃច្បាប់នេះ មានការភាន់ច្រឡំក្នុងការឱ្យនិយមន័យនៃពាក្យ បទប្បញ្ញត្តិ និង បទបញ្ជា ដែលចេញដោយអាជ្ញាធរអត្តិសនីកម្ពុជា ។ ការឱ្យនិយមន័យនៃពាក្យ បទប្បញ្ញត្តិ និង បទបញ្ជា ដែលរដ្ឋសភាបានផ្តល់មកជូនក្រុមប្រឹក្សាធម្មនុញ្ញ តាមរយៈលិខិតប្រធានរដ្ឋសភា លេខ ៣១ រស ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ២០០១ ដូចមានយោងខាងលើ ជាការឱ្យនិយមន័យខុសប្លែកពីការឱ្យនិយមន័យតាមទម្លាប់ប្រើក្នុងប្រព័ន្ធច្បាប់កម្ពុជា ។ ក្នុងភាសាច្បាប់ខ្មែរ ពាក្យ បទប្បញ្ញត្តិ និង បទបញ្ជា មានន័យដូចតទៅ :

បទប្បញ្ញត្តិ ពុំមែនជាប្រភេទច្បាប់ថ្មី ឬ ប្រភេទបទបញ្ជាថ្មីណាមួយទៀតផ្សេងទេ នៅក្នុងឋានានុក្រមនៃធម្មនិយាមតតិយុត្តិកម្ពុជា ។ តាមការឱ្យនិយមន័យរបស់រដ្ឋសភា បទប្បញ្ញត្តិ ហាក់ដូចជាប្រភេទវិធានតតិយុត្តិមួយថ្មី ដែលមានឋានៈខ្ពស់ជាងបទបញ្ជា ។ ក្នុងឋានានុក្រមនៃធម្មនិយាមតតិយុត្តិយើងសព្វថ្ងៃនេះ នៅពីលើ បទបញ្ជា ភ្លាមមានតែ ច្បាប់ ប៉ុណ្ណោះ ។

បទប្បញ្ញត្តិ តាមន័យក្នុងច្បាប់ខ្មែរ គឺជាវិធានតតិយុត្តិដែលមានចែងក្នុង មាត្រានៃច្បាប់ ឬ នៃបទបញ្ជា ។

បទបញ្ជា ជាវិធាន ឬ អត្ថបទគតិយុត្តដែលមានវិសាលភាពទូទៅ និង មិនចំពោះ មុខបុគ្គលណាមួយឡើយ ហើយដែលធ្វើឡើងដោយអាជ្ញាធរវរដ្ឋបាលមានសមត្ថកិច្ច។

បទបញ្ជា ស្ថិតក្នុងឋានានុក្រម ក្រោមច្បាប់ (ច្បាប់ដែលអនុម័តដោយអង្គការនីតិបញ្ញត្តិ)។

បទបញ្ជា មានពីរប្រភេទ គឺបទបញ្ជាទូទៅ និង បទបញ្ជាដោយឡែក។

បទបញ្ជាទូទៅ មានវិសាលភាពទូទៅលើបុគ្គល គ្រប់ប្រភេទ និង ទូទាំងប្រទេស។

បទបញ្ជាដោយឡែក មានវិសាលភាពទូទៅលើបុគ្គលតាមក្រុម តាមប្រភេទ សេវាកម្មសាធារណៈ តាមវិជ្ជាជីវៈ ឬ តាមតំបន់ទីកន្លែង។

បទបញ្ជា ដែលអាជ្ញាធរអគ្គិសនីអាចចេញបាន ជាបទបញ្ជាដោយឡែកតែប៉ុណ្ណោះ គឺថាមិនមែនជាបទបញ្ជាទូទៅដែលជាសមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រីក្នុងនាម រាជរដ្ឋាភិបាលនោះឡើយ។

បទបញ្ជា ពុំមែន ជាការបញ្ជា ឬ ការបង្គាប់ដូចការឱ្យនិយមន័យរបស់រដ្ឋសភា ក្នុងច្បាប់អគ្គិសនីនេះទេ។ ពាក្យ ការបញ្ជា ឬ ការបង្គាប់ មិនមែនជាពាក្យច្បាប់ ដែលមានអានុភាពគតិយុត្ត គឺគ្រាន់តែជាពាក្យ សាមញ្ញ ប្រើក្នុងភាសាសាមញ្ញតែប៉ុណ្ណោះ

-យល់ឃើញថា ដើម្បីកុំឱ្យមានការភាន់ច្រឡំក្នុងការប្រើភាសាច្បាប់ និង ដើម្បីឱ្យស្របនឹងប្រព័ន្ធច្បាប់កម្ពុជា អាជ្ញាធរអគ្គិសនីត្រូវប្រើតែពាក្យបទបញ្ជា ឬ សេចក្តីសម្រេចក្នុងការដាក់វិធានការផ្សេងៗដល់អ្នកកាន់អាជ្ញាប័ណ្ណ អគ្គិសនី និង សាធារណជន។

អាជ្ញាធរអគ្គិសនីកម្ពុជាប្រើពាក្យ បទប្បញ្ញត្តិ បានតែក្នុងអត្ថបទនៃបទបញ្ជា របស់ខ្លួនតែប៉ុណ្ណោះ។

-យល់ឃើញថា ខ្លឹមសារនៃជំពូកទាំង ១៣ និង គ្រប់មាត្រាទាំង ៧៩ នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានកន្លែងណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ក្រោមលក្ខខណ្ឌនៃការឱ្យនិយមន័យ និង ការប្រើពាក្យ បទប្បញ្ញត្តិ និង បទបញ្ជា ដូចមានចែងក្នុងមូលបទខាងលើ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០០ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយកាល ពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ០៤៥ រស ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០១ **ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពី " ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ "** ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២ ខែ មករា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ២ ហើយព្រឹទ្ធសភាក៏បានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ១៥ ខែ ឆ្នាំ ដដែល នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ដោយបានអនុម័តយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង គ្មានការកែប្រែអ្វីឡើយ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០១។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា មាត្រា ៣ វាក្យខ័ណ្ឌទី១ នៃច្បាប់នេះ បានយោងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និង ចង្កុលមាត្រានៃក្រមព្រហ្មទណ្ឌនេះ ចំនួនដប់ ដែលក្នុងចំណោមនោះ មាត្រា ២០៩ ៥០០ ៥០៦ និង ៥០៧ បានចែងថា "... ទោសឧក្រិដ្ឋថ្នាក់ទីបី "។ មាត្រា ២១ នៃក្រមព្រហ្មទណ្ឌដែលបានបញ្ជាក់ថា "... ទោសឧក្រិដ្ឋថ្នាក់ទីបី គឺជាទោសសម្លាប់ "។ ដូច្នេះទាំងអក្សរ ទាំងខ្លឹមសារវាក្យខ័ណ្ឌពាក់ព័ន្ធនេះ មានន័យផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដែលមាត្រា ៣២ វាក្យខ័ណ្ឌទី ២ បានចែងថា " ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ "

-យល់ឃើញថា មាត្រា ៣ វាក្យខ័ណ្ឌទី ២ នៃច្បាប់នេះបានពន្យារពេលបន្ថែម ២០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្ម ដែលមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានកំណត់ត្រឹមតែដប់ឆ្នាំ។ អានុភាពនៃមាត្រា ៣ វាក្យខ័ណ្ឌទី ២ នេះ បានធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ជាសារវន្តមួយ : "អប្រតិសកម្មភាពនៃច្បាប់ថ្មីលើបទល្មើសដែលបានកើតឡើងក្នុងអតីតកាល " ដែលប្រទេសកម្ពុជា ក៏ដូចអារ្យប្រទេសមួយចំនួនបានទទួលស្គាល់ជាទូទៅក្នុងសម័យមុនឆ្នាំ១៩៧៥ ក៏ដូចជាសម័យក្រោយឆ្នាំ១៩៧៨ ដោយរាប់បញ្ចូលទាំងសម័យអន្តរកាលនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផង។ ប៉ុន្តែកម្ពុជាមិនបានបញ្ជាក់ថា គោលការណ៍ជាសារវន្តនេះមានតម្លៃស្មើ

រដ្ឋធម្មនុញ្ញឡើយ ហេតុដូច្នេះហើយបានជាសភាធម្មនុញ្ញដែលជាអង្គការជ្រើសតាំងតាមនីតិវិធីស្របច្បាប់ និងតំណាងឱ្យប្រជារាស្ត្រពិតប្រាកដក្នុងការតាក់តែងរដ្ឋធម្មនុញ្ញមិនបានបញ្ញត្តិពីគោលការណ៍នេះក្នុងមាត្រាណាឡើយ ក្នុងបុព្វកថាក៏មិនមានដែរ។ លើសពីនេះទៅទៀត ទុកជាគោលការណ៍នេះ មានតម្លៃស្មើនឹងអ្វីក៏ដោយ ឬ ត្រូវបានចារឹកជាលាយលក្ខអក្សរ ឬក៏គ្មាន ក៏គេត្រូវគោរពគោលការណ៍មួយទៀត "រាល់គោលការណ៍មានសមាសភាពពីរ : វិធាន និង អញ្ញត្រកម្ម" បើវិធានមានតម្លៃស្មើអ្វី អញ្ញត្រកម្មក៏មានតម្លៃស្មើគ្នា។ អប្រតិសកម្មភាពដែលមិនត្រូវមានចែងក្នុងរដ្ឋធម្មនុញ្ញ គេបានឃើញនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ គោលការណ៍ ត្រឹះនៃក្រមព្រហ្មទណ្ឌនេះក៏មានការវៀរលែងដែរ។ មាត្រា ៦ វាក្យខ័ណ្ឌទី ២ បានចែងថា : " ... ប៉ុន្តែបើច្បាប់ថ្មីនេះ លុបចោលបទល្មើសណាមួយ ឬ សម្រាលទោសរបស់បទល្មើសណាមួយវិញ បទល្មើសដែលបានប្រព្រឹត្តមុនច្បាប់នេះ ត្រូវបានរួចផុតពីទោស ឬ ក៏ត្រូវបានសម្រាលទោសនោះតាមច្បាប់ថ្មី កុំឱ្យតែបទល្មើសនោះបានទទួលទោសជាស្ថាពររួចហើយ"។ ត្រង់នេះ ច្បាប់ថ្មីដែលយើងកំពុងពិនិត្យបានបំពេញលក្ខណៈបានដោយបរិបូរណ៌។ មាត្រា ៣៨ និង ៣៩ បានបន្ថយទោសប្រហារជីវិតមកត្រឹមតែទោសជាប់គុកអស់មួយជីវិតតែប៉ុណ្ណោះ។ ម្យ៉ាងទៀត ទោសជាប់គុកដោយបង្ខំឱ្យធ្វើការជាទម្ងន់ (Travaux forcés) ឬ ទោសដាក់គុកបង្ខំឱ្យធ្វើការ និង បង្ខាំងមិនឱ្យចេញ (réclusion) មកត្រឹមជាប់គុកធម្មតា (emprisonnemént)។ សារណាអំណោយផលមួយទៀត គឺការពារលក្ខណៈចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ ទន្ទឹមនឹងលក្ខណៈចរិកពិសេសនៃករណី។ មាត្រាមួយនៃច្បាប់នេះ បានបន្ថែមលក្ខណៈបណ្តឹងជាវត្ថុធាតុតួបង្កើបទល្មើស (éléménts constitutifs de l'infraction) ច្រើនទៀតទៅលើលក្ខណៈជាទម្លាប់ដែលមានស្រាប់នៅក្នុងមាត្រាទាំងឡាយដែលគេចង្អុលក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ លក្ខណៈបន្ថែមទាំងនោះគឺ :

-ចំពោះពិរុទ្ធជន មានតែមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត

-ចំពោះបទល្មើស កម្រិតត្រឹមឧក្រិដ្ឋកម្ម និង ការរំលោភធ្ងន់ធ្ងរ

-ចំពោះចិរវេលា កម្រិតត្រឹមអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ១៩៧៩។

រួមសេចក្តីទៅ មិនមានឃើញអ្វីប៉ះពាល់ដល់ធម្មនុញ្ញភាពទេ

-យល់ឃើញថា មាត្រា ៩ ដល់មាត្រា ៣២ ដែលបានបញ្ញត្តិពីសមាសភាពចៅក្រមជំនុំជម្រះ ការតែងតាំង ការសម្រេចសេចក្តី សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ប្រធាន អនុប្រធានការិយាល័យរដ្ឋបាល និង បុគ្គលិកជំនួយការផ្សេងៗ មានភាគីខ្មែរ និង ភាគីមកពីអង្គការសហប្រជាជាតិ ដូចមានតារាងសំយោគខាងក្រោមនេះ :

សមាសភាព	សាលាដំបូង	សាលាឧទ្ធរណ៍	សាលាកំពូល	ការិយាល័យរដ្ឋបាល
១-ចៅក្រមជម្រះក្តី - ខ្មែរ (ប្រធាន) - អ.ស.ប	 ៣ ២	 ៤ ៣	 ៥ ៤	
សរុប	៥	៧	៩	
២-សំឡេងអប្បបរមាក្នុងការសម្រេច	៤	៥	៦	

៣-សហព្រះរាជអាជ្ញា - ខ្មែរ - អ.ស.ប	 ១ ១	 ១ ១	 ១ ១	
សរុប	២	២	២	
៤-សហចៅក្រមស៊ើបអង្កេត - ខ្មែរ - អ.ស.ប	 ១ ១	 ១ ១	 ១ ១	
សរុប	២	២	២	
៥-ការិយាល័យរដ្ឋបាល - ខ្មែរ ប្រធាន - អ.ស.ប អនុប្រធាន				 ១ ១
សរុប				២

ដើម្បីបម្រើការអង្គជំនុំជម្រះវិសាមញ្ញនេះ ទាំងភាគីខ្មែរ ទាំងភាគីមកពីអង្គការសហប្រជាជាតិ សុទ្ធតែត្រូវបានតែងតាំងឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នកំពូលជាតិខ្មែរសុទ្ធសាធ សូម្បីតែប្រធាន និង អនុប្រធានការិយាល័យរដ្ឋបាលក៏ត្រូវបានតែងតាំងដោយអាជ្ញាធរកម្ពុជាដែរ។ អង្គការសហប្រជាជាតិមានភារកិច្ចត្រឹមស្នើបញ្ជីបេក្ខជនតែប៉ុណ្ណោះ ហើយគ្មានសិទ្ធិសម្រេចទេ។ គេមិនឃើញមានមាត្រាណាមួយនៃរដ្ឋធម្មនុញ្ញ ហាមឃាត់មិនឱ្យស្ថាប័នជាតិ ជាពិសេសឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តែងតាំងជនមកពីអង្គការសហប្រជាជាតិដែលកម្ពុជាជាសមាជិកដែរនោះទេ។ បើនិយាយឱ្យអស់ទៅ ក្នុងឋានៈខ្លួនជាអង្គការប្រមូលផ្តុំប្រជាជាតិស្ទើរតែទាំងអស់ក្នុងពិភពលោក អង្គការសហប្រជាជាតិ អាចឧទ្ទេសនាមបេក្ខជនគ្រប់សញ្ជាតិ រួមមានទាំងខ្មែរ ឬ ខ្មែរមានសញ្ជាតិពីរផង។ គ្រប់លំដាប់ថ្នាក់នៃអង្គជំនុំជម្រះក្តី : សាខាដំបូង សាលាឧទ្ធរណ៍ តុលាការកំពូល ភាគីខ្មែរសុទ្ធតែមានចំនួនភាគច្រើន ហើយសុទ្ធតែខ្មែរទៀតដែលត្រូវបានទទួលឋានៈជាប្រធាន។ ប៉ុន្តែចំនួនសំឡេងអប្បបរមាក្នុងសេចក្តីសម្រេចដែលមានកម្ពស់ខ្ពស់ ជាយន្តការតុល្យការមួយធ្វើឱ្យមានសមតាខាងផ្លូវយុត្តិធម៌ ព្រោះភាគីទាំងពីរចាំបាច់ត្រូវតែសហការគ្នាដោយខានមិនបាន។ ការយកប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ និង ការរើសយករាជធានីភ្នំពេញជាទីតាំងដំណើរការជាការគាំពារថ្មីមួយទៀតដល់អធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនេះ បានយោងច្បាប់ចំនួនប្រាំមួយដែលមានចែងក្នុង មាត្រា ៣ ៤ ៥ ៦ ៧ និង ៨ ។ ក្នុងចំណោមនេះ ប្រាំទៅហើយ (ប្រាំបួងក្រោយ) ដែលសុទ្ធជាអនុសញ្ញាអន្តរជាតិ។ ដូច្នេះការទាមទារឱ្យមានការរួមចំណែកពីសំណាក់អង្គការសហប្រជាជាតិ ជាការចាំបាច់

-យល់ឃើញថា មាត្រា ៤០ ដែលបានហាមឃាត់មិនឱ្យរាជរដ្ឋាភិបាលកម្ពុជា ស្នើសុំឱ្យមានការលើកលែងទោស ឬ ការអនុគ្រោះទោស មិនមានធ្វើឱ្យប៉ះពាល់ដល់ធម្មនុញ្ញភាពទេ ពីព្រោះមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់ថា ពីព្រះមហាក្សត្រ មិនមែនពីរាជរដ្ឋាភិបាលឡើយ។ មាត្រានេះចែងថា " ព្រះមហាក្សត្រមានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និង លើកលែងទោស "។

សម្រេច

មាត្រា ១ : ផ្អែកតាមមូលបទខាងលើ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២ ខែ មករា ឆ្នាំ២០០១ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទប្បញ្ញត្តិទាំងឡាយណាដែលបានចែងថា "... ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី " ដែលជាទោសសម្រាប់ក្នុងមាត្រា ២០៩ ៥០០ ៥០៦ និង ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៤១/០០៣/២០០១ កបធ.ធ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភា លេខ ០៧៤ រស ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០១ **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០១ នាសម័យប្រជុំលើកទី ៥ នីតិកាលទី ២ ហើយព្រឹទ្ធសភាក៏បានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំដដែល នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ដោយបានអនុម័តយល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង គ្មានការកែប្រែអ្វីឡើយ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០០១។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវប្រកាសឱ្យប្រើ

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញឡើយ

-យល់ឃើញថា ខ្លឹមសារទាំង ១០ ជំពូក ដែលមាន ៥០ មាត្រា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញឡើយ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីរការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែ មករា ឆ្នាំ២០០១ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០០១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៤២/០០៤/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ០១០៧ រស ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០១ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០០១ នាសម័យប្រជុំលើកទី ៥ នីតិកាលទី ២ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ដោយបានអនុម័តយល់ស្របតាមទម្រង់ និង គតិច្បាប់ទាំងស្រុង ដោយគ្មានកែប្រែអ្វីឡើយ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០១។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវប្រកាសឱ្យប្រើ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញឡើយ

-យល់ឃើញថា ខ្លឹមសារទាំង ១៨ ជំពូក ដែលមាន ២៨៨ មាត្រា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០០១ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០០១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៤៣/០០៥/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានរដ្ឋសភា លេខ ៤៨៩ រស ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០១ **ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃការធ្វើនិយតកម្មមាត្រា ៣ នៃច្បាប់ស្តីពីបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ** ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០១ នាសម័យប្រជុំលើកទី ៦ នីតិកាលទី ២ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ដោយយល់ស្របតាមលើទម្រង់ និង គតិនៃច្បាប់ទាំងស្រុង គ្មានកែប្រែអ្វីឡើយ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០១

-បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០០១ បានប្រកាសថា " ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ " ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទប្បញ្ញត្តិទាំងឡាយដែលចែងថា "...ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី " ដែលជាទោសសម្លាប់ក្នុងមាត្រា ២០៩ ៥០០ ៥០៦ និង ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិគារក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ អនុម័តការធ្វើនិយតកម្មមាត្រា ៣ នៃច្បាប់នេះ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា ការធ្វើនិយតកម្មមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បានឆ្លើយតបជាវិជ្ជមានទៅនឹងការកត់សម្គាល់របស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងសេចក្តីសម្រេចលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០០១។

សម្រេច

មាត្រា ១ : ផ្អែកតាមមូលបទខាងលើ មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តយល់ព្រមធ្វើនិយតកម្មកាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៤៧/០០២/២០០២ កបធ.ច ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ៨៣០ រស ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០២ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០២ ក្នុងសម័យប្រជុំរដ្ឋសភាលើកទី ៨ នីតិកាលទី ២។

ក្រោយពីបានស្តាប់រចនាសម្ព័ន្ធរបស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ

-យល់ឃើញថា ប្រធានព្រឹទ្ធសភា (ស្តីទី) ដែលបានសរសេរថាព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យអត្ថបទច្បាប់នេះ ពុំបានបើកសម័យប្រជុំព្រឹទ្ធសភាពេញអង្គដើម្បីអនុម័តសេចក្តីសម្រេចយ៉ាងដូចនេះទេ។ ដូច្នេះគឺជាសេចក្តីសម្រេចឯកតោភាគីផ្ទាល់ខ្លួនរបស់ប្រធានព្រឹទ្ធសភា (ស្តីទី) គឺថា មិនមែនរបស់ព្រឹទ្ធសភាដូចដែលមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបានតម្រូវនោះឡើយ

-យល់ឃើញថា ក្នុងករណីដូចបានលើកឡើងខាងលើនេះ វិធានទាំងឡាយដែលមានចែងក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០០ ស្តីពីការបកស្រាយមាត្រា ១១៣ ថ្មី វាក្យខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែ ៥ ថ្ងៃ " ក៏មិនត្រូវបានអនុវត្តតាមដែរ

-យល់ឃើញថា ការគោរពនីតិវិធីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ជាការចាំបាច់សម្រាប់តម្រូវការនៃនីតិរដ្ឋគួលភាពដែលចាប់ពីពេលនេះតទៅមិនគួរឱ្យមានការខ្វះខាតឡើយ

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារមាត្រាទាំងពីរនៃច្បាប់នេះក៏ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : យោងតាមមូលបទខាងលើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៥២/០០៣/២០០៣ កបធ.ច ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញសំណើលេខ ១១៧ រស ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០០៣ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា **ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព លើវិសោធនកម្មប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ២០០៣

-បានឃើញប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដែលអគ្គលេខាធិការដ្ឋានរដ្ឋសភាបានផ្ញើមកក្រុមប្រឹក្សាធម្មនុញ្ញនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ២០០៣ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃ ខែ ឆ្នាំ ដដែល ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី២ ឃ្លាទី១ ដែលចែងថា " បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។" និង មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្ម ប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ជាការស្របតាមរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពលើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាការកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដោយផ្អែកតាមមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី២ ឃ្លាទី២ ដែលចែងថា " ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើ ស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ ។ "

-យល់ឃើញថា ប្រការ ៣៦ ថ្មី និង ប្រការ ៣៦ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ខុសគ្នាត្រង់ការបន្ថែមលើប្រការ ៣៦ (ចាស់) នូវវាក្យខ័ណ្ឌមួយថ្មីទៀតដែលចែងថា " វិធីបញ្ចេញមតិដោយលើកដៃ ឬ ដោយបោះឆ្នោតចំហខាងលើនេះអាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិច ។ "

-យល់ឃើញថា ប្រការ ៣៨ ថ្មី និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាខុសគ្នាត្រង់ប្រការ ៣៨ ថ្មី ប្តូរដាក់ពាក្យ សម្តាល់ថា ព្រម មុនដាក់ ពាក្យខ្សែវ សម្តាល់ថា មិនព្រម ។ អត្ថន័យទាំងអស់នៅដដែល ការប្តូរដាក់មុនក្រោយ ដើម្បីឱ្យមានភាពរលូន និង ពិរោះស្តាប់ " ព្រម " " មិនព្រម " " អនុបវាទ " មិនមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ប្រការ ៣៦ ថ្មី មិនមានចែងច្បាស់លាស់អំពីនីតិវិធីដែលត្រូវប្រើប្រព័ន្ធអេឡិចត្រូនិចក្នុងការបោះឆ្នោតចំហ ។ ការមិនបានចែងនីតិវិធីអាចនឹងបណ្តាលឱ្យមានការប៉ះពាល់ដល់ប្រការ ៣៨ ថ្មី ដែលមានបញ្ជាក់ច្រង់ថា " អាជ្ញាសភាកាន់ហិបឆ្នោតដើរទទួលប្រមូលយកសន្លឹកឆ្នោតពីសមាជិករដ្ឋសភា " ។ ទោះបីមានបច្ចេកវិទ្យាដល់កម្រិតខ្ពស់ក៏នៅមានការលំបាកក្នុងការបំពេញលក្ខខ័ណ្ឌឱ្យមានអាជ្ញាសភា ប្រតិបត្តិការងារដូចនេះបានឡើយ

-យល់ឃើញថា ដើម្បីឱ្យស្របនឹងរដ្ឋធម្មនុញ្ញ ច្រង់មាត្រា ៥ គួរប្រើភាសាខ្មែរដែលមានសម្រាប់ជំនួសពាក្យបរទេស គឺពាក្យ អសន្យាណូ ជំនួសពាក្យ " អេឡិចត្រូនិច " ។

សម្រេច

មាត្រា ១ : វិសោធនកម្មលើប្រការ ៣៦ និង ប្រការ ៣៨ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី២ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសំរេច លេខ:០៥៩/០០១/២០០៤ កបធ.ច ចុះថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

-បានឃើញលិខិតលេខ ១០៧ រស ចុះថ្ងៃទី០២ ខែ សីហា ឆ្នាំ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្តីទី **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០០៤។

ក្រោយពីបានស្តាប់របាយការណ៍សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយប្រធានរដ្ឋសភាស្តីទីជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាការកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា នៅក្នុងគ្រប់ជំពូក និងប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ពុំមានបទប្បញ្ញត្តិណាដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែបទប្បញ្ញត្តិនៃប្រការ ៥១ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាស្តីពីការជ្រើសតាំងប្រធានបណ្តោះអាសន្នមួយរូបឱ្យដឹកនាំការប្រជុំ ។ បទប្បញ្ញត្តិនេះ ជាប្រការមួយមានការលំបាកក្នុងការអនុវត្តជាក់ស្តែង ហើយមិនស្របនឹងមាត្រា៨៧ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

សម្រេច

មាត្រា ១ : បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មាន ១៧ ជំពូក និង ៨៣ ប្រការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥១ ដែលមិនស្របនឹងមាត្រា ៨៧ ថ្មីនៃរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៦០/០០២/២០០៤ កបធ.ច ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតរបស់តំណាងរាស្ត្រចំនួន២១រូប ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០៤ **"ស្នើសុំពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ"** ហើយដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ទទួលបាននៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៤ វេលាមៅង ១៥ និង ៤០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា កថាខណ្ឌទី១នៃមាត្រា ១៣៦ថ្មី នៃរដ្ឋធម្មនុញ្ញបានចែងថា " ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ " ។ កថាខិណ្ឌនេះ ពុំមានចែងអ្វីទាក់ទងដល់សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមទេ

-យល់ឃើញថា ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញក្នុងផ្នែកទី២ ស្តីពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចំពោះធម្មនុញ្ញភាពនៃច្បាប់ ជាព្រះរាជក្រមដែលចែងលំអិតសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញពិសេសនៅត្រង់មាត្រា ១៥ បានចែងថា "ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយ

រដ្ឋធម្មនុញ្ញ និង ច្បាប់ដែលអនុម័តដោយរដ្ឋសភា ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។ មាត្រា១៥ នេះ ពុំមានចែងថាក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចពិនិត្យធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមទេ ។

-យល់ឃើញថា សំណើរបស់ឯកឧត្តម លោកជំទាវតំណាងរាស្ត្រ ចំនួន ២១រូប ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ "ស្នើសុំពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" មិនស្ថិតនៅក្នុងក្របខ័ណ្ឌមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-យល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញធ្លាប់បានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាច្រើន ប៉ុន្តែពុំដែលបានពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលមានលក្ខណៈជារដ្ឋធម្មនុញ្ញ ដូចជាច្បាប់ធម្មនុញ្ញបន្ថែមនេះទេ ។ ម្យ៉ាងទៀតច្បាប់ធម្មនុញ្ញបន្ថែមនេះ ជាច្បាប់កំពូលមួយ មានចែងពីគោលដៅរបស់ច្បាប់មានមាត្រានៃច្បាប់ដោយឡែក និង ហានានុក្រមស្មើនឹងច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ទៅហើយ ។ ដូច្នេះច្បាប់ធម្មនុញ្ញនេះ គឺជារដ្ឋធម្មនុញ្ញ ដែលពុំអាចពិនិត្យធម្មនុញ្ញភាពបានឡើយ ។

សម្រេច

មាត្រា ១ : យោងតាមមូលបទខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ការពិនិត្យធម្មនុញ្ញភាពនៃ "ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ" ពុំមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។

មាត្រា ២ : សេចក្តីសម្រេចនេះថ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៦២/០០៤/២០០៤ កបធ.ច ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

-បានឃើញលិខិត ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤ របស់តំណាងរាស្ត្រចំនួន ១៣រូប ដែល**ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម។**

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប បានធ្វើលិខិតមួយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីបាតុកម្ម ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១០:០០ ព្រឹក។ តំណាងរាស្ត្រជាម្ចាស់សំណើមានចំនួន ១៣រូប ដូច្នេះ គឺគ្រប់គ្រាន់តាមបទប្បញ្ញត្តិនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញហើយ ។

ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម /០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨

- យល់ឃើញថា បាតុកម្ម ជាអំពើប្រព្រឹត្តដោយជនមួយក្រុម សំដែងឱ្យសាធារណជនទាំងពួងឃើញ ឬ ដឹងនូវមនោសញ្ចេតនា គំនិត ឬ ឆន្ទៈណាមួយរបស់ក្រុមខ្លួន។ សិទ្ធិធ្វើបាតុកម្ម និង សិទ្ធិធ្វើកូដកម្ម ជាសិទ្ធិរបស់ប្រជាពលរដ្ឋ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។ ប៉ុន្តែប្រជាពលរដ្ឋត្រូវប្រើសិទ្ធិនេះ ដោយសន្តិវិធី កុំឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ហើយក៏កុំឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ បរិស្ថាន សុខុមាលភាពសាធារណៈ និង សន្តិសុខសង្គម។ មានតែច្បាប់ទេ ដែលកំណត់ក្របខ័ណ្ឌនៃការធ្វើបាតុកម្ម គឺច្បាប់កំណត់ឱ្យអាជ្ញាធរសាធារណៈ ចាត់វិធានការនានា ដើម្បីធានាសិទ្ធិរបស់បាតុករផង ហើយដើម្បីរក្សាឱ្យបាននូវរបៀបរៀបរយសាធារណៈ បរិស្ថាន សុខុមាលភាព និង សន្តិសុខសង្គមផង ។ មាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញ ចែងច្បាស់ថា " ***សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។*** "
- យល់ឃើញថា កាលបើក្របខ័ណ្ឌដែលច្បាប់កំណត់ឱ្យអាជ្ញាធរសាធារណៈ ចាត់វិធានការណាមួយនោះ លែងសមស្រប នឹងសភាពការណ៍បច្ចុប្បន្ននៃប្រទេសជាតិ មានតែរដ្ឋសភាទេ ដែលអាចកែប្រែបទប្បញ្ញត្តិនៃច្បាប់ដែលពុំសមស្រប នោះឱ្យសមស្របទៅវិញ ។ បើពុំនោះសោតទេ បទប្បញ្ញត្តិនៃច្បាប់នោះ នៅតែបន្តមានអានុភាពអនុវត្តដដែល។ មាត្រា ១៥៨ ថ្មី (មាត្រា ១៣៩ ចាស់) នៃរដ្ឋធម្មនុញ្ញ ចែងច្បាស់ថា " ***ច្បាប់ និង បទដ្ឋានទាំងអស់នៅកម្ពុជាដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និង ទ្រព្យសម្បត្តិក្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។*** "
- យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប ដែលបានស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់បាតុកម្ម ដែលរដ្ឋសភានៃអតីតរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ១៩៩១ បានលើកឡើងថា ខ្លឹមសារក្នុងមាត្រាខ្លះ នៃច្បាប់នេះបានផ្ទុយទៅនឹងស្មារតីមាត្រា ៣៧ នៃរដ្ឋធម្មនុញ្ញ ប៉ុន្តែពុំបានចង្អុលឱ្យច្បាស់ថា តើបទប្បញ្ញត្តិនៃមាត្រាណាមួយដែលផ្ទុយនោះទេ
- យល់ឃើញថា បើនិយាយអំពីខ្លឹមសារវិញ ច្បាប់ស្តីពីបាតុកម្ម ដែលអនុម័តដោយរដ្ឋសភាអតីតរដ្ឋកម្ពុជា កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ មិនផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីបាតុកម្ម ដែលអនុម័តដោយរដ្ឋសភាអតីតរដ្ឋកម្ពុជា កាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៦៣/០០៥/២០០៤ កបធ.ច ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

- បានឃើញលិខិត ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់តំណាងរាស្ត្រ ចំនួន ១៣ រូប **ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃមាត្រា ៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល។**

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣រូប បានផ្ញើលិខិតមួយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃមាត្រា ៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១៤:២០ ល្ងាច។ តំណាងរាស្ត្រជាម្ចាស់សំណើចំនួន ១៣រូប នេះ គឺគ្រប់គ្រាន់តាមបទប្បញ្ញត្តិនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញហើយ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបានដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ១៩៩៨

- យល់ឃើញថា សំណើរបស់តំណាងរាស្ត្រចំនួន ១៣រូប បានលើកឡើងថា *បទបរិហារកេរ្តិ៍ និងជេរប្រមាថដែលមានចែងក្នុងមាត្រា ៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល បានអនុម័តដោយឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា តាំងពីថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ មកម្ល៉េះ ។ នៅឆ្នាំ ១៩៩៣ សភាធម្មនុញ្ញបានអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាថ្មីមួយដែលបានផ្តល់អភ័យឯកសិទ្ធិដល់សមាជិករដ្ឋសភា ដូចចែងក្នុងមាត្រា ៨០ ថា " តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។ ...* "។ ហេតុដូច្នេះហើយ ទើបតំណាងរាស្ត្រចំនួន ១៣ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលពាក់ព័ន្ធទៅនឹងមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីអភ័យឯកសិទ្ធិសភា

- យល់ឃើញថា តំណាងរាស្ត្រគ្រប់រូបមានអភ័យឯកសិទ្ធិសភា ដែលធានាមិនឱ្យតំណាងរាស្ត្របារម្ភអំពីការរំលោភបំពានពីសំណាក់អំណាចនីតិប្រតិបត្តិ ឬ អំណាចតុលាការ ។ ប៉ុន្តែអភ័យឯកសិទ្ធិនេះ ក៏មានព្រំដែនកំណត់ដែរ

-យល់ឃើញថា តំណាងរាស្ត្រ មិនអាចប្រើប្រាស់អភ័យឯកសិទ្ធិនេះឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ (មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ) ឬ ប្រព្រឹត្តអំពើល្មើសច្បាប់ព្រហ្មទណ្ឌ

-យល់ឃើញថា យោងតាមខ្លឹមសារមាត្រា ៣១ មាត្រា ៣៨ មាត្រា ៣៩ និង មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ មាត្រា ៦៣ ស្តីពីការបរិហារកេរ្តឹ និង ការជេរប្រមាថ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ឃើញថា មិនមាន ចំណុចណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា មាត្រា ១៥៨ ថ្មី (មាត្រា ១៣៩ ចាស់) នៃរដ្ឋធម្មនុញ្ញ ចែងថា" *ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុត្តល និង ដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោល លើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។*" ។ ដូច្នេះ ផ្អែកលើខ្លឹមសារមាត្រា ១៥៨ ថ្មី (មាត្រា ១៣៩ ចាស់) នៃរដ្ឋធម្មនុញ្ញ មាត្រា ៦៣ ស្តីពីការបរិហារកេរ្តឹ និង ការជេរប្រមាថ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ត្រូវស្ថិតនៅជាធរមាន ពីព្រោះពុំទាន់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោលនូវបទប្បញ្ញត្តិនៃមាត្រានេះទេ ។

សម្រេច

មាត្រា ១ : មាត្រា ៦៣ ស្តីពីការបរិហារកេរ្តឹ និង ការជេរប្រមាថ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៦៤/០៣៦/២០០៤ កបធ.ច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

-បានឃើញលិខិតលេខ ២៥៥ រស ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ដែល**ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ** ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី បានធ្វើលិខិតលេខ ២៥៥ រស ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១១:១៥ ព្រឹក ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើនេះមកពិនិត្យបានដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨
- យល់ឃើញថា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិត្រូវបានតាក់តែងឡើងក្រោយពីព្រះមហាក្សត្រទ្រង់បានផ្ញើព្រះរាជសាររបស់ព្រះអង្គ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៤ ផ្ញើថ្វាយ ប្រគេនព្រះសង្ឃ និង ជូនជនរួមជាតិដើម្បីសុំចូលនិវត្តន៍ ហើយបើតាមខ្លឹមសារនៃព្រះរាជសារនេះ និង ព្រះរាជសារបន្តបន្ទាប់ការចូលនិវត្តន៍ គឺការដាក់រាជសម្បត្តិ ។ ព្រះរាជសាររបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងមានអានុភាពខ្ពស់បំផុត
- យល់ឃើញថា ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនេះ មាន ៥ ជំពូក ចែកចេញជា ១៨ មាត្រា ។

១-ជំពូកទី ១

ជំពូកនេះ មាន ២មាត្រា ហើយចែងអំពីបទប្បញ្ញត្តិទូទៅពាក់ព័ន្ធនឹងគោលដៅនៃច្បាប់ និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជសម្បត្តិដែលជាអ្នកជ្រើសតាំងព្រះមហាក្សត្រថ្មី។ ត្រង់នេះ គឺស្របនឹងមាត្រា ១០ នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី១ ដែលចែងថា " ***រាជរាជានិយមកម្ពុជា ជារបបជ្រើសតាំង*** " ហើយនិងមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី៣ ដែលចែងថា " ***ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ នីមួយៗត្រូវមានកំណត់ក្នុងច្បាប់មួយ*** " ។ ជំពូកទី ១ ទាំងមូលស្របនឹងរដ្ឋធម្មនុញ្ញ

២-ជំពូកទី ២

ជំពូកនេះ មាន ៥មាត្រា ពាក់ព័ន្ធនឹងការរៀបចំ និង សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ ហើយបញ្ជាក់អំពីតួនាទី និង ភារកិច្ចរបស់ប្រធាន អនុប្រធាន និង រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដែលត្រូវរក្សាកំណត់ហេតុ និង ឯកសារទាំងអស់របស់ក្រុមប្រឹក្សារាជសម្បត្តិមិនឱ្យខ្ចរខ្ចាយបានឡើយ ។ ក្រុមប្រឹក្សារាជសម្បត្តិមានប្រធានព្រឹទ្ធសភាជាប្រធាន និង អនុប្រធាន ២ រូប គឺ ប្រធានរដ្ឋសភាជាអនុប្រធានទី ១ និង នាយករដ្ឋមន្ត្រី ជាអនុប្រធានទី ២ ។ ក្រៅពីនេះ មានសមាជិក ៦ រូបទៀត ដូចមានចែងក្នុងមាត្រា ១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ។ ដូច្នេះ ជំពូកទី ២ ទាំងមូលស្របនឹងមាត្រា ១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ

៣-ជំពូកទី ៣

ក្នុងជំពូកនេះ មាន ៨ មាត្រា ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចជារបៀបធ្វើការប្រជុំ កូរ៉ុម ការសម្ងាត់នៃការពិភាក្សា ការអនុម័ត ការបោះឆ្នោតសម្ងាត់ ការជ្រើសរើសជាព្រះមហាក្សត្រក្នុងចំណោមសមាជិកនៃព្រះរាជវង្សានុវង្ស ដូចមានចែងក្នុងមាត្រា ១៤ នៃរដ្ឋធម្មនុញ្ញ ការធ្វើសច្ចាប្រណិធាន ការផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការជ្រើសរើសព្រះមហាក្សត្រថ្មី និង ការធ្វើព្រះរាជពិធីអភិសេកជាដើម។ ដោយឡែកមាត្រា ១០ ដោយសារការសុំចូលនិវត្តន៍ គឺជាការដាក់រាជសម្បត្តិ ដូចបានរៀបរាប់ក្នុងការយល់ឃើញខាងលើ ដូច្នេះជំពូកទី ៣ ស្របនឹងរដ្ឋធម្មនុញ្ញ

៤-ជំពូកទី ៤ និង ទី ៥

ជំពូកទាំងពីរនេះពុំមានបទប្បញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញឡើយ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលមាន ៥ ជំពូក និង ១៨ មាត្រា ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៦៥/០០៧/២០០៤ កបធ.ច ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

-បានឃើញលិខិតលេខ ២៥៣ រស ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ** ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតនេះ នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ វេលាម៉ោង ៧:៤៨ ព្រឹក

-បានឃើញសេចក្តីសម្រេចលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា " ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ " ស្របនឹងរដ្ឋធម្មនុញ្ញ

លើកលែងតែបទប្បញ្ញត្តិទាំងឡាយណាដែលបានចែងថា " ...ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី ៣ " ដែលជាទោសសម្លាប់ក្នុងមាត្រា ២០៩ មាត្រា ៥០០ មាត្រា ៥០៦ និង មាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ

-បានឃើញសេចក្តីសម្រេចលេខ ០៤៣/០០៥/២០០១ កបធ.ច.ធ.ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសថា មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលរដ្ឋសភាបានអនុម័តយល់ព្រមធ្វើនីយតកម្ម កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១ ស្របនឹងរដ្ឋធម្មនុញ្ញ។

ក្រោយពីបានស្តាប់រចនាសម្ព័ន្ធរបស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដោយប្រធានរដ្ឋសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី១ វាក្យខ័ណ្ឌទី២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី២ វាក្យខ័ណ្ឌទី២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ចំណុចដែលបានកែប្រែមានជាអាទិ៍ដូចតទៅ ÷

១-ការកែប្រែអាជ្ញាយុកាល (មាត្រា ៣ ថ្មី) គឺអាជ្ញាយុកាលនៃពាក្យបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំ តទៅទៀត (រីឯមាត្រា ៣ ចាស់ អាជ្ញាយុកាលនេះត្រូវបានពន្យារពេលបន្ថែម ២០ ឆ្នាំ ទៀតតែប៉ុណ្ណោះ)។

២-ការកែសម្រួលរចនាសម្ព័ន្ធសាលាជម្រះក្តី (មាត្រា ៣ ថ្មី) គឺរចនាសម្ព័ន្ធនៃអង្គជំនុំជម្រះវិសាមញ្ញដែលមាន ៣ ថ្នាក់ ត្រូវបានសម្រួលមកត្រឹម ២ ថ្នាក់ គឺសាលាដំបូង និង តុលាការកំពូល (តុលាការកំពូលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផង និង សម្រេចសេចក្តីចុងក្រោយផង)។

៣-ការកែប្រែសមាសភាពនៃអង្គជំនុំជម្រះតុលាការកំពូលឱ្យមានចៅក្រមខ្មែរ ៤រូប ដែលមួយរូបធ្វើជាប្រធាន និង ចៅក្រមអន្តរជាតិ ៣រូប ។ អង្គជំនុំជម្រះតុលាការកំពូលនេះ សម្រេចសេចក្តីបិទផ្លូវតវ៉ា (មាត្រា ៩ ថ្មី)។

៤-ការកែប្រែអំពីសិទ្ធិពេញលេញរបស់ជនជាប់ចោទ និង អភ័យឯកសិទ្ធិសម្រាប់មន្ត្រីតុលាការនិងមេធាវី ដោយផ្អែកលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ (មាត្រា ៤២ ថ្មី)។

៥-ការកែប្រែបន្ថែមអំពីនីតិវិធីឱ្យបានច្បាស់ថែមទៀតដូចតទៅនេះ : " ប្រសិនបើនីតិវិធីដែលមានស្រាប់ ពុំបានចែងអំពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពមិនសមស្របនៃនីតិវិធីទាំងអស់នេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកិរិតអន្តរជាតិ " (មាត្រា ២០ ថ្មី មាត្រា២៣ ថ្មី)។

៦-ការចែងបន្ថែមអំពីវិសាលភាពនៃការលើកលែងទោស និង អនុគ្រោះទោសដែលអាចផ្តល់ឱ្យមានមុនការអនុម័តច្បាប់នេះ គឺសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ (មាត្រា ៤០ ថ្មី)។

៧-ការចែងបន្ថែមអំពីលក្ខខ័ណ្ឌចៅក្រមដែលត្រូវតែងតាំង ហើយចំណើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវមានបទពិសោធន៍រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង (មាត្រា ១០ ថ្មី) ។

៨-សហព្រះរាជអាជ្ញាបរទេស មានសិទ្ធិតែងតាំងសហព្រះរាជអាជ្ញារងបរទេស (មាត្រា ២២ ថ្មី) ។

៩-ការចែងបន្ថែមអំពីភាពមិនអាចរំលោភបំពានបាននៃបណ្ណាសារដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត សហព្រះ-រាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល និង ជាទូទៅ ឯកសារ និង សម្ភារទាំងអស់ដែលអាចរកបាន ហើយដែលជាកម្មសិទ្ធិរបស់អ្នកទាំងនោះ ឬ ប្រើប្រាស់ដោយជនណាក៏ដោយក្នុងរយៈពេលនៃដំណើរការជំនុំជម្រះនេះ (មាត្រា ៤២ ថ្មី) ។

១០-ការកាត់បន្ថយការប្រើប្រាស់ភាសាជាផ្លូវការមកត្រឹម ៣ ភាសា គឺភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង (មាត្រា ៤៥ ថ្មី) ។

១១-ការកែប្រែដោយលុបចោលបទប្បញ្ញត្តិដូចតទៅ :

-លុបពាក្យ " មូលនិធិស្ម័ត្រចិត្ត " នៅក្នុងចំណុចទី២ នៃមាត្រា ៤៤ ចាស់ ។

-លុបចំណុចទី៣ នៃមាត្រា ៤៤ ចាស់ ។

ចំណុចកែប្រែទាំង ១១ ខាងលើ និងចំណុចកែប្រែដទៃទៀត ពុំមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនេះ ពុំមានបទប្បញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២ មាត្រា ៣ មាត្រា ៩ មាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៧ មាត្រា ១៨ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣១ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៩ មាត្រា ៤០ មាត្រា ៤២ មាត្រា ៤៣ មាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និង មាត្រា ៤៧ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ អាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៦៦/០០៨/២០០៤ កបធ.ច ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

- បានឃើញលិខិតលេខ ៣០៣ រស ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីពី **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការដោយប្រធានរដ្ឋសភាស្តីពី ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)
- យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការជាការកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ពុំមានចំណុចណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៤ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៦៧/០០៩/២០០៤ កបធ.ច ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

- បានឃើញលិខិតលេខ ៣០៥ រស ចុះថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០០៤ របស់សម្តេច **ឧេង សំរិន** ប្រធានរដ្ឋសភា **ស្តីពីសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី** ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតនេះនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអចិន្ត្រៃយ៍

ក្រោយពីបានពិភាក្សាក្នុងកិច្ចប្រជុំតាមច្បាប់ហើយ

- យល់ឃើញថា ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលប្រធានរដ្ឋសភាសុំពិនិត្យធម្មនុញ្ញភាព ជាច្បាប់រៀបចំអង្គការមួយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព ស្របតាមមាត្រា ១៤០ ថ្មី កថាខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា មាត្រា ១ ដល់ មាត្រា៦ ដែលចែងពីការបង្កើតក្រសួងកិច្ចការនារីស្របនឹងមេចក្តីសម្រេចនៃក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១២ កបធ.សសរ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៩ និងមិនមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយកាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៦៨/០១០/២០០៤ កបធ.ច ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

- បានឃើញលិខិតលេខ ៣០៤ រស ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់សម្តេច **ឧេង សំរិន** ប្រធានរដ្ឋសភា **ស្តីពីស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី ក្នុងការពិនិត្យ អនុម័តច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ដោយប្រធានរដ្ឋសភាស្តីពី ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការសម្រេចអំពីធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការ ជាការកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសពីរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារនៃមាត្រា ១ មាត្រា ២ មាត្រា ៣ មាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ពុំមានបទប្បញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ កាលពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៦៩/០០១/២០០៥ កបធ.ច ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

.....

-បានឃើញលិខិតលេខ ១៨៣ រស ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ ៨៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិការយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ* ។ " និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា " *ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភាដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ* " ។ ដូច្នេះ ស់ណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណមូឌ្ធិ** ព្រះប្រធានរដ្ឋសភា លេខ ១៨៣ រស ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ ដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០០៥ គឺស្របតាមរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ក្នុងប្រការ ៣៣ ថ្មី វាក្យខ័ណ្ឌទី៣ មានបទប្បញ្ញត្តិដែលចែងថា "ការប្រជុំនេះមិនទាមទារកូរ៉ុមទេ" ដែលត្រង់នេះ គេគួរពិចារណាទៅលើមាត្រា ៨៨ វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ដែលចែងថា : "ការប្រជុំរដ្ឋសភានឹងយកជាការបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់ នៃសមាជិករដ្ឋសភាទាំងមូល" ។ ក្នុងស្មារតីនៃប្រការ ៣៣ ថ្មី នេះ គឺរដ្ឋសភាចង់ចោទសួររាជរដ្ឋាភិបាលក្នុងមួយសប្តាហ៍មួយថ្ងៃ ដើម្បីជាព័ត៌មាន ។ រដ្ឋធម្មនុញ្ញ ពុំមានបទប្បញ្ញត្តិណាហាមប្រជុំរបៀបនេះទេ ដូច្នេះ ការដាក់ពាក្យបន្ថែមដូចខាងលើ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ
- យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ត្រង់ប្រការ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និងប្រការ ៨៣ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែមនោះទេ ។

សម្រេច

មាត្រា ១ : វិសោធនកម្មនៃប្រការ២ ៣ ៤ ៥ ៦ ៧ ៩ ១០ ១៤ ១៥ ១៧ ២២ ៣១ ថ្មី ៣៣ ៤០ ៤១ ៤៨ ៥១ ៥៥ ៥៦ ៥៨ ៥៩ ៦០ និង ប្រការ ៨៣ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ និង ច្បាប់ធម្មនុញ្ញបន្ថែម ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០០៥ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧០/០០២/២០០៥ កបធ.ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៥៣៨ រស ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៥ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្តីពី **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា** ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ព្រមតាមទម្រង់ និងគតិច្បាប់នេះ នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ផងដែរ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលសំណើនេះ នៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៥ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ
- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវ នូវបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ទម្រង់នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលមាន ១៣ ជំពូក ៣៧ មាត្រា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ កាលពីថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ របស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧១/០០៣/២០០៥ កបធ.ច ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៦៣៣ រស ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៥ របស់សម្តេច **ហោ សំរិន** ប្រធានរដ្ឋសភា **ស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពប្រការ ៤៧ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៥ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមប្រុងតាមច្បាប់ហើយ

- យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាព ប្រការ ៤៧ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដោយប្រធានរដ្ឋសភាស្តីទី ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)
- យល់ឃើញថា ការពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពនៃប្រការ ៤៧ ថ្មី (ពីរ) បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ)
- យល់ឃើញថា ប្រការ ៤៧ ថ្មី (ពីរ) នេះ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ពុំមានអ្វីផ្ទុយនឹងមាត្រា ៨៨ ថ្មី វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ប្រការ ៤៧ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧២/០១៤/២០០៥ កបធ.ច ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ២០២/០៧០៥/ពស/នវ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ របស់សម្តេច **ជា សុំម** ប្រធានព្រឹទ្ធសភា ដែល**ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា** ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការស្នើសុំឱ្យពិនិត្យធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយប្រធានព្រឹទ្ធសភា ជាការស្របនឹងរដ្ឋធម្មនុញ្ញ (ឃ្លាទី ១ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ការពិនិត្យ និងសម្រេចអំពីធម្មនុញ្ញភាពប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ (ឃ្លាទី ២ វាក្យខ័ណ្ឌទី ២ នៃមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ)

-យល់ឃើញថា ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីផ្ទុយនឹងមាត្រា ១១១ ថ្មី (មួយ) វាក្យខ័ណ្ឌទី ៣ នៃរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ប្រការ ៤៤ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧៤/០០១/២០០៦ កបធ.ច ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ២៧៤ រស ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ របស់សម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ២ ថ្មី ៥ ថ្មី ១០ ថ្មី ៣៥ ៤៧ ថ្មី(ពីរ) និងប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០០៦ វេលាម៉ោង ១០:៣១ នាទី។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី១ ចែងថា "*បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ* ។" និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា "*ច្បាប់*

រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភា ដើម្បីពិនិត្យតើច្បាប់ទាំងនោះ ស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញមុននឹងត្រូវបានប្រកាសឱ្យប្រើ ។

សំណើរបស់សម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា លេខ ២៧៤ រស ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ ដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០០៦ នៅវេលាម៉ោង ១០:៣១ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

-យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី៣ត្រង់ប្រការ ២ថ្មី ៥ថ្មី ១០ថ្មី ៣៥ ៤៧ ថ្មី(ពីរ) និងប្រការ ៨២ ពុំមានលក្ខណៈផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : វិសោធនកម្មប្រការ ២ ថ្មី ៥ ថ្មី ១០ ថ្មី ៣៥ ៤៧ ថ្មី(ពីរ) និងប្រការ ៨២ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧៥/០០២/២០០៦ កបធ.ច ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញសំណើលេខ ៣០០ រស ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីមជ្ឈត្តការផ្ទៃកពាណិជ្ជកម្ម** ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានយល់ព្រមឱ្យរដ្ឋសភាបន្តនីតិវិធីតាមរយៈលិខិតលេខ ០១៧/០៣០៦/ពស/នវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០០៦ ។ អត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលសំណើនេះ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ វេលាម៉ោង ១០:៤០ នាទី ព្រឹក ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានស្តាប់របាយការណ៍បំភ្លឺរបស់តំណាងក្រសួងពាណិជ្ជកម្ម
ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ
- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់នេះ
- យល់ឃើញថា មាត្រា ៥ នៃច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ត្រូវបកស្រាយថា តុលាការអាចធ្វើអន្តរាគមន៍ បានក្នុងករណីដែលភាគីស្នើសុំ ហើយមិនកម្រិតអំណាចរបស់តុលាការឡើយ
- យល់ឃើញថា មាត្រា ៤២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ដែលបានប្រគល់សិទ្ធិឱ្យសាលាឧទ្ធរណ៍សម្រេចលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបានតែក្នុងករណីដែលតុលាការពាណិជ្ជកម្ម មិនទាន់បានបង្កើត
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ក្រៅពីមាត្រា ៥ និងមាត្រា ៤២ ដែលបានកត់សម្គាល់ខាងលើ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីមជ្ឈត្តការផ្ទែកពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានយល់ព្រមឱ្យរដ្ឋសភាបន្តនីតិវិធីតាមរយៈលិខិតលេខ ០១៧/០៣០៦/ពស/នវ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧៦/០០៣/២០០៦ កបធ.ច ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៣៦៧ រស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ១៥ ថ្មី និងប្រការ ៤៨ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ វេលាម៉ោង ១០ ព្រឹក ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់កថាខណ្ឌទី២ ឃ្លាទី ១ ចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ* ។ " និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា " *ច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង វិសោធនកម្មនៃច្បាប់រៀបចំអង្គការ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ក្រោយពីរដ្ឋសភាបានអនុម័តត្រូវដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដោយប្រធានរដ្ឋសភាដើម្បីពិនិត្យតើច្បាប់ទាំងនោះស្រប ឬ មិនស្របនឹងរដ្ឋធម្មនុញ្ញ មុននឹងត្រូវបានប្រកាសឱ្យប្រើ* " ។

សំណើរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា លេខ ៣៦៧ រស ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០៦ គឺស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

- យល់ឃើញថា វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ត្រង់ប្រការ ១៥ ថ្មី និង ប្រការ ៤៨ ថ្មី ពុំមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : វិសោធនកម្មប្រការ ១៥ ថ្មី និងប្រការ ៤៨ ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧៧/០០៤/២០០៦ កបធ.ច ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ០៥៤/០៥០៦/ពស/នវ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០០៦ របស់សម្តេច **ស ខេង** ប្រធានព្រឹទ្ធសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ វេលាម៉ោង ១៤ : ១០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌទី២ ឃ្លាទី១ ចែងថា "*បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុនទីប្រកាសឱ្យប្រើ*" ។ សំណើរបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា លេខ ០៥៤/០៥០៦/ពស/ន៧ ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៦ វេលាម៉ោង ១៤:១០ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញ ភាពនេះមកពិនិត្យបាន

-យល់ឃើញថា មាត្រា ១០៦ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញបានប្រគល់ឱ្យព្រឹទ្ធសភា (មិនមែនការិយាល័យបណ្តោះអាសន្នទេ) ប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយ១និងបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល

-យល់ឃើញថា ប្រការ ៥ ចំណុច ខ ដែលចែងថា " *ការិយាល័យបណ្តោះអាសន្នមានការកិច្ចជ្រើសតាំងប្រធាន និង អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ ពីព្រោះការិយាល័យបណ្តោះអាសន្នមានសិទ្ធិរៀបចំការបោះឆ្នោតជ្រើសតាំងប្រធាន និងអនុប្រធានទាំងពីររបស់ព្រឹទ្ធសភាតែប៉ុណ្ណោះ។ ការជ្រើសតាំងប្រធាន និង អនុប្រធានទាំងពីររបស់ព្រឹទ្ធសភា ជាការកិច្ចរបស់ព្រឹទ្ធសភា

-យល់ឃើញថា ប្រការ ១៩ កថាខណ្ឌទី២ ដែលចែងថា " *ក្នុងករណីពិសេសបន្ទាន់ ដែលមិនអាចបោះឆ្នោតដាច់ដោយឡែកពីគ្នាបាន ការបោះឆ្នោតអាចធ្វើឡើងក្នុងពេលតែមួយមានទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ បាន។ សន្លឹកឆ្នោត ត្រូវធ្វើដាច់ដោយឡែកពីគ្នា* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី (មួយ) កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយ១ និង ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* " តែប៉ុណ្ណោះ

-យល់ឃើញថា ប្រការ ២០ ដែលចែងថា " *កាលបើជ្រើសរើសប្រធាន និង អនុប្រធានបានហើយប្រធានការិយាល័យបណ្តោះអាសន្ន ត្រូវប្រកាសបញ្ចប់ភារកិច្ចរបស់ការិយាល័យបណ្តោះអាសន្ន ហើយប្រគល់ការងារជូនប្រធានព្រឹទ្ធសភាដែលទើបបានជ្រើសតាំង* " ផ្ទុយនឹងមាត្រា ១០៦ ថ្មី(មួយ) កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយ១ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* "

-យល់ឃើញថា ប្រការ ២៥ ផ្ទុយនឹងមាត្រា ១០៦ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា ប្រការ ១០៩ កថាខណ្ឌទី២ បានចែងថា "*ក្នុងករណីទុញ្ញទាល់ពុំមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនេះទេ ប្រធានព្រឹទ្ធសភាត្រូវសុំការសម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ ពីសម័យប្រជុំពេញអង្គអំពីនីតិវិធីសមស្រប ដែលត្រូវយកមកអនុវត្ត*" នោះ មានលក្ខណៈផ្ទុយនឹងមាត្រា១៤០ ថ្មី កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញដែលចែងថា "*បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ*"

-យល់ឃើញថា នៅក្នុងគ្រប់ជំពូក និង ប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែបទប្បញ្ញត្តិនៃប្រការ ៥ ចំណុច ខ ប្រការ ១៩ កថាខណ្ឌទី ២ ប្រការ ២០ ប្រការ ២៥ និង ប្រការ ១០៩ កថាខណ្ឌទី ២ ។

សម្រេច

មាត្រា ១ : បទបញ្ជាផ្ទៃក្នុងថ្មីរបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី ១ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែប្រការ ៥ ចំណុច ខ ដែលមិនស្របនឹងមាត្រា ១០៦ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ ប្រការ ១៩ កថាខណ្ឌទី ២ ប្រការ ២០ ប្រការ ២៥ មិនស្របនឹងមាត្រា ១០៦ថ្មី (មួយ)កថាខណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ១០៩ កថាខណ្ឌទី២ មិនស្របនឹងមាត្រា ១៤០ថ្មី កថាខណ្ឌទី២នៃរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ :០៧៨/០០៥ / ២០០៦ កបធ.ច ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ៦៦២ រស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់** ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់យល់ស្របតាមទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែកាលពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី២ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ វេលាម៉ោង ០៩:១៥នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យល់ឃើញថា សំណើរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ១៩៩៨
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា នៅក្នុងគ្រប់មាត្រាទាំងអស់ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានបទប្បញ្ញត្តិណាដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : តាមមូលបទខាងលើ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់យល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែកាលពីថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គ លើកទី១ នីតិកាលទី២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៧៩/០០៦/២០០៦ កបធ.ច ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៦៦៣ រស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពអត្ថបទច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ វេលាម៉ោង ៩: ១៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ១៤០ ថ្មីនៃរដ្ឋធម្មនុញ្ញ ត្រង់កថាខណ្ឌទី២ ឃ្លាទី១ ចែងថា "*បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់ស្បៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ*"។ សំណើរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា លេខ ៦៦៣ រស ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ វេលាម៉ោង ៩:១៥ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

-យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ

-យល់ឃើញថា ខ្លឹមសារច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលបានបន្ថែមចំនួនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីឱ្យមានប្រសិទ្ធភាពការងារ មិនមានអ្វីផ្ទុយនឹងរដ្ឋធម្មនុញ្ញឡើយ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលរដ្ឋសភាអនុម័ត នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ស្របតាមទម្រង់ និង គតិច្បាប់ទាំងស្រុងនៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សាយភ្លាំ ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ :០៨០/០០៧ / ២០០៦ កបធ.ច ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ០៨០/០៦០៦/ពស/នវ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ របស់សម្តេច **ស៊ា ស៊ុម** ប្រធានព្រឹទ្ធសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពវិសោធនកម្មបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា** ដែលព្រឹទ្ធសភាបានអនុម័តដោយមានសំឡេងយល់ព្រមចំនួន ៥៩ លើ ៥៩ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី ១ នីតិកាលទី ២ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ២០០៦ វេលាម៉ោង ១៦:៣០នាទី។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ប្រការ ២ ថ្មី មិនមានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ប្រការ ៤ ថ្មី (ប្រការ ៥ ចាស់ កែប្រែ) ស្របនឹងមាត្រា ១០៦ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ប្រការ ១៨ ថ្មី (ប្រការ ១៩ ចាស់ កែប្រែ) ស្របនឹងមាត្រា ១០៦ ថ្មី(មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ប្រការ ៤២ ថ្មី (ប្រការ ៤៣ ចាស់ កែប្រែ) និង ប្រការ ១០៥ ថ្មី (ប្រការ ១០៦ ចាស់ កែប្រែ) មិនមានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ប្រការ ១០៨ ថ្មី (ប្រការ ១០៩ ចាស់ កែប្រែ) ស្របនឹងមាត្រា ១១៤ ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ។

សម្រេច

មាត្រា ១ : តាមមូលបទខាងលើ វិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី ១ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សាយភ្លាម ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ :០៨១/០០៨/២០០៦ កបធ.ច ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៩១៦ រស ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ វេលាម៉ោង ១០ និង ១៣ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រង់វាក្យខ័ណ្ឌទី ២ ឃ្លាទី ១ ចែងថា " *បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ* "។ សំណើរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា លេខ៩១៦រស ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៦ វេលា

ម៉ោង១០ និង ១៣ នាទី គឺស្របតាមរដ្ឋធម្មនុញ្ញ ។ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំឱ្យពិនិត្យធម្មនុញ្ញ ភាពនេះមកពិនិត្យបាន

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់ខាងលើនេះ

-យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា មិនមានអ្វីដែលមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរដ្ឋសភា នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្រប កាលពីថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៦ នាសម័យប្រជុំ វិសាមញ្ញព្រឹទ្ធសភា នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ :០៨២/០០៩/២០០៦ កបធ.ច ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ តរ.ករម.៣០/០៦ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់ឯកឧត្តម លោកជំទាវ តំណាងរាស្ត្រ ចំនួន ១៦ រូប **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិកៈ តំណាងរាស្ត្រ** ដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ០៩ : ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា សំណើរបស់ឯកឧត្តម និង លោកជំទាវតំណាងរាស្ត្រចំនួន ១៦រូប ស្របតាមល័ក្ខខ័ណ្ឌនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាច ទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

-យល់ឃើញថា អភ័យឯកសិទ្ធិសភាត្រូវបានផ្តល់ជូនរដ្ឋសភា

-យល់ឃើញថា តំណាងរាស្ត្រគ្រប់រូបមានអភ័យឯកសិទ្ធិសភា ដែលធានាមិនឱ្យតំណាងរាស្ត្របារម្ភអំពីការរំលោភបំពានពីសំណាក់អំណាចនីតិប្រតិបត្តិ ឬ អំណាចតុលាការ ។ ប៉ុន្តែអភ័យឯកសិទ្ធិនេះ ក៏មានព្រំដែនកំណត់ដែរ

-យល់ឃើញថា មាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ មានខ្លឹមសារក្រើនរំឭកដល់តំណាងរាស្ត្រ ហើយពុំមានធ្វើឱ្យតំណាងរាស្ត្របាត់បង់អភ័យឯកសិទ្ធិសភារបស់ខ្លួនឡើយ ។

សម្រេច

មាត្រា ១ : ផ្អែកតាមមូលបទខាងលើមាត្រា ៥ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ពុំមានអធម្មនុញ្ញភាពទេ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ :០៨៨/០១៥/២០០៦ កបធ.ច ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ១២៤១ រស ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និង មាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦ វេលាម៉ោង ១៥ និង ៤០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើនេះមកពិនិត្យបាន

- យល់ឃើញថា មាត្រា ១៤ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១៤ ថ្មី ដោយគ្រាន់តែលុបពាក្យ "តែ ១ ដងគត់" ក្នុងឃ្លាទី ២ ចំណុចទី ១

- យល់ឃើញថា មាត្រា ៥៧ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៥៧ ថ្មី ដោយគ្រាន់តែកែសម្រួលពី "ដោយគណៈកម្មការពិសេសមួយដែលតែងតាំងដោយរាជរដ្ឋាភិបាល" មក "ដោយក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ" ។ ការធ្វើវិសោធនកម្មខាងលើនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញ នោះទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របទាំងស្រុងកាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៨៩/០១៦/២០០៦ កបធ.ច ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ សឆ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់តំណាងរាស្ត្រ ចំនួន ១៤រូប **ស្នើសូមពិនិត្យមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ ដើម្បីធ្វើការប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ០៩ : ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា កម្មវត្ថុនៃលិខិតរបស់តំណាងរាស្ត្រ ចំនួន ១៤ រូប មានខ្លឹមសារបង្ហាប់បញ្ជា ពីព្រោះប្រើពាក្យថា " *សូមពិនិត្យមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ ដើម្បីធ្វើការប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ* "
- យល់ឃើញថា ការយោងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញនៅក្នុងលិខិតលេខ សឆ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០០៦របស់តំណាងរាស្ត្រ ចំនួន ១៤ រូប មិនត្រឹមត្រូវ ពីព្រោះច្បាប់ស្តីពីលក្ខន្តិក:តំណាងរាស្ត្រ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០០៦ រួចទៅហើយ
- យល់ឃើញថា ខ្លឹមសារនៃលិខិតលេខ សឆ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់តំណាងរាស្ត្រ ចំនួន ១៤ រូប បានថ្លែងថា "*...យើងខ្ញុំបានឃើញនូវចម្លើយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ ពាក់ព័ន្ធនឹងមាត្រា ៥ នៃច្បាប់នេះរួចហើយ ដោយក្រុមប្រឹក្សាធម្មនុញ្ញបានឆ្លើយបញ្ជាក់ថា មាត្រា ៥ នោះ ពុំមានអធម្មនុញ្ញភាពទេ ។ យើងខ្ញុំមានការសោកស្តាយ ដែលក្រុមប្រឹក្សាពុំបានពិនិត្យនូវខ្លឹមសារនៃមាត្រា ៤ ផង ដែលមាត្រានេះបង្ហាញមិនអាចប្រកែកបាននូវអធម្មនុញ្ញភាព ។ ព្រោះវាមានលក្ខណ:ងាយយល់ជាង* " ។ ជាគោលការណ៍ និង តាមយុត្តិសាស្ត្ររបស់ខ្លួនតាំងពីឆ្នាំ១៩៩៨ មកក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងបានឡើយ លុះត្រាតែមានការស្នើសុំពីឥស្សរជន ដូចមានចែងក្នុងមាត្រា ១៤០ ថ្មី មាត្រា

១៤១ថ្មី វាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ឬ ប្រជារាស្ត្រដូចមានចែងក្នុងមាត្រា ១៤១ថ្មី វាក្យខ័ណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ទើបក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ

- យល់ឃើញថា ថ្វីបើមានបញ្ហាខ្លះ ក្រុមប្រឹក្សាធម្មនុញ្ញអាចយកសំណើរបស់តំណាងរាស្ត្រចំនួន ១៤ រូប មកពិនិត្យ នៅក្នុងក្របខ័ណ្ឌនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨
- យល់ឃើញថា អភ័យឯកសិទ្ធិសភា មិនមែនជាឯកសិទ្ធិរបស់តំណាងរាស្ត្រទេ ប៉ុន្តែជាការធានាមួយផ្តល់ជូនរដ្ឋសភា ដើម្បីឱ្យការប្រព្រឹត្តទៅរបស់ខ្លួនមានប្រសិទ្ធភាពល្អ និង គ្មានឧបសគ្គ ។ ផ្តើមចេញពីអភ័យឯកសិទ្ធិផ្តល់ជូនរដ្ឋសភានេះ សមាជិកម្នាក់ៗរបស់រដ្ឋសភាមិនត្រូវបានគេចោទប្រកាន់ ឃាត់ខ្លួន ចាប់ខ្លួន ឬ ឃុំខ្លួនជាដាច់ខាត ដោយសារការបញ្ចេញមតិ ឬ ការបោះឆ្នោតទាំងឡាយក្នុងពេលបំពេញមុខងាររបស់ខ្លួននៅរដ្ឋសភា។ ប៉ុន្តែការរួចផុតពីការទទួលខុសត្រូវនេះ ក៏មានព្រំដែនកំណត់ដែរ គឺអំពើ ឬ សំដីខុសឆ្គងទាំងឡាយរបស់សមាជិករដ្ឋសភា នឹងអាចត្រូវបានផ្តន្ទាទោសផ្នែកវិន័យដោយរដ្ឋសភា ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា
- យល់ឃើញថា ក្រៅពីពេលបំពេញមុខងាររបស់ខ្លួននៅរដ្ឋសភា តំណាងរាស្ត្រម្នាក់ៗនឹងអាចត្រូវបានគេចោទប្រកាន់ ឃាត់ខ្លួន ចាប់ខ្លួន ឬ ឃុំខ្លួនទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វ៉ៃរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ជាបន្ទាន់ដើម្បីសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខដើម្បីអនុម័ត
- យល់ឃើញថា ការសម្រេចព្យួរអភ័យឯកសិទ្ធិសភាពីតំណាងរាស្ត្រ ឬ ការសម្រេចប្រគល់ឱ្យវិញនូវអភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់រដ្ឋសភា
- យល់ឃើញថា បទប្បញ្ញត្តិក្នុងចំណុចទី ១ និង ចំណុចទី ២ នៃមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មានចែងអំពីអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រ ដែលតាមការពិតជាអភ័យឯកសិទ្ធិរបស់រដ្ឋសភាទេ ។

សម្រេច

មាត្រា ១ : ផ្អែកតាមមូលបទខាងលើមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ ពុំមានអធម្មនុញ្ញភាពទេ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សព្វផ្សាយ ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៩០/០០១/២០០៧ កបធ.ច ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ០០២ រស ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦ របស់ឯកឧត្តម **ទូន ញ៉ាល** ប្រធានរដ្ឋសភា ស្តីទី **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ** ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ដោយឯកភាពទាំងស្រុងតាមទម្រង់ និង គតិនៃអត្ថបទច្បាប់នេះ ដោយឥតកែប្រែក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ នាថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៦ ដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៧ វេលាម៉ោង ១៥:៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិការាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋ-ធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ទូន ញ៉ាល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨
- យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សា-ធម្មនុញ្ញ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិក្នុងមាត្រាតែមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ មិនមានចំណុចណាដែលអាចចាត់ទុកថា មិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ដោយឯកភាពទាំងស្រុងតាមទម្រង់ និង គតិនៃអត្ថបទច្បាប់នេះ ដោយឥតកែប្រែក្នុងសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ នាថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៩១/០០២/២០០៧ កបធ.ច ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ០០១ រស ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ឯកឧត្តម **ខួន ស៊ុំឈ** ប្រធានរដ្ឋសភា ស្តីទី **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៧ វេលាម៉ោង ១៥ និង ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខួន ស៊ុំឈ** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ សំណើនេះអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៣ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៣ ថ្មី ដោយលុបឃ្លា " ***នៅថ្ងៃអាទិត្យនៃសប្តាហ៍ទី៨ មុនដំណាច់ឆ្នាំទី ៥ នៃអាណត្តិរបស់រដ្ឋសភា*** " និងបន្ថែម " ***កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*** " " ***ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ*** " និងយកឃ្លា " ***លើកលែងតែក្នុងស្ថានភាពណាមួយដូចខាងក្រោម*** " មកដាក់ក្នុងវាក្យខ័ណ្ឌថ្មីនេះ។ បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្ជឹមសារដើមទាំងស្រុង
- យល់ឃើញថា មាត្រា ៤៩ ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៤៩ ថ្មី (ពីរ) ដោយបន្ថែមមួយ វាក្យខ័ណ្ឌ " ***នៅឆ្នាំដែលមានការបោះឆ្នោតជាសកល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចសម្រេចកាលបរិច្ឆេទ និង រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត និង ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្សេងពីនេះ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោតយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃ*** " បទប្បញ្ញត្តិឯទៀតរក្សាទុកដដែល
- យល់ឃើញថា មាត្រា ៧៣ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៧៣ ថ្មី ដោយបន្ថែមមួយវាក្យខ័ណ្ឌ " **របៀបបែបបទប្តឹងជំទាស់ ឬ តវ៉ាក្នុងពេលឃោសនាបោះឆ្នោត និង ការដោះស្រាយពាក្យបណ្តឹងត្រូវកំណត់ដោយបទបញ្ជា និង នីតិវិធី** ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចលេចក្តីចុងក្រោយ " ។ បទប្បញ្ញត្តិឯទៀត រក្សាទុកដដែល

-យល់ឃើញថា មាត្រា ១២០ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១២០ ថ្មី ដោយដកស្រង់ខ្លឹមសារពីមាត្រា ៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដោយគ្រាន់តែជំនួរពាក្យ " ***សមាជិកព្រឹទ្ធសភា*** " មក " ***សមាជិកវុឌ្ឍសភា*** " វិញតែប៉ុណ្ណោះ

-យល់ឃើញថា បទប្បញ្ញត្តិទាំងអស់ក្នុងមាត្រាមួយ និង មាត្រាពីរនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញនោះទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ស្របតាមទម្រង់ និង គតិច្បាប់ទាំងស្រុង នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ :០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញព្រះរាជសារ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ វេលាម៉ោង ១៤ និង ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រប់ជ្រុងជ្រាយច្បាប់ហើយ

- យល់ឃើញថា ព្រះរាជសាររបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ បានធ្វើឡើងត្រឹមត្រូវ តាមមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-យល់ឃើញថា មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋបានចែងថា " ចំពោះបទឧក្រិដ្ឋ និង បទឧក្រិដ្ឋ តម្រូវឱ្យច្វើការ ចៅក្រមមិនត្រូវគិតពីស្ថានត្រាប្រណីទោស ឬបន្ទុរបន្ថយទោសក្រោមអប្បបរមា ឬ ព្យួរទោសបានឡើយ។ ចំពោះបទមជ្ឈឹមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ **អាចត្រូវព្យួរទោសទាំងមូល** ឬ មួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើស មិនត្រូវទទួលរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុន១ក្នុងរយៈពេល ៥ ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន "

-យល់ឃើញថា មាត្រា ៨ នេះ កែប្រែតែមាត្រា ៧០ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល **ពុំមានប៉ះពាល់ដល់សិទ្ធិ និង ផលប្រយោជន៍កុមារឡើយ**។ បទប្បញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋខាងលើនេះ ពុំមានអធម្មនុញ្ញភាពទេ

-យល់ឃើញថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់។ ពាក្យថា ច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិង ច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ។

សម្រេច

មាត្រា ១ : មាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ច្វើនៅរាជធានីភ្នំពេញថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៨

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ៤៦១រស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ វេលាម៉ោង ១៧ និង១០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញនិងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៧ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន

-យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា នៅក្នុងគ្រប់មាត្រាទាំងអស់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃ អង្គារ ទី ០១ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៨ ក្នុងកិច្ចប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ៤៦០រស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៨ របស់សម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា**

រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ព្រមនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ២ ហើយដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ វេលាម៉ោង ១៧ និង ១០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យល់ឃើញថា រដ្ឋសភាបានអនុវត្តតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលមាន ៦ជំពូក ៩២មាត្រា ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ និងព្រឹទ្ធសភា បានពិនិត្យចប់សព្វគ្រប់រួចហើយកាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៨ ក្នុងកិច្ចប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្ត្រីសម្រេច លេខ : ១០៨/០០១/២០១០ កបធ.ច ចុះថ្ងៃទី ០៤ ខែ កុម្ភ: ឆ្នាំ២០១០

ក្នុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ០៣៩ រស ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១០ របស់ឯកឧត្តម **ទូន ញ៉ុល** ប្រធានរដ្ឋសភាស្តីទី **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីអស្សាមិករណ៍** ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី២ នៃព្រឹទ្ធសភានាថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១០ វេលាម៉ោង ០៩ និង ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីអស្សាមិករណ៍

-យល់ឃើញថា សំណើរបស់ឯកឧត្តម **ទូន ញ៉ុល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីអស្សាមិករណ៍ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ច្បាប់ស្តីពីអស្សាមិករណ៍ដែលមាន ៨ ជំពូក និង ៣៩ មាត្រា ក្នុងនោះ ÷

- មាត្រា ១ ចែងថា " ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និង សំណងឱ្យបានសមរម្យ និងយុត្តិធមិ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណ: បម្រើឱ្យផលប្រយោជន៍សាធារណ: ផលប្រយោជន៍ជាតិ និង ការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។ "
- មាត្រា ២ ចែងថា " ច្បាប់នេះមានគោលបំណងជាអាទី :
  - ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធមិ
  - ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធមិ
  - បម្រើផលប្រយោជន៍សាធារណ: និង ផលប្រយោជន៍ជាតិ
  - ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណ: ។ "

មាត្រាទាំងពីរនេះ ស្របនឹងមាត្រា ៤៤ វាក្យខ័ណ្ឌទី២ និង ទី ៣នៃរដ្ឋធម្មនុញ្ញដែលចែងថា ÷

" កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។ "

" ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាម្នាយបាននោះ លុះត្រាតែប្រយោជន៍សាធារណ: តម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធមិ ។ "

ជាមួយគ្នានេះមាត្រា ៦១នៃរដ្ឋធម្មនុញ្ញ ចែងថា " ***រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេស វិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ទាប់ពីតំបន់ជាច់ស្រយាល ដោយយកចិត្តទុកដាក់ទៅលើ នយោបាយទឹក ភ្លើង ផ្លូវ និង មធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និង ប្រព័ន្ធគណនាទាន*** "

-យល់ឃើញថា ច្បាប់ស្តីពីអស្សាមិករណ៍បានធានាការទូទាត់សំណងជាមុនដោយសមរម្យនិងយុត្តិធម៌ដូចមានបញ្ជាក់នៅក្នុង ÷

• មាត្រា ១៩ ដែលចែងថា " ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុអាចធ្វើទៅបាន លុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធម៌ តាមគោលការណ៍ និង**នីតិវិធី**នៃការទូទាត់សំណង ... ។ "

• មាត្រា ២២ ដែលចែងថា " ប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍ ។ "

• មាត្រា ២៤ ដែលចែងថា " សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួស ទៅតាមភាពជាក់ស្តែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៍ ... ។ "

-យល់ឃើញថា មាត្រា ៣៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ ដែលចែងថា " ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និងយុត្តិធម៌ ... " ស្របទៅនឹងមាត្រា ៣៩នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " ***ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្តឹងបរិហារប្តឹងតវ៉ា ឬ ប្តឹងទាមសំណងជូសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និង សំណងជូសជុលការខូចខាតជាសមត្ថកិច្ច របស់តុលាការ*** ។ "

-យល់ឃើញថា ខ្លឹមសារនៅក្នុងមាត្រាទាំងអស់នៃច្បាប់ស្តីពីអស្សាមិករណ៍ ពុំមានបទប្បញ្ញត្តិណាមួយផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី **២៩** ខែ **ធ្នូ** ឆ្នាំ**២០០៩** នាសម័យប្រជុំ

រដ្ឋសភាលើកទី៣ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើ ទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ នៃព្រឹទ្ធសភានាថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ១១០/០០៣/២០១០ កបធ.ច ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ១៩៤ រ.ស ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១០ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ**ដែលរដ្ឋសភា បានអនុម័តពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១០ នាសម័យប្រជុំវិសាមញ្ញនៃរដ្ឋសភា នីតិកាលទី៤ និង ព្រឹទ្ធសភាបាន ពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ នាសម័យប្រជុំវិសាមញ្ញនៃ ព្រឹទ្ធសភា នីតិកាលទី២ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១០ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១០ វេលាម៉ោង ១០ និង ៤៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃ រដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

-យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹង រដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៤ មាត្រា ចែងពីគោលបំណង គោលដៅ វិសាលភាពនៃច្បាប់ និង និយមន័យនៃពាក្យបច្ចេកទេសដែលប្រើនៅក្នុងអត្ថបទច្បាប់នេះ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី២ ស្តីពីស្ថាប័នប្រឆាំងអំពើពុករលួយ មាន ១១ មាត្រា ចែងពីស្ថាប័នប្រឆាំងអំពើពុករលួយ ការបង្កើតក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ អាណត្តិ ការដកចេញពីតំណែង និង ការជំនួសតំណែង ការជ្រើសតាំងប្រធាន និង អនុប្រធាន ឋានៈរបស់សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង ភារកិច្ច របស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ការបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ លក្ខណសម្បត្តិនៃប្រធាន និង អនុប្រធាននៃអង្គភាពប្រឆាំងអំពើពុករលួយ ភារកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ មន្ត្រីនៃអង្គភាព ប្រឆាំងអំពើពុករលួយ និង បណ្តាញនៃអង្គភាពប្រឆាំងអំពើពុករលួយ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹង រដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៣ ស្តីពីថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយមាន ១ មាត្រា ចែងពីថវិកា និង ធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៤ ស្តីពីការប្រកាសទ្រព្យសម្បត្តិ និង បំណុល មាន ៤ មាត្រា ចែងពីសមាសភាព បុគ្គលដែលត្រូវប្រកាសទ្រព្យសម្បត្តិ និង បំណុល របបប្រកាសទ្រព្យសម្បត្តិ និង បំណុល ជនផ្សេងទៀតដែលត្រូវ ប្រកាសទ្រព្យសម្បត្តិ និង បំណុល និងការរក្សាទុកឯកសារប្រកាសទ្រព្យសម្បត្តិ និង បំណុល ពុំមានបទប្បញ្ញត្តិ ណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៥ ស្តីពីនីតិវិធីអនុវត្តចំពោះបទល្មើសពុករលួយ និង អាជ្ញាធរមានសមត្ថកិច្ច មាន ១១ មាត្រា ចែងពីនីតិវិធីសម្រាប់អនុវត្តចំពោះបទល្មើសពុករលួយ មន្ត្រីមានសមត្ថកិច្ចនៅក្នុងការស៊ើបអង្កេតបទល្មើស ពុករលួយ ការផ្តល់នីតិសម្បទាចំពោះមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ សម្ប៥ អំណាចស៊ើបអង្កេតរបស់ អង្គភាពប្រឆាំងអំពើពុករលួយ បុព្វសិទ្ធិពិសេសរបស់អង្គភាពប្រឆាំងអំពើពុករលួយ បុព្វសិទ្ធិរបស់អង្គភាពប្រឆាំង អំពើពុករលួយទាក់ទងនឹងការតាមដាន បុព្វសិទ្ធិរបស់អង្គភាពប្រឆាំងអំពើពុករលួយទាក់ទងនឹងការបង្កកទ្រព្យ សម្បត្តិរបស់បុគ្គល បុព្វសិទ្ធិរបស់អង្គភាពក្នុងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរសាធារណៈ ការចាប់យក និង នីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌ។ ជំពូកទី៥នេះ ទាក់ទងនឹងជំពូកទី៣ នៃរដ្ឋធម្មនុញ្ញ ដែលចែងអំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ។ ជាគោលការណ៍ សិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋខ្មែរ ត្រូវបានធានា ដោយរដ្ឋធម្មនុញ្ញ។ ប៉ុន្តែក្នុងករណីដែលមានតម្រុយជាក់លាក់ថា មានបទល្មើសពុករលួយ អង្គភាពប្រឆាំងអំពើ ពុករលួយ អាចចាប់ផ្តើមស៊ើបអង្កេតតែទៅលើបទល្មើសពុករលួយប៉ុណ្ណោះ ដោយចាត់វិធានការទៅតាមនីតិវិធី ដែលមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និង ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះ ជំពូកទី ៥ ពុំមាន បទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៦ ស្តីពីបទល្មើសពុករលួយ និង ទោស ចែងពីបទល្មើសពុករលួយដែលមានបញ្ញត្តិនៅក្នុង ក្រមព្រហ្មទណ្ឌ បទស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ បទសូកប៉ាន់ ចំពោះមន្ត្រីសាធារណៈបរទេស ឬ មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ បទរំលោភអំណាច បទមានទ្រព្យសម្បត្តិ ដោយខុសច្បាប់ បទទទួលផលបន្តពីបទល្មើសពុករលួយ បទមិនប្រកាសទ្រព្យសម្បត្តិ និង បំណុល បទទម្លាយ ការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ បទរារាំង និង ការជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំង

អំពើពុករលួយ បទប្តឹងបរិហារដោយការក្លែតក្លែងបន្លំ បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក បទល្មើសពុករលួយតូចតាច និង ទោស ការប៉ុនប៉ង ទោសបន្ថែមអនុវត្តចំពោះបទល្មើសពុករលួយ ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល ការផ្សាយចេញនូវកំណត់ត្រារបស់ធនាគារ សេចក្តីសម្រេចរឹបអូស និង ការទាមទារឱ្យបញ្ចូនផ្លូវផលនៃបទល្មើសពុករលួយ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៧ ស្តីពីបត្យាប័ន និង ជំនួយផ្នែកច្បាប់ទៅវិញទៅមក មាន ៤ មាត្រា ចែងពីបទប្បញ្ញត្តិដែលត្រូវអនុវត្តនៅក្នុងរឿងបត្យាប័ន ជំនួយផ្នែកច្បាប់ទៅវិញទៅមក ករណីពលរដ្ឋខ្មែរដែលមានសញ្ជាតិលើសពីមួយ និង នីតិវិធីជំនួយផ្នែកច្បាប់ទៅវិញទៅមក ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៨ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា ចែងពីការរៀបចំដំណើរការរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៩ ស្តីពីអវសានប្បញ្ញត្តិ មាន ៣ មាត្រា ចែងពីនិរាករណ៍ ការប្រកាសឱ្យប្រើច្បាប់ និងការអនុវត្តច្បាប់ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារទាំង ៩ ជំពូក ៥៧ មាត្រា នៃច្បាប់នេះ ពុំមានបទប្បញ្ញត្តិណាមិនប្រែបនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០១០ នាសម័យប្រជុំវិសាមញ្ញនៃរដ្ឋសភា នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ រៀង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ នាសម័យប្រជុំវិសាមញ្ញនៃព្រឹទ្ធសភា នីតិកាលទី២ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១០ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១១៣/០០១/២០១១ សជធ.ច ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ០៦៩ រ.ស ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០១១ របស់ឯកឧត្តម **ខួន ញ៉ឹល** ប្រធានរដ្ឋសភា ស្តីពី **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា** ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាល

ទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២០ ខែមករា ឆ្នាំ២០១១ ហើយដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១ វេលាម៉ោង ១៥ និង ៤៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា

-យល់ឃើញថា សំណើរបស់ឯកឧត្តម **ទូន ញ៉ុល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា ដែលចែងអំពីគោលដៅកំណត់ ការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា និយមន័យនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា បញ្ហាសំខាន់ៗ របស់ប្រទេសជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី២ ស្តីពីការរៀបចំសមាជ មាន ៦ មាត្រា ចែងអំពីប្រធានសមាជ ទីកន្លែងប្រារព្ធធ្វើសមាជ សមាសភាពគណៈកម្មាធិការសមាជ មុខងាររបស់ប្រធានសមាជ អត្តលេខាធិការដ្ឋានសមាជ និងបន្ទុកចំណាយ សម្រាប់ដំណើរការសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៣ ស្តីពីការប្រព្រឹត្តទៅនៃសមាជ មាន ៤ មាត្រា ចែងអំពីឥស្សរជនដែលមានសិទ្ធិផ្តួចផ្តើម ឱ្យមានការប្រជុំសមាជ ការកោះអញ្ជើញឱ្យចូលរួមប្រជុំសមាជ កូរ៉ុមនៃការប្រជុំសមាជ សំឡេងអនុម័តរបស់សមាជ តម្លៃនៃសេចក្តីសម្រេចរបស់សមាជ ការផ្សព្វផ្សាយ និង ការចុះក្នុងរាជកិច្ច ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ជំពូកទី៤ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា ចែងអំពីរយៈពេលនៃការកោះប្រជុំលើកដំបូងរបស់សមាជ ដើម្បីពិនិត្យ និង អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សមាជ និង ការអនុវត្តបទបញ្ជាផ្ទៃក្នុងរដ្ឋសភាសម្រាប់ដំណើរការកិច្ចប្រជុំសមាជលើកដំបូង ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ខ្លឹមសារទាំង ៤ ជំពូក ១៤មាត្រា នៃច្បាប់នេះ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃ ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១១៤/០០២/២០១១ កបធ.ច ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១១

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ០០៤/១១ ស.ម ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១១ របស់សម្តេច **ស៊ីសុចត្តិ ឪចំនមុនីរឥ្ស** ប្រធានសមាជស្តីទី **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា** ដែលសមាជរដ្ឋសភានិងព្រឹទ្ធសភាប្រជុំលើកដំបូង នាថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១១ បានអនុម័តដោយសំឡេង ១៣១/១៥៥ ហើយដែលអត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១១ វេលាម៉ោង ១៦ និង ២០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិការាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា បទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ជាបទបញ្ជាផ្ទៃក្នុងមួយពិសេសសម្រាប់ស្ថាប័ន នីតិប្បញ្ញត្តិកំពូលរដ្ឋសភានិងព្រឹទ្ធសភា អនុវត្តក្នុងកាលៈទេសៈដែលប្រទេសជាតិមានបញ្ហាស៊ីខាន់ៗ ត្រូវដោះស្រាយ
- យល់ឃើញថា នៅក្នុងដំណើរការនៃកិច្ចប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភាលើកដំបូង បទបញ្ជាផ្ទៃក្នុងរដ្ឋសភាត្រូវ យកមកអនុវត្តរហូតដល់សមាជអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនបាន
- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងច្បាប់ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ក្នុងការរៀបចំបទបញ្ជាផ្ទៃក្នុងនេះ
- យល់ឃើញថា លិខិតរបស់សម្តេច **ស៊ីសុចត្តិ ឪចំនមុនីរឥ្ស** ប្រធានសមាជស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះ មកពិនិត្យបាន
- យល់ឃើញថា សមាជរដ្ឋសភានិងព្រឹទ្ធសភាលើកដំបូង បានអនុម័តបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១១ ដោយទទួលបានសំឡេងចំនួន ១៣១/១៥៥ ស្របតាមមាត្រា១៤ ជំពូកទី៤ អំពីអន្តរប្បញ្ញត្តិនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០២១១/០០៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១១ ដែលចែងថា " *សមាជ ប្រជុំលើកដំបូងរបស់ខ្លួន ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ យ៉ាងយូរក្រោយពេលច្បាប់នេះចូលជាធរមាន ដើម្បី ពិនិត្យ និង អនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល និង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល* ។ "

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី១ អំពីបទប្បញ្ញត្តិទូទៅ** មានពីរប្រការ ដែលកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា អំពីនីតិវិធីទាំងឡាយដែលត្រូវអនុវត្តក្នុងសមាជ និង អំពីអចិន្ត្រៃយ៍ភាព ព្រមទាំងសមាជិកនៃអង្គសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី២ អំពីប្រធាន អនុប្រធាន និង គណៈកម្មាធិការសមាជ** មានបួនប្រការ គឺប្រការ ៣ ដល់ប្រការ៦ ក្នុងនោះ ប្រការ ៣ និង ប្រការ ៦ ចែងអំពីសមាសភាពគណៈកម្មាធិការសមាជ និង អំពីតួនាទីរបស់គណៈកម្មាធិការសមាជ រីឯប្រការ ៤ ចែងអំពីមុខងារប្រធានសមាជ ។ ប្រការ ៣ ប្រការ ៤ និង ប្រការ ៦ នៃបទបញ្ជាផ្ទៃក្នុងនេះស្របទៅនឹងមាត្រា ៦ មាត្រា ៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ព្រមទាំងស្របនឹងរដ្ឋធម្មនុញ្ញ ។ ចំណែកឯវាក្យខ័ណ្ឌទី១ នៃប្រការ ៥ គឺផ្ទុយនឹងបទប្បញ្ញត្តិវាក្យខ័ណ្ឌទី២ មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ដែលពុំមានចែងអំពី " អនុប្រធានសមាជ " និង " អនុប្រធានសមាជធ្វើការជូសប្រធានតាមលិខិតផ្ទេរសិទ្ធិ " ទេ ។ ចំពោះវាក្យខ័ណ្ឌទី២ នៃប្រការ ៥ គឺស្របនឹងបទប្បញ្ញត្តិវាក្យខ័ណ្ឌទី៣ មាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា និងស្របតាមរដ្ឋធម្មនុញ្ញ

-យល់ឃើញថា **ជំពូកទី៣ អំពីអគ្គលេខាធិការដ្ឋានសមាជ** ដែលមានពីរប្រការ គឺប្រការ ៧ និងប្រការ ៨ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ៤ អំពីរបៀបវារៈ** មានពីរប្រការ គឺប្រការ ៩ និង ប្រការ ១០ ដែលចែងអំពីគណៈកម្មាធិការសមាជជាអ្នករៀបចំរបៀបវារៈកិច្ចប្រជុំសមាជ និង **អំពីការរៀបចំលំដាប់មុនក្រោយរបស់**របៀបវារៈនៃអង្គប្រជុំសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ៥ អំពីរបៀបប្រជុំសមាជ** មានដប់បួនប្រការ ពីប្រការ ១១ ដល់ប្រការ ២៤ ដែលចែងអំពីការរៀបចំអាសនានុក្រមនៃសមាជិកសមាជ អំពីប្រធាន អនុប្រធាន និងចំនួនសមាជិក នៅក្នុងក្រុមនីមួយ១ អំពីថ្ងៃប្រជុំនិងទីកន្លែងប្រជុំសមាជ **អំពីលិខិតអញ្ជើញ** អំពីកូរ៉ុម អំពីការប្រជុំសមាជ **អំពីលេខាធិការសមាជ**និងភារកិច្ចរបស់លេខាធិការសមាជ អំពីការជជែកពិភាក្សា និង អំពីវិន័យនៃការជជែកពិភាក្សា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ៦ អំពីការរក្សាសេចក្តីស្ងប់ស្ងាត់ក្នុងពេលប្រជុំ** មានមួយប្រការ គឺប្រការ ២៥ ដែលចែងអំពីភារៈរបស់ប្រធានសមាជ រក្សាការពារមិនឱ្យមានភាពជ្រួលច្របល់ និង ភយន្តរាយកើតមានឡើងដល់សមាជ ហើយប្រធានសមាជអាចសុំអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងទ័ព ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី៧ អំពីការនាមកប្រជុំ** មានមួយប្រការ គឺប្រការ ២៦ ដែលកំណត់អំពីអវត្តមាន និងការជូនដំណឹងមកប្រធានសមាជអំពីអវត្តមានរបស់សមាជិកសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី៨ អំពីការបញ្ចេញមតិ** មានបីប្រការ គឺប្រការ ២៧ ដល់ប្រការ ២៩ ដែលចែងអំពីវិធីនៃការបញ្ចេញមតិ អំពីនីតិវិធីនៃការបោះឆ្នោតបញ្ចេញមតិរបស់អង្គសមាជត្រូវអនុវត្តតាមប្រការ ៣៧

ប្រការ ៣៨ ថ្មី និង ប្រការ ៣៩ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និង កំណត់ចំនួនសំឡេងអនុម័តរបស់សមាជ ព្រមទាំងការប្រកាសលទ្ធផលនៃការបោះឆ្នោតមតិរបស់អង្គសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី៩ អំពីវិន័យ** មានមួយប្រការ គឺប្រការ ៣០ ដែលកំណត់យកប្រការ ៧៣ ប្រការ ៧៤ ប្រការ ៧៥ និង ប្រការ ៧៩ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា សម្រាប់ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះសមាជិកសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី១០ អំពីការកែប្រែបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា** មានមួយប្រការ គឺប្រការ ៣១ ដែលកំណត់នូវចំនួនសមាជិកសមាជដែលអាចស៊ុំកែប្រែបទបញ្ជាផ្ទៃក្នុង និងចំនួនសំឡេងនៃការអនុម័ត ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា នៅក្នុងគ្រប់ជំពូក និងប្រការទាំងអស់នៃបទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែវាក្យខ័ណ្ឌទី១ នៃប្រការ ៥ ។

សម្រេច

មាត្រា ១ : បទបញ្ជាផ្ទៃក្នុងនៃសមាជរដ្ឋសភានិងព្រឹទ្ធសភា ដែលសមាជរដ្ឋសភានិងព្រឹទ្ធសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែវាក្យខ័ណ្ឌទី១ នៃប្រការ ៥ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១១៥/០០៣/២០១១ សប.ធ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ៣៦០ រ.ស ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១១ របស់ឯកឧត្តម **ខួន ស៊ុំឈ** ប្រធានរដ្ឋសភាស្តីទី **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ** ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១១ វេលាម៉ោង ១៦ និង ៤០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិការបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃ រដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

-យល់ឃើញថា សំណើរបស់ឯកឧត្តម **ទូន ញ៉ុល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន

-យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ មាន **ពីរមាត្រា** និង មានខ្លឹមសារ ដូចខាងក្រោម ÷

មាត្រាមួយ.- ត្រូវបានបន្ថែមមាត្រា ១០ស្ទួន កែប្រែមាត្រា ១៦ និង លុបមាត្រា ៥៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១០ ។

មាត្រាពីរ.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

-យល់ឃើញថា វិសោធនកម្មខាងលើនេះ បានធ្វើឡើងតែទៅលើ **បីមាត្រា** ប៉ុណ្ណោះ ÷

១-មាត្រា ១០ស្ទួន ចែងថា ÷ "*ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ចេញប្រកាសក្នុងការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពប្រឆាំងអំពើពុករលួយ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន និងការតែងតាំង ផ្ទាស់ប្តូរបញ្ចប់ការកិច្ច មន្ត្រីក្របខណ្ឌស្ថាប័នប្រឆាំងអំពើពុករលួយចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។*" មាត្រា ១០ស្ទួន នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

២-មាត្រា ១៦ថ្មី ចែងថា ÷ "*ស្ថាប័នប្រឆាំងអំពើពុករលួយមានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំនើរការការងាររបស់ខ្លួនដែលស្ថិតនៅក្នុងថវិការបស់ជាតិ ។ ស្ថាប័នប្រឆាំងអំពើពុករលួយទទួលធនធានចាំបាច់នានាពីរដ្ឋាភិបាល និងមានសិទ្ធិទទួលនូវអំនៅយ ឬ ជំនួយពីអង្គការជាតិ អន្តរជាតិនានា ។ ស្ថាប័នប្រឆាំងអំពើពុករលួយមិនត្រូវទទួលជំនួយណាដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ ។*

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាអាណាប័កដើមខ្សែ ។

ការគ្រប់គ្រង និងចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។"

ពាក្យ "*រដ្ឋាភិបាល*" ដែលមានសរសេរនៅក្នុងឃ្លាទី២ វាក្យខ័ណ្ឌទី១ មាត្រា ១៦ថ្មី មិនស្របនឹងជំពូកទី ១០ ថ្មី នៃរដ្ឋធម្មនុញ្ញទេ។ ហេតុដូច្នេះ បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌទី១ មាត្រា ១៦ថ្មី ត្រូវបានប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ។ រីឯបទប្បញ្ញត្តិនៃវាក្យខ័ណ្ឌទី២ និង វាក្យខ័ណ្ឌទី៣ មាត្រា ១៦ថ្មី ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

៣-**មាត្រា ៥៧** ត្រូវបានលុបចោល ។ មាត្រានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ លើកលែងតែវាក្យខ័ណ្ឌទី១ មាត្រា ១៦ថ្មី ក្នុង **មាត្រាមួយ** ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែវាក្យខ័ណ្ឌទី១ មាត្រា ១៦ថ្មី ក្នុង **មាត្រាមួយ** ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១១៦/០០៤/២០១១ កបធ.ច ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១១

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៤៣៤ រ.ស ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១១ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១១** នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១១ វេលាម៉ោង ១៧ និង ០៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះមគ្គតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាន **ពីរមាត្រា** និងមានខ្លឹមសារដូចខាងក្រោម ÷

មាត្រាមួយ.- ត្រូវបានកែប្រែមាត្រា ១០៩ មាត្រា ១៣១ និង មាត្រា ១៣៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ មាត្រា ៣២ថ្មី មាត្រា ៥៤ថ្មី មាត្រា ៥៦ថ្មី មាត្រា ៥៩ថ្មី មាត្រា ៦១ថ្មី មាត្រា ៦២ថ្មី មាត្រា ៦៤ថ្មី មាត្រា ៦៥ថ្មី មាត្រា ៦៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ និងមាត្រា ៤៩ថ្មី(ពីរ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។

មាត្រាពីរ.- ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ខាងលើនេះ បានធ្វើវិសោធនកម្មទៅលើ ១៣ មាត្រា ដូចខាងក្រោម ÷

  ១-មាត្រា ៣២.-ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **៣២.- ថ្មី(ពីរ)**

  - កែពី " គណៈកម្មការខេត្ត ក្រុង " ទៅជា " ***គណៈកម្មការរាជធានី ខេត្ត*** " ក្នុងវាក្យខ័ណ្ឌទី២
  - កែពី " មាត្រា ១៣ ថ្មី " ទៅជា " ***មាត្រា ១៣ថ្មី (ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី៤

  បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

  មាត្រា ៣២ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

  ២-មាត្រា ៤៩.- ថ្មី(ពីរ) ត្រូវបានធ្វើវិសោធនកម្មទៅជា **មាត្រា ៤៩.- ថ្មី(បី)**

  កែពី " ដប់ប្រាំ (១៥) ថ្ងៃ " ទៅជា " ***សាមសិប (៣០) ថ្ងៃ*** " ក្នុងវាក្យខ័ណ្ឌទី២ និងបានបន្ថែមមួយវាក្យខ័ណ្ឌ " ***ការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត និង ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ដែលត្រូវបង្កើតថ្មីដែលត្រូវកែប្រែព្រំប្រទល់តាមលិខិតខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងលិខិតខ័ណ្ឌដែលចែងក្នុងច្បាប់នេះ និងបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*** " ជាវាក្យខ័ណ្ឌទី៤ ។

  បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៤៩ ថ្មី(បី)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៣-មាត្រា ៥៤.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៥៤.- ថ្មី(ពីរ)

- កែពី " មាត្រា ៤៩ ថ្មី(ពីរ) " ទៅជា " ***មាត្រា ៤៩ ថ្មី(បី)*** " ក្នុងចំណុច ក

- កែពី " មាត្រា ៥៤ ថ្មី " ទៅជា " ***មាត្រា ៥៤ ថ្មី(ពីរ)*** " ក្នុងចំណុច ឃ ង និង ច

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៥៤ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៤-មាត្រា ៥៦.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៥៦.- ថ្មី(ពីរ)

- កែពី " មាត្រា ៥៤ ថ្មី " ទៅជា " ***មាត្រា ៥៤ ថ្មី(ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី១

- កែពី " គណៈកម្មការខេត្ត ក្រុង " ទៅជា " ***គណៈកម្មការរាជធានី ខេត្ត*** " ក្នុងវាក្យខ័ណ្ឌទី២

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៥៦ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៥-មាត្រា ៥៩.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៥៩.- ថ្មី(ពីរ)

- កែពី " មាត្រា ៥៤ ថ្មី " ទៅជា " ***មាត្រា ៥៤ ថ្មី(ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី១

- កែពី " គណៈកម្មការខេត្ត ក្រុង " ទៅជា " ***គណៈកម្មការរាជធានី ខេត្ត*** " ក្នុងវាក្យខ័ណ្ឌទី២

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៥៩ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៦-មាត្រា ៦១.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦១.- ថ្មី(ពីរ)

- កែពី " មាត្រា ៥៤ ថ្មី " ទៅជា " ***មាត្រា ៥៤ ថ្មី(ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី២

- កែពី " មាត្រា ៦២ ថ្មី " ទៅជា " ***មាត្រា ៦២ ថ្មី(ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី៣

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦១ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៧-មាត្រា ៦២.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦២.- ថ្មី(ពីរ)

កែពី " មាត្រា ៥៤ ថ្មី " ទៅជា " ***មាត្រា ៥៤ ថ្មី(ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី៤

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦២ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

៨-មាត្រា ៦៤.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៦៤.- ថ្មី(ពីរ)

កែពី " មាត្រា ៥៤ ថ្មី " ទៅជា " ***មាត្រា ៥៤ ថ្មី(ពីរ)*** " និងបន្ថែមវាក្យខ័ណ្ឌទី៤ "***នៅឆ្នាំដែលមានការរៀបចំ ការបោះឆ្នោតជាសកល ការប្តឹងជំទាសមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ មានរយៈពេលដប់(១០)ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។***"

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦៤ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

៩-មាត្រា ៦៥.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **៦៥.- ថ្មី(ពីរ)**

កែពី " មាត្រា ៥៤ ថ្មី " ទៅជា "***មាត្រា ៥៤ ថ្មី(ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី៥

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦៥ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

១០-មាត្រា ៦៦.- ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **៦៦.- ថ្មី(ពីរ)**

កែពី " មាត្រា ៥៤ ថ្មី " ទៅជា "***មាត្រា ៥៤ ថ្មី(ពីរ)*** " ក្នុងវាក្យខ័ណ្ឌទី៣

បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល ។

មាត្រា ៦៦ ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

១១-មាត្រា ១០៩.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **១០៩.- ថ្មី**

"គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវប្រមូលកំណត់ហេតុ និង ឯកសារទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោត ***រួចធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។ កំណត់ហេតុនេះត្រូវធ្វើជាបួនច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មួយច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត មួយច្បាប់បិទផ្សាយនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និង មួយច្បាប់ទៀតទុកជាឯកសារ ។***"

បន្ថែមវាក្យខ័ណ្ឌទី២ និងទី៣ ដូចតទៅ "***ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវបើកការប្រជុំសម្រេចជាសាធារណៈជាបន្ទាន់ ។***"

"***ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬ តំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតជាបន្ទាន់ ។***"

មាត្រា ១០៩ ថ្មីនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

១២-មាត្រា ១៣១.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **១៣១.- ថ្មី**

"ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.000.000) រៀលទៅដល់ដប់លាន (១0.000.000) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ឬ និង ***ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់***

រយៈពេលប្រាំ (៥)ឆ្នាំ ចំពោះជនណា ឬ គណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹង ***មាត្រា ៧៣ថ្មី*** ឬ មាត្រា ៧៦ នៃច្បាប់នេះ។"

មាត្រា ១៣១ ថ្មីនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

១៣-មាត្រា ១៣៣.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា **១៣៣.- ថ្មី**

"ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧២ នៃច្បាប់នេះ។ ក្នុងករណីដែលពុំព្រមអនុវត្តតាមត្រូវ ***លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត*** សម្រាប់រយៈពេលប្រាំ (៥)ឆ្នាំ លុប បេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.000.000) រៀលដល់ដប់លាន (១0.000.000) រៀល។"

មាត្រា ១៣៣ ថ្មីនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា មាត្រាមួយ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១0 ខែ មិថុនា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១១៧/០០៥/២០១១ កបធ.ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១១

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៨៣៥ រ.ស ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើអត្ថបទច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១១** នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភា បានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែក្នុងសម័យ ប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១១ វេលាម៉ោង ១៧ និង ០៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិការបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាន **ពីរមាត្រា**
- យល់ឃើញថា ក្នុង**មាត្រាមួយ**នៃច្បាប់ខាងលើនេះ មាត្រា ១៩០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១៩០ ថ្មី(ពីរ) ដោយពន្យារកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣ ទៅធ្វើនៅថ្ងៃអាទិត្យ ទី ០៣ ខែ មិថុនា ឆ្នាំ២០១២ វិញ ។

មាត្រា ១៩០.- ថ្មី(ពីរ)នេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា **មាត្រាពីរ** ដែលចែងថា ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១១៨/០០៦/២០១១ កបធ.ច ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១១

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០១០ ប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញសេចក្តីសម្រេចលេខ ១១៥/០០៣/២០១១ កបធ.ច ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៦៣៣ រ.ស ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានរដ្ឋសភាអនុម័តកែសម្រួលនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ ហើយព្រឹទ្ធសភាបានប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថា គ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ ឡើយ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះ នៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១១ វេលាម៉ោង ១៦ និង ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាអ្វីមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា តាមសេចក្តីសម្រេចលេខ ១១៥/០០៣/២០១១ កបធ.ច ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចក្នុងមាត្រា ១ ដូចតទៅ "ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី៩ នីតិកាលទី២ នាថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែវាក្យខណ្ឌទី១ មាត្រា ១៦ ថ្មី ក្នុង**មាត្រាមួយ**។"
- យល់ឃើញថា បន្ទាប់ពីមានសំណើរបស់រាជរដ្ឋាភិបាលលេខ ៣៩៩ លស.កបច ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១១ រដ្ឋសភាបានកែតម្រូវវាក្យខណ្ឌទី១ មាត្រា ១៦ ថ្មី ក្នុង**មាត្រាមួយ** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយរួចហើយ កាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ ដើម្បីឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១១៥/០០៣/២០១១ កបធ.ច ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០១១ ។ ព្រឹទ្ធសភាបានប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថា គ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ ឡើយ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានកែតម្រូវនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី៤ ហើយព្រឹទ្ធសភាបានប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថាគ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ឡើយ ត្រូវបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១២២/០០៣/២០១២ កបធ.ច ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ០២៦/០៧១២/ពស/ព.ន.វ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ របស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាព នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដែលបានអនុម័តយល់ព្រមចំនួន ៤៥ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល នាសម័យប្រជុំលើកទី១ នីតិកាលទី៣ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ ហើយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះនៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១២ វេលាម៉ោង ០៩ និង ៤៥ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះផ្លូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ស្របនឹងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ដោយមានសំឡេងយល់ព្រម ៤៥ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលគឺស្របនឹងមាត្រា ១១៤ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ១ "អំពីការិយាល័យបណ្តោះអាសន្ន និងការកិច្ច"** ដែលមាន ៣ ប្រការ គឺប្រការ ១ ដល់ប្រការ ៣ ស្របនឹងមាត្រា ១០៦ថ្មី (មួយ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ២ "អំពីសុពលភាពនៃអាណត្តិរបស់សមាជិកគ្រឹះឋសភា"** ដែលមាន ២ ប្រការ គឺប្រការ ៤ និង ប្រការ ៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៣ "អំពីប្រធាន អនុប្រធាន គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការនានារបស់គ្រឹះឋសភា"** ដែលមាន ២១ ប្រការ គឺប្រការ ៦ ដល់ប្រការ ២៦ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៤ "អំពីអគ្គលេខាធិការដ្ឋានគ្រឹះឋសភា"** ដែលមាន ៤ ប្រការ គឺប្រការ ២៧ ដល់ប្រការ ៣០ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **ជំពូកទី ៥ "អំពីថវិកា"** ដែលមាន ១ ប្រការ គឺប្រការ ៣១ ថ្មីឡើងស្របនឹងមាត្រា ១០៥ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា **ជំពូកទី ៦ "អំពីការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាផ្សេងៗ"** ដែលមាន ៤ ប្រការ គឺប្រការ ៣២ ដល់ប្រការ ៣៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញ ថា **ជំពូកទី ៧ "អំពីរបៀបទារៈប្រជុំ"** ដែលមាន ២ ប្រការ គឺប្រការ ៣៦ និង ប្រការ ៣៧ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ៨ "អំពីរបៀបប្រជុំ"** ដែលមាន ១៩ ប្រការ គឺប្រការ ៣៨ ដល់ប្រការ ៥៦ ធ្វើឡើងស្របនឹងមាត្រា ១១០ថ្មី និង មាត្រា ១១១ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា **ជំពូកទី ៩ "អំពីការពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬបញ្ហាផ្ទៃក្នុងតូចក្នុងពេលប្រជុំក្រឹត្តសភា"** ដែលមាន ៤ ប្រការ គឺប្រការ ៥៧ ដល់ប្រការ ៦០ ធ្វើឡើងស្របនឹងមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា **ជំពូកទី ១០ "អំពីការបញ្ឈប់ឋានៈ"** ដែលមាន ៧ ប្រការ គឺប្រការ ៦១ ដល់ប្រការ ៦៧ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ១១ "អំពីការរក្សាសេចក្តីសុខស្ងាត់ក្នុងពេលប្រជុំ"** ដែលមាន ៣ ប្រការ គឺប្រការ ៦៨ ដល់ប្រការ ៧០ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ១២ "អំពីការឈប់ ឬការខានមកប្រជុំ"** ដែលមាន ៥ ប្រការ គឺប្រការ ៧១ ដល់ប្រការ ៧៥ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ១៣ "អំពីវិន័យក្នុងព្រឹទ្ធសភា"** ដែលមាន ៦ ប្រការ គឺប្រការ ៧៦ ដល់ប្រការ ៨១ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ១៤ "អំពីការសុំកែប្រែបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា"** ដែលមាន ២ ប្រការ គឺប្រការ ៨២ និងប្រការ ៨៣ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា **ជំពូកទី ១៥ "អំពីអត្ថសាធកប្បញ្ញត្តិ"** ដែលមាន ១ ប្រការ គឺប្រការ ៨៤ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

-យល់ឃើញថា បទប្បញ្ញត្តិទាំងអស់នៃប្រការទាំង ៨៤ នៅក្នុងជំពូកទាំង ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានអនុម័តនាសម័យប្រជុំលើកទី១ នីតិកាលទី៣ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១២ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០២ កបធ.សសរ.ច ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

.....

-បានឃើញសំណើរបស់ក្រុមអ្នកតំណាងរាស្ត្រ ១៥ នាក់ ឱ្យពិនិត្យបកស្រាយមាត្រាមួយចំនួននៃច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មលើមាត្រា និង ជំពូកមួយចំនួន ដែលត្រូវរដ្ឋសភាអនុម័តកាលពី ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ១៩៩៩ ដោយលើកបញ្ហាក់មាត្រា ១៤០ ថ្មី ១៥៤ ថ្មី និង ១៥៦ ថ្មី នៃច្បាប់រដ្ឋធម្មនុញ្ញ និង បង្ហាញនូវចម្ងល់ថា ហេតុដូចម្តេចបានជាច្បាប់ធម្មនុញ្ញឥតបានបញ្ជូនទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ហេតុដូចម្តេចបានជាចាំបាច់មានអន្តរប្បញ្ញត្តិ ក្នុងការប្រកាសឱ្យចូលជាធរមានភ្លាមនូវរដ្ឋធម្មនុញ្ញ និង ក្នុងការជ្រើសតាំងព្រះមហាក្សត្រ តាមលក្ខខណ្ឌដែលមានប្រធាន និង អនុប្រធានព្រឹទ្ធសភាផងនោះម្តងទៀត ហើយព្រមទាំងបានលើកជាឧទាហរណ៍ថា "ការមិនបញ្ជូនច្បាប់រៀបចំព្រឹទ្ធសភាទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ហើយនិងការបង្កើតមាត្រានៃអន្តរប្បញ្ញត្តិទាំងពីរនេះ បែរជាធ្វើឱ្យច្បាប់ធម្មនុញ្ញនេះមិនស្របច្បាប់ និង មិនរលូនទៅវិញ។" ដែលទទួលបាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៩៩

-បានឃើញឯកសារនានាពីរដ្ឋសភា ដែលទាក់ទងនឹងមាត្រា ១៤០ថ្មី ១៥៤ថ្មី និង ១៥៦ថ្មី នៃច្បាប់ធម្មនុញ្ញ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ១៤០ ថ្មី ឃ្លាទី១ នៃកថាខណ្ឌទី២ បានចែងច្បាស់ថា "បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ" គឺមានន័យថា ច្បាប់តម្រូវឱ្យបញ្ជូនជាចាំបាច់មកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនូវបទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយដែលបានអនុម័តហើយ មុននឹងប្រកាសឱ្យប្រើ។ ច្បាប់ធម្មនុញ្ញ មិនមែនជាច្បាប់រៀបចំអង្គការទេ ហើយច្បាប់ មិនតម្រូវឱ្យបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើឡើយ

-យល់ឃើញថា មាត្រា ១៥៤ ថ្មី បានចែងច្បាស់ក្នុងអន្តរប្បញ្ញត្តិថា : "រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័តត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា" គឺមានន័យថា ច្បាប់ធម្មនុញ្ញជាផ្នែកជាប់ក្នុងអត្ថបទនៃរដ្ឋធម្មនុញ្ញ។ ដូច្នេះមាត្រានេះសម្រាប់តែប្រកាសឱ្យចូលជាធរមានភ្លាមនូវច្បាប់ធម្មនុញ្ញប៉ុណ្ណោះ។ គេត្រូវដាក់ពាក្យថា "រដ្ឋធម្មនុញ្ញ" ក្នុងមាត្រានេះ ពីព្រោះនៅពេលត្រូវបានអនុម័តហើយ ច្បាប់ធម្មនុញ្ញត្រូវចូលក្នុងរដ្ឋធម្មនុញ្ញ

-យល់ឃើញថា មាត្រា ១៥៦ ថ្មី បានចែងច្បាស់ក្នុងអន្តរប្បញ្ញត្តិថា : "ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ " គឺមានន័យថា ជាលក្ខខណ្ឌក្នុងការជ្រើសរើសព្រះមហាក្សត្រក្នុងករណីដែលពុំមានព្រះមហាក្សត្រ ក្រោយពេលដែលច្បាប់ធម្មនុញ្ញនេះចូលជាធរមាន។ ប៉ុន្តែតាមការជាក់ស្តែងពុំមានករណីនេះទេ ដូច្នេះក្នុងការជ្រើសរើសព្រះមហាក្សត្រថ្មី គឺត្រូវតែគោរពតាមមាត្រា ១៣ ថ្មី និង មាត្រា ១៤ នៃរដ្ឋធម្មនុញ្ញ ។

សម្រេច

មាត្រា ១ : ក្នុងន័យដូចមានបកស្រាយ ដែលបានរៀបរាប់ក្នុងមូលបទខាងលើនេះ មាត្រា ១៤០ ថ្មី ឃ្លាទី១ កថាខ័ណ្ឌទី២ មាត្រា ១៥៤ ថ្មី និង មាត្រា ១៥៦ ថ្មី នៃច្បាប់ធម្មនុញ្ញ មិនមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិណានៃរដ្ឋធម្មនុញ្ញឡើយ ។

មាត្រា ១ : សេចក្តីសម្រេចនេះ ធ្វើនៅភ្នំពេញថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

សេចក្តីសម្រេច លេខ : ០៣ កបធ. សសរ.ច ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញ**សំណើសុំឱ្យពិនិត្យបកស្រាយមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញ** ដោយក្រុមអ្នកតំណាងរាស្ត្រ ៤១រូប ដែលបានលើកបញ្ហាក់ថា មានមតិយោបល់ជាច្រើនប្លែកៗពីគ្នា ប្រកបដោយភាពចម្រូងចម្រាស់ទាំងក្នុងមតិជាតិ ទាំងក្នុងមតិអន្តរជាតិ អង្គការសារព័ត៌មាននានា អង្គការក្រៅរដ្ឋាភិបាល។ ល។ ជុំវិញការកាត់ទោសមេខ្មែរក្រហម **តា ម៉ុក** ក្រោយពីការចាប់ខ្លួនកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៩៩ ពិសេស ខ្លះលើកឡើងថា ត្រូវតែបញ្ជូនខ្លួនទៅតុលាការអន្តរជាតិក្នុងប្រទេសណាមួយ ខ្លះទៀតថា ត្រូវតែដំណើរការកាត់ទោសនៅក្នុងប្រទេសទើបត្រឹមត្រូវ ដែលទទួលបាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ០៦ ខែ មេសា ឆ្នាំ១៩៩៩

-បានឃើញឯកសារនានាពីរដ្ឋសភា ដែលទាក់ទងនឹងមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី១ ដែលចែងថា "ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក" គឺក្នុងគោលបំណងដ៏ពិសិដ្ឋ ដើម្បីការពារសិទ្ធិផលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់ៗរូប ពិសេសការពារពីការដកសញ្ជាតិខ្មែរ ពីការនិរទេស ឬ ពីការចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយ

-យល់ឃើញថា ខ្លឹមសារមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញនេះ ការចាប់បញ្ជូនខ្លួនឬវប្រជាពលរដ្ឋខ្មែរណាម្នាក់ទៅឱ្យប្រទេសក្រៅណាមួយ អាចធ្វើទៅបាន លុះត្រាតែមានកិច្ចព្រមព្រៀងទៅវិញទៅមក ។

សម្រេច

មាត្រា ១ : ការចាប់បញ្ជូនខ្លួនពលរដ្ឋខ្មែរគ្រប់ៗរូបទៅឱ្យកាត់ទោស ឬ/និង ទទួលរងទោសនៅប្រទេសក្រៅមិនអាចធ្វើទៅបានឡើយក្នុងក្របខ័ណ្ឌនៃខ្លឹមសារមាត្រា ៣៣ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញដែលបានចែងថា : "ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក" ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅភ្នំពេញថ្ងៃទី ២៨ ខែ មេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

សេចក្តីសម្រេច លេខ : ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ០៩៥/៥០០/ពស/ជក របស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០០ **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី ជំពូកទី ៨ នៃរដ្ឋធម្មនុញ្ញ ។**

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ប្រធានព្រឹទ្ធសភា បានសុំក្នុងលិខិតលេខ ០៩៥/៥០០/ពស/ជក របស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០០ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយតែវាក្យខ័ណ្ឌទី១ នៃមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ ជាពិសេសត្រង់សេចក្តីថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ "

-យល់ឃើញថា យើងអាចលើកយកពាក្យថា "បើជាការប្រញាប់ " មកពិនិត្យបានក្នុងបួនករណី គឺ :

-១- ករណីដែលក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់មានមាត្រាណាមួយចែងថា : "ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ "។

-២- ករណីដែលមានលិខិតផ្លូវការរបស់រាជរដ្ឋាភិបាល ឬ របស់ម្ចាស់សេចក្តីស្នើច្បាប់សុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះជាការប្រញាប់។

-៣- ករណីដែលមានការស្នើសុំពីរដ្ឋសភា ឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់។

-៤- ករណីដែលរាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់។

ករណីទី១ : ករណីដែលក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ មានមាត្រាណាមួយចែងថា : "ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ "។

ជាបឋម យើងគួរធ្វើការវែកញែកវាង "ការប្រញាប់ក្នុងការធ្វើច្បាប់ " ហើយនិង " ការប្រញាប់ក្នុងការអនុវត្តច្បាប់ "។

"ការប្រញាប់ក្នុងការធ្វើច្បាប់" គឺបានន័យថា រដ្ឋសភា ត្រូវខំធ្វើនិងអនុម័តច្បាប់ឱ្យបានឆាប់រហ័ស ហើយច្រើនតែតាមសំណើសុំរបស់រាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ។ ប៉ុន្តែនេះគ្រាន់តែជាការខិតខំរបស់រដ្ឋសភា មិនមែនជាការបង្ខំរដ្ឋសភាឱ្យធ្វើតាមសំណូមពរនោះទេ។

"ការប្រញាប់ក្នុងការអនុវត្តច្បាប់" គឺក្នុងន័យដែលមានចែងក្នុងមាត្រា ៩៣ថ្មី វាក្យខ័ណ្ឌទី១នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្តីថា : "ប៉ុន្តែបើច្បាប់នេះចែងថា ជាការប្រញាប់ ច្បាប់នេះ ត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ " ។ ពាក្យថា "ចូលជាធរមាន " គឺសំដៅលើការអនុវត្តច្បាប់។

ប្រការដែលមានមាត្រាណាមួយចែងក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ថា : "ច្បាប់នេះ ត្រូវចាត់ទុកជាការប្រញាប់ " នោះ គឺសំដៅទៅលើ "ការប្រញាប់ក្នុងការអនុវត្តច្បាប់ " ប៉ុណ្ណោះ ពីព្រោះជាខ្លឹមសារនៃសេចក្តីដែលមានចែងក្នុងច្បាប់តែម្តង ដើម្បីតម្រូវការអនុវត្តឱ្យស្របនឹងមាត្រា ៩៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ។ គឺមិនមែនតាមលិខិតមួយផ្សេងដោយឡែកដែលធ្វើឡើងដោយរាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ដើម្បីសុំឱ្យរដ្ឋសភាពិនិត្យជាការប្រញាប់ឡើយ។

ក្នុងករណីនេះ បើមានត្រឹមតែមាត្រា ក្នុងសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ចែងថា : " ជាការប្រញាប់ " ប៉ុណ្ណោះ គឺមិនមែនជា "ការប្រញាប់ក្នុងការធ្វើច្បាប់ទេ "។ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ខែ សម្រាប់ពិនិត្យ ហើយឱ្យយោបល់។

ករណីទី២ : រាជរដ្ឋាភិបាលធ្វើលិខិតស្នើសុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ជាការប្រញាប់ ទោះបីក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់បានចែង ឬ មិនបានចែងថា "ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ "ក៏ដោយ។

ក្នុងករណីនេះ រដ្ឋសភាត្រូវសម្រេចលើពាក្យសុំនោះ តាមនីតិវិធីដែលមានចែងក្នុងប្រការ ៤៥ និង ៤៦ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា គឺថា រាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ត្រូវជូនហេតុផលអំពីការសុំជាការប្រញាប់នោះ។ ប្រធានរដ្ឋសភានាំសេចក្តីទៅថ្លែងជម្រាបរដ្ឋសភា ដើម្បីសុំរដ្ឋសភាសម្រេចថា យល់ព្រមទុកជាការប្រញាប់ ឬ មិនយល់ព្រម។

បើរដ្ឋសភាសម្រេចថាយល់ព្រម ពេលនោះរដ្ឋសភាយកសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់មកពិនិត្យ ពិភាក្សាមុនគេ ស្របតាមប្រការ ៤៤ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ ក្រោយបានអនុម័តយល់ព្រមលើកដំបូងហើយ រដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់ដូចមានចែងក្នុងមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ។ បើគ្មានពាក្យសុំពីរដ្ឋសភាថា ជាការប្រញាប់ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ ខែ សម្រាប់ពិនិត្យ និងឱ្យយោបល់។

<u>ករណីទី៣</u> :ជាការត្រឹមត្រូវ រដ្ឋសភាអាចនឹងស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ ¯ជាការប្រញាប់ ¯បានដែរ នៅពេលដែលរដ្ឋសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ដែលខ្លួនបានអនុម័តយល់ព្រមលើកដំបូងរួចហើយ មកព្រឹទ្ធសភាតាមមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ។ ការស្នើសុំរបស់រដ្ឋសភាឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់នេះ មានចែងក្នុងប្រការ ៤២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ព្រឹទ្ធសភាត្រូវសម្រេចលើពាក្យសុំនេះ តាមនីតិវិធីដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺថា រដ្ឋសភាត្រូវជូនហេតុផលជាលាយលក្ខណ៍អក្សរ ហើយប្រធានព្រឹទ្ធសភានាំពាក្យទៅថ្លែងជម្រាបព្រឹទ្ធសភា ដើម្បីសុំព្រឹទ្ធសភាសម្រេចថា យល់ព្រម ឬ មិនយល់ព្រមទុកជាការប្រញាប់។

ដូច្នេះ វាអាស្រ័យលើព្រឹទ្ធសភាជាអ្នកសម្រេចថាគួរទុកជាការប្រញាប់ ឬ មិនគួរ ទោះបីមានសំណើពីរដ្ឋសភាថា ទុកជាការប្រញាប់ក៏ដោយ។ បើព្រឹទ្ធសភាយល់ថា គួរទុកជាការប្រញាប់តាមសំណើរបស់រដ្ឋសភា ពេលនោះព្រឹទ្ធសភាត្រូវអនុវត្តតាមប្រការ ៤១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺត្រូវចុះសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ក្នុងរបៀបវារៈពិភាក្សាមុនគេ ហើយត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលប្រាំថ្ងៃ ដើម្បីឱ្យស្របនឹងមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ។ បើព្រឹទ្ធសភាយល់ថា មិនគួរទុកជាការប្រញាប់ទេ ព្រឹទ្ធសភាមានរយៈពេល ១ខែ ដូចធម្មតា សម្រាប់ពិនិត្យ និង ឱ្យយោបល់ ។

<u>ករណីទី៤</u> : រដ្ឋសភាពុំបានសុំទេ ប៉ុន្តែរាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់សុំឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់។ នីតិវិធីដូចក្នុងករណីទី៣ ដែរ គឺត្រូវអនុវត្តប្រការ ៤១ ៤២ និង ៤៣ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។ ព្រឹទ្ធសភាជាអ្នកសម្រេចខ្លួនឯងថា គួរយល់ព្រមតាមការសុំឬទេ។ បើយល់ព្រមត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេល ៥ ថ្ងៃ។ ប៉ុន្តែបើមិនយល់ព្រមទេ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ ខែ ដដែល។

តាមការវិភាគទាំង ៤ ករណីខាងលើនេះមក ព្រឹទ្ធសភាមានរយៈពេលធម្មតា ១ ខែ ក្នុងការពិនិត្យ និង ឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់។ ក្នុងករណីដែលមានពាក្យសុំពីរដ្ឋសភា ពីរាជរដ្ឋាភិបាល ឬ ពីម្ចាស់សេចក្តីស្នើច្បាប់ឱ្យពិនិត្យជាការប្រញាប់ ព្រឹទ្ធសភាមានអំណាចសម្រេចខ្លួនឯងថាត្រូវទុក ឬ មិនត្រូវទុកជាការប្រញាប់

-យល់ឃើញថា របៀបគិតរយៈពេល ឬ របៀបរាប់ថ្ងៃ ពុំមានចែងក្នុងច្បាប់ណាមួយឱ្យបានច្បាស់លាស់ទេ ក្នុងប្រទេសយើង។ តាមទម្លាប់រដ្ឋបាលក្តី តុលាការក្តី គេមានរបៀបរាប់ថ្ងៃ និង រយៈពេលពីរយ៉ាងគឺ :

១-របៀបរាប់រយៈពេលគត់ (ជាភាសាបារាំងគេហៅថា "délai franc")

២-របៀបរាប់រយៈពេលមិនគត់ (ជាភាសាបារាំងគេហៅថា "délai non franc")

<u>របៀបរាប់ទី១ : រយៈពេលគត់</u>

គឺគេមិនរាប់ថ្ងៃទទួល (ឯកសារ)ដែលជាភាសាឡាតាំងហៅថា (dies a quo) និងថ្ងៃដែលត្រូវផុតដែលភាសាឡាតាំង (dies ad quem)។ ឧបមាថា រយៈពេលគត់ ៥ ថ្ងៃ។ ថ្ងៃទទួលឯកសារ គឺ ថ្ងៃទី៥ មិថុនា ហើយនិងថ្ងៃដែលត្រូវផុតគឺថ្ងៃទី ១០ មិថុនា។ គេមិនរាប់ថ្ងៃទី ៥ មិថុនា ទេ គឺគេចាប់រាប់ ពីថ្ងៃទី ៦ មិថុនាទៅ។ គេមិនរាប់ ថ្ងៃទី ១០ មិថុនា ដែលជាថ្ងៃត្រូវផុតទេ គឺគេរាប់ថ្ងៃទី ១១ មិថុនា ទើបចប់ផុតបរិបូរណ៍។ ហើយគេរាប់ពីម៉ោង ១២ យប់ (ម៉ោងសូន្យ) ដល់ម៉ោង ១២ យប់ សម្រាប់ពេញមួយថ្ងៃ។

ដូច្នេះ ក្នុងឧទាហរណ៍ខាងលើនេះ គេត្រូវរាប់ថ្ងៃទី ១១ មិថុនា រហូតដល់ម៉ោង ១២ យប់ ទើបផុតរយៈពេលគត់ ៥ ថ្ងៃ។

<u>របៀបរាប់ទី ២ : រយៈពេលមិនគត់</u>

គឺគេមិនរាប់ថ្ងៃទទួល (ឯកសារ) ដូចគ្នានឹងរបៀបរាប់ទី១ ដែរ។ ប៉ុន្តែ គេរាប់ថ្ងៃដែលត្រូវផុតគឺថ្ងៃទី១០ មិថុនា រហូតដល់ម៉ោង ១២ យប់។

ក្នុងករណីគ្មានការប្រញាប់ គេប្រើរបៀបរាប់ទី១។ រយៈពេលនេះ ច្រើនតែវែង ដូចជា ១ខែ ឬ ២ខែ។ ល។

ក្នុងករណី "ការប្រញាប់ " គេប្រើរបៀបទី២។ រយៈពេលនេះច្រើនតែខ្លី ដូចជា ៥ ថ្ងៃ ឬ រាប់ម៉ោង (៤៨ ម៉ោង ឬ ៧២ ម៉ោង។ ល។) គេច្រើនប្រើរបៀបរាប់នេះ សម្រាប់កិច្ចការដែលប្រញាប់ ដូចជាក្នុងករណីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាដើម។

ក្នុងករណីដែលច្បាប់បានចែងថា "ថ្ងៃគត់ "គេត្រូវអនុវត្តរបៀបរាប់ទី១ គឺរយៈពេលគត់។ របៀបរាប់ថ្ងៃទាំងពីរយ៉ាងនេះ ប្រទេសយើងធ្លាប់ប្រើកាលក្នុងសម័យមុនមានចម្បាំង (ឆ្នាំ១៩៧០) ហើយប្រទេសជាច្រើនក្នុងលោកក៏គេប្រើដែរ ដូចជាប្រទេសបារាំងជាដើម។

យោងតាមទម្លាប់នេះ មាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញដែលបានបញ្ជាក់ច្បាស់ថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកត្រឹមតែប្រាំថ្ងៃ " បានន័យថា ព្រឹទ្ធសភាត្រូវប្រើរបៀបរាប់ទី២ គឺថា របៀបរាប់រយៈពេលមិនគត់។

បើថ្ងៃចុងក្រោយដែលត្រូវចប់ធ្លាក់ចំថ្ងៃឈប់សម្រាក ដូចជាថ្ងៃសៅរ៍ អាទិត្យ ឬ ថ្ងៃបុណ្យ ដែលច្បាប់អនុញ្ញាតឱ្យឈប់ គេត្រូវរំកិលថ្ងៃនោះរហូតដល់ថ្ងៃចូលធ្វើការទី១ ពេញមួយថ្ងៃទៀត។

ប៉ុន្តែបើថ្ងៃឈប់សម្រាកស្ថិតនៅចន្លោះថ្ងៃទទួលឯកសារ (dies a quo)និង ថ្ងៃផុតកំណត់ (dies ad quem) រយៈពេល (៥ ថ្ងៃ) នោះ ឥតមានប្រែប្រួលឡើយ គឺថាគ្មានរកយកថ្ងៃធ្វើការណាមកជំនួសបានទេ។ នេះជាទម្លាប់ដែលគេតែងប្រតិបត្តិតាម ជាទូទៅសឹងតែគ្រប់ប្រទេស។

សម្រេច

មាត្រា ១ : មាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់រយៈពេលនោះត្រូវបន្តយមកនៅត្រឹមតែប្រាំថ្ងៃ " ត្រូវបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ចំពោះការប្រញាប់ និងរយៈពេល។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៣៨/០០៤/២០០០ កបធ.ច ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ២៥៨/១០០០/ពស/អគ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០០ របស់សម្តេចប្រធានព្រឹទ្ធសភា **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ដែលទទួលបាននៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០០

-បានឃើញឯកសារទទួលពីរដ្ឋសភា ទាក់ទងនឹងការពិភាក្សាលើមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ។

ក្រោយពីបានស្តាប់រចនាសម្ព័ន្ធរបស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា មាត្រា ៩៩ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងជាអាទិ៍ថា ព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ

-យល់ឃើញថា ការងារក្នុងក្របខ័ណ្ឌនីតិប្បញ្ញត្តិរបស់ព្រឹទ្ធសភា ត្រូវបានចែងក្នុង មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញរួចហើយ ដូច្នេះមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល " គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា

-យល់ឃើញថា ព្រឹទ្ធសភាមានភារកិច្ចជួយសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បីជួយរកដំនោះស្រាយវិបត្តិនយោបាយ នៅពេលណាដែលវិបត្តិនេះកើតឡើង។ ការងារនេះមានវិសាលភាពទូលំទូលាយ មិនអាចកម្រិតព្រំដែនតាមលិខិតបទដ្ឋានអ្វីបានទេ ហើយក៏មិនអាចចែងជាច្បាប់អ្វីបន្ថែមទៀតពីលើមាត្រា ១១២ ថ្មី ដែរ។

-យល់ឃើញថា មាត្រា ១១២ ថ្មី បានផ្តល់សិទ្ធិអំណាចជូនព្រឹទ្ធសភា អាចធ្វើអន្តរាគមន៍គ្រប់ពេលវេលាចូលទៅជួយដោះស្រាយវិបត្តិតូច ឬ ធំ ក្នុងកិច្ចការនយោបាយរវាងរដ្ឋសភា និង រាជរដ្ឋាភិបាលតាមធ្យោបាយផ្សេងៗ ដែលមានដោយពុំកម្រិតក្របខ័ណ្ឌនៃពេលវេលាឡើយ។ មាត្រា ១១២ ថ្មី បានផ្តល់កិត្តិយស និង ការទុកចិត្តជូនព្រឹទ្ធសភា ជាហេតុបញ្ជាក់ថា តួនាទីសម្របសម្រួលផ្ទៃកនយោបាយរបស់ព្រឹទ្ធសភា មានសារសំខាន់ណាស់ សម្រាប់អាយុជីវិតរបស់ប្រទេសជាតិ

-យល់ឃើញថា ព្រឹទ្ធសភា មានភាពចាស់ទុំខាងនយោបាយ ដូច្នេះតួនាទីសម្របសម្រួលខាងនយោបាយនៃព្រឹទ្ធសភា ពិតជាត្រូវបានយកចិត្តទុកដាក់ដោយរដ្ឋសភា និងរាជរដ្ឋាភិបាល

-យល់ឃើញថា តួនាទីនយោបាយរបស់ព្រឹទ្ធសភា ពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភា និងរាជរដ្ឋាភិបាល ធ្វើតាមព្រឹទ្ធសភាឡើយ។ ការសម្របសម្រួលរបស់ព្រឹទ្ធសភា អាចចាត់ទុកថា បានលទ្ធផលជាវិជ្ជមាន លុះត្រាតែរដ្ឋសភា និងរាជរដ្ឋាភិបាលព្រមព្រៀងស្រុះស្រួលគ្នា។

សម្រេច

មាត្រា ១ : ក្នុងន័យដូចបានបកស្រាយក្នុងមូលបទខាងលើ ភារកិច្ចរបស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលការងារ រវាងរដ្ឋសភា និង រាជរដ្ឋាភិបាល ដែលមានចែងចែងក្នុង មាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៤៤/០០៦/២០០១ កបធ.ច ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញបណ្តឹងរបស់ក្រុមតំណាងរាស្ត្រ ១៥ រូប " **ប្តឹងពីការរំលោភរដ្ឋធម្មនុញ្ញ នៃក្រុមអ្នកតំណាងរាស្ត្រ ០៦រូប ក្នុងគណៈកម្មការសាធារណការ ដឹកជញ្ជូន ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល និង ពាណិជ្ជកម្ម នៃរដ្ឋសភាលើមាត្រាទាំងឡាយក្នុងជំពូកទី៣ ស្តីពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ និង បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា** " ដោយស្នើឱ្យពិនិត្យ និង បកស្រាយ ដើម្បីទប់ស្កាត់កុំឱ្យមានការរំលោភក្នុងការដកហូតប្រធានគណៈកម្មការ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០០១។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រប់ត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ការដកប្រធានគណៈកម្មការនៃរដ្ឋសភាដែលក្នុងបណ្តឹងបានចង្អុលបង្ហាញត្រង់ជំពូកទី៣ នៃរដ្ឋធម្មនុញ្ញពុំមានបទប្បញ្ញត្តិណាដែលចែងពាក់ព័ន្ធដល់គណៈកម្មការនានារបស់រដ្ឋសភាទេ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញមិនអាចលើកបញ្ហានេះមកពិភាក្សាបានទេ

-យល់ឃើញថា ពាក្យបណ្តឹងដែលសុំឱ្យ " ពិនិត្យ និង ផ្តល់ការបកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា " បានកំណត់ក្របខ័ណ្ឌនៃការបកស្រាយ ដើម្បីកុំឱ្យមានការរំលោភលើប្រការណាមួយក្នុងការដកហូតប្រធានគណៈកម្មការចេញពីតំណែង

-យល់ឃើញថា ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាមានតែប្រការ១០ ប៉ុណ្ណោះទេដែលមានចែងពីការជ្រើសរើសប្រធានគណៈកម្មការ ។ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាពុំទាន់ទទួលបានការត្រួតពិនិត្យធម្មនុញ្ញភាពពីក្រុមប្រឹក្សាធម្មនុញ្ញរហូតមកដល់សព្វថ្ងៃនេះ ប៉ុន្តែដោយអនុលោមតាមមាត្រា ៥៤ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " រដ្ឋសភាបង្កើតគណៈកម្មការផ្សេង១ដែលចាំបាច់ ។ ការរៀបចំ និង ការប្រព្រឹត្តទៅនៃរដ្ឋសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ " ដូច្នេះប្រការ ១០ នេះក៏ពុំមានអ្វីប៉ះពាល់ដល់រដ្ឋធម្មនុញ្ញដែរ

-យល់ឃើញថា ការផ្លាស់ប្តូរសមាសភាពគណៈកម្មការរដ្ឋសភាជាកិច្ចការផ្ទៃក្នុងផ្ទាល់របស់រដ្ឋសភាដែលជាអំណាចនីតិប្បញ្ញត្តិ ឯករាជដាច់ដោយឡែកពីអំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ដូចមានចែងក្នុងមាត្រា ៥១ ថ្មី នៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា " ការចែកកូតា ភាគរយនៃអាសនៈអ្នកតំណាងរាស្ត្រក្នុងរដសភា ... " ក៏ជាកិច្ចការផ្ទៃក្នុងផ្ទាល់របស់អំណាចនីតិប្បញ្ញត្តិនេះដែរ

-យល់ឃើញថា កិច្ចការផ្ទៃក្នុងផ្ទាល់របស់រដ្ឋសភាក្នុងក្របខ័ណ្ឌគោលការណ៍នៃមាត្រា ៥១ ថ្មី នៃរដ្ឋធម្មនុញ្ញ ពុំអាចស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អំណាចណាមួយ ឬ ស្ថាប័នណាមួយក្រៅពីអង្គការរដ្ឋសភាខ្លួនឯង ដូចជាគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ អង្គប្រជុំពេញអង្គរបស់រដ្ឋសភាជាដើម និង មិនស្ថិតនៅក្នុងក្របខ័ណ្ឌមាត្រា ១៤០ ថ្មី ១៤១ ថ្មី និង មាត្រា ៥២ នៃរដ្ឋធម្មនុញ្ញ និង មិនស្ថិតនៅក្នុងក្របខ័ណ្ឌមាត្រា ១៦ មាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

ហេតុដូច្នេះ ក្នុងលក្ខខណ្ឌនេះ ក្រុមប្រឹក្សាធម្មនុញ្ញពុំមានសិទ្ធិត្រួតពិនិត្យការដោះដូរសមាសភាពគណៈកម្មការរដ្ឋសភាបានទេ ។

សម្រេច

មាត្រា ១ : យោងតាមមូលបទខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ការផ្លាស់ប្តូរប្រធានគណៈកម្មការ ឬ សមាសភាពគណៈកម្មការរដ្ឋសភាពុំស្ថិតនៅក្នុងសមត្ថកិច្ចត្រួតពិនិត្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០១ ទាសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៤៨/០០៣/២០០២ កបធ.ច ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតលេខ ១៣៤/០៨០២/ពស/ក្រ.ច ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០២ របស់ព្រះអង្គម្ចាស់ស្តេចក្រុមឃុន **ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស** ប្រធានព្រឹទ្ធសភាស្តីទី**ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ " មាត្រា ១០១ ថ្មី " និងពាក្យ " ការបោះឆ្នោតអសកល " ដែលមានប្រើក្នុងមាត្រា ៩៩ ថ្មី និង មាត្រា ១០០ ថ្មី នៃរដ្ឋធម្មនុញ្ញ** ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០២ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា តាមមាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ពាក្យបណ្តឹងរបស់ស្តេចក្រុមឃុន **ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស** ប្រធានព្រឹទ្ធសភា ស្តីទី ខាងលើអាចទទួលយកមកពិចារណាបាន

-យល់ឃើញថា ក្នុងមាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ ពាក្យដែលគួរពិចារណា និង អាចមានការភាន់ច្រឡំ គឺអ្នកបោះឆ្នោត អង្គបោះឆ្នោត មណ្ឌលបោះឆ្នោត។

-យល់ឃើញថា អ្នកបោះឆ្នោត គឺអ្នកដែលមានគ្រប់លក្ខណសម្បត្តិតាមច្បាប់កំណត់។

-យល់ឃើញថា អង្គបោះឆ្នោត គឺជាក្រុមមនុស្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់អាចទៅបោះឆ្នោតបានតាមការ កំណត់នៃច្បាប់ សម្រាប់រើសតំណាងឱ្យភូមិភាគ ឬ តំណាងវិជ្ជាជីវៈនានា។ ឧទាហរណ៍ ច្បាប់អាចកំណត់ថាជា ក្រុមជនជាតិ ជាក្រុមកសិករ ក្រុមអ្នកនៃសាទ ក្រុមពាណិជ្ជករ ក្រុមឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និង ក្រុមវិជ្ជាជីវៈដទៃទៀត។ ល។

-យល់ឃើញថា មណ្ឌលបោះឆ្នោត ជារង្វង់ដែនដីភូមិសាស្ត្រ ដែលច្បាប់កំណត់សម្រាប់អង្គបោះឆ្នោត។ ឧទាហរណ៍ ច្បាប់អាចនឹងកំណត់យកភូមិភាគ ឬ ខេត្តក្រុង។ ល។ ជាមណ្ឌលបោះឆ្នោត

-យល់ឃើញថា ការបោះឆ្នោតអសកល ជាការបោះឆ្នោតមិនទូទៅដូចការបោះឆ្នោតសកល។ ច្បាប់បន្ថែមលក្ខខណ្ឌ ផ្សេងទៀតដល់អ្នកបោះឆ្នោតលើសពីលក្ខខណ្ឌដែលតម្រូវដល់អ្នកបោះឆ្នោតសកល។ ឧទាហរណ៍ ដូចជាអ្នកមាន សិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតសកលហើយ ប៉ុន្តែត្រូវជាក្រុមកសិករ ក្រុមអ្នកនៃសាទ ក្រុមពាណិជ្ជករ ក្រុម ឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និង ក្រុមវិជ្ជាជីវៈដទៃទៀត។ ល។ ថែមទៀត។ ការបោះឆ្នោតអសកល អាចប្រព្រឹត្តទៅបានដោយចំពោះ ឬ មិនចំពោះ។

សម្រេច

មាត្រា ១ : មាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង ពាក្យ ការបោះឆ្នោតអសកល ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុង មូលបទខាងលើ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើ អំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៤៩/០០៤/២០០២ កបធ.ច ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតប្រធានព្រឹទ្ធសភាស្តីទីលេខ ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០២ **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខណ្ឌទី២ និង ទី៥ នៃរដ្ឋធម្មនុញ្ញ។**

ក្រោយពីបានស្តាប់រាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិគាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីបានសុំក្នុងលិខិតលេខ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០២ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី២ និង ទី៥ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្តីថា " បើព្រឹទ្ធសភា...ពុំបានឱ្យយោបល់សោះ " ហើយនិងកថាខណ្ឌទី៥ ដែលមានសេចក្តីថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬ ពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ "

-យល់ឃើញថា សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងការបកស្រាយរដ្ឋធម្មនុញ្ញមានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង ក្នុងមាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

តាមមាត្រា ១៤១ ថ្មី ក្នុងចំណោមឥស្សរជនដែលអាចលើកសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ គឺមានប្រធានព្រឹទ្ធសភាផងដែរ។

ដូច្នេះ យោងតាមមាត្រា ១៣៦ ថ្មី និង ១៤១ ថ្មី នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពិនិត្យសំណើសុំបកស្រាយមាត្រា ១១៣ ថ្មី កថាខណ្ឌទី២ និង ទី៥ របស់ប្រធានព្រឹទ្ធសភាស្តីទីខាងលើនេះបាន

-យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីសុំឱ្យបកស្រាយជាដំបូង កថាខណ្ឌទី២ នៃមាត្រា ១១៣ ថ្មី ត្រង់ពាក្យថា " បើព្រឹទ្ធសភា...ពុំបានឱ្យយោបល់សោះ " ។

តាមបទប្បញ្ញត្តិដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា ១១៣ ថ្មី ព្រឹទ្ធសភាត្រូវពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្នុងករណីធម្មតា ប៉ុន្តែបើជាការប្រញាប់ គឺត្រឹមតែ ០៥ ថ្ងៃ ប៉ុណ្ណោះ។ ដូច្នេះក្នុង ករណីធម្មតា ជុតរយៈពេលមួយខែ គិតពីថ្ងៃដែល "រដ្ឋសភាដាក់ឱ្យពិនិត្យ" បើព្រឹទ្ធសភានៅស្ងៀមស្ងាត់ឥតធ្វើអ្វី ឬ ឥតឆ្លើយអ្វីសោះទៅរដ្ឋសភាវិញនោះគឺបានន័យថា "ព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ"។ ប៉ុន្តែពាក្យថា "ព្រឹទ្ធសភា" គឺមានន័យថា ត្រូវមានការប្រជុំពេញអង្គរបស់ព្រឹទ្ធសភា ដើម្បីសម្រេចថា " មិនឱ្យយោបល់ "។

បញ្ហាដែលស្មុគស្មាញ គឺនៅត្រង់រដ្ឋសភាសុំឱ្យព្រឹទ្ធសភាពិនិត្យជា "ការប្រញាប់"។ ក្នុងករណីនេះបើបើព្រឹទ្ធសភានៅស្ងៀមមិនឆ្លើយតបទៅវិញហួសពី ៥ ថ្ងៃ តើរដ្ឋសភាអាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបានឬទេ ?

យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០០០ និង ដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាដែរ

ព្រឹទ្ធសភាមានអំណាចសម្រេចខ្លួនឯងថា "យល់ព្រម ឬ មិនយល់ព្រមទុកជាការប្រញាប់"។ ប៉ុន្តែបើព្រឹទ្ធសភាមិនបានសម្រេចអ្វីសោះ ហើយនៅស្ងាត់ស្ងៀម លើសពី ៥ ថ្ងៃ នោះ ត្រូវចាត់ទុកថាព្រឹទ្ធសភាទទួលយល់ព្រមថា ជាការប្រញាប់ ហើយរដ្ឋសភាអាចយកច្បាប់នោះទៅប្រកាសឱ្យប្រើក្នុងរយៈពេល ៥ ថ្ងៃបាន។ បើព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គបានសម្រេចថា " ជាការប្រញាប់ " តាមសំណើសុំរបស់រដ្ឋសភា ហើយក៏បានធ្វើការពិភាក្សាទៅស្រាប់តែមាន ការរាំងស្ទះដោយថាហេតុបណ្តាលឱ្យហួសរយៈពេល ៥ ថ្ងៃ ទៅនោះ រដ្ឋសភាក្នុងករណីនេះ អាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបាន ដោយមិនចាំបាច់រង់ចាំការអនុម័តរបស់ព្រឹទ្ធសភាឡើយ

-យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីបានសុំជាបន្ទាប់មកទៀតឱ្យបកស្រាយ កថាខណ្ឌទី៥ នៃមាត្រា ១១៣ ថ្មី ដែលមានសេចក្តីថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬ ពន្យារពេល ដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ "។

កថាខណ្ឌទី៥ នេះទាក់ទងនឹងរយៈពេលនៃ " ការបង្វិលទៅបង្វិលមកវាងព្រឹទ្ធសភា និងរដ្ឋសភា " ដែលមានចែងក្នុង កថាខណ្ឌទី៤ នៃមាត្រា ១១៣ ថ្មី។

ក្នុងករណីដែលព្រឹទ្ធសភាមិនឯកភាពតាមការអនុម័តដំបូងរបស់រដ្ឋសភា ព្រឹទ្ធសភាបង្វិលទៅរដ្ឋសភាជាលើកទី១ ស្នើសុំកែប្រែ។ រដ្ឋសភាបានទទួលហើយ ប៉ុន្តែមិនឯកភាពទាំងស្រុង ឬ ដោយអធ្ងឹ និង សំណើសុំកែប្រែរបស់ព្រឹទ្ធសភា ក៏បង្វិលមកព្រឹទ្ធសភាវិញសុំឱ្យពិចារណាជាថ្មី។ ព្រឹទ្ធសភាពិចារណាជាថ្មីហើយក៏បង្វិលទៅរដ្ឋសភាវិញ ដោយបញ្ជាក់យោបល់របស់ខ្លួនម្តងទៀត។ បើរដ្ឋសភាមិនទាន់ឯកភាពតាមព្រឹទ្ធសភា ការបង្វិលទៅបង្វិលមកអាចបន្តទៅទៀតបាន ជាធម្មតាក្នុងរយៈពេលមួយខែសម្រាប់ពិនិត្យច្បាប់ផ្សេងៗក្រៅពីច្បាប់ថវិកាជាតិ និង ហិរញ្ញវត្ថុដែលត្រូវកម្រិតត្រឹម ១០ថ្ងៃ។ បើជាការប្រញាប់រយៈពេលនេះមកនៅត្រឹម ២ថ្ងៃ តែប៉ុណ្ណោះ។ រយៈពេលនៃការបង្វិលនេះត្រូវគិតពីថ្ងៃបង្វិលលើកទី១ របស់ព្រឹទ្ធសភា។

ពាក្យថា "បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់" បានន័យថា ក្រោយបានទទួលការសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះពីព្រឹទ្ធសភាទៅ រដ្ឋសភាមិនបានធ្វើអ្វីសោះរហូតដុត ១ ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ ទៅតាមករណីនីមួយៗដូចបានរៀបរាប់ខាងលើ។

ពាក្យថា "ពន្យារពេលដែលកំណត់ទុក" បានន័យថា រដ្ឋសភាបានធ្វើការប្រជុំពេញអង្គ សម្រេចពន្យារពេលពិនិត្យឱ្យលើសពី ១ ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ ទៅតាមករណីនីមួយៗនោះ។

ពាក្យថា "រយៈពេលជាគោលការណ៍ សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភា" នោះគឺ រយៈពេល ១ ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ នេះហើយ។

ពេលវេលាដែលលើសពីរដ្ឋធម្មនុញ្ញកំណត់ ដោយសារការទុក ឬ ការសម្រេចពន្យាររបស់រដ្ឋសភានេះត្រូវបន្ថែមឱ្យព្រឹទ្ធសភា ឱ្យបានស្មើគ្នានឹងរដ្ឋសភាដែរ។ ក្នុងការអនុវត្តជាក់ស្តែង ដើម្បីឱ្យបានស្មើគ្នាកើត គេត្រូវរាប់ចំនួនថ្ងៃដែលរដ្ឋសភាបានប្រើប្រាស់ក្នុងរយៈពេលទាំងនោះដើម្បីឱ្យដឹងច្បាស់ សម្រាប់គិតចំនួនថ្ងៃដែលព្រឹទ្ធសភាត្រូវមានស្មើគ្នាដែរ។

ដូច្នេះ "ក្នុងរយៈពេលជាគោលការណ៍ ១ ខែ" រដ្ឋសភាមានសិទ្ធិប្រើប្រាស់ ១៥ថ្ងៃ ចំណែកឯព្រឹទ្ធសភាក៏ ១៥ ថ្ងៃ ដូចគ្នាដែរ។ បើរដ្ឋសភាប្រើពេលលើសថែម ឧបមាថា ៣ថ្ងៃ ខាងព្រឹទ្ធសភាក៏មានសិទ្ធិបន្ថែម ៣ ថ្ងៃ ទៀតដូច១គ្នា។

របៀបគិតនេះត្រូវអនុវត្តដូចគ្នាចំពោះ " រយៈពេលជាគោលការណ៍ ១០ ថ្ងៃ " និង " រយៈពេលជាគោលការណ៍ ២ ថ្ងៃ " ទៅតាមករណីជាយថាហេតុ។

ជារួមគេត្រូវចែក " រយៈពេលជាគោលការណ៍ " ទីមួយៗជាពីរស្មើគ្នា គឺថាបើ " ១០ ថ្ងៃ " គឺ ៥ ថ្ងៃ សម្រាប់រដ្ឋសភា ហើយនិង ៥ ថ្ងៃទៀត សម្រាប់ព្រឹទ្ធសភា។ បើ " ២ ថ្ងៃ " គឺ ១ ថ្ងៃ សម្រាប់រដ្ឋសភា និង ១ ថ្ងៃ ទៀតសម្រាប់ព្រឹទ្ធសភា។ ហើយបើរដ្ឋសភាបន្ថែមលើសប៉ុន្មានថ្ងៃ ព្រឹទ្ធសភាក៏មានសិទ្ធិបន្ថែមចំនួនថ្ងៃលើសឱ្យស្មើគ្នានឹងរដ្ឋសភាដូចគ្នា។

គួរកត់សម្គាល់ម្យ៉ាងទៀតថា " រយៈពេលជាគោលការណ៍ " ទាំងអស់នេះ សុទ្ធតែជា " រយៈពេលមិនគត់ " ដែលគេត្រូវអនុវត្តតាមវិធានដែលមានចែងក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២ /២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០០។

សម្រេច

មាត្រា ១ : មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី២ ត្រង់ពាក្យថា "បើព្រឹទ្ធសភា...ពុំបានឱ្យយោបល់សោះ" និងកថាខណ្ឌទី៥ ត្រូវបកស្រាយដូចមានចែងក្នុងមូលបទខាងលើ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

សេចក្តីសម្រេច លេខ : ០៥៤/០០៥/២០០៣ កបធ.ច ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិតរបស់តំណាងរាស្ត្រចំនួន ១៨រូប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយបំភ្លឺលើខ្លឹមសារវាក្យខណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ** ថាតើចំពោះមុខស្ថានភាពខាងលើនេះ ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ? ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាផ្តឹមផ្តួចតាមច្បាប់ហើយ

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៨ នាក់ គឺលើសពីមួយភាគដប់ (១៣រូប) នៃចំនួនតំណាងរាស្ត្រនៅរដ្ឋសភា បានផ្ញើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ នៅវេលាម៉ោង ១០ ព្រឹក ។ ចំនួន ១៨ នាក់នេះ ត្រប់គ្រាន់តាមបទប្បញ្ញត្តិនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ផងដែរ

-យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយប៉ះពាល់នូវខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញក្នុងបរិបទនៃសំណួរមួយដែលសួរថា ចំពោះមុខស្ថានភាពនេះ តើការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?

-យល់ឃើញថា ចំពោះសំណួរនេះ បញ្ហានឹងកើតមានឡើងតែក្នុងករណីដែលគ្មានការជ្រើសតាំងអ្នកតំណាងរាស្ត្រថ្មីជំនួសអ្នកតំណាងរាស្ត្រដែលទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាកសមាជិកភាពរដ្ឋសភា ហើយដែលចំនួនតំណាងរាស្ត្ររដ្ឋសភាទាំងអស់ត្រូវចុះថយនៅសល់តិចជាង ១២០រូប ប៉ុណ្ណោះ ។

ក្នុងបរិបទនេះ ក្រុមប្រឹក្សាធម្មនុញ្ញ សូមធ្វើការបកស្រាយដូចតទៅ ÷

១.ខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ

វាក្យខ័ណ្ឌទី ១ នៃមាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ ចែងថា : រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប ។ ត្រង់នេះ មានន័យថា យ៉ាងតិចណាស់ត្រូវមានសមាជិកជាតំណាងរាស្ត្រចំនួន ១២០រូប ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន ។ ច្បាប់បោះឆ្នោតមិនអាចកំណត់ចំនួនតំណាងរាស្ត្រតិចជាង ១២០រូប បានទេ ។ វាក្យខ័ណ្ឌទី១ នេះជាលក្ខខណ្ឌចាំបាច់សម្រាប់ការបង្កើតរដ្ឋសភា ប៉ុន្តែមិនមែនសម្រាប់ដំណើរការរបស់រដ្ឋសភាទេ ។

នៅពេលបោះឆ្នោតចប់ហើយ លទ្ធផលត្រូវឱ្យបានតំណាងរាស្ត្រចាប់ពី ១២០រូប ឡើងទៅ ទៅតាមការកំណត់នៃច្បាប់បោះឆ្នោត ទើបអាចបង្កើតរដ្ឋសភានីតិកាលថ្មីមួយបាន ដោយគោរពទៅតាមនីតិវិធីដែលមានចែងក្នុងមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ គឺថា រដ្ឋសភាដែលកើតចេញពីការបោះឆ្នោត ត្រូវចូលកាន់តំណែងជាផ្លូវការនៅពេលសម័យប្រជុំដំបូង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ហើយនឹងមានការប្រកាសសម្រេចសុពលភាពឈ្មោះអ្នកតំណាងរាស្ត្របិទផ្សាយក្នុងមន្ទីររដ្ឋសភា និង ជាសាធារណៈ។ ចាប់ពីពេលនេះមក រដ្ឋសភានឹងមានសុពលភាពរហូតដល់ចប់អាណត្តិរបស់ខ្លួនក្នុងករណីធម្មតា លើកលែងតែក្នុង

ករណីពិសេសនៃការរំលាយរដ្ឋសភាដោយមកពីមានការទម្លាក់រាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល ១២ ខែ ដូចមានចែងក្នុងមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។ ហេតុដូច្នេះហើយ ទើបមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញចែងថា " រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ ... " ។

ការវិភាគខាងលើនេះ បង្ហាញឱ្យឃើញថាការប្រែប្រួលនៃចំនួនតំណាងរាស្ត្រ ក្នុងរយៈវេលានៃការប្រព្រឹត្តទៅនៃនីតិកាល មិនអាចធ្វើឱ្យប៉ះពាល់ដល់សុពលភាពរដ្ឋសភាទាំងមូលបានឡើយ ។ ដូច្នេះ ទោះបីចំនួនតំណាងរាស្ត្រប្រែប្រួលចុះថយក្រោម ១២០រូប យ៉ាងណាក៏ដោយ កុំឱ្យតែទាបជាងក្បាលម្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ក៏រដ្ឋសភានៅតែអាចដំនើរការបានដូចធម្មតា ហើយជាពិសេសការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញក៏អាចនឹងប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

២.មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ

មាត្រា ៩៥ នេះ ចែងថា : ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬ ព្រាសចាកសមាជិកភាព ដែលកើតមានឡើង ៦ខែយ៉ាងតិចមុនចប់នីតិកាលត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ក្នុងច្បាប់បោះឆ្នោត ។

ក្នុងបរិបទនៃសំណូររបស់អ្នកតំណាងរាស្ត្រទាំង ១៨ នាក់នោះ ការបកស្រាយមាត្រា ៩៥ នេះសំដៅតែទៅលើបញ្ហានៃការចាត់ការជ្រើសតាំងសមាជិកជំនួស និង រយៈពេល ៦ខែ មុនចប់នីតិកាល។ ដូច្នេះ ចំណុចផ្សេងៗទៀតនៃមាត្រា ៩៥ នឹងមិនត្រូវលើកយកមកពិនិត្យក្នុងទីនេះទេ ។

មានពីរករណីដែលត្រូវវែកញែក គឺ ÷

<u>ករណីទី១</u> : បើនីតិកាលនៅយូរជាង ៦ខែ ឬ ស្មើនឹង ៦ខែ ត្រូវមានការជ្រើសតាំងសមាជិកជំនួសតាមនីតិវិធីដែលមានចែងក្នុងច្បាប់បោះឆ្នោត ឧទាហរណ៍ដូចសព្វថ្ងៃនេះគឺមាត្រា ១២០ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ តាមមាត្រា ១២០ នេះសាមីគណបក្សនយោបាយអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស ដោយជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលរបស់សាមីខ្លួននោះមកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ។ សាមីគណបក្សនយោបាយ ជាចាំបាច់ត្រូវតែស្នើជ្រើសតាំងសមាជិកថ្មីជំនួស ទើបស្របនឹងមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ ដែលបានចែងច្បាស់ថា " ត្រូវចាត់ការជ្រើសតាំងជំនួស... " ។

<u>ករណីទី២</u> :បើនីតិកាលនៅសល់តិចជាង ៦ខែ ថ្វីបើមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមិនបានបញ្ជាក់ក៏ដោយ ប៉ុន្តែតាមខ្ញុំមសារគឺមិនត្រូវមានការជ្រើសតាំងសមាជិកថ្មីជំនួសទេ

-យល់ឃើញថា ទោះក្នុងករណីណាក៏ដោយ លើកលែងតែចំនួនតំណាងរាស្ត្រនៅសល់តិចជាងក្បាលម្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានជានិច្ចរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយឥតខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

សម្រេច

មាត្រា ១ : វាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ និង សុពលភាពនៃការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភាត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ០៦១/០០៣/២០០៤ កបធ.ច ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

-បានឃើញលិខិត ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន ១៦ រូប **សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ**

-បានឃើញឯកសារទទួលពីរដ្ឋសភាទាក់ទងនឹងការពិភាក្សារបស់សភាធម្មនុញ្ញ លើមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ។

ក្រោយពីបានស្តាប់របាយការណ៍សង្ខេប

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា តំណាងរាស្ត្រ ១៦ រូប គឺលើសពីមួយភាគដប់នៃចំនួនតំណាងរាស្ត្រនៅរដ្ឋសភា បានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៤ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១១ ខែសីហា ឆ្នាំ ២០០៤ វេលាម៉ោង ១៤ :២៣ នាទី។ ចំនួន ១៦ រូបនេះ គឺគ្រប់គ្រាន់តាមបទប្បញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ផងដែរ

-យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដោយដាក់ជាបញ្ហា ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ "***ក្រោយពីមានព្រះរាជសាររបស់ព្រះមហាក្សត្រ ស្តីពីព្រះរាជហេតុម៉ត់ដាក់រាជសម្បត្តិជាញឹកញាប់នោះមក មានការបកស្រាយខុសៗគ្នា រវាងនាយករដ្ឋមន្ត្រី និង ក្រុមអ្នកច្បាប់មួយចំនួនស្តីពីការដាក់រាជសម្បត្តិនេះ ។***" ពាក់ព័ន្ធសំខាន់លើវាក្យខ័ណ្ឌទី ២ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា "***ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋជាមួយជីវិត***" ។ ត្រង់នេះ មានន័យថា ព្រះមហាក្សត្រទ្រង់ត្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋជាមួយជីវិត។ ព្រះរាជតួនាទីក្នុងការត្រងរាជសម្បត្តិជាប់ជាមួយព្រះរាជតួនាទីជាព្រះប្រមុខរដ្ឋ ដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ ។ ដូច្នេះ ព្រះមហាក្សត្រទ្រង់ត្រងរាជសម្បត្តិ និង ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត គឺរជ្ជកាលរបស់ព្រះមហាក្សត្រត្រូវបានកំណត់ចាប់ពីពេលដែលព្រះអង្គឡើងត្រងរាជសម្បត្តិ រហូតដល់ពេលព្រះអង្គចូលទិវង្គត

-យល់ឃើញថា សភាធម្មនុញ្ញបានអនុម័តមាត្រា ១២ មាត្រា ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឱ្យមានការជ្រើសតាំងព្រះមហាក្សត្រថ្មី ក្នុងករណីព្រះមហាក្សត្រសោយទិវង្គតតែប៉ុណ្ណោះ

-យល់ឃើញថា ការដាក់រាជសម្បត្តិ មិនមានចែងក្នុងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១ : មាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១០៧/០០៣/២០០៤ កបធ.ច ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា **ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ** ដោយយោងតាមសំណើលេខ ០៦៥/០៤ ស.ន.ក.ជ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៤ របស់គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៤ វេលាម៉ោង ១៤ និង ៣០នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថា លិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន

-យល់ឃើញថា មាត្រា ៤ នៃរដ្ឋធម្មនុញ្ញចែងថា " ***ចាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ*** " ។ ចាវចនានៃព្រះរាជាណាចក្រកម្ពុជា ជារូបមន្តសង្ខេបមួយតែប៉ុណ្ណោះ បញ្ជាក់អំពីទិសដៅកំណត់សកម្មភាពទាំងឡាយរបស់បុគ្គល រួមមានរូបវន្តបុគ្គល និង នីតិបុគ្គលដែលរស់នៅ និង មានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បុគ្គលទាំងនោះត្រូវយកចិត្តទុកដាក់ចំពោះ ជាតិ សាសនា និង ព្រះមហាក្សត្រ ។ ចំពោះការប្រតិបត្តិខាងផ្នែកវិសាសនា មានកំណត់ក្នុងបទប្បញ្ញត្តិនៃមាត្រាផ្សេងៗទៀតនៃរដ្ឋធម្មនុញ្ញ

-យល់ឃើញថា មាត្រា ៤៣ ចែងអំពីសិទ្ធិខាងជំនឿរបស់ប្រជាពលរដ្ឋខ្មែរ ។

•វាក្យខ័ណ្ឌទី១ ចែងថា " ***ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ*** " ។ វាក្យខ័ណ្ឌនេះមានន័យថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសេរីភាពបរិបូរណ៍ក្នុងការជឿ ឬ ការប្រតិបត្តិជំនឿ និង សាសនា តាមសតិសម្បជញ្ញៈរបស់ខ្លួន គ្រប់ពេលវេលា និង គ្រប់កាលៈទេសៈ ។

•វាក្យខ័ណ្ឌទី២ ចែងថា " ***សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានធានាក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ*** " ។ វាក្យខ័ណ្ឌទី២ នេះ មានន័យថា រដ្ឋត្រូវធានាឱ្យសេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនាដំណើរការបានជាធម្មតា **ប៉ុន្តែសេរីភាព និង ការប្រព្រឹត្តនេះ ក៏មានព្រំដែនកំណត់ដែរ** ។ ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃ ព្រមទាំងត្រូវគោរពសិទ្ធិ សេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ ឬ សាសនារបស់អ្នកដទៃទៀតផង។ ម្យ៉ាងវិញទៀត ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្លូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈជាដាច់ខាត ។

•វាក្យខ័ណ្ឌទី៣ ចែងថា " ***ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ*** " ។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយវាក្យខ័ណ្ឌទី៣ នៃមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងដូច្នេះហើយទើបបទប្បញ្ញត្តិនៃមាត្រាដទៃផ្សេងទៀតនៃរដ្ឋធម្មនុញ្ញ និង អត្ថបទច្បាប់ ព្រមទាំងអត្ថបទក្រោមច្បាប់ កំណត់ស្របតាមស្មារតីខាងលើនេះ

-យល់ឃើញថា ដោយសារ ***ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ*** ទើប ÷

• នៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋបានផ្តល់ការជួយឧបត្ថម្ភ គាំទ្រ និង លើកតម្កើងវិស័យព្រះពុទ្ធសាសនាឱ្យបានរីកចម្រើន ថ្កុំថ្កើង រុងរឿង ស័ក្តិសមជាសាសនារបស់រដ្ឋ ។ ហេតុនេះ ទើបនៅក្នុងព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រកម្ពុជាគ្រងរាជសម្បត្តិ ក៏មានវត្តមានរបស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ តាមព្រះរាជប្បវេណីដែរ។ មិនតែប៉ុណ្ណោះ ថ្ងៃបុណ្យធំៗក្នុងព្រះពុទ្ធសាសនា ជាអាទិ៍ថ្ងៃបុណ្យមាឃបូជា វិសាខបូជា ត្រូវបានចាត់ទុកជាថ្ងៃបុណ្យជាតិ

• សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ត្រូវបានឱ្យតង់ជាសមាជិកនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចមានចែងក្នុងមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ម្យ៉ាងទៀត សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះអង្គត្រូវបានតង់ជាអធិបតីក្នុងពិធីធ្វើសច្ចាប្រណិធានធំៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទាំងឡាយនៃរដ្ឋធម្មនុញ្ញ ហើយនៅក្នុងភ្លេងជាតិនគរវាជទៀតសោត វគ្គទី៣ ចែងថា " ***ត្រាប់វត្តអារាមឮតែសូរសំឡេងធម៌ សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា ធ្វើយើងជាអ្នក ណើជាក់ស្មោះស្ម័គ្រ តាមបែបដូនតា គង់តែទេវតា នឹងជួយជ្រោមជ្រែងថ្កុំថ្កើង ប្រយោជន៍ឱ្យ ដល់ប្រទេសខ្មែរ ជាមហានគរ*** ។ "

•វាក្យខ័ណ្ឌទី៣ មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា " ***រដ្ឋជួយផ្សព្វផ្សាយ និងលើកតម្កើងសាលាបាលី និង ពុទ្ធិកសិក្សា*** "

•ហើយប្រជាពលរដ្ឋខ្មែរភាគច្រើនលើសលប់នៅព្រះរាជាណាចក្រកម្ពុជា បានលើក ***ទង់ជាតិ ទង់ព្រះពុទ្ធសាសនា*** និង ***ទង់ព្រះមហាក្សត្រ*** នៅទន្ទឹមគ្នា ព្រមទាំងមានសតិសម្បជញ្ញៈជឿជាក់ថា អាណាចក្រ និង ពុទ្ធចក្រ ត្រូវដើរទន្ទឹមគ្នា ទើបជាតិបានថ្កុំថ្កើង រុងរឿង ។

សម្រេច

មាត្រា ១ : មាត្រា ៨ និង មាត្រា ៨៣ នៃរដ្ឋធម្មនុញ្ញ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

សេចក្តីសម្រេច លេខ : ១១២/០០៥/២០១០ កបធ.ច ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

.....

- បានឃើញលិខិត ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១០ របស់ឯកឧត្តម និង លោកជំទាវ តំណាងរាស្ត្រ ចំនួន ២២រូប ដែលមានឯកឧត្តម **ស៊ុក ប៊ុនហុក** ជាតំណាង **ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយអំពីសុពលភាពនៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ** ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតនេះ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០ វេលាម៉ោង ១៦ និង ១៥នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា លិខិតរបស់ឯកឧត្តម និង លោកជំទាវតំណាងរាស្ត្រចំនួន ២២រូប ដែលបានស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយអំពីសុពលភាពនៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ បានធ្វើឡើងស្របតាមមាត្រា ១៣៦ថ្មី មាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ថ្មី មាត្រា ១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើនេះមកពិនិត្យបាន

- យល់ឃើញថា សមាជរដ្ឋសភា និង ព្រឹទ្ធសភា មានចែងក្នុងមាត្រា ១១៦ថ្មី និង មាត្រា ១១៧ថ្មី ជំពូកទី៩ថ្មី នៃរដ្ឋធម្មនុញ្ញ ដូចតទៅ ÷

មាត្រា ១១៦_ថ្មី ***ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។***

មាត្រា ១១៧_ថ្មី *បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ត្រូវដាក់ជូនពិភាក្សាក្នុងព្រឹទ្ធសភា ដើម្បីសម្រេចតាមសំណើរបស់ព្រះមហាក្សត្រ ឬ តាមសំណើរបស់ប្រធានព្រឹទ្ធសភា ឬ តាមសំណើរបស់ប្រធានរដ្ឋសភា ឬ តាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ឬ តាមសំណើរបស់ប្រធានគណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឬ តាមសំណើរបស់ប្រធានគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភា ឬ តាមសំណើរបស់ប្រធានគណៈកម្មការអចិន្ត្រៃយ៍ក្រុមប្រឹក្សាធម្មនុញ្ញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

យើងខ្ញុំ ក្រុមអ្នកតំណាងរាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា

គោរពជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : សំណើពិនិត្យបកស្រាយនូវមាត្រាមួយចំនួននៃច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មលើមាត្រា និង ជំពូកមួយចំនួនដែលត្រូវរដ្ឋសភាអនុម័ត កាលពីថ្ងៃទី ៤ ខែ មីនា ឆ្នាំ១៩៩៩ ។

យោង : - មាត្រា ១៨.១ ថ្មី នៃច្បាប់ធម្មនុញ្ញ (មាត្រា ១១៧ នៃរដ្ឋធម្មនុញ្ញ) ។

- ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ១៩៩៩ ។

តបកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំសូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យបកស្រាយនូវមាត្រា :

- មាត្រា ១៨០ ថ្មី នៃច្បាប់ធម្មនុញ្ញ (មាត្រា ១២១ នៃរដ្ឋធម្មនុញ្ញ) បានចែងជាអាទិ៍ថា " ... បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុនធ្វើប្រកាសឲ្យប្រើ ... " ។

- មាត្រា ១៥៨ ថ្មី នៃច្បាប់ធម្មនុញ្ញ (មាត្រា ១៣៥ នៃរដ្ឋធម្មនុញ្ញ) បានចែងថា " រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័តត្រូវបានប្រកាសឲ្យចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ "

- មាត្រា ១៥៦ ថ្មី នៃច្បាប់ធម្មនុញ្ញ (មាត្រា ១៣៧ នៃរដ្ឋធម្មនុញ្ញ) បានចែងថា " ក្រោយរដ្ឋធម្មនុញ្ញនេះ ចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលំដាប់ខ័ណ្ឌដែលមានចែងក្នុងមាត្រា១៣ ថ្មី និង ១៤ ។ " ។

យើងខ្ញុំសូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយនូវចម្ងល់ដូចមានខាងក្រោមនេះ :

- ហេតុដូចម្តេចបានជាច្បាប់ធម្មនុញ្ញ ឥតបានបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឲ្យប្រើ ?

- ហេតុដូចម្តេចបានជាចាំបាច់មានអន្តរប្បញ្ញត្តិ ក្នុងការប្រកាសឲ្យចូលជាធរមានភ្លាមនូវរដ្ឋធម្មនុញ្ញ ដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ? ពីព្រោះរដ្ឋធម្មនុញ្ញនេះបានប្រកាសចូលជាធរមានភ្លាម ដោយព្រះប្រមុខរដ្ឋនៅឆ្នាំ១៩៩៣ រួចរាល់អស់ហើយ ។

- ហេតុដូចម្តេចបានជាចាំបាច់មានអន្តរប្បញ្ញត្តិ ក្នុងការជ្រើសតាំងព្រះមហាក្សត្រ តាមលំដាប់ខ័ណ្ឌថ្មី ដែលមានប្រធាន និង អនុប្រធានព្រឹទ្ធសភាផងនោះម្តងទៀត ? ពីព្រោះព្រះមហាក្សត្របានជ្រើសតាំងតាមផ្លូវច្បាប់រួចរាល់អស់ហើយ ។

ជាឧទាហរណ៍ ការមិនបញ្ជូនច្បាប់រៀបចំព្រឹទ្ធសភាទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឲ្យប្រើ ហើយនិងការបង្កើតមាត្រានៃអន្តរប្បញ្ញត្តិទាំងពីរនេះ បែរជាធ្វើឲ្យច្បាប់ធម្មនុញ្ញនេះមិន

ស្របច្បាប់និងមិនរលួនទៅវិញ ។

ហេតុដូចនេះ ការពិនិត្យបកស្រាយនូវមាត្រាខាងលើ មានសារៈសំខាន់ណាស់ ដើម្បីធ្វើឲ្យ ព្រះរាជាណាចក្រកម្ពុជានៃយើងទៅជានីតិរដ្ឋមួយក្នុងបណ្តាប្រទេសទាំងឡាយ ដែលគាន់លទ្ធិប្រជា-ធិបតេយ្យសេរីពហុបក្ស ។

នៅទីបញ្ចប់នេះ សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យបកស្រាយតាមសំណើរបស់យើងខ្ញុំជាអ្នក តំណាងរាស្ត្រ ដូចមានរាយនាម និង ហត្ថលេខាខាងក្រោម ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រ អំពីយើងខ្ញុំ ។

រាជធានីនៅភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ១៩៩៩

ហត្ថលេខា

អ្នកតំណាងរាស្ត្រ ១៥រូប

ចម្លងជូនចាយ និង ជូន

- ព្រះមហាក្សត្រ
- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អង្គទូត និង លោកតំណាងអគ្គលេខាធិការ អ.ស.ប
- អង្គការសិទ្ធិមនុស្សជាតិ និង អន្តរជាតិ
- អ្នកសារព័ត៌មានជាតិ និង អន្តរជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៣/៩៩

ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៩៩

សេចក្តីសម្រេច

លេខ : ០២ កបធ.សសរ.ច

ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៩

ក្រមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រម នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើ និងចូលជាធរមានភ្ជាមនូវច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៥០ ៥១ ៥៣ និង មាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូក ទី១៤ នៃរដ្ឋធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើរបស់ក្រុមអ្នកតំណាងរាស្ត្រ ១៥ នាក់ ឱ្យពិនិត្យបកស្រាយមាត្រាមួយចំនួននៃច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មលើមាត្រា និង ជំពូកមួយចំនួន ដែលត្រូវរដ្ឋសភាអនុម័តកាលពីថ្ងៃទី ០៤ ខែ មីនា ឆ្នាំ១៩៩៩ ដោយលើកបញ្ជាក់មាត្រា ១៤០ ថ្មី ១៥៤ ថ្មី និង ១៥៦ ថ្មី នៃច្បាប់ធម្មនុញ្ញ និង បង្ហាញនូវចម្ងល់ថា ហេតុដូចម្តេចបានជាច្បាប់ធម្មនុញ្ញឥតបានបញ្ជូនទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ហេតុដូចម្តេចបានជាចាំបាច់មានអន្តរប្បញ្ញត្តិ ក្នុងការប្រកាសឱ្យចូលជាធរមានភ្ជាមនូវរដ្ឋធម្មនុញ្ញ និង ក្នុងការជ្រើសតាំងព្រះមហាក្សត្រតាមល័ក្ខខ័ណ្ឌដែលមានប្រធាន និង អនុប្រធានព្រឹទ្ធសភាផងនោះម្តងទៀត ហើយព្រមទាំងបាន លើកជាឧទាហរណ៍ថា ៖ ការមិនបញ្ជូនច្បាប់រៀបចំព្រឹទ្ធសភាទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ហើយនិងការបង្កើតមាត្រានៃអន្តរប្បញ្ញត្តិទាំងពីរ នេះ បែរជាធ្វើឱ្យច្បាប់ធម្មនុញ្ញនេះមិនស្របច្បាប់ និងមិនរលូនទៅវិញ ។ ដែលទទួលបាននៅអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៩៩
- បានឃើញឯកសារនានាពីរដ្ឋសភា ដែលទាក់ទងនឹងមាត្រា ១៤០ថ្មី ១៥៤ថ្មី និង ១៥៦ថ្មី នៃច្បាប់ធម្មនុញ្ញ

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា ១៤០ ថ្មី ឃ្លាទី១ នៃកថាខ័ណ្ឌទី២ បានចែងច្បាស់ថា " បទបញ្ជាផ្ទៃក្នុងរដ្ឋសភាបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុន នឹងប្រកាសឱ្យប្រើ " គឺមានន័យថា ច្បាប់តម្រូវឱ្យបញ្ជូនជាចាំបាច់មកឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យនូវបទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយដែលបានអនុម័តហើយ មុននឹងប្រកាសឱ្យប្រើ ។ ច្បាប់ធម្មនុញ្ញមិនមែនជាច្បាប់រៀបចំអង្គការទេ ហើយច្បាប់មិនតម្រូវឱ្យបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងប្រកាសឱ្យប្រើឡើយ ។
- យល់ឃើញថា មាត្រា ១៥៤ ថ្មី បានចែងច្បាស់ក្នុងអន្តរប្បញ្ញត្តិថា : " រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័តត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាមដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា " គឺមានន័យថា ច្បាប់ធម្មនុញ្ញជាផ្នែកជាប់ក្នុងអត្ថបទនៃរដ្ឋធម្មនុញ្ញ ។ ដូច្នេះមាត្រានេះសម្រាប់តែប្រកាសឱ្យចូលជាធរមានភ្លាមនូវច្បាប់ធម្មនុញ្ញប៉ុណ្ណោះ។ គេត្រូវដាក់ពាក្យថា " រដ្ឋធម្មនុញ្ញ " ក្នុងមាត្រានេះ ពីព្រោះនៅពេលត្រូវបានអនុម័ត ហើយច្បាប់ធម្មនុញ្ញត្រូវចូលក្នុងរដ្ឋធម្មនុញ្ញ ។
- យល់ឃើញថា មាត្រា ១៥៦ ថ្មី បានចែងច្បាស់ក្នុងអន្តរប្បញ្ញត្តិថា : " ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមលំដាប់ខ័ណ្ឌដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ " គឺមានន័យថា ជាលំដាប់ខ័ណ្ឌក្នុងការជ្រើសរើសព្រះមហាក្សត្រក្នុងករណីដែលពុំមានព្រះមហាក្សត្រ ក្រោយពេលដែលច្បាប់ធម្មនុញ្ញនេះចូលជាធរមាន ។ ប៉ុន្តែតាមការជាក់ស្តែងពុំមានករណីនេះទេ ដូច្នេះក្នុងការជ្រើសរើសព្រះមហាក្សត្រថ្មី គឺត្រូវតែគោរពតាមមាត្រា ១៣ ថ្មី និង មាត្រា ១៤ នៃរដ្ឋធម្មនុញ្ញ ។

សម្រេច

មាត្រា ១ : ក្នុងន័យដូចមានបកស្រាយ ដែលបានរៀបរាប់ក្នុងមូលបទខាងលើនេះ មាត្រា ១៤០ ថ្មី ឃ្លាទី១ កថាខ័ណ្ឌទី២ មាត្រា ១៥៤ ថ្មី និង មាត្រា ១៥៦ ថ្មី នៃច្បាប់ធម្មនុញ្ញ មិនមានខ្លឹមសារផ្ទុយនឹងបទប្បញ្ញត្តិណានៃរដ្ឋធម្មនុញ្ញឡើយ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅភ្នំពេញថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៩

ខ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឃុត្តលេខា និង ត្រា

ចាន់ សុភ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យើងខ្ញុំក្រុមអ្នកតំណាងរាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា

គោរពជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

<u>កម្មវត្ថុ</u> : សំណើសុំពិនិត្យបកស្រាយមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

<u>យោង</u> : - មាត្រា ១៨១ ថ្មី និង មាត្រា ១៣៦ ថ្មី នៃច្បាប់ធម្មនុញ្ញ

យើងខ្ញុំមានកិត្តិយស សូមជម្រាបជូន ឯកឧត្តមមេត្តាជ្រាបថា ក្រោយការចាប់ខ្លួនបានមេខ្មែរក្រហមឈ្មោះតាម៉ុក កាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៩៩ មក មានមតិជាច្រើនប្លែកៗពីគ្នាបានលើកឡើងជុំវិញការកាត់ទោសមេខ្មែរក្រហមរូបនេះ ពិសេសខ្លះថា ត្រូវតែបញ្ជូនតាម៉ុកទៅកាត់ទោសនៅតុលាការអន្តរជាតិក្នុងប្រទេសណាមួយ ខ្លះទៀតថាត្រូវតែដំណើរការកាត់ទោសនៅក្នុងប្រទេសទើបត្រឹមត្រូវ ។

ដោយមានយោបល់ចម្រុងចម្រាសក្នុងមតិជាតិ និង អន្តរជាតិ អង្គការសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល ។ ល ។ ដែលធ្វើឲ្យមានការងឿងឆ្ងល់បន្តបន្ទាប់ យើងខ្ញុំជាសមាជិករដ្ឋសភាដូចមានឈ្មោះខាងក្រោមនេះមានកាតព្វកិច្ចស្វែងរកការបំភ្លឺមួយពិសេសពីក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នមានសមត្ថកិច្ច ។

អាស្រ័យហេតុនេះ យើងខ្ញុំទាំងអស់គ្នា សូមស្នើក្រុមប្រឹក្សាធម្មនុញ្ញមេត្តាធ្វើការបកស្រាយមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តាមការគួរ ។

ខ្ញុំសូម ឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ១៩៩៩

ហត្ថលេខា

អ្នកតំណាងរាស្ត្រ ៥១រូប

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៤/៩៩

ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ១៩៩៩

សេចក្តីសម្រេច

លេខ : ០៣ កបធ.សសរ.ច

ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ១៩៩៩

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញសំណើសុំឱ្យពិនិត្យបកស្រាយមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញ ដោយក្រុមអ្នកតំណាងរាស្ត្រ ៤១រូប ដែលបានលើកបញ្ជាក់ថា មានមតិយោបល់ជាច្រើនប្លែក១ពីគ្នា ប្រកបដោយភាពចម្រូងចម្រាសទាំងក្នុង មតិជាតិទាំងក្នុងមតិអន្តរជាតិ អង្គការសារពតិមាននានា អង្គការក្រៅរដ្ឋាភិបាល។ ល។ ជុំវិញការកាត់ទោសមេខ្មែរក្រហម **តា ម៉ុក** ក្រោយពីការចាប់ខ្លួនកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៩៩ ពិសេសខ្លះលើកឡើងថា ត្រូវតែបញ្ជូនខ្លួនទៅតុលាក.រអន្តរជាតិក្នុងប្រទេសណាមួយ ខ្លះទៀតថា ត្រូវតែដំណើរការកាត់ទោសនៅក្នុងប្រទេសទើបត្រឹមត្រូវដែលទទួលបាននៅអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃ ទី ០៦ ខែ មេសា ឆ្នាំ១៩៩៩
- បានឃើញឯកសារនានាពីរដ្ឋសភា ដែលទាក់ទងនឹងមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញ

ក្រោយពីបានស្តាប់របាយក.រណ៍របស់សមាជីករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី១ ដែលចែងថា " ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក " គឺក្នុងគោលបំណងដ៏ពិសិដ្ឋ ដើម្បីការពារសិទ្ធិផលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់១រូប ពិសេសការពារពីការដកសញ្ជាតិខ្មែរ ពីការនិរទេស ឬ ពីការចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយ ។
- យល់ឃើញថា ខ្លឹមសារមាត្រា ៣៣ នៃរដ្ឋធម្មនុញ្ញនេះ ការចាប់បញ្ជូនខ្លួនន្ទូវប្រជាពលរដ្ឋខ្មែរ ណាម្នាក់ទៅឱ្យប្រទេសក្រៅណាមួយ អាចធ្វើទៅបាន លុះត្រាតែមានកិច្ចព្រមព្រៀងទៅវិញទៅមក ។

សម្រេច

មាត្រា ១ : ការចាប់បញ្ជូនខ្លួនពលរដ្ឋខ្មែរគ្រប់ៗរូបទៅឱ្យកាត់ទោស ឬ/និង ទទួលរងទោសនៅប្រទេសក្រៅមិនអាចធ្វើទៅបានឡើយក្នុងក្របខ័ណ្ឌនៃខ្លឹមសារមាត្រា ៣៣ កថាខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញដែលបាន ចែងថា : " ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬ ចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទេវិញទៅមក " ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅភ្នំពេញថ្ងៃទី ២៨ ខែ មេសា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ១៩៩៩

ម.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ចាន់ សុភ

ព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៩៥/៥០០/ពស/ជ.ក

សូមជំរាបជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

<u>កម្មវត្ថុ</u> : សំណើសុំបកស្រាយមាត្រា ១១៣ ថ្មី ជំពូកទី៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

ដូចកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសជំរាបជូនឯកឧត្តមប្រធានថា ក្នុងការអនុវត្តន៍ការងារក្នុងរយៈពេលជាងមួយឆ្នាំកន្លងមកនេះ ព្រឹទ្ធសភាបានខិតខំធ្វើសកម្មភាពដែលជាប្រយោជន៍ដល់ជាតិ និងប្រជារាស្ត្រយើង ដោយស្មារតីទទួលខុសត្រូវនិងផ្ទិតផ្ទង់អនុវត្តតាមរដ្ឋធម្មនុញ្ញ ។ តែនៅក្នុងការងារជាក់ស្តែងបានលេចចេញនូវបញ្ហាមួយចំនួនពាក់ព័ន្ធនឹងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ជាពិសេសត្រង់វាក្យខ័ណ្ឌទី១ ដែលចែងថា : " ព្រឹទ្ធសភាពិនិត្យ ហើយឲ្យយោបល់ក្នុងរយៈពេលមួយខែ យ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័ត យល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ " ។

ក្នុងពេលកន្លងមកក៏ដូចបច្ចុប្បន្ននេះ មានច្បាប់ជាច្រើនដែលរដ្ឋសភាបានអនុម័ត (ជាច្បាប់ដែលមានច្រើនជំពូក និង ច្រើនមាត្រា) ហើយត្រូវបានបញ្ជូនមកព្រឹទ្ធសភាឲ្យអនុម័តជាការប្រញាប់ ។ ច្បាប់ទាំងនោះសោតទៀត នៅមាត្រាខាងក្រោយតែងតែចែងថា : " ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ " ។

បើអនុវត្តតាមមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ ជំពូកទី៨ នៃរដ្ឋធម្មនុញ្ញ ព្រឹទ្ធសភាមានរយៈពេលត្រឹមតែប្រាំថ្ងៃក្នុងការពិនិត្យ និង ផ្តល់យោបល់ទៅរដ្ឋសភាវិញ ។ ប្រការនេះបានដាក់ការកៀបសង្កត់មកលើព្រឹទ្ធសភា ដើម្បីឲ្យធ្វើការសម្រេចចិត្តដោយពិបាក :

ទី១-ឬមួយបញ្ជូនទៅរដ្ឋសភាវិញទាំងស្រុងដដែល ដោយព្រឹទ្ធសភាគ្មានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាពិនិត្យ និង ផ្តល់យោបល់ ។

ទី២-ឬមួយបង្ខំចិត្តធ្វើការពិនិត្យ និង ផ្តល់យោបល់ពីច្បាប់ទាំងនោះដោយតក់ក្រហល់ ទាំងពុំបានស៊ីជម្រៅឲ្យបានគ្រប់សព្វជង ។

ប្រឈមមុខនឹងហេតុការណ៍នេះ និង យោងតាមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញចែងក្នុងជំពូកទី១២ ថ្មី មាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ ខ្ញុំសូមស្នើក្រុមប្រឹក្សាធម្មនុញ្ញមេត្តាជួយបកស្រាយមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញត្រង់ : " <u>បើជាការប្រញាប់</u> <u>រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែ</u>ប្រាំថ្ងៃ " :

ទី១-ឃ្លាថា " <u>បើជាការប្រញាប់</u> " តើសំដៅទៅរកលក្ខន្តិកៈច្បាប់ លក្ខខណ្ឌច្បាប់ និង នីតិវិធីច្បាប់បែបណាខ្លះ ? ពាក្យថា " ប្រញាប់ " តើសំដៅទៅរកការកំណត់ថា " ប្រញាប់ " របស់រដ្ឋសភា ឬ

របស់រាជរដ្ឋាភិបាល ឬ របស់ស្ថាប័នទាំងពីរ ? ឬមួយអាស្រ័យលើការកំណត់របស់ព្រឹទ្ធសភា ទទួលយល់ព្រមចាត់ទុកជាការប្រញាប់ ឬ មួយយោងទៅតាមមាត្រាខាងក្រោយនៃច្បាប់ដែលចែងថា " ច្បាប់នោះត្រូវបានចាត់ទុកជាការប្រញាប់ " ។

ទី២-ឃ្លាថា " រយៈពេលនោះត្រូវបន្តយមកនៅត្រឹមតែប្រាំថ្ងៃ " ។ តើរយៈពេលប្រាំថ្ងៃនេះរាប់បញ្ចូលទាំងថ្ងៃបុណ្យ និង ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (ថ្ងៃសៅរ៍ - ថ្ងៃអាទិត្យ) ដែរឬទេ ? តើការរាប់ប្រាំថ្ងៃនេះចាប់ពីថ្ងៃណា : ពីថ្ងៃដែលរដ្ឋសភាបានអនុម័តច្បាប់នេះ ឬ ចាប់ពីថ្ងៃដែលច្បាប់នេះបានមកដល់មន្ទីរព្រឹទ្ធសភា ? ឬ ប្រាំថ្ងៃនេះ ចាប់ពីថ្ងៃដែលព្រឹទ្ធសភាបានចាប់ផ្តើមពិភាក្សាលើច្បាប់នេះ ?

សេចក្តីដូចជំរាបខាងលើ សូមឯកឧត្តមប្រធានមេត្តាជ្រាប និងមេត្តាជួយបកស្រាយ តាមការគួរ ដើម្បីព្រឹទ្ធសភាអាចបំពេញការងារប្រកបដោយប្រសិទ្ធភាពពិតប្រាកដ ។

សូមឯកឧត្តមប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្របំផុតពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០០

ប្រធានព្រឹទ្ធសភា

ហត្ថលេខា

ជា ស៊ីម

ចម្លងជូន

- ឧទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា

ក្រៅមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៣១/០០៣/២០០០

ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០០០

សេចក្តីសម្រេច

លេខ : ០៣៦/០០២/២០០០ កបធ.ច

ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០០

ក្រៅមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨/០៤/៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានឃើញបទបញ្ជាផ្ទៃក្នុងរដ្ឋសភា
- បានឃើញលិខិតលេខ ០៥៥/៥០០/ពស/ជក របស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០០ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី ជំពូកទី៨ នៃរដ្ឋធម្មនុញ្ញ

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា ប្រធានព្រឹៈសភា បានសុំក្នុងលិខិតលេខ ០៥៥/៥០០/ពស/ជក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០០ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយតែវាក្យខ័ណ្ឌទី១ នៃមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ ជាពិសេសត្រង់សេចក្តីថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ " ។
- យល់ឃើញថា យើងអាចលើកយកពាក្យថា " បើជាការប្រញាប់ " មកពិនិត្យបានក្នុងបួនករណី គឺ :

-១-ករណីដែលក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់មានមាត្រាណាមួយចែងថា : " ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ " ។

-២-ករណីដែលមានលិខិតផ្លូវការរបស់រាជរដ្ឋាភិបាល ឬ របស់ម្ចាស់សេចក្តីស្នើច្បាប់សុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះជាការប្រញាប់ ។

-៣-ករណីដែលមានការស្នើសុំពីរដ្ឋសភា ឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។

-៤-ករណីដែលរាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់ ។

ករណីទី១ : ករណីដែលក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ មានមាត្រាណាមួយចែងថា : " ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ " ។

ជាបឋម យើងគួរធ្វើការវែកញែកវាង " ការប្រញាប់ក្នុងការធ្វើច្បាប់ " ហើយនិង " ការប្រញាប់ក្នុងការអនុវត្តន៍ច្បាប់ " ។

" ការប្រញាប់ក្នុងការធ្វើច្បាប់ " គឺបានន័យថា រដ្ឋសភា ត្រូវខំធ្វើនិងអនុម័តច្បាប់ឱ្យបានឆាប់រហ័ស ហើយច្រើនតែតាមសំណើសុំរបស់រាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ។ ប៉ុន្តែនេះគ្រាន់តែជាការខិតខំរបស់រដ្ឋសភាមិនមែនជាការបង្ខំរដ្ឋសភាឱ្យធ្វើតាមសំណូមពរនោះទេ ។

" ការប្រញាប់ក្នុងការអនុវត្តន៍ច្បាប់ " គឺក្នុងន័យដែលមានចែងក្នុងមាត្រា ៥៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្តីថា : " ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ " ។ ពាក្យថា " ចូលជាធរមាន " គឺសំដៅលើការអនុវត្តន៍ច្បាប់ ។

ប្រការដែលមានមាត្រាណាមួយចែងក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ថា : " ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ " នោះ គឺសំដៅទៅលើ " ការប្រញាប់ក្នុងការអនុវត្តន៍ច្បាប់ " ប៉ុណ្ណោះ ពីព្រោះជាខ្លឹមសារនៃសេចក្តីដែលមានចែងក្នុងច្បាប់តែម្តង ដើម្បីតម្រូវការអនុវត្តន៍ឱ្យស្របនឹង មាត្រា ៥៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ។ គឺមិនមែនតាមលិខិតមួយផ្សេងដោយឡែកដែលធ្វើឡើងដោយរាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ដើម្បីសុំឱ្យរដ្ឋសភាពិនិត្យជាការប្រញាប់ឡើយ ។

ក្នុងករណីនេះបើមានត្រឹមតែមាត្រា ក្នុងសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ចែងថា : " ជាការប្រញាប់ " ប៉ុណ្ណោះ គឺមិនមែនជា " ការប្រញាប់ក្នុងការធ្វើច្បាប់ទេ " ។ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ខែ សម្រាប់ពិនិត្យ ហើយឱ្យយោបល់ ។

ករណីទី២ : រាជរដ្ឋាភិបាលធ្វើលិខិតសុំឱ្យរដ្ឋសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ជាការប្រញាប់ ទោះបីក្នុងអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់បានចែង ឬ មិនបានចែងថា " ច្បាប់នេះត្រូវបានចាត់ទុកជាការប្រញាប់ " ក៏ដោយ ។

ក្នុងករណីនេះ រដ្ឋសភាត្រូវសម្រេចលើពាក្យសុំនោះ តាមនីតិវិធីដែលមានចែងក្នុងប្រការ ៤៥ និង ៤៦ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា គឺថា រាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់ ត្រូវជូនហេតុផលអំពីការសុំជាការប្រញាប់នោះ។ ប្រធានរដ្ឋសភានាំសេចក្តីទៅថ្លែងជម្រាបរដ្ឋសភា ដើម្បីសុំរដ្ឋសភាសម្រេចថា យល់ព្រម ទុកជាការប្រញាប់ ឬមិនយល់ព្រម ។

បើរដ្ឋសភាសម្រេចយល់ព្រម ពេលនោះរដ្ឋសភាយកសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ មកពិនិត្យពិភាក្សាមុនគេ ស្របតាមប្រការ ៤៤ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ ក្រោយបានអនុម័តយល់ព្រមលើកដំបូង ហើយ រដ្ឋសភាបញ្ជូនមកព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់ដូចមានចែងក្នុងមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១

នៃរដ្ឋធម្មនុញ្ញ ។ បើគ្មានពាក្យសុំពីរដ្ឋសភាថា ជាការប្រញាប់ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ ខែ សម្រាប់ពិនិត្យ និងឱ្យយោបល់ ។

ករណីទី៣ : ជាការត្រឹមត្រូវរដ្ឋសភាអាចនឹងស្នើសុំឱ្យព្រឹទ្ធសភាពិនិត្យសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ " ជាការប្រញាប់ " បានដែរ នៅពេលដែលរដ្ឋសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ដែលខ្លួនបានអនុម័តយល់ព្រមលើកដំបូងរួចហើយ មកព្រឹទ្ធសភាតាមមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ។ ការស្នើសុំរបស់រដ្ឋសភាឱ្យព្រឹទ្ធសភាពិនិត្យជាការប្រញាប់នេះ មានចែងក្នុងប្រការ ៤២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ព្រឹទ្ធសភាត្រូវសម្រេចលើពាក្យសុំនេះ តាមនីតិវិធីដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺថា រដ្ឋសភាត្រូវជូនហេតុផលជាលាយលក្ខអក្សរ ហើយប្រធានព្រឹទ្ធសភានាំពាក្យទៅថ្លែងជំរាបព្រឹទ្ធសភា ដើម្បីសុំព្រឹទ្ធសភាសម្រេចថា យល់ព្រម ឬ មិនយល់ព្រមទុកជាការប្រញាប់ ។

ដូច្នេះ វាអាស្រ័យលើព្រឹទ្ធសភាជាអ្នកសម្រេចថាគួរទុកជាការប្រញាប់ ឬ មិនគួរ ទោះបីមានសំណើពីរដ្ឋសភាថា ទុកជាការប្រញាប់ក៏ដោយ ។ បើព្រឹទ្ធសភាយល់ថា គួរទុកជាការប្រញាប់តាមសំណើរបស់រដ្ឋសភា ពេលនោះព្រឹទ្ធសភាត្រូវអនុវត្តតាមប្រការ ៤១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គឺត្រូវចុះសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ក្នុងរបៀបវារៈពិភាក្សាមុនគេ ហើយត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេលប្រាំថ្ងៃ ដើម្បីឱ្យស្របនឹងមាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ។ បើព្រឹទ្ធសភាយល់ថា មិនគួរទុកជាការប្រញាប់ទេ ព្រឹទ្ធសភាមានរយៈពេល ១ខែ ដូចធម្មតា សម្រាប់ពិនិត្យ និង ឱ្យយោបល់ ។

ករណីទី៤ : រដ្ឋសភាពុំបានសុំទេ ប៉ុន្តែរាជរដ្ឋាភិបាល ឬ ម្ចាស់សេចក្តីស្នើច្បាប់សុំឱ្យព្រឹទ្ធសភា ពិនិត្យជាការប្រញាប់ ។ នីតិវិធីដូចក្នុងករណីទី៣ ដែរ គឺត្រូវអនុវត្តប្រការ ៤១ ៤២ និង ៤៣ នៃបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។ ព្រឹទ្ធសភាជាអ្នកសម្រេចខ្លួនឯងថា គួរយល់ព្រមតាមការសុំឬទេ ។ បើយល់ព្រមត្រូវពិនិត្យ និងឱ្យយោបល់ក្នុងរយៈពេល ៥ ថ្ងៃ ។ ប៉ុន្តែបើមិនយល់ព្រមទេ ព្រឹទ្ធសភាមានរយៈពេលធម្មតា គឺ ១ ខែ ដដែល ។

តាមការវិភាគទាំង ៤ ករណីខាងលើនេះមក ព្រឹទ្ធសភាមានរយៈពេលធម្មតា ១ ខែ ក្នុងការ ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ ។ ក្នុងករណីដែលមានពាក្យសុំពីរដ្ឋសភា ពីរាជរដ្ឋាភិបាល ឬ ពីម្ចាស់សេចក្តីស្នើច្បាប់ ឱ្យពិនិត្យជាការប្រញាប់ ព្រឹទ្ធសភាមានអំណាចសម្រេចខ្លួនឯងថា ត្រូវទុក ឬ មិនត្រូវទុកជាការប្រញាប់ ។

- យល់ឃើញថា របៀបគិតរយៈពេល ឬ របៀបរាប់ថ្ងៃ ពុំមានចែងក្នុងច្បាប់ណាមួយឱ្យបានច្បាស់លាស់ទេ ក្នុងប្រទេសយើង ។ តាមទម្លាប់រដ្ឋបាលក្តី តុលាការក្តី គេមានរបៀបរាប់ថ្ងៃ និង រយៈពេលពីរយ៉ាងគឺ :

  ១-របៀបរាប់រយៈពេលគត់ (ជាភាសាបារាំងគេហៅថា « délai franc ») ។

  ២-របៀបរាប់រយៈពេលមិនគត់ (ជាភាសាបារាំងគេហៅថា « délai non franc ») ។

របៀបរាប់ទី១ : រយៈពេលគត់

គឺគេមិនរាប់ថ្ងៃទទួល (ឯកសារ) ដែលភាសាឡាតាំងហៅថា (dies a quo) និងថ្ងៃដែលត្រូវផុត ដែល

ភាសាឡាតាំងហៅថា (dies ad quem) ។ ឧបមាថា រយៈពេលគត់ ៥ ថ្ងៃ។ ថ្ងៃទទួលឯកសារ គឺថ្ងៃទី ៥មិថុនា ហើយនិងថ្ងៃដែលត្រូវផុតគឺថ្ងៃទី ១០ មិថុនា ។ គេមិនរាប់ថ្ងៃទី ៥ មិថុនា ទេ គឺគេចាប់រាប់ពីថ្ងៃទី ៦ មិថុនា ទៅ ។ គេមិនរាប់ថ្ងៃទី ១០ មិថុនា ដែលជាថ្ងៃត្រូវផុតទេ គឺគេរាប់ថ្ងៃទី ១១ មិថុនា ទើបចប់ផុតបរិច្ឆេរណ៍ ។ ហើយគេរាប់ពីម៉ោង ១២ យប់ (ម៉ោងសូន្យ) ដល់ម៉ោង ១២ យប់ សម្រាប់រាប់មួយថ្ងៃពេញ ។

ដូច្នេះ ក្នុងឧទាហរណ៍ខាងលើនេះ គេត្រូវរាប់ថ្ងៃទី ១១ មិថុនា រហូតដល់ម៉ោង ១២ យប់ ទើបផុតរយៈពេលគត់ ៥ ថ្ងៃ ។

<u>របៀបរាប់ទី ២ : រយៈពេលមិនគត់</u>

គឺគេមិនរាប់ថ្ងៃទទួល (ឯកសារ) ដូចគ្នានឹងរបៀបរាប់ទី១ ដែរ ។ ប៉ុន្តែគេរាប់ថ្ងៃដែលត្រូវផុតគឺថ្ងៃទី ១០ មិថុនា រហូតដល់ម៉ោង ១២ យប់ ។

ក្នុងករណីគ្មានការប្រញាប់ គេប្រើរបៀបរាប់ទី១។ រយៈពេលនេះ ច្រើនតែវែង ដូចជា ១ ខែ ឬ ២ ខែ។ល។

ក្នុងករណី " ការប្រញាប់ " គេប្រើរបៀបទី២ ។ រយៈពេលនេះច្រើនតែខ្លី ដូចជា ៥ ថ្ងៃ ឬ រាប់ ម៉ោង (៤៨ ម៉ោង ឬ ៧២ ម៉ោង។ ល។) គេច្រើនប្រើរបៀបរាប់នេះ សម្រាប់កិច្ចការដែលប្រញាប់ ដូចក្នុងករណីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាដើម ។

ក្នុងករណីដែលច្បាប់បានចែងថា " ថ្ងៃគត់ " គេត្រូវអនុវត្តរបៀបរាប់ទី១ គឺរយៈពេលគត់ ។ របៀបរាប់ថ្ងៃទាំងពីរយ៉ាងនេះ ប្រទេសយើងធ្លាប់ប្រើកាលក្នុងសម័យមុនមានចំបាំង (ឆ្នាំ១៩៧0) ហើយប្រទេសជាច្រើនក្នុងលោកក៏គេប្រើដែរ ដូចជាប្រទេសបារាំងជាដើម ។

យោងតាមទម្លាប់នេះ មាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញដែលបានបញ្ជាក់ច្បាស់ថា " បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកត្រឹមតែប្រាំថ្ងៃ " បានន័យថា ព្រឹទ្ធសភាត្រូវប្រើរបៀបរាប់ ទី២ គឺថារបៀបរាប់រយៈពេលមិនគត់ ។

បើថ្ងៃចុងក្រោយដែលត្រូវចប់ ធ្លាក់ចំថ្ងៃឈប់សម្រាក ដូចជាថ្ងៃសៅរ៍ អាទិត្យ ឬ ថ្ងៃបុណ្យ ដែលច្បាប់អនុញ្ញាតឱ្យឈប់ គេត្រូវរំកិលថ្ងៃនោះរហូតដល់ថ្ងៃចូលធ្វើការទី១ ពេញមួយថ្ងៃទៀត ។

ប៉ុន្តែបើថ្ងៃឈប់សម្រាកស្ថិតនៅចន្លោះថ្ងៃទទួលឯកសារ (dies a quo) និង ថ្ងៃផុតកំណត់ (dies ad quem) រយៈពេល (៥ ថ្ងៃ) នោះ ឥតមានប្រែប្រួលឡើយ គឺថាគ្មានរកយកថ្ងៃធ្វើការណាមកជំនួសបានទេ ។ នេះជាទម្លាប់ដែលគេតែងប្រតិបត្តិតាម ជាទូទៅ សឹងតែគ្រប់ប្រទេស ។

សម្រួច

មាត្រា ១ : មាត្រា ១១៣ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ទាក់ទងនឹងឃ្លាថា " បើជាការប្រញាប់រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ " ត្រូវបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ចំពោះការប្រញាប់ និងរយៈពេល ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២000 នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២000

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ចាន់ សុភ

ព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ២៥៨/២០០០/ពស/អ.គ

សូមជំរាបជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : សំណើសុំបកស្រាយមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមប្រធានជ្រាបថា សព្វថ្ងៃនេះក្រុមការងារជំនាញព្រឹទ្ធសភា និងគណៈកម្មការនីតិកម្មព្រឹទ្ធសភា កំពុងសិក្សាលើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាដោយបានកែសម្រួលលើចំណុចខ្លះ តាមការងារជាក់ស្តែង និង តាមការវិវត្តន៍ថ្មីរបស់ព្រឹទ្ធសភា។ ផ្អែកតាមមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញមេត្តាជួយបកស្រាយបំភ្លឺលើមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា " ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងារ រវាងរដ្ឋសភា និង រាជរដ្ឋាភិបាល " ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវតួនាទី និងសិទ្ធិអំណាចរបស់ព្រឹទ្ធសភា។ ពាក្យថា " សម្របសម្រួល " មានន័យជាច្រើនដែលចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំក្នុងការអនុវត្តន៍ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានជ្រាប និងជួយសម្រួលតាមការគួរ។

សូមឯកឧត្តមប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្របំផុត ពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០០

ប្រធានព្រឹទ្ធសភា

ហត្ថលេខា

ជា សុំម

ចម្លងជូន

- គណៈកម្មការទាំង ៩ ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជ្រាបជាព័ត៌មាន "

ព្រះរាជាណាចក្រកម្ពុជា

ក្រៅមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៣៥/០០៧/២០០០

ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០០

សេចក្តីសម្រេច

លេខ : ០៣៨/០០៤/២០០០ កបធ.ច

ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០០

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ២៥៨/១០០០/ពស/អគ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០០ របស់សម្តេចប្រធានព្រឹទ្ធសភា សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាដែលទទួលបាននៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០០
- បានឃើញឯកសារទទួលពីរដ្ឋសភា ទាក់ទងនឹងការពិភាក្សាលើមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា មាត្រា ៩៩ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងជាអាទិ៍ថា ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិបញ្ញត្តិ។
- យល់ឃើញថា ការងារក្នុងក្របខ័ណ្ឌនីតិបញ្ញត្តិរបស់ព្រឹទ្ធសភា ត្រូវបានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញរួចហើយ ដូច្នេះមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងារវាងរដ្ឋសភា និងរាជរដ្ឋាភិបាល " គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ។
- យល់ឃើញថា ព្រឹទ្ធសភាមានភារកិច្ចជួយសម្របសម្រួលការងាររដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បីជួយរកដំណោះស្រាយវិបត្តិនយោបាយ នៅពេលណាដែលវិបត្តិនេះកើតឡើង ។ ការងារនេះមានវិសាលភាពទូលំទូលាយមិនអាចកម្រិតព្រំដែនតាមលិខិតបទដ្ឋានអ្វីបានទេ ហើយក៏មិនអាចចែងជាច្បាប់អ្វីបន្ថែមទៀតពីលើមាត្រា ១១២ ថ្មី ដែរ ។

- យល់ឃើញថា មាត្រា ១១២ ថ្មី បានផ្តល់សិទ្ធិអំណាចជូនព្រឹទ្ធសភា អាចធ្វើអន្តរាគមន៍គ្រប់ពេលវេលាចូលទៅជួយដោះស្រាយវិបត្តិតូច ឬ ធំ ក្នុងកិច្ចការនយោបាយរវាងរដ្ឋសភានិងរាជរដ្ឋាភិបាលតាមមធ្យោបាយផ្សេងៗ ដែលមានដោយពុំកម្រិតក្របខ័ណ្ឌនៃពេលវេលាឡើយ ។ មាត្រា ១១២ ថ្មី បានផ្តល់កិត្តិយស និង ការទុកចិត្តជូនព្រឹទ្ធសភា ជាហេតុបញ្ជាក់ថា តួនាទីសម្របសម្រួលផ្ទៃកននយោបាយរបស់ព្រឹទ្ធសភា មានសារៈសំខាន់ណាស់សម្រាប់អាយុជីវិតរបស់ប្រទេសជាតិ ។
- យល់ឃើញថា ព្រឹទ្ធសភាមានភាពចាស់ទុំខាងនយោបាយ ដូច្នេះតួនាទីសម្របសម្រួលខាងនយោបាយនៃព្រឹទ្ធសភាពិតជាត្រូវបានយកចិត្តទុកដាក់ ដោយរដ្ឋសភា និងរាជរដ្ឋាភិបាល ។
- យល់ឃើញថា តួនាទីនយោបាយរបស់ព្រឹទ្ធសភា ពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភា និងរាជរដ្ឋាភិបាល ធ្វើតាមព្រឹទ្ធសភាឡើយ។ ការសម្របសម្រួលរបស់ព្រឹទ្ធសភា អាចចាត់ទុកថា បានលទ្ធផលជាវិជ្ជមាន លុះត្រាតែរដ្ឋសភា និងរាជរដ្ឋាភិបាលព្រមព្រៀងស្រុះស្រួលគ្នា ។

សម្រេច

មាត្រា ១ : ក្នុងន័យដូចបានបកស្រាយក្នុងមូលបទខាងលើ ការកិច្ចរបស់ព្រឹទ្ធសភា ក្នុងការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ដែលមានចែងក្នុងមាត្រា ១១២ ថ្មី នៃរដ្ឋធម្មនុញ្ញ គឺជាតួនាទីនយោបាយរបស់ព្រឹទ្ធសភា ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០០

ស.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ចាន់ សុភ

ព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៣៤/០៨០២/ពស/ក្រច

ជម្រាបជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

<u>កម្មវត្ថុ</u> : សំណើសុំជួយបកស្រាយ - មាត្រា ១០១ ថ្មី - និង ពាក្យ - ការបោះឆ្នោតអសកល - ដែលមានប្រើក្នុងមាត្រា ៩៩ ថ្មី និង មាត្រា ១០០ ថ្មី នៃរដ្ឋធម្មនុញ្ញ ។

<u>យោង</u> : មាត្រា ១៣៦ ថ្មី និង មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ព្រឹទ្ធសភានៅមានការយល់ពុំទាន់បានច្បាស់លាស់នូវ - មាត្រា ១០១ ថ្មី - និងពាក្យ - ការបោះឆ្នោតអសកល - ដែលមានប្រើក្នុងមាត្រា ៩៩ ថ្មី និង មាត្រា ១០០ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ដើម្បីជៀសវាងនូវការបកស្រាយខុស ប្រាសចាកពីខ្លឹមសារពិតប្រាកដនៃរដ្ឋធម្មនុញ្ញ ឬ ការមិនមានឯកភាពក្នុងកិច្ចពិភាក្សានានានៅក្នុងការកសាង និង អនុម័តច្បាប់ឲ្យបានត្រឹមត្រូវ ។

សេចក្តីដូចបានជំរាបជូនខាងលើ សូមឯកឧត្តមជួយធ្វើការបកស្រាយនូវខ្លឹមសារនៃ - មាត្រា ១០១ ថ្មី - និង - ការបោះឆ្នោតអសកល - (មាត្រា ៩៩ មាត្រា ១០០ ថ្មី) តាមការគួរ ។

សូមឯកឧត្តមទទួលនូវ សេចក្តីរាប់អានប្រកបដោយភាតរភាព អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០២

ប្រធានព្រឹទ្ធសភាស្តីទី

ព្រះហស្តលេខា

ស៊ីសុវត្ថិ ជីវំនមុនីរក្ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៥២/០០៦/២០០២

ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០២

សេចក្តីសម្រេច

លេខ : ០៤៨/០០៣/២០០២ កបធ.ច

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១៣៤/០៨០២/ពស/ក្រ.ច ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០២ របស់ព្រះអង្គម្ចាស់ស្តេចក្រុមឃុន **ស៊ីសុវត្ថិ ជីវ័នមុនីរ៉ុង** ប្រធានព្រឹទ្ធសភាស្តីពីស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ " មាត្រា ១០១ ថ្មី " និងពាក្យ " ការបោះឆ្នោតអសកល " ដែលមានបើកក្នុងមាត្រា ៩៩ ថ្មី និង មាត្រា ១០០ ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០០២

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា តាមមាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ពាក្យបណ្តឹងរបស់ស្តេចក្រុម **ស៊ីសុវត្ថិ ជីវ័នមុនីរ៉ុង** ប្រធានព្រឹទ្ធសភាស្តីពីខាងលើអាចទទួលយកមកពិចារណាបាន ។
- យល់ឃើញថា ក្នុងមាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ ពាក្យដែលគួរពិចារណា និងអាចមានការភ័ន្តច្រឡំ គឺអ្នកបោះឆ្នោត អង្គបោះឆ្នោត មណ្ឌលបោះឆ្នោត ។
- យល់ឃើញថា អ្នកបោះឆ្នោត គឺអ្នកដែលមានគ្រប់លក្ខណៈសម្បត្តិតាមច្បាប់កំណត់ ។
- យល់ឃើញថា អង្គបោះឆ្នោត គឺជាក្រុមមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចទៅបោះឆ្នោតបានតាម

ការកំណត់នៃច្បាប់ សម្រាប់ពីរសតំណាងឱ្យភូមិភាគ ឬ តំណាងវិជ្ជាជីវៈនានា ។ ឧទាហរណ៍ ច្បាប់អាចកំណត់ថា ជាក្រុមជនជាតិ ជាក្រុមកសិករ ក្រុមអ្នកនេសាទ ក្រុមពាណិជ្ជករ ក្រុមឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និង ក្រុមវិជ្ជាជីវៈដទៃទៀត ។ ល។

- យល់ឃើញថា មណ្ឌលបោះឆ្នោត ជារង្វង់ដែនដីភូមិសាស្ត្រ ដែលច្បាប់កំណត់សម្រាប់អង្គបោះឆ្នោត ។ ឧទាហរណ៍ ច្បាប់អាចនឹងកំណត់យកភូមិភាគ ឬ ខេត្តក្រុង ។ ល។ ជាមណ្ឌលបោះឆ្នោត ។
- យល់ឃើញថា ការបោះឆ្នោតអសកល ជាការបោះឆ្នោតមិនទូទៅដូចការបោះឆ្នោតសកល ។ ច្បាប់បន្ថែមលក្ខ-ខណ្ឌផ្សេងទៀតដល់អ្នកបោះឆ្នោត លើសពីលក្ខខណ្ឌដែលតម្រូវដល់អ្នកបោះឆ្នោតសកល ។ ឧទាហរណ៍ ដូចជា អ្នកមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតសកលហើយ ប៉ុន្តែត្រូវជាក្រុមកសិករ ក្រុមអ្នកនេសាទ ក្រុមពាណិជ្ជករ ក្រុមឧស្សាហករ ក្រុមកម្មករ មន្ត្រីរាជការ និង ក្រុមវិជ្ជាជីវៈដទៃទៀត ។ ល។ ថែមទៀត ។ ការបោះឆ្នោតអសកលអ.ប្រព្រឹត្តទៅដោយចំពោះ ឬ មិនចំពោះ ។

សម្រេច

មាត្រា ១ : មាត្រា ១០១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង ពាក្យ ការបោះឆ្នោតអសកល ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុម-ប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២

ម.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ចាន់ សុភ

ព្រះរាជាណាចក្រកម្ពុជា

ព្រឹទ្ធសភា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៥២/០៩០២/ពស/នវ

សូមជម្រាបជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

<u>កម្មវត្ថុ</u> : សំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ

<u>យោង</u> : - មាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា ១៨១ ថ្មី នៃរដ្ឋធម្មនុញ្ញ

តាមសេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមប្រធានមេត្តាជ្រាបថា ព្រឹទ្ធសភាតែងតែជួបការលំបាកជារឿយៗ បណ្តាលមកពីភាពមិនច្បាស់លាស់នៃបញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញ ជាពិសេសត្រង់មាត្រា ១១៣ ថ្មី :

- កថាខ័ណ្ឌទី២ ដែលមានសេចក្តីថា " បើព្រឹទ្ធសភា... ពុំបានឲ្យយោបល់សោះក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះនឹងត្រូវបានយកទៅប្រកាសឲ្យប្រើ " ។

តើពាក្យថា " បើព្រឹទ្ធសភា... ពុំបានឲ្យយោបល់សោះ " នេះមានន័យយ៉ាងដូចម្តេច ?

- កថាខ័ណ្ឌទី៥ ដែលមានសេចក្តីថា " បើរដ្ឋសភាទុកឲ្យហួសរយៈពេលកំណត់ ឬ ពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឲ្យស្មើគ្នាដែរ " ។

តើកថាខ័ណ្ឌទី៥ នេះមានន័យយ៉ាងដូចម្តេច ?

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តមប្រធានមេត្តាបកស្រាយសេចក្តីខាងលើនេះដោយអនុគ្រោះ។

សូមឯកឧត្តមប្រធានទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រប់ជុតពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០២

ប្រធានព្រឹទ្ធសភាស្តីទី

ព្រះហស្តលេខា

ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស

ព្រះរាជាណាចក្រកម្ពុជា

ក្រមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៥៤/០០៨/២០០២

ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០០២

សេចក្តីសម្រេច

លេខ : ០៤៩/០០៤/២០០២ កបធ.ច

ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០២

ក្រមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០០ ស្តីពីការបកស្រាយវាក្យខ័ណ្ឌទី១ នៃមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ

  បានឃើញលិខិតប្រធានព្រឹទ្ធសភាស្តីពី លេខ ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០២ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី២ និង ទី៥ នៃរដ្ឋធម្មនុញ្ញ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីពីបានសុំក្នុងលិខិតលេខ ១៥២/០៩០២/ពស/នវ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០២ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ ត្រង់សេចក្តីថា " បើព្រឹទ្ធសភា ... ពុំបានឱ្យយោបល់សោះ " ហើយនិងកថាខ័ណ្ឌទី៥ ដែលមានសេចក្តីថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬ ពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ " ។
- យល់ឃើញថា សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងការបកស្រាយរដ្ឋធម្មនុញ្ញ មានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង ក្នុងមាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

តាមមាត្រា ១៤១ ថ្មី ក្នុងចំណោមឥស្សរជនដែលអាចលើកសំណើសុំបកស្រាយរដ្ឋធម្មនុញ្ញ គឺមានប្រធានព្រឹទ្ធសភាផងដែរ ។

ដូច្នេះ យោងតាមមាត្រា ១៣៦ ថ្មី និង ១៤១ ថ្មី នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពិនិត្យសំណើសុំបកស្រាយមាត្រា ១១៣ ថ្មី កថាខ័ណ្ឌទី២ និង ទី៥ របស់ប្រធានព្រឹទ្ធសភាស្តីទីខាងលើនេះបាន ។

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទីសុំឱ្យបកស្រាយជាដំបូង កថាខ័ណ្ឌទី២ នៃមាត្រា ១១៣ ថ្មី ត្រង់ពាក្យថា " បើព្រឹទ្ធសភា ... ពុំបានឱ្យយោបល់សោះ " ។

តាមបទប្បញ្ញត្តិដែលមានចែងក្នុងកថាខ័ណ្ឌទី១ នៃមាត្រា ១១៣ ថ្មី ព្រឹទ្ធសភាត្រូវពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្នុងករណីធម្មតា ប៉ុន្តែលើជាការប្រញាប់ គឺត្រឹមតែ ០៥ ថ្ងៃ ប៉ុណ្ណោះ ។ ដូច្នេះក្នុងករណីធម្មតា ផុតរយៈពេលមួយខែ គិតពីថ្ងៃដែល " **រដ្ឋសភាបានដាក់ឱ្យពិនិត្យ** " បើព្រឹទ្ធសភានៅស្ងៀមស្ងាត់ឥតធ្វើអ្វី ឬឥតឆ្លើយអ្វីសោះទៅរដ្ឋសភាវិញនោះគឺបានន័យថា " ព្រឹទ្ធសភាពុំបានឱ្យយោបល់សោះ " ។ ប៉ុន្តែពាក្យថា " ព្រឹទ្ធសភា " គឺមានន័យថា ត្រូវមានការប្រជុំពេញអង្គរបស់ព្រឹទសភា ដើម្បីសម្រេចថា " មិនឱ្យយោបល់ " ។

បញ្ហាដែលស្មុគស្មាញ គឺនៅត្រង់រដ្ឋសភាសុំឱ្យព្រឹទ្ធសភាពិនិត្យជា " ការប្រញាប់ " ។ ក្នុងករណីនេះ បើព្រឹទ្ធសភានៅស្ងៀមមិនឆ្លើយតបទៅវិញហួសពី ៥ ថ្ងៃ តើរដ្ឋសភាអាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបានឬទេ ?

យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០០ និងដូចមានចែងក្នុងប្រការ ៤៣ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភាដែរ ព្រឹទ្ធសភាមានអំណាចសម្រេចខ្លួនឯងថា " យល់ព្រម ឬ មិនយល់ព្រមទុកជាការប្រញាប់ " ។ ប៉ុន្តែបើព្រឹទ្ធសភាមិនបានសម្រេចអ្វីសោះ ហើយនៅស្ងាត់ស្ងៀមលើសពី ៥ ថ្ងៃ នោះត្រូវចាត់ទុកថា ព្រឹទ្ធសភាទទួលយល់ព្រមថាជាការប្រញាប់ ហើយរដ្ឋសភាអាចយកច្បាប់នោះទៅប្រកាសឱ្យប្រើក្នុងរយៈពេល ៥ ថ្ងៃបាន ។ បើព្រឹទ្ធសភាក្នុងសម័យប្រជុំពេញអង្គបានសម្រេចថា " ជាការប្រញាប់ " តាមសំណើសុំរបស់រដ្ឋសភា ហើយក៏បានធ្វើការពិភាក្សាទៅស្រាប់តែមានការរាំងស្ទះជាយថាហេតុបណ្តាលឱ្យហួសរយៈពេល ៥ ថ្ងៃទៅនោះ រដ្ឋសភាក្នុងករណីនេះ អាចយកច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះទៅប្រកាសឱ្យប្រើបាន ដោយមិនចាំបាច់រង់ចាំការអនុម័តរបស់ព្រឹទ្ធសភាឡើយ ។

- យល់ឃើញថា ប្រធានព្រឹទ្ធសភាស្តីទី បានសុំជាបន្ទាប់មកទៀតឱ្យបកស្រាយកថាខ័ណ្ឌទី៥ នៃមាត្រា ១១៣ ថ្មី ដែលមានសេចក្តីថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬ ពន្យារពេល ដែលកំណត់ទុក សម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ " ។

កថាខ័ណ្ឌទី៥ នេះទាក់ទងនឹងរយៈពេលនៃ " ការបង្ហិលទៅបង្ហិលមកវាងព្រឹទ្ធសភា និង រដ្ឋសភា " ដែលមានចែងក្នុងកថាខ័ណ្ឌទី៤ នៃមាត្រា ១១៣ ថ្មី ។

ក្នុងករណីព្រឹទ្ធសភាមិនឯកភាពតាមការអនុម័តដំបូងរបស់រដ្ឋសភា ព្រឹទ្ធសភាបង្ហិលទៅរដ្ឋសភាជាលើកទី១ ស្នើសុំកែប្រែ ។ រដ្ឋសភាបានទទួលហើយ ប៉ុន្តែមិនឯកភាពទាំងស្រុង ឬ ដោយអន្ទើ និង សំណើសុំកែប្រែរបស់ព្រឹទ្ធសភា

ក៍បង្វិលមកព្រឹទ្ធសភាវិញសុំឱ្យពិចារណាជាថ្មី។ ព្រឹទ្ធសភាពិចារណាជាថ្មីហើយក៍បង្វិលទៅរដ្ឋសភាវិញដោយបញ្ជាក់យោបល់របស់ខ្លួនម្តងទៀត ។ បើរដ្ឋសភាមិនទាន់ឯកភាពតាមព្រឹទ្ធសភា ការបង្វិលទៅបង្វិលមកអាចបន្តទៅទៀតបាន ជាធម្មតាក្នុងរយៈពេលមួយខែសម្រាប់ពិនិត្យច្បាប់ផ្សេងៗ ក្រៅពី ច្បាប់ថវិកាជាតិ និង ហិរញ្ញវត្ថុដែលត្រូវកម្រិតត្រឹម ១០ថ្ងៃ ។ បើជាការប្រញាប់រយៈពេលនេះមកនៅត្រឹម ២ថ្ងៃ តែប៉ុណ្ណោះ ។ រយៈពេលនៃការបង្វិលនេះត្រូវគិតពីថ្ងៃបង្វិលលើកទី១ របស់ព្រឹទ្ធសភា ។

ពាក្យថា " បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ " បានន័យថា ក្រោយបានទទួលការសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះពីព្រឹទ្ធសភាទៅរដ្ឋសភាមិនបានធ្វើអ្វីសោះរហូតដុត ១ ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ ទៅតាមករណីនីមួយៗដូចបានរៀបរាប់ខាងលើ ។

ពាក្យថា " ពន្យារពេលដែលកំណត់ទុក " បានន័យថា រដ្ឋសភាបានធ្វើការប្រជុំពេញអង្គ សម្រេចពន្យាពេលពិនិត្យឱ្យលើសពី ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ ទៅតាមករណីនីមួយៗនោះ ។

ពាក្យថា " រយៈពេលជាគោលការណ៍ សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភា " នោះ គឺរយៈពេល ១ ខែ ឬ ១០ ថ្ងៃ ឬ ២ ថ្ងៃ នេះហើយ ។

ពេលវេលាដែលលើសពីរដ្ឋធម្មនុញ្ញកំណត់ ដោយសារការទុក ឬ ការសម្រេចពន្យាររបស់រដ្ឋសភានេះត្រូវបន្ថែមឱ្យព្រឹទ្ធសភា ឱ្យបានស្មើគ្នានឹងរដ្ឋសភាដែរ ។ ក្នុងការអនុវត្តន៍ជាក់ស្តែង ដើម្បីឱ្យបានស្មើគ្នាកើត គេត្រូវរាប់ចំនួនថ្ងៃដែលរដ្ឋសភាបានប្រើប្រាស់ក្នុងរយៈពេលទាំងនោះ ដើម្បីឱ្យដឹងច្បាស់ សម្រាប់គិតចំនួនថ្ងៃ ដែលព្រឹទ្ធសភាត្រូវមានស្មើគ្នាដែរ ។

ដូច្នេះ " ក្នុងរយៈពេលជាគោលការណ៍ ១ ខែ " រដ្ឋសភាមានសិទ្ធិប្រើប្រាស់ ១៥ ថ្ងៃ ចំណែកឯព្រឹទ្ធសភាក៍ ១៥ថ្ងៃដូចគ្នាដែរ ។ បើរដ្ឋសភាប្រើពេលលើសថែម ឧបមាថា ៣ថ្ងៃ ខាងព្រឹទ្ធសភាក៍មានសិទ្ធិបន្ថែម ៣ថ្ងៃទៀតដូច១គ្នា ។

របៀបគិតនេះត្រូវអនុវត្តដូចគ្នាចំពោះ " រយៈពេលជាគោលការណ៍ ១០ ថ្ងៃ " និង " រយៈពេលជាគោលការណ៍ ២ ថ្ងៃ " ទៅតាមករណីជាយថាហេតុ ។

ជារួមគេត្រូវចែក " រយៈពេលជាគោលការណ៍ " ទីមួយៗជាពីរស្មើគ្នា គឺថាបើ " ១០ ថ្ងៃ " គឺ ៥ ថ្ងៃ សម្រាប់រដ្ឋសភា ហើយនិង ៥ ថ្ងៃទៀត សម្រាប់ព្រឹទ្ធសភា ។ បើ " ២ ថ្ងៃ " គឺ " ១ ថ្ងៃ " សម្រាប់រដ្ឋសភា និង " ១ ថ្ងៃ " ទៀតសម្រាប់ព្រឹទ្ធសភា ។ ហើយបើរដ្ឋសភាបន្ថែមលើសប៉ុន្មានថ្ងៃ ព្រឹទ្ធសភាក៍មានសិទ្ធិបន្ថែមចំនួនថ្ងៃលើសឱ្យស្មើគ្នានឹងរដ្ឋសភាដូចគ្នា ។

គួរកត់សម្គាល់ម្យ៉ាងទៀតថា " រយៈពេលជាគោលការណ៍ " ទាំងអស់នេះ សុទ្ធតែជា " រយៈពេលមិនគត់ " ដែលគេត្រូវអនុវត្តតាមវិធានដែរមានចែងក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៣៦/០០២/២០០០ កបធ.ច ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០០ ។

សម្រេច

មាត្រា ១ : មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី២ ត្រង់ពាក្យថា " បើព្រឹទ្ធសភា ... ពុំបានឱ្យយោបល់សោះ " និងកថាខ័ណ្ឌទី៥ ត្រូវបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរបិទផ្នូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០២

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ជិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា ជាតិ សាសនា ព្រះមហាក្សត្រ

យើងខ្ញុំទាំងអស់គ្នាជាតំណាងរាស្ត្រហត្ថលេខី ដូចមានរាយឈ្មោះខាងក្រោម :

សូមគោរពជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : សំណើសុំបកស្រាយវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ

យោង : - មាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា ១៥ និង ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រតម/០៤៩៨/០៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ១៩៩៨
- មាត្រា ១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ ជស/រកម/១៨៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧
- មាត្រា ១២០ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២
- លិខិតលេខ ០៩/០៣ កបធ.សជណ ចុះថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ២០០៣ របស់ក្រុមប្រឹក្សា-ធម្មនុញ្ញ

តបសេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំមានកិត្តិយសជំរាបជូន ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញជ្រាបថា អាស្រ័យដោយមានតំណាងរាស្ត្រពីគណបក្សហ៊ុនស៊ុនប៊ិច និងគណបក្ស សម រង្ស៊ី មួយចំនួនបានបាត់បង់សមាជិកភាពពីតំណាងរាស្ត្រដោយស្វ័យប្រវត្តិ (មាត្រា ១២០ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ) ហើយដែលក្រុម-ប្រឹក្សាធម្មនុញ្ញបានធ្វើលិខិតបញ្ជាក់ជូនតំណាងរាស្ត្រតាមរយៈគណបក្ស សម រង្ស៊ី ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៣ យើងខ្ញុំសុំឲ្យមានការបកស្រាយបំភ្លឺលើខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៥ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ ថាតើចំពោះមុខស្ថានភាពខាងលើនេះ ការប្រជុំពេញអង្គជា សាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភា នឹងអាចប្រព្រឹត្តទៅបានរហូតដល់សភាថ្មីចូលកាន់តំណែងស្រប តាមរដ្ឋធម្មនុញ្ញដែរឬទេ ?

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធានមេត្តាបកស្រាយបញ្ជាក់តាមការគួរ ។

ឯកឧត្តមប្រធាន ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៣

ហត្ថលេខា

អ្នកតំណាងរាស្ត្រ ១៨រូប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ច្បាប់ប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៦៩/០១៣/២០០៣

ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣

អនុក្រឹត្យសម្រេច

លេខ : ០៥៤/០០៥/២០០៣ អបធ.ច

ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣

ច្បាប់ប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨ /០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ ១ស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៩/០៣ អបធ.សជណ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០០៣
- បានឃើញលិខិតរបស់តំណាងរាស្ត្រចំនួន ១៨រូប ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៣ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយបំភ្លឺលើខ្លឹមសារវាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៩៩ ជំពូកទី៧ នៃរដ្ឋធម្មនុញ្ញ ថាតើចំពោះមុខស្ថានភាពខាងលើនេះ ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?

ក្រោយពីបានស្តាប់ការបកស្រាយរបស់សមាជិកអាយការណ៍

ក្រោយពីបានពិនិត្យក្បាត្រមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា តំណាងរាស្ត្រចំនួន ១៨ នាក់ គឺលើសពីមួយភាគដប់ (**១៣រូប**) នៃចំនួនតំណាងរាស្ត្រ នៅរដ្ឋសភាបានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី**១៤** ខែ **កក្កដា** ឆ្នាំ**២០០៣** ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយវាក្យខ័ណ្ឌទី**១** មាត្រា **៧៦** និង មាត្រា **៩៥ ជំពូកទី៧** នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ**២០០៣** នៅវេលាម៉ោង ១០ ព្រឹក ។ ចំនួន ១៨ នាក់នេះ គ្រប់គ្រាន់តាមបទប្បញ្ញត្តិនៃមាត្រា **១៤១** ថ្មី នៃរដ្ឋធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ និង មាត្រា ១៨ នៃច្បាប់**ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ**ក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/**០៤៩៨/០៦** ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ**១៩៩៨** ផងដែរ ។
- យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយបំភ្លឺនូវខ្លឹមសារវាក្យខ័ណ្ឌទី**១** មាត្រា **៧៦** និង មាត្រា **៩៥** នៃរដ្ឋធម្មនុញ្ញក្នុងបរិបទនៃសំណួរមួយដែលសួរថា ចំពោះមុខស្ថានភាពនេះ តើការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ស្របតាមរដ្ឋធម្មនុញ្ញដែរឬទេ ?
- យល់ឃើញថា ចំពោះសំណួរនេះ បញ្ហានឹងកើតមានឡើងតែក្នុងករណីដែលគ្មានការជ្រើសតាំង អ្នកតំណាងរាស្ត្រថ្មីជំនួសអ្នកតំណាងរាស្ត្រដែលទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាក សមាជិកភាពរដ្ឋសភា ហើយដែលចំនួនតំណាងរាស្ត្ររដ្ឋសភាទាំងអស់ត្រូវចុះថយទៅសល់តិចជាង ១២០ រូបប៉ុណ្ណោះ ។ ក្នុងបរិបទនេះនេះ ក្រុមប្រឹក្សាធម្មនុញ្ញសូមធ្វើការបកស្រាយដូចតទៅ :

១-វាក្យខ័ណ្ឌទី១ មាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ

វាក្យខ័ណ្ឌទី ១ នៃមាត្រា ៧៦ នៃរដ្ឋធម្មនុញ្ញ ចែងថា : រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០ រូប ។ ត្រង់នេះមានន័យថា យ៉ាងតិចណាស់ត្រូវមានសមាជិកជាតំណាងរាស្ត្រចំនួន **១២០រូប** ទើបអាចបង្កើតរដ្ឋសភាក្នុងនីតិកាលនីមួយៗបាន ។ ច្បាប់បោះឆ្នោតមិនអាចកំណត់ចំនួនតំណាងរាស្ត្រតិចជាង ១២០រូប បានទេ ។ វាក្យខ័ណ្ឌទី១ នេះជាលក្ខខ័ណ្ឌចាំបាច់សម្រាប់ការបង្កើតរដ្ឋសភា ប៉ុន្តែមិនមែនសម្រាប់ដំណើរការរបស់រដ្ឋសភាទេ ។

នៅពេលបោះឆ្នោតចប់ហើយ លទ្ធផលត្រូវឱ្យបានតំណាងរាស្ត្រចាប់ពី ១២០រូប ឡើងទៅ ទៅតាមការកំណត់នៃច្បាប់បោះឆ្នោត ទើបអាចបង្កើតរដ្ឋសភានីតិកាលថ្មីមួយបាន ដោយគោរពទៅតាមនីតិវិធីដែល

មានចែងក្នុងមាត្រា ៨២ នៃរដ្ឋធម្មនុញ្ញ និង ប្រការ ៣ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ។ គឺថា រដ្ឋសភាដែលកើតចេញពីការបោះឆ្នោត ត្រូវចូលកាន់តំណែងជាផ្លូវការនៅពេលសម័យប្រជុំដំបូង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ហើយនឹងមានការប្រកាសសម្រេចសុពលភាពឈ្មោះអ្នកតំណាងរាស្ត្របិទផ្សាយក្នុងមន្ទីររដ្ឋសភា និង ជាសាធារណៈ ។ ចាប់ពីពេលនេះមក រដ្ឋសភានឹងមានសុពលភាពរហូតដល់ចប់អាណត្តិរបស់ខ្លួនក្នុងករណីធម្មតា លើកលែងតែក្នុងករណីពិសេសនៃការរំលាយរដ្ឋសភាដោយមកពីមានការទម្លាក់រាជរដ្ឋាភិបាលពីរដងក្នុងរយៈពេល ១២ ខែ ដូចមានចែងក្នុងមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ ។ ហេតុដូច្នេះហើយ ទើបមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញចែងថា " រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ ... " ។

ការវិភាគខាងលើនេះ បង្ហាញឱ្យឃើញថាការប្រែប្រួលនៃចំនួនតំណាងរាស្ត្រ ក្នុងរយៈវេលានៃការប្រព្រឹត្តទៅនៃនីតិកាល មិនអាចធ្វើឱ្យប៉ះពាល់ដល់សុពលភាពរដ្ឋសភាទាំងមូលបានឡើយ ។ ដូច្នេះទោះបីចំនួនតំណាងរាស្ត្រប្រែប្រួលចុះថយក្រោម ១២០រូប យ៉ាងណាក៏ដោយ កុំឱ្យតែទាបជាងកូរ៉ូមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ក៏រដ្ឋសភានៅតែអាចដំណើរការបានដូចធម្មតា ហើយជាពិសេសការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញក៏អាចនឹងប្រព្រឹត្តទៅបានរហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

២-មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញ

មាត្រា ៩៥ នេះ ចែងថា : ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬ ប្រាសចាកសមាជិកភាពដែលកើតមានឡើង ៦ ខែយ៉ាងតិចមុនចប់នីតិកាលត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះតាមលំនាំណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ក្នុងច្បាប់បោះឆ្នោត ។

ក្នុងបរិបទនៃសំណួរបស់អ្នកតំណាងរាស្ត្រទាំង ១៨ នាក់នោះ ការបកស្រាយមាត្រា ៩៥ នេះសំដៅតែទៅលើបញ្ហានៃការចាត់ការជ្រើសតាំងសមាជិកជំនួស និង រយៈពេល ៦ ខែ មុនចប់នីតិកាល ។ ដូច្នេះចំណុចផ្សេងទៀតនៃមាត្រា ៩៥ នឹងមិនត្រូវលើកយកមកពិនិត្យក្នុងទីនេះទេ ។

មានពីរករណីដែលត្រូវវែកញ្ញក គឺ :

<u>ករណីទី១</u> : ម្យើនីតិកាលនៅយូរជាង ៦ ខែ ឬ ស្មើនឹង ៦ ខែ ត្រូវមានការជ្រើសតាំងសមាជិកជំនួសតាមនីតិវិធីដែលមានចែងក្នុងច្បាប់បោះឆ្នោត ឧទាហរណ៍ដូចសព្វថ្ងៃនេះគឺមាត្រា ១២០ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ តាមមាត្រា ១២០ នេះសាមីគណបក្សនយោបាយអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលរបស់សាមីខ្លួននោះ មកជំនួសដោយមិនបាច់បោះឆ្នោតឡើងវិញ ។ សាមីគណបក្ស

ឧយោបាយ ជាចាំបាច់ ត្រូវតែស្នើជ្រើសតាំងសមាជិកថ្មីជំនួស ទើបស្របនឹងមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដែលបានចែងច្បាស់ថា " ត្រូវទាត់ការជ្រើសតាំងជំនួស ... " ។

<u>ករណីទី២</u> : បើនីតិកាលនៅសល់តិចជាង ៦ ខែ ថ្ងៃបើមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមិនបានបញ្ជាក់ក៏ដោយប៉ុន្តែតាមខ្ជីមសារ គឺមិនត្រូវមានការជ្រើសតាំងសមាជិកថ្មីជំនួសទេ ។

- យល់ឃើញថា ទោះក្នុងករណីណាក៏ដោយ លើកលែងតែចំនួនតំណាងរាស្ត្រនៅសល់តិចជាងក្រុមប្រាំពីរភាគដប់នៃសមាជិករដ្ឋសភាទាំងមូល ការប្រជុំពេញអង្គជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភានឹងអាចប្រព្រឹត្តទៅបានជានិច្ច រហូតដល់រដ្ឋសភាថ្មីចូលកាន់តំណែង ដោយឥតខុសនឹងរដ្ឋធម្មនុញ្ញឡើយ ។

សម្រេច

មាត្រា ១ : វាក្យខ័ណ្ឌទី១ មាត្រា ៧៦ និង មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ និង សុពលភាពនៃការប្រជុំពេញអង្គ ជាសាមញ្ញ ឬ ជាវិសាមញ្ញរបស់រដ្ឋសភាត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសម្រេចស្ថាពរ បិទជ្នូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអ៍ណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០០៣

ជ.ត្រូមប្រឹកប្រាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ចិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

ជម្រាបជូន

ឯកឧត្តម ប៊ិន ឈិន ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : សុំបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ

យោង : មាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំជាក្រុមអ្នកតំណាងរាស្ត្រ ដែលមានរាយនាម និង ហត្ថលេខីខាងក្រោម សូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញ មេត្តាបំពេញតួនាទីរបស់ខ្លួន ដូចមានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញស្តីពីការគ្រងរាជសម្បត្តិនៃព្រះមហាក្សត្រ ព្រោះថា ក្រោយពីមានព្រះរាជសាររបស់ព្រះករុណាព្រះមហាក្សត្រ ស្តីពីព្រះរាជ-ហឫទ័យចង់ដាក់រាជសម្បត្តិជាញឹកញាប់នោះមក មានការបកស្រាយខុសៗគ្នា រវាងនាយករដ្ឋមន្ត្រី និងក្រុមអ្នកច្បាប់មួយចំនួនស្តីពីការដាក់រាជសម្បត្តិនេះ ។

ដើម្បីកុំឲ្យទំនាស់ពាក្យសម្តីនេះចេះតែកើតមានបន្តទៅទៀត ហើយដោយសារមានតែស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញតែមួយគត់ ដែលមានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញនោះ យើងខ្ញុំសូមឲ្យក្រុមប្រឹក្សា-ធម្មនុញ្ញមេត្តាធ្វើការបកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០០៤

ហត្ថលេខា

អ្នកតំណាងរាស្ត្រ ១៦រូប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៨៣/០០៦/២០០៤

ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤

សេចក្តីសំរេច

លេខ : ០៦១ /០០៣/២០០៤ កបធ.ច

ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤

ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិត ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ របស់ក្រុមតំណាងរាស្ត្រចំនួន ១៦ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ

-បានឃើញឯកសារទទួលពីរដ្ឋសភាទាក់ទងនឹងការពិភាក្សារបស់សភាធម្មនុញ្ញ លើមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ

ក្រោយពីបានស្តាប់របាយការណ៍សមាជិការយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវភាមច្បាប់រួយ

-យល់ឃើញថា តំណាងរាស្ត្រ ១៦ រូប គឺលើសពីមួយភាគដប់នៃចំនួនតំណាងរាស្ត្រនៅរដ្ឋសភា បានធ្វើលិខិតមួយមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៤ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៧ នៃរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ វេលាម៉ោង ១៤ :២៣ នាទី ។ ចំនួន ១៦ រូប នេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ជងដែរ ។

-យល់ឃើញថា លិខិតតំណាងរាស្ត្រ សុំឱ្យបកស្រាយមាត្រា ៣ នៃរដ្ឋធម្មនុញ្ញ ដោយដាក់ជាបញ្ហា ក្នុងករណីព្រះមហាក្សត្រដាក់រាជសម្បត្តិ " *ក្រោយពីមានព្រះរាជសារបស់ព្រះមហាក្សត្រ ស្តីពីព្រះរាជហប្ចទ៍យចង់ដាក់រាជសម្បត្តិជាញឹកញាប់នោះមក មានការបកស្រាយខុសៗ ត្នា រវាងនាយករដ្ឋមន្ត្រី និង ក្រុមអ្នកច្បាប់មួយចំនួនស្តីពីការដាក់រាជសម្បត្តិនេះ ។* " ពាក់ព័ន្ធស់ខាន់លើវាក្យខ័ណ្ឌទី ២ នៃមាត្រា ៣ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " *ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត* " ។ ត្រង់នេះ មានន័យថា ព្រះមហាក្សត្រ ទ្រង់ត្រងរាជសម្បត្តិ និងទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។ ព្រះរាជតួនាទី ក្នុងការត្រងរាជសម្បត្តិ ជាប់ជាមួយព្រះរាជតួនាទី ជាព្រះប្រមុខរដ្ឋ ដោយមិនអាចផ្តាច់ចេញពីគ្នាបានទេ ។ ដូច្នេះ ព្រះមហាក្សត្រទ្រង់ត្រងរាជសម្បត្តិ និង ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត គឺរជ្ជកាលរបស់ព្រះមហាក្សត្រត្រូវបានកំណត់ចាប់ពីពេលដែលព្រះអង្គឡើងត្រងរាជសម្បត្តិ រហូតដល់ពេលព្រះអង្គចូលទិវង្គត ។

-យល់ឃើញថា សភាធម្មនុញ្ញបានអនុម័តមាត្រា ១២ មាត្រា ១៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានការជ្រើសតាំងព្រះមហាក្សត្រថ្មី ក្នុងករណីព្រះមហាក្សត្រ សោយទិវង្គតតែប៉ុណ្ណោះ ។

-យល់ឃើញថា ការដាក់រាជសម្បត្តិ មិនមានចែងក្នុងរដ្ឋធម្មនុញ្ញទេ ។

សំរេច

មាត្រា ១.- មាត្រា ៣ នៃរដ្ឋធម្មនុញ្ញ ត្រូវបកស្រាយដូចមានបញ្ជាក់ក្នុងមូលបទខាងលើ ។

មាត្រា ២.- សេចក្តីស់រេចនេះ ច្ចើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីស់រេចស្ថាពរ បិទផ្ទូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៤

ជ.ក្នុងម្រឹកប្រាកម្មនុញ្ញ

ប្រកាន

ចិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ : ៩៦០ រ.ស

គោរពជូន

ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

ភ្ជាប់ជូន : សំណើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៨ និងមាត្រា ៨៣ នៃរដ្ឋធម្មនុញ្ញ

យោង : លិខិតលេខ ០៦៥/០៩ ស.ន.ក.ជ របស់គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូម **ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** ជ្រាបថា : ខ្ញុំបាទទទួលសំណើពី **គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា** សុំខ្ញុំស្នើមក ក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៨ និងមាត្រា ៨៣ នៃរដ្ឋធម្មនុញ្ញ ដើម្បីជម្រះមន្ទិលនៅក្នុងស្ថាប័នពុទ្ធសាសនា ដើម្បីបានផ្សព្វផ្សាយនៅក្នុងអនុសំវច្ឆរៈមហាសន្និបាត មន្ត្រីសង្ឃទូទាំងប្រទេសលើកទី១៨ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០៩ ខាងមុខនេះ ។

អាស្រ័យហេតុនេះសូម **ឯកឧត្តម** ជួយពិនិត្យ និងបកស្រាយជូនដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តម** ទទួលនូវការស្រលាញ់រាប់អានដ៏ស្មោះអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៩

ប្រធានរដ្ឋសភា

ហត្ថលេខា និង ត្រា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៦៩/០០៧/២០០៩

ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩

សេចក្តីសម្រេច

លេខ : ១០៧/០០៣/២០០៩ កបច.ច

ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ដោយយោងតាមសំណើលេខ ០៦៥/០៩ ស.ន.ក.ជ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៩ របស់គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ។ដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០៩ វេលាម៉ោង ១៤ និង ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកអចិន្ត្រៃយ៍

ក្រោយពីបានពិគារក្សាគ្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា លិខិតលេខ ៩៦០ រ.ស. ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ

បានច្បើឡើង ស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន

- យល់ឃើញថា មាត្រា ៤ នៃរដ្ឋធម្មនុញ្ញចែងថា " *ចារិតនាមៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ* " ។ ចារិតនៃព្រះរាជាណាចក្រកម្ពុជា ជារូបមន្តសរុបមួយតែប៉ុណ្ណោះ បញ្ជាក់អំពីនិសដៅ កំណត់សកម្មភាពទាំងឡាយរបស់បុគ្គល រួមមានរូបវន្តបុគ្គល និង នីតិបុគ្គល ដែលរស់នៅ និង មានអាសយដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បុគ្គលទាំងនោះត្រូវយកចិត្តទុកដាក់ចំពោះ ជាតិ សាសនា និង ព្រះមហាក្សត្រ។ ចំពោះការប្រតិបត្តិខាងផ្នូវសាសនា មានកំណត់ក្នុងបទប្បញ្ញត្តិនៃមាត្រាផ្សេងៗទៀតនៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា មាត្រា ៨៣ ចែងអំពីសិទ្ធិខាងជំនឿរបស់ប្រជាពលរដ្ឋខ្មែរ ។

• វាក្យខ័ណ្ឌទី១ ចែងថា " *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ* " ។ វាក្យខ័ណ្ឌនេះ មានន័យថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសេរីភាពបរិបូរណ៍ក្នុងការជឿ ឬ ការប្រតិបត្តិជំនឿ និង សាសនា តាមសតិសម្បជញ្ញៈរបស់ខ្លួន គ្រប់ពេលវេលា និង គ្រប់កាលៈទេសៈ ។

• វាក្យខ័ណ្ឌទី២ ចែងថា " *សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្នូវសាសនា ត្រូវបានរដ្ឋធានាក្នុងលំក្រខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ* " ។ វាក្យខ័ណ្ឌទី២ នេះ មានន័យថា រដ្ឋត្រូវធានាឱ្យសេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្នូវសាសនាដំណើរការ បានជាធម្មតា ប៉ុន្តែសេរីភាព និង ការប្រព្រឹត្តនេះ ក៏មានព្រំដែនកំណត់ដែរ ។ ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្នូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់ជំនឿ ឬ សាសនាដទៃ ព្រមទាំងត្រូវគោរពសិទ្ធិសេរីភាព និង ការប្រតិបត្តិខាងផ្នូវជំនឿ ឬ សាសនារបស់អ្នកដទៃទៀតផង ។ ម្យ៉ាងវិញទៀត ការប្រើសេរីភាព និង ការប្រតិបត្តិខាងផ្នូវជំនឿ និង សាសនា មិនត្រូវឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈជាដាច់ខាត ។

• វាក្យខ័ណ្ឌទី៣ ចែងថា " *ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ* " ។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ដោយវាក្យខ័ណ្ឌទី៣ នៃមាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញបានចែងយ៉ាងដូច្នេះហើយ ទើបបទប្បញ្ញត្តិនៃមាត្រាដទៃផ្សេងទៀតនៃរដ្ឋធម្មនុញ្ញ និង អត្ថបទច្បាប់ ព្រមទាំងអត្ថបទក្រមច្បាប់ កំណត់ស្របតាមស្មារតីខាងលើនេះ

- យល់ឃើញថា ដោយសារ *ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ* ទើប ÷

• នៅក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋបានផ្តល់ការជួយឧបត្ថម្ភ គាំទ្រ និង លើកតម្កើងវិស័យព្រះពុទ្ធសាសនាឱ្យបានរីកចម្រើន ថ្កុំថ្កើង រុងរឿង ស័ក្តិសមជាសាសនារបស់រដ្ឋ ។ ហេតុនេះ ទើបនៅក្នុងព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រកម្ពុជាគ្រងរាជសម្បត្តិ ក៏មានវត្តមានរបស់សម្តេចព្រះសង្ឃរាជទាំងពីរគណៈ តាមព្រះរាជប្បវេណីដែរ។ មិនតែប៉ុណ្ណោះ ថ្ងៃបុណ្យធំៗក្នុងព្រះពុទ្ធសាសនា ជាអាទិ៍ថ្ងៃបុណ្យមាឃបូជា វិសាខបូជា ត្រូវបានចាត់ទុកជាថ្ងៃបុណ្យជាតិ

• សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ត្រូវបានឱ្យគង់ជាសមាជិកនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចមានចែងក្នុងមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ម្យ៉ាងទៀត សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះអង្គត្រូវបានគង់ជាអធិបតីក្នុងពិធីធ្វើសច្ចាប្រណិធានធំៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទាំងឡាយនៃរដ្ឋធម្មនុញ្ញ ហើយនៅក្នុងភ្លេងជាតិនគររាជទៀតសោត វគ្គទី៣ ចែងថា " *ត្រប់វត្ត អារាម ព្ធតែសូរស័ព្ធធមិ សូត្រដោយអំណរ រំព្ធកគុណពុទ្ធសាសនា ចូរយើងជាអ្នក ជ្បឹជាក់ស្មោះស្ម័ត្រ តាមបែបដូនតា គង់តែទៀតា និងជួយជ្រោមជ្រែងផ្គត់ផ្គង់ ប្រយោជន៍ឱ្យ ដល់ប្រទេសខ្មែរ ជាមហានគរ ។* "

• វាក្យខ័ណ្ឌទី៣ មាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញ បានចែងថា " *រដ្ឋជួយជ្យព្ធជ្យាយ និង លើកតម្កើងសាលាបាលី និង ពុទ្ធិកសិក្សា* "

• ហើយប្រជាពលរដ្ឋខ្មែរភាគច្រើនលើសពាក្យនៅព្រះរាជាណាចក្រកម្ពុជា បានលើក ទង់ជាតិ ទង់ព្រះពុទ្ធសាសនា និង ទង់ព្រះមហាក្សត្រ នៅទន្ទីមត្នា ព្រមទាំងមានសតិសម្បជញ្ញៈជ្បឹជាក់ថា អាណាចក្រ និង ពុទ្ធចក្រ ត្រូវដើរទន្ទីមត្នា ទើបជាតិបានថ្ពុំថ្កើង រុងរឿង ។

សម្រេច

មាត្រា ១. មាត្រា ៤ និង មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២. សេចក្តីសម្រេចនេះ ត្រឹនៅរាជធានិភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ មិនផ្ទូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានិភ្នំពេញ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៩

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា ជាតិ សាសនា ព្រះមហាក្សត្រ

យើងខ្ញុំទាំងអស់គ្នាជាតំណាងរាស្ត្រ

គោរពជូន

ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

តាមរយៈ : **សម្តេចអគ្គមហាពញ្ញាចក្រី ប្រធានរដ្ឋសភា**

កម្មវត្ថុ : សំណើសុំបកស្រាយចំណុចទី៤ នៃមាត្រា ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ

យោង : - មាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ

សេចក្តីដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមឲ្យក្រុមប្រឹក្សាធម្មនុញ្ញ មេត្តាបកស្រាយអំពីសុពលភាព ចំណុចទី៤ នៃមាត្រា ១៥៧ ថ្មី ជំពូកទី១៦ អំពីអន្តរប្បញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ។

សូមឯកឧត្តមប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១០

តំណាងក្រុមតំណាងរាស្ត្រហត្ថលេខី

ហត្ថលេខា

សុិក ប៊ុនហុក

លេខ : ៥៨៧ រស

ជូនយើញ និង បញ្ជូនមក

ឯកឧត្តម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ដើម្បីជួយបកស្រាយ តាមការគួរ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០

ប្រធានរដ្ឋសភា

ហត្ថលេខា និង ត្រា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៧៧/០០៨/២០១០

ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០

សេចក្តីសម្រេច

លេខ : ១១២/០០៥/២០១០ កបធ.ច

ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិត ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០១០ របស់ឯកឧត្តម និង លោកជំទាវ តំណាងរាស្ត្រ ចំនួន ២២រូប ដែលមានឯកឧត្តម **សុិក ចុិនហុក** ជាតំណាង ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយអំពីសុពលភាព នៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។ អត្តលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតនេះ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១០ វេលាម៉ោង ១៦ និង ១៥នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកបាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា លិខិតរបស់ឯកឧត្តម និង លោកជំទាវ តំណាងរាស្ត្រចំនួន ២២រូប ដែលបានស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ អំពីសុពលភាព នៃចំណុចទី៤ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ បានធ្វើឡើងស្របតាមមាត្រា ១៣៦ថ្មី មាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ថ្មី មាត្រា ១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលសំណើនេះមកពិនិត្យបាន

- យល់ឃើញថា សមាជរដ្ឋសភា និង ព្រឹទ្ធសភា មានចែងក្នុងមាត្រា ១១៦ថ្មី និង មាត្រា ១១៧ថ្មី ជំពូកទី៩ថ្មី នៃរដ្ឋធម្មនុញ្ញ ដូចតទៅ ៖

មាត្រា ១១៦_ថ្មី *ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ។*

មាត្រា ១១៧_ថ្មី *បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ដូចមានចែងក្នុងមាត្រា ១១៦ថ្មី ខាងលើ ព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជ និងត្រូវកំណត់ក្នុងច្បាប់មួយ ។*

- យល់ឃើញថា មាត្រា ១៥៧ថ្មី ជំពូកទី១៦ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា ៖

មាត្រា ១៥៧_ថ្មី *នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។*

សម្រាប់នីតិកាលទី១ នៃព្រឹទ្ធសភា :

-សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។

-ព្រះមហាក្សត្រ ទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីរូប ព្រមទាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ។

-សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិកនៃគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ។

-កិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

តាមខ្លឹមសារនៃមាត្រា ១៥៧ថ្មីនេះ ថិរវេលាសុពលភាពនៃចំណុចទី៤ វាក្យខណ្ឌទី២ នៃមាត្រាខាងលើ មានមិនលើសពីថិរវេលានៃនីតិកាលទី១របស់ព្រឹទ្ធសភាទេ មានន័យថា កិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ត្រូវដឹកនាំដោយប្រធានរដ្ឋសភា និង ប្រធានព្រឹទ្ធសភា ក្នុងឋានៈជាសហប្រធានបានតែនៅក្នុងនីតិកាលទី១នៃព្រឹទ្ធសភាតែប៉ុណ្ណោះ ។

ចំពោះកិច្ចប្រជុំជាសមាជរដ្ឋសភា និង ព្រឹទ្ធសភា ក្នុងនីតិកាលជាបន្តបន្ទាប់ទៀតរបស់ព្រឹទ្ធសភា និងត្រូវរៀបចំ និង ប្រព្រឹត្តទៅតាមច្បាប់មួយ ដូចមានចែងក្នុងមាត្រា ១១៧ថ្មី នៃរដ្ឋធម្មនុញ្ញ ។

សម្រេច

មាត្រា ១.- បទប្បញ្ញត្តិនៃចំណុចទី៤ វាក្យខណ្ឌទី២ មាត្រា ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

ប.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

លេខ : ១០៨/០៧១៥/ពស/ន.វ

សូមជម្រាបជូន

ឯកឧត្តម ឯក សំអុល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : សំណើសុំបកស្រាយមាត្រា ៩១ ថ្មី នៃរដ្ឋធម្មនុញ្ញ

យោង : - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាកិច្ចប្រជុំថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៥

តបតាមសេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា ដើម្បីឲ្យមានសង្គតិភាពជាមួយរដ្ឋសភាក្នុងការគណនាប្រាក់សោធននិវត្តន៍ ព្រឹទ្ធសភាស្នើធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា ។ ប៉ុន្តែមាត្រា ៩១ ថ្មី នៃរដ្ឋធម្មនុញ្ញពុំបានចែងកំណត់ឲ្យសមាជិកព្រឹទ្ធសភា មានសិទ្ធិក្នុងការធ្វើវិសោធនកម្មច្បាប់ ដូចតំណាងរាស្ត្រនោះទេ ។ ហេតុនេះដើម្បីឲ្យព្រឹទ្ធសភា មានលទ្ធភាពដំណើរការងារនេះឲ្យបានសមស្រប សូមក្រុមប្រឹក្សាធម្មនុញ្ញមេត្តាបកស្រាយមាត្រា ៩១ ថ្មី នៃរដ្ឋធម្មនុញ្ញ អំពីសិទ្ធិរបស់ព្រឹទ្ធសភាក្នុងការស្នើធ្វើវិសោធនកម្មច្បាប់ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** ជ្រាប និងចាត់ចែងនីតិវិធី តាមការគួរ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៥

ប្រធានព្រឹទ្ធសភា

ហត្ថលេខា និង ត្រា

សម្តេចតេជោសេនាតេជ្ជ សាយ ឈុំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ២៥៦/០០៣/២០១៥

ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥

សេចក្តីសម្រេច

លេខ : ១៥៥/០០៣/២០១៥ សប្រធ.ច

ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកអ/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/.កម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ១០៨/០៧១៥/ពស/ន៧ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា សើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ វេលាម៉ោង ១៥ និង ៥១ នាទី។

ក្រោយពីបានស្តាប់រាយការណ៍របស់សមាជិកាអាយការណ៍

ក្រោយពីបានពិភាក្សាយុត្តិធម្មដោយប្រុងប្រយ័ត្ន

- បានឃើញថា លិខិតលេខ ១០៨/០៧១៥/ពស/ន៧ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៥ របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដែលស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឡើងស្របនឹងវាក្យខ័ណ្ឌទី១ មាត្រា១៣៦ថ្មី

ហាត្រា១៤១ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា១៥ថ្មី មាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំបកស្រាយមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នេះមកពិនិត្យបាន

យល់ឃើញថា មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាន២វាក្យខ័ណ្ឌ ដែលចែងថា :

"សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។ គំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះរំលំដៅបង្ខយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។"

វាក្យខ័ណ្ឌទី១នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ បានកំណត់អំពីសិទ្ធិរបស់សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី ក្នុងការផ្តួចផ្តើមគំនិតធ្វើច្បាប់។ វាក្យខ័ណ្ឌទី១នេះ មានន័យថា :

- សមាជិកព្រឹទ្ធសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។
- សមាជិករដ្ឋសភា ១រូប ឬច្រើនរូប មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។
- សមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភា អានសិទ្ធិរួមគ្នាផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ ឬអានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។

ការផ្តួចផ្តើមគំនិតធ្វើច្បាប់ និងការផ្តួចផ្តើមគំនិតធ្វើច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន ពីសំណាក់សមាជិកព្រឹទ្ធសភា ឬពីសមាជិករដ្ឋសភា ឬពីសមាជិកព្រឹទ្ធសភានិងសមាជិករដ្ឋសភារួមគ្នាជាបាត្តលេខិ ត្រូវធ្វើជាសេចក្តីស្នើច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់។

- នាយករដ្ឋមន្ត្រីមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ និងមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ណាមួយដែលកំពុងនៅជាធរមាន។ នាយករដ្ឋមន្ត្រីត្រូវធ្វើជាសេចក្តីព្រាងច្បាប់ និងត្រូវបំពេញទម្រង់បែបបទទៅតាមនីតិវិធីនៃការធ្វើច្បាប់។

វាក្យខ័ណ្ឌទី២នៃមាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញ មានន័យថា ជាការបញ្ជាក់បន្ថែមទៅលើខ្លឹមសារនៃវាក្យខ័ណ្ឌទី១ ដោយហាមគំណាងរាស្ត្រមិនឱ្យធ្វើវិសោធនកម្មច្បាប់ដែលសំដៅបង្ខយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។

- យល់ឃើញថា តាមការបកស្រាយខាងលើនេះ សមាជិកព្រឹទ្ធសភាមានសិទ្ធិស្នើធ្វើវិសោធនកម្ម ច្បាប់បាន។

សម្រេច

មាត្រា ១.- មាត្រា៩១ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សាយភ្លាម ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥

ប. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៩/០១ ខសរ

សូមជូន

ឯកឧត្តម ប៊ិន ឈិន

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

<u>កម្មវត្ថុ</u> : សំណើសុំបកស្រាយមាត្រា ១២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់

<u>យោង</u> : មាត្រា ១៣៦ ថ្មី និង មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

តបតាមកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំសូមជម្រាបឯកឧត្តមប្រធានជ្រាបថា ក្នុងកិច្ចប្រជុំកុបសែល ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០០១ នៅសណ្ឋាគារជូលីណា មានការបកស្រាយខុសគ្នារវាងតំណាង គ.ជ.ប និង សមាជិកនៃអង្គប្រជុំខ្លះលើមាត្រា ១២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលត្រូវបានចែងថា " ក្នុងករណីបណ្តឹងជំទាស់ត្រូវបានយល់ព្រម គណៈកម្មការឃុំ-សង្កាត់រៀបចំបោះឆ្នោតត្រូវបដិសេធការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានការប្តឹងជំទាស់នោះ រួចហើយលុបបញ្ជីបេក្ខជននោះចេញ ព្រមទាំងដកហូត និង បដិសេធលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជននោះ " ។ ការបកស្រាយខុសគ្នានោះមានដូចតទៅ :

១-ភាគីខាងតំណាង គ.ជ.ប

បានបកស្រាយថា បើកាលណា គ.ជ.ប យល់ព្រមតាមបណ្តឹងជំទាស់លើករណីបេក្ខជននីមួយៗដែលជាសេចក្តីសម្រេចចុងក្រោយ នោះគយ/សប ត្រូវបដិសេធការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ រួចហើយលុបបញ្ជីបេក្ខជនចេញតែម្តង ដោយមិនអនុញ្ញាតឲ្យគណបក្សនយោបាយរកបេក្ខជនមានល័ក្ខខ័ណ្ឌត្រឹមត្រូវមកជំនួសបេក្ខជនដែលបដិសេធនោះទេ គឺត្រីមួយស្មុយ ស្មុយមួយត្រក ។

២-ភាគីខាងសមាជិកនៃអង្គប្រជុំខ្លះ

បានបកស្រាយថា បើកាលណា គ.ជ.ប បានយល់ព្រមតាមបណ្តឹងជំទាស់លើករណីបេក្ខជននីមួយៗ ដែលជាសេចក្តីសម្រេចចុងក្រោយ នោះគណបក្សនយោបាយអាចរកបេក្ខជនល្អមកជំនួសបាន គឺត្រីមួយស្មុយ អាចរកត្រីមួយទៀតល្អមកជំនួសវិញបាន ។ លើកលែងតែគណបក្សនយោបាយណាដែលមិនព្រមរកបេក្ខជន ឬ ក៏រកបេក្ខជនដែលមានល័ក្ខខ័ណ្ឌត្រឹមត្រូវមិនទាន់ពេលកំណត់ដើម្បីយកមកជំនួសឲ្យបានគ្រប់ចំនួននៃក្រុមប្រឹក្សាឃុំ-សង្កាត់នីមួយៗ ដែលកំណត់ដោយក្រសួងមហាផ្ទៃ ទើបគយ-សប ត្រូវបដិសេធការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ រួចហើយលុបបញ្ជីបេក្ខជននោះចេញតែម្តង ។ ពាក្យថា ការចុះបញ្ជីបេក្ខជន និង ពាក្យថាបញ្ជីបេក្ខជន មានន័យខុសគ្នា ។ បើកាលណា គ្មានករណីជំនួស និង គ្មានឧទ្ធរណ៍ដោយបើកសវនាការតែមួយលើកដូចនេះ គឺជុំយពីគោល

ការណ៍នៃលទ្ធិប្រជាធិបតេយ្យ ។

តាមការយល់ឃើញរបស់យើងខ្ញុំ បើបេក្ខជនមួយមានលក្ខខ័ណ្ឌមិនត្រឹមត្រូវ ហើយបដិសេធទាំងបេក្ខជនមានលក្ខខ័ណ្ឌត្រឹមត្រូវទាំងអស់តែម្តង នឹងធ្វើឲ្យច្បាប់នេះមានអធម្មនុញ្ញភាព គឺផ្ទុយនឹងជំពូកទី៣ មាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មិនស្របតាមមាត្រា ១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ព្រមទាំងផ្ទុយពីគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យផងដែរ ។

ដូច្នេះសូមក្រុមប្រឹក្សាធម្មនុញ្ញ មេត្តាបកស្រាយបំភ្លឺនូវខ្លឹមសារនៃមាត្រា ១២១ ដូចបានលើកឡើងខាងលើនេះតាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រ អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០០១

ហត្ថលេខា

អ្នកតំណាងរាស្ត្រ ១៥រូប

ចម្លងជូន

- ឧទ្ធរណ៍យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ឧទ្ធរណ៍យនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ក្រសួងមហាផ្ទៃ
- សមាជិកកុបសែល

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៤៤/០០៧/២០០១

ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០០១

សេចក្តីសម្រេច

លេខ : ០៤៥/០០៧/២០០១ កបធ.ច

ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់
- បានឃើញបណ្តឹងរបស់អ្នកតំណាងរាស្ត្រ ១៥រូប ស្នើសុំបកស្រាយមាត្រា ១២១ នៃព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃ ទី ០២ ខែ តុលា ឆ្នាំ២០០១

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិគារក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា ពាក្យបណ្តឹងលេខ ១៩/០១ ខរស ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០០១ របស់អ្នកតំណាងរាស្ត្រទាំង ១៥រូប មានមូលហេតុច្បាស់លាស់ និង អនុលោមតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃ រដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលពាក្យបណ្តឹងនោះមកពិភាក្សាបាន ។

- យល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នេះ ស្របនឹងរដ្ឋធម្មនុញ្ញរួចហើយ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤២/០០៤/២០០១ កបធ.ច ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០០១ ។
- យល់ឃើញថា " **បញ្ជីបេក្ខជនដំបូង** " (មាត្រា ១១៦ និង មាត្រា ១១៧ នៃព្រះរាជក្រមលេខ នស/រកម/ ០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់) គឺជាបញ្ជីបេក្ខជនដែលមិនទាន់ទៅជា " **បញ្ជីបេក្ខជនផ្លូវការ** " ដូច្នេះក្នុងរយៈពេលដែលមិនទាន់ទៅជា " **បញ្ជីបេក្ខជនផ្លូវការ** " ការបំពេញលក្ខខណ្ឌដែលខ្វះខាត ត្រូវតែអាចធ្វើទៅបាន។ ករណីនៃមាត្រា ១២១ នៃព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ គឺស្ថិតនៅក្នុងតំណាក់កាលនៃ " **បញ្ជីបេក្ខជនដំបូង** " នៅឡើយ។ គោលការណ៍នៃការកែតម្រូវចំណុចខ្វះខាត ឬ ការផ្ទាស់ប្តូរបេក្ខជន ត្រូវតែអនុវត្តបានចំពោះមាត្រា ១២១ ។ ម៉្យាងទៀត ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នេះក៏ពុំមានបទបញ្ញត្តិត្រង់ណារហាមមិនឱ្យធ្វើការបំពេញបន្ថែម ឬ ផ្ទាស់ប្តូរបេក្ខជនដែលត្រូវប្រជាពលរដ្ឋប្តឹងជំទាស់នោះដែរ ។

សម្រេច

មាត្រា ១ : យោងតាមមូលបទខាងលើ ក្នុងត្រង់ដំណាក់កាលនៃ " បញ្ជីបេក្ខជនដំបូង " ការកែតម្រូវចំណុចខ្វះខាត ឬ ការផ្ទាស់ប្តូរបេក្ខជនដែលប្រជាពលរដ្ឋបានប្តឹងជំទាស់ ត្រូវធ្វើបានជានិច្ច គឺរួមទាំងដំណាក់កាលនៃករណីដែលមានចែងក្នុងមាត្រា ១២១ នៃព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុម-ប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ប៊ិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ : ៥៩៧ រ.ស

សូមជម្រាបជូន

ឯកឧត្តម ជិន ឈិន

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាជ្រាប ។

ភ្ជាប់ជូន : សំណើសុំបកស្រាយមាត្រា ៣៨ នៃព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ អំពីស្ថាប័នដែលមានសមត្ថកិច្ចផ្តន្ទាទោស ។

យោង : - តាមលិខិតរបស់លោក **គល់ បញ្ញា** លេខ ៣២៧/០២ គ.ប.ស.យ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០២ ។

- មាត្រា ១៨១ ថ្មី និង ជំពូកទី១២ ថ្មី អំពីក្រុមប្រឹក្សាធម្មនុញ្ញនៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តម ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ

តាមកម្មវត្ថុយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម មេត្តាជ្រាបថា រដ្ឋសភាបានទទួលនូវលិខិតរបស់លោក **គល់ បញ្ញា** នាយកប្រតិបត្តិ នៃគណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ស្តីពីសំណើសុំប្តឹងក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីសុំបកស្រាយជំពូកទី៩ ស្តីពីទោសប្បញ្ញត្តិ ត្រង់មាត្រា ៣៨ នៃព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។

ដោយយោងទៅតាមមាត្រា ១៨១ ថ្មី ត្រង់ជំពូកទី១២ ថ្មី ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ របស់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សូមឯកឧត្តម មេត្តាបកស្រាយបំភ្លឺ ស្តីពីច្បាប់គណបក្សនយោបាយ អំពីស្ថាប័នដែលមានសមត្ថកិច្ចផ្តន្ទាទោស តាមការគួរ ។

សូមជូនភ្ជាប់មកជាមួយនូវលិខិតរបស់លោក គល់ បញ្ញា ចំនួន ១ ច្បាប់ ។

សូមឯកឧត្តមមេត្តាទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០១

ប្រធានរដ្ឋសភា

ព្រះហស្តលេខា

នរោត្តម រណឫទ្ធិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ : ៦១៦ រ.ស

សូមជម្រាបជូន

ឯកឧត្តម ចិន ឈិន

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាជ្រាប ៖

កម្មវត្ថុ : សំណើសុំបកស្រាយមាត្រា ៣៨ នៃព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ អំពីស្ថាប័នដែលមានសមត្ថកិច្ចផ្តន្ទាទោស ។

យោង : - តាមលិខិតរបស់លោក **គល់ បញ្ញា** លេខ ៣២៧/០២ គ.ប.ស.យ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០២ ។

- មាត្រា ១៨១ ថ្មី និង ជំពូកទី១២ ថ្មី អំពីក្រុមប្រឹក្សាធម្មនុញ្ញនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

ឯកឧត្តម ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ

តាមកម្មវត្ថុយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា រដ្ឋសភាបានទទួលនូវលិខិតរបស់លោក **គល់ បញ្ញា** នាយកប្រតិបត្តិនៃគណៈកម្មាធិការ ដើម្បីបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ស្តីពីសំណើសុំប្តឹងក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីសុំបកស្រាយជំពូកទី៩ ស្តីពីទោសប្បញ្ញត្តិ ត្រង់មាត្រា ៣៨ នៃព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។

ដោយយោងទៅតាមមាត្រា ១៨១ ថ្មី ត្រង់ជំពូកទី១២ ថ្មី ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញរបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សូមឯកឧត្តមមេត្តាបកស្រាយបំភ្លឺ ស្តីពីច្បាប់គណបក្សនយោបាយ អំពីស្ថាប័នដែលមានសមត្ថកិច្ចផ្តន្ទាទោសតាមការគួរ ។

សូមជូនភ្ជាប់មកជាមួយនូវលិខិតរបស់លោក **គល់ បញ្ញា** ចំនួន ១ ច្បាប់ ។

សូមឯកឧត្តម មេត្តាទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០២

ប្រធានរដ្ឋសភាស្តីទី

ហត្ថលេខា

ហេង សំរិន

ព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាធម្មនុញ្ញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៤៩/០០៣/២០០២

ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០២

សេចក្តីសម្រេច

លេខ : ០៤៦/០០១/២០០២ កបធ.ច

ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញពាក្យបណ្តឹងលេខ ៥៩៧ រស ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០១ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា កែប្រែដោយពាក្យបណ្តឹងលេខ ៦១៦ រស ចុះថ្ងៃទី ២៦ ខែ [illegible]ដា ឆ្នាំ២០០២ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី (ដោយខុសឆ្គងពីឆ្នាំ២០០១ មក ២០០២ វិញ) សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៣៨ ជំពូកទី៩ នៃច្បាប់ស្តីពីគណបក្សនយោបាយ អំពី ស្ថាប័នដែលមានសមត្ថកិច្ចផ្តន្ទាទោស តាមសំណូមពររបស់លោក គល់ បញ្ញា នាយកប្រតិបត្តិគណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី [illegible]ង យុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល COMFREL) តាមពាក្យបណ្តឹងលេខ ៣២៧/០២ គ.ប.ស.យ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០២ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០២ និង ពាក្យបណ្តឹងកែប្រែបានទទួលនៅថ្ងៃ ទី ៣០ ខែ កក្កដា ឆ្នាំ២០០២ ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា តាមមាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញពាក្យបណ្តឹងរបស់សម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាកែប្រែដោយពាក្យបណ្តឹងរបស់

សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ខាងលើអាចទទួលយកមកពិចារណាបាន ។

- យល់ឃើញថា តាមមាត្រា ១២៨ ថ្មី វាក្យខ័ណ្ឌទី៣ និង ទី៤ នៃរដ្ឋធម្មនុញ្ញ : " អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។ អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និង សាលាជម្រះក្តីគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ " ។
- យល់ឃើញថា :

  " មាត្រា ១២៩ ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ ចែងថា : " មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី " ។

  " មាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា : " គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬ នីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ " ។

  " មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា : " មានតែអង្គការអយ្យការទេដែលមានសិទ្ធធ្វើបណ្តឹងអាជ្ញា " ។
- យល់ឃើញថា ការពិន័យដែលអាចធ្វើទៅបានក្រៅពីតុលាការ មានតែការពិន័យដែលមានលក្ខណៈជាពិន័យអន្តរការណ៍
- យល់ឃើញថា ការពិន័យអន្តរការណ៍ អាចធ្វើទៅបាន លុះត្រាតែមានចែងច្បាស់ក្នុងច្បាប់ ព្រមទាំងចែងច្បាស់ពីអាជ្ញាធររដ្ឋបាលដែលត្រូវអនុវត្ត ឬ ច្បាប់បានអនុញ្ញាតឱ្យចែងក្នុងលិខិតបទដ្ឋានផ្សេងទៀតដូចជាអនុក្រឹត្យ ប្រកាស ។ ល ។ ក្រៅពីករណីនេះ អាជ្ញាធររដ្ឋបាលសាធារណៈពាក់ព័ន្ធមានភារកិច្ចត្រឹមកសាងសំណុំរឿងបញ្ជូនទៅតុលាការតែប៉ុណ្ណោះ ។
- យល់ឃើញថា បទបញ្ញត្តិក្នុងមាត្រា ៣៨ នេះមិនមានចែងអំពីសមត្ថកិច្ចណាមួយច្បាស់ ឬ ក៏អនុញ្ញាតឱ្យចែងក្នុងលិខិតបទដ្ឋានផ្សេងទៀតដែរ ។ ដូច្នេះក្រសួងពាក់ព័ន្ធមិនមានសមត្ថកិច្ចលើបទល្មើសនេះទេ ។
- យល់ឃើញថា ការផ្តន្ទាទោសផ្ទាកសកម្មភាពគណបក្សនយោបាយជាបណ្ណោះអាសន្នដែលមានចែងក្នុងមាត្រា ៣៨ ក៏ជាសមត្ថកិច្ចរបស់តុលាការដែរ ។

សម្រេច

មាត្រា ១ : យោងតាមមូលបទខាងលើ មានតែតុលាការទេ ដែលមានសមត្ថកិច្ចផ្តន្ទាទោស ករណីទាក់ទងនឹងមាត្រា ៣៨ នៃច្បាប់ស្តីពីគណបក្សនយោបាយ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុម-ប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ចិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា ជាតិ សាសនា ព្រះមហាក្សត្រ

ជម្រាបជូន

ឯកឧត្តម ចិន ឈិន

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

<u>កម្មវត្ថុ</u> : ស្នើបកស្រាយមាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដែលអនុម័តថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១

<u>យោង</u> : មាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ នៃរដ្ឋធម្មនុញ្ញ

យើងខ្ញុំជាតំណាងរាស្ត្រ សូមស្នើមកក្រុមប្រឹក្សាធម្មនុញ្ញ ឲ្យបកស្រាយបញ្ជាក់ពីអត្ថន័យ មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ដែលចែងថា :

" ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ-សង្កាត់ ក្រុមប្រឹក្សាឃុំ-សង្កាត់ នីមួយៗត្រូវជ្រើសរើសឲ្យមានមេភូមិម្នាក់សម្រាប់ភូមិនីមួយៗដែលចំណុះឃុំ-សង្កាត់របស់ខ្លួន ។

មេភូមិត្រូវរៀបចំចាត់តាំងឲ្យមានអនុប្រធានមួយរូប និង សមាជិកមួយរូបជាជំនួយការ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និង ការតែងតាំងជំនួយការមេភូមិ ។ "

ក្នុងន័យនេះ តើក្រុមប្រឹក្សាឃុំ-សង្កាត់ អាចតែងតាំងមេភូមិ និង អនុប្រធានភូមិជាបណ្តោះ អាសន្នបានដែរឬទេ ដើម្បីបំពេញការងាររហូតដល់មានសេចក្តីណែនាំអំពីបែបបទ នីតិវិធី ពីក្រសួងមហាផ្ទៃ ស្តីពីការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និង ការតែងតាំងជំនួយការមេភូមិ ? ។

សូមឯកឧត្តម ទទួលនូវការរាប់អានស្មោះអំពីយើងខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០២

ហត្ថលេខា

អ្នកតំណាងរាស្ត្រ ១៣រូប



ក្រុមប្រឹក្សាធម្មនុញ្ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿង

លេខ : ០៥៦/០១០/២០០២

ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២

សេចក្តីសម្រេច

លេខ : ០៥០/០០១/២០០៣ កបធ.ច

ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញលិខិតចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០២ របស់សមាជិកសភា ១៣រូប នៃគណបក្ស សម រង្សី ជូនរាកឧត្តមប្រធាន **មិន ឈិន** ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ ឆ្នាំ ដដែល ។

ក្រោយពីបានស្តាប់ឃោសការណ៍ៃបស់សមាជិកវាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សមាជិកសភាចំនួន ១៣រូប បានស្នើមកក្រុមប្រឹក្សាធម្មនុញ្ញក្នុងចំនួនលើសពីមួយភាគដប់ (១/១០ x ១២២) ឱ្យបកស្រាយមាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។ ស់ណើនេះស្របតាមមាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ ។ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញអាចយកស់ណើនេះមកពិនិត្យបាន ។

- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ ម្យ៉ាងជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ម្យ៉ាងទៀតជាភ្នាក់ងារតំណាងរដ្ឋដែលស្ថិតនៅក្រោមការចាត់តាំង ឬ ការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ (មាត្រា ៤២) ។ ក្នុងឋានៈជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីធំធេងក្នុងការបំពេញកិច្ចការមូលដ្ឋាន រៀបចំសណ្តាប់ធ្នាប់សាធារណៈ សេវាសាធារណៈ ជាសុកភាព និង សុខុមាលភាព អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ថែរក្សាបរិស្ថាន ។ ល ។ ក្នុងក្របខ័ណ្ឌនយោបាយវិមជ្ឈការ ។ ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវគោរព និង អនុវត្តតាមការណែនាំថ្នាក់លើ តាមលំដាប់ឋានានុក្រម ។
- យល់ឃើញថា មាត្រា ៣០ (វាក្យខ័ណ្ឌទី១ និង ទី២) នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំជ្រើសរើសមេភូមិ ។ មេភូមិត្រូវរៀបចំចាត់តាំងអនុប្រធានភូមិ និង សមាជិកជាជំនួយការ (លក្ខណៈគ្រប់គ្រាន់) បានតម្រូវយ៉ាងច្បាស់ថា (វាក្យខ័ណ្ឌទី៣) : " រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធី នៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ និងការតែងតាំងជំនួយការភូមិ " ដែលជាបទបញ្ញត្តិមានលក្ខណៈចាំបាច់ ។ មាត្រា ៨៦ បានបញ្ជាក់បន្ថែមក្នុងអន្តរប្បញ្ញត្តិថា ត្រូវធ្វើ ... " តាមបែបបទនីតិវិធីដូចមានចែងក្នុងមាត្រា ៣០ នៃច្បាប់នេះ " ។
- យល់ឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មិនបានកំណត់រយៈពេលឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចេញសេចក្តីណែនាំក្នុងរឿងនេះទេ ប៉ុន្តែការពិនិត្យបានបង្ហាញឱ្យឃើញថា មានការកំណត់រយៈពេលសម្រាប់រឿងផ្សេងៗអាទ្យែត មានយ៉ាងយូរត្រឹម ០៦ ខែ ។ ការពិនិត្យបន្ថែមបានបង្ហាញឱ្យឃើញថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានតម្រូវឱ្យក្រសួងមហាផ្ទៃចេញសេចក្តីណែនាំចំនួនប្រហែលម្ភៃ សម្រាប់បង្កើនប្រសិទ្ធភាពនៃនយោបាយវិមជ្ឈការនេះ ។
- យល់ឃើញថា " គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ " ដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធានបង្កើតដោយមាត្រា ៨៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្នុងគោលដៅបង្កលក្ខណៈសម្បត្តិអោយស្រួលដល់នយោបាយវិមជ្ឈការមានសមត្ថកិច្ចគ្រប់គ្រាន់ (មាត្រា ៨៨) ក្នុងការដោះស្រាយ ឬ ជំរុញឱ្យមានការណែនាំក្នុងរយៈពេលសមស្របមួយ ។
- យល់ឃើញថា តាមមាត្រា ៤៤ ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងឋានៈជាភ្នាក់ងាររដ្ឋ អាចត្រូវបានទទួលប្រតិភូកម្មអំណាចពីសំណាក់អាជ្ញាធររដ្ឋសម្រាប់កិច្ចការអនុវត្តន៍ លើកលែងតែវិស័យដែលមានចែងច្បាស់ក្នុងមាត្រា ៤៥ ដែលជាសមត្ថកិច្ចរបស់អាជ្ញាធរកណ្តាល ។
- យល់ឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឋានៈជាភ្នាក់ងារតំណាងរដ្ឋត្រូវស្នើសុំការណែនាំគោលការណ៍នៃ

ការរៀបចំជ្រើសរើសមេភូមិពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទោះបីក្នុងលក្ខណៈជាការជ្រើសរើសបណ្តោះអាសន្ត ក៏ដោយ ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃមានកាតព្វកិច្ចត្រូវធ្វើយតបចំពោះសំណូមពរនេះក្នុងរយៈពេលមួយ សមស្រប ។

សម្រេច

មាត្រា ១ : មាត្រា ៣០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបកស្រាយតាមមូលបទខាងលើនេះ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៣

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ចាត្តលេខា នៃ ត្រា

ចិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ : ៣៩០ រ.ស

ជម្រាបជូន

ឯកឧត្តម ចិន ឈិន

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

សូមមេត្តាជ្រាប ។

កម្មវត្ថុ : ករណីបណ្តឹងរបស់លោក **គង់ បញ្ញា** នាយកប្រតិបត្តិ នៃគណៈកម្មាធិការដើម្បីបោះឆ្នោតដោយសេរី និង យុត្តិធម៌ នៃកម្ពុជា

យោង : លិខិតលេខ សធ ១៨២/០៣ គ.ប.ស.យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៣

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមឯកឧត្តម មេត្តាបំភ្លឺចំពោះបណ្តឹងដូចមានភ្ជាប់មកជាមួយស្រាប់ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាជួយពិនិត្យ និង បំភ្លឺតាមការគួរ ។

សូមឯកឧត្តម មេត្តាទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៣

ប្រធានរដ្ឋសភា

ព្រះហស្តលេខា

នរោត្តម រណឫទ្ធិ

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ខុមហ្វ្រែល COMFREL

លេខ : ១៨២/០៣ គ.ប.ស.យ ភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៣

សូមគ្រាបបង្គំទូលថ្វាយ

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ

ព្រះប្រធានរដ្ឋសភា

កម្មវត្ថុ : សូមព្រះរាជានុញ្ញាតប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីសុំការបកស្រាយមាត្រា ១៣៧ ថ្មី វាក្យខ័ណ្ឌទី១-២ នៃព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រ ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយក្នុងកម្មវត្ថុខាងលើ ទូលព្រះបង្គំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមជំរាបទូលថ្វាយព្រះអង្គទ្រង់ព្រះមេត្តាជ្រាបថា : ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រង់ជំពូកទី១២ ស្តីពីអន្តរប្បញ្ញត្តិ មាត្រា ១៣៧ ថ្មី វាក្យខ័ណ្ឌទី១-២ ដែលចែងថា " ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាថ្ងៃអាទិត្យ ទី ២៧ ខែ កក្កដា ឆ្នាំ២០០៣ ការរាប់សន្លឹកឆ្នោតដូចមានចែងក្នុងមាត្រា ១០២ មាត្រា ១០៣ មាត្រា ១០៤ និង មាត្រា ១០៦ នៃច្បាប់ស្តីពីការបោះ-ឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅទីស្នាក់ការគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោតនៃព្រះរាជ-ណាចក្រកម្ពុជា ឬ ទីកន្លែងណាមួយដែលមានសុវត្ថិភាពតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបទបញ្ជា នីតិវិធីលំអិតនៃការដឹកជញ្ជូនហិបឆ្នោត ការរាប់សន្លឹកឆ្នោត ដើម្បីធានាឲ្យការរាប់សន្លឹកឆ្នោតប្រព្រឹត្តទៅប្រកបដោយតម្លាភាព មានសុវត្ថិភាព គ្មានការគំរាមកំហែង គ្មានការប៉ះពិតប៉ះពាល់ និង ធានាឲ្យបានឆ្លុះឆ្លងសេរី ត្រឹមត្រូវ និង យុត្តិធម៌ " ។

ទូលព្រះបង្គំយើងខ្ញុំយល់ថា នៅក្នុងបទបញ្ជា និង នីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជំពូកទី៨ ចំណុច ៨.១៥ ដែលចែងថា " ក្រុមរាប់សន្លឹកឆ្នោតនីមួយៗ រាចទទួលរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតពីមួយ (១) ដល់ បី (៣) " ហាក់បីដូចជាមិនស្របទៅតាមស្មារតីនៃមាត្រា ១៣៧ ថ្មី នេះ ។ ស្មារតីនៃមាត្រា ១៣៧ ថ្មី នេះ គឺចង់ឲ្យមានការចាក់បញ្ចូលសន្លឹកឆ្នោតគ្រប់ការិយាល័យបោះឆ្នោតទាំងអស់ រួចទើបធ្វើការបែងចែកសន្លឹកឆ្នោតទាំងនេះទៅតាមក្រុមរាប់សន្លឹកឆ្នោតនីមួយៗ គឺដើម្បីធានាឲ្យបាននូវលទ្ធផលពីការិយាល័យបោះឆ្នោតនីមួយៗ នឹងមិនត្រូវបានគេដឹងថា ប្រជាពលរដ្ឋមកពីភូមិណា (ការិយាល័យណាមួយ) បោះឆ្នោតឲ្យគណបក្សនយោបាយណា ហើយក៏ដើម្បីបង្កើននូវភាពសម្ងាត់នៃសន្លឹកឆ្នោតផងដែរ។ ការបង្កើននូវភាពសម្ងាត់នៃសន្លឹកឆ្នោតនៅ

តាមភូមិ ឬ ការិយាល័យនេះ គឺអាចកាត់បន្ថយបាននូវការរើសអើងទាក់ទិនដល់ការអភិវឌ្ឍន៍ក្រោយពេលបោះឆ្នោត ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើនេះ សូមព្រះអង្គទ្រង់ព្រះមេត្តាលើកការប្តឹងប្រទានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធ្វើការបកស្រាយអំពីអត្ថន័យខ្លឹមសារនៃមាត្រានេះដោយព្រះមេត្តាប្រោស ។

សូមព្រះអង្គទ្រង់ព្រះមេត្តាទទួលនូវគារវកិច្ច និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីទូលព្រះបង្គំ។

នាយកប្រតិបត្តិ

ហត្ថលេខា

គល់ បញ្ញា

ភ្ជាប់មកជាមួយនូវ :

បចក្តីថ្លែងការរបស់ខុមហ្រ្វែល

- ការវិភាគរបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៦៨/០១២/២០០៣

ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ២០០៣

សេចក្តីសម្រេច

លេខ : ០៥៣/០០៤/២០០៣ កបធ.ច

ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីរិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៣៩០ រស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៣ របស់ប្រធានរដ្ឋសភា ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញបំភ្លឺចំពោះបណ្តឹងលេខ ១៨២/០៣ ត.ប.ស.យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០០៣ របស់លោក **គល់ បញ្ញា** នាយកប្រតិបត្តិនៃគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា ហើយដែលអត្តលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៣

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់

- យល់ឃើញថា ការសុំរបស់ប្រធានរដ្ឋសភាក្នុងលិខិតលេខ ៣៩០ រស ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៣

ឱ្យបំភ្លឺចំពោះសំណើរបស់លោក **គង់ ឃញ្ញា** លេខ ១៨២/០៣ ត.ប.ស.យ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៣ សុំឱ្យបកស្រាយមាត្រា ១៣៧ ថ្មី វាក្យខ័ណ្ឌទី១ និង ទី២ នៃព្រះរាជក្រម លេខ នស/រកម/ ០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ អាចយកមកពិនិត្យបាន ដោយអនុលោមតាមមាត្រា ១៤១ ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨

- យល់ឃើញថា វាក្យខ័ណ្ឌទី១ នៃមាត្រា ១៣៧ ថ្មី នៃព្រះរាជក្រមលេខ នស/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០០២ នេះ សំដៅទៅលើទីកន្លែងនៃការរាប់សន្លឹកឆ្នោតដែលត្រូវធ្វើជាគោលការណ៍ នៅទីស្នាក់ការគណៈកម្មាធិការឃុំ សង្កាត់រៀបចំការបោះឆ្នោត ប៉ុន្តែក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិ-រៀបចំការបោះឆ្នោតមានសិទ្ធិកំណត់យកទីកន្លែងសុវត្ថិភាពណាមួយក៏បាន
- យល់ឃើញថា វាក្យខ័ណ្ឌទី២ នៃមាត្រា ១៣៧ ថ្មី ដដែលនេះ មិនមានលំអិតឱ្យច្បាស់លាស់អំពីនីតិវិធីនៃ ការដឹកជញ្ជូនហិបឆ្នោត ឬ ការរាប់សន្លឹកឆ្នោតទេ ដោយទុកការកិច្ចនេះជូនគណៈកម្មាធិការជាតិរៀបចំ-ការបោះឆ្នោត (ត.ជ.ប) ក្នុងស្មារតីចង់ឱ្យ ត.ជ.ប មានលទ្ធភាពគ្រប់គ្រាន់ក្នុងការរិះរកប្រតិបត្តិភាព (ភាពដែលអាចប្រតិបត្តិបាន) ដែលត្រូវឆ្លើយនឹងលក្ខខ័ណ្ឌតម្លាភាព សុវត្ថិភាព គ្មានការតំរាមតំហែង គ្មានការបំភិតបំភ័យ លក្ខណៈសេរី ត្រឹមត្រូវ និង យុត្តិធម៌ ដែលច្បាប់បានបញ្ញត្តិនោះ ។

ដូច្នេះ ជាស្មារតីច្បាប់ ក៏ពុំមានត្រង់ណាដែលបង្ហាញឱ្យឃើញថា ចង់ឱ្យមានការចាក់បញ្ចូលសន្លឹកឆ្នោត តាមរបៀបណាមួយជាក់ច្បាស់នោះឡើយ

- យល់ឃើញថា ការសម្ងាត់របស់អ្នកបោះឆ្នោតក្នុងការបោះឆ្នោត ជាគោលការណ៍ សម្រាប់ការពារសិទ្ធិ ជ្ជាល់ខ្លួនបុគ្គលអ្នកបោះឆ្នោត និង សន្តិសុខសុវត្ថិភាពរបស់គេ ។ គោលការណ៍នេះ ក្នុងពេលបច្ចុប្បន្នពុំ អាចមានវិសាលភាពដល់ភូមិការ និង សហគមន៍ភូមិសាស្ត្រឡើយ ទោះបីក្នុងករណីណាក៏ដោយ ។ នៅក្នុង ច្បាប់បោះឆ្នោតជាធរមាន ពុំទាន់មានគោលការណ៍ដើម្បីការពារការសម្ងាត់អ្នកបោះឆ្នោតជាសមូហភាព តាមសហគមន៍ភូមិសាស្ត្រនៅឡើយទេ ។

សម្រេច

មាត្រា ១ : វាក្យខ័ណ្ឌទី១ និង ទី២ នៃមាត្រា ១៣៧ ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃ ទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើស តាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃ

ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាច
ទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០៣

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

ជិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ : ៨២៧ រស

ជម្រាបជូន

ឯកឧត្តម ចឺន ឈិន

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

ភ្ជាប់ជូន : សំណើក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើការបកស្រាយមាត្រា ១២៨ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

យោង : លិខិតរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជាខុមហ្វ្រែល (COMFREL) លេខ ២៨៧/០៣ គ ប សយ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣

ឯកឧត្តម ជាធីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រធានជ្រាបថា: រដ្ឋសភាបានទទួលលិខិតសំណូមរបស់គណៈកម្មាធិការខុមហ្វ្រែល ដែលបានដាក់សំណូមទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធ្វើការបកស្រាយច្បាប់វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ចំពោះសំណូមរបស់គណៈកម្មាធិការខុមហ្វ្រែល ដែលបានសូមខាងលើនេះ ខ្ញុំសូមជូនមកឯកឧត្តមប្រធានមេត្តាទទួលពិនិត្យ និង ចាត់ឲ្យមានការបំភ្លឺ ស្របតាមនីតិវិធីនៃច្បាប់រដ្ឋធម្មនុញ្ញ ។

សូមឯកឧត្តមប្រធាន ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៣

ប្រធានរដ្ឋសភា

ព្រះហស្តលេខា

នរោត្តម រណឫទ្ធិ

ចម្លងជូន

- ខុទ្ទកាល័យព្រះមហាក្សត្រ
- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- សាមីសំណូរ

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ខុមហ្វ្រែល COMFREL
លេខ : ២៨៧/០៣ គ.ប.ស.យ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
ព្រះប្រធានរដ្ឋសភា

កម្មវត្ថុ : សូមព្រះរាជានុញ្ញាតប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីសុំការបកស្រាយមាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយក្នុងកម្មវត្ថុខាងលើ ទូលព្រះបង្គំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមជំរាបទូលថ្វាយព្រះអង្គទ្រង់ព្រះមេត្តាជ្រាបថា : ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រង់ជំពូកទី១១ ស្តីពីទោសប្បញ្ញត្តិ មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ ដែលចែងថា " ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពីប្រាំលាន (៥.000.000)រៀល ទៅ ម្ភៃប្រាំលាន (២៥.000.000)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ... " ។

ទូលព្រះបង្គំយើងខ្ញុំយល់ឃើញថា នៅក្នុងមាត្រានេះមិនបានកំណត់ច្បាស់លាស់ថា ការពិន័យជាប្រាក់នេះ ស្ថាប័នណាដែលមានសមត្ថកិច្ចពិន័យឡើយ ។ ម្យ៉ាងវិញទៀតនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ គឺមាននីតិវិធីកំណត់ច្បាស់លាស់ ។ តាមការអនុវត្តន៍ជាក់ស្តែងកន្លងមកនៅក្នុងនីតិវិធីជំពូកទី១១ គ.ជ.ប បានធ្វើការពិន័យអ្នកដែលប្រព្រឹត្តល្មើសនឹងមាត្រានៃច្បាប់នេះទោះបីនៅក្នុងច្បាប់ចែងមិនច្បាស់លាស់អំពីអំណាចនេះក៏ដោយ ។

សេចក្តីដូចបានក្រាបបង្គំទូលថ្វាយខាងលើនេះ សូមព្រះអង្គទ្រង់ព្រះមេត្តាលើកការប្តឹងប្រទានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធ្វើការបកស្រាយអំពីអត្ថន័យខ្លឹមសារនៃមាត្រានេះដោយព្រះមេត្តាប្រោស ។

សូមព្រះអង្គទ្រង់ព្រះមេត្តាទទួលនូវគារវកិច្ច និងសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីទូលព្រះបង្គំ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣
នាយកប្រតិបត្តិ
ហត្ថលេខា
គង់ បញ្ញា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ០៧៥/០១៩/២០០៣

ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

សេចក្តីសម្រេច

លេខ : ០៥៨/០០៩/២០០៣ កបធ.ច

ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០៤៦/០០១/២០០២ កបធ.ច ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០២ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៤២៧ រស ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៣ របស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភាបញ្ជូនលិខិតលោក **គស់ មញ្ញា** នាយកប្រតិបត្តិរបស់គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា (COMFREL) មកក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យធ្វើការបកស្រាយមាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ តាមពាក្យបណ្តឹង លេខ ២៨៧/គ.ប.ស.យ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញទទួលបាននៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៣

គ្រោយពីបានស្តាប់របាយការណ៍សមាជិកវាយការណ៍

គ្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់រៀយ

- យល់ឃើញថា តាមមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យបណ្តឹងរបស់សម្តេចក្រុមព្រះប្រធានរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យពិភាក្សាបាន
- យល់ឃើញថា មាត្រា ៧៦ វាក្យខ័ណ្ឌទី ៥ នៃរដ្ឋធម្មនុញ្ញ បានបញ្ញត្តិឱ្យច្បាប់បោះឆ្នោតកំណត់អំពី " អង្គការរៀបចំការបោះឆ្នោត បែបបទ និង ការប្រព្រឹត្តទៅនៃការបោះឆ្នោត "
- យល់ឃើញថា តាមការបញ្ជាក់របស់ក្រសួងមហាផ្ទៃ ដែលជាអ្នកតាក់តែងសេចក្តីព្រាងដើមនៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គំនិតគឺឱ្យ គ.ជ.ប ជាអ្នកធ្វើការពិន័យ
- យល់ឃើញថា តាមកំណត់ហេតុនៃការពិភាក្សានៅរដ្ឋសភានាឆ្នាំ២០០២ និង ឆ្នាំ១៩៩៧ ពុំមានយោបល់សុំកែប្រែគំនិតដើមរបស់សេចក្តីព្រាងមាត្រា ១២៤ ថ្មី និង មាត្រា ១២៤ ចាស់ លើចំណុចខាងលើនេះទេ
- យល់ឃើញថា មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របានចែងថា " ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតលុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.000.000) រៀល ទៅម្តៃប្រាំលាន (២៥.000.000) រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ... " ។ ក្នុងឃ្លានេះ យោងតាមទឡ្ឌីករណ៍ខាងលើការពិន័យជាប្រាក់ ក៏ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ គ.ជ.ប ដែរ ។

សម្រេច

មាត្រា ១ : មាត្រា ១២៤ ថ្មី វាក្យខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបកស្រាយដូចមានក្នុងមូលបទខាងលើ ។

មាត្រា ២ : សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ- ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០០៣

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

មិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១៦៨ ល.ស

សូមជម្រាបជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : សំណើសុំបកស្រាយមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ។

យោង : មាត្រា ១៣៦ ថ្មី និងមាត្រា ១៨១ ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមឯកឧត្តមប្រធានមេត្តាដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញធ្វើការបកស្រាយបទប្បញ្ញត្តិនៃមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ :១៦៤/០០២/២០០៩

ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩

សេចក្តីសម្រេច

លេខ :១០៥/០០១/២០០៩ កបធ.ច

ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញលិខិតលេខ ១៦៨ លស ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ វេលាម៉ោង ១៦ និង ៥០ នាទី ។

ក្រោយពីបានស្តាប់រាយការណ៍របស់សមាជិកអាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះគ្រួចតាមច្បាប់ហើយ

- យល់ឃើញថា ស្របតាមមាត្រា១៣៦ថ្មី មាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៥ថ្មី មាត្រា១៨ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលសំណើសុំបកស្រាយ លេខ ១៦៨ លស ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី យកមកពិនិត្យបាន
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា ១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានបកស្រាយថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលកំពុងបំពេញមុខងារជាសកម្ម គ្មានសិទ្ធិជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាបានទេ មានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និង យោធា មិនអាចធ្វើការងាររបស់ខ្លួនផង និងជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាផងបានទេ ។ ពាក្យថា " មន្ត្រីរាជការស៊ីវិល " រួមមាន មន្ត្រីរាជការក្នុងក្របខណ្ឌនីតិបញ្ញត្តិ ក្របខណ្ឌនីតិប្រតិបត្តិ ក្របខណ្ឌតុលាការ និងក្របខណ្ឌពិសេសផ្សេងទៀត
- យល់ឃើញថា តាមស្មារតីនៃមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។ បទបញ្ញត្តិបន្ថយសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត
- យល់ឃើញថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំបានហាមឃាត់ដាច់ខាតមិនឱ្យឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ ប្រសិនបើមន្ត្រីរាជការស៊ីវិល និងយោធាទាំងនោះ មានចំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សាមីខ្លួនត្រូវតែចំពេញលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់នេះ
- យល់ឃើញថា បទបញ្ញត្តិនៃមាត្រា១៨ ដែលចែកជា ៣ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចខាងក្រោមនេះ÷

ក/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ១ មានន័យថា ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា ដែលមានចំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ។ ពាក្យថា " ដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ(០៧)ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ " មានន័យថា ដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងារតែប៉ុណ្ណោះ មិនមែនមានន័យថា ដាក់លាក្យសុំលាលែងពីមុខងារ ឬពីមុខតំណែងឡើយ ។ បទបញ្ញត្តិនេះមានន័យម្យ៉ាងទៀតថា មន្ត្រីរាជការស៊ីវិល និងយោធាដែលចង់ស្តើជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវសុំការអនុញ្ញាតអវត្តមានពីការងារ ក្នុងរយៈពេលដូចបានកំណត់ខាងលើ ។

ខ/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី ២ មានន័យថា សាមីខ្លួនជាប់ឆ្នោត ត្រូវធ្វើពាក្យទៅក្រសួង ឬ ស្ថាប័នរបស់ខ្លួន សុំទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សាតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតក្នុងរយៈពេលនៃអាណត្តិនោះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬ ឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ទៀតផង ។

ប្រសិនបើបេក្ខជនជាប់ឆ្នោតហើយ ហើយគ្មានចំណងចង់នៅបម្រើការងារជាសមាជិកក្រុមប្រឹក្សាទេនោះ សាមីខ្លួនត្រូវធ្វើពាក្យទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីសុំដកបេក្ខភាពរបស់ខ្លួនចេញពីបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។ ក្នុងករណីនេះ សាមីខ្លួនអាចមកកាន់ការងារដើមរបស់ខ្លួនវិញបាន។

គ/-បទបញ្ញត្តិនៃវាក្យខ័ណ្ឌទី៣ មានន័យថា នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចត្រឡប់មកបម្រើការងារនៅក្រសួង ឬ ស្ថាប័នដើមរបស់ខ្លួនវិញបាន ប៉ុន្តែសាមីខ្លួននឹងអាចបានទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញបាននោះ គឺអាស្រ័យដោយក្រសួង ឬ ស្ថាប័នជាអ្នកសម្រេច មិនមែនសាមីខ្លួនអាចទទួលមុខងារ ឬ មុខតំណែងដើមរបស់ខ្លួនវិញ ដោយស្វ័យប្រវត្តិនោះឡើយ ។

សម្រេច

មាត្រា ១-បទបញ្ញត្តិនៃមាត្រា ១៧ និង មាត្រា ១៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២-សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

ម.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា ជាតិ សាសនា ព្រះមហាក្សត្រ

យើងខ្ញុំជាអ្នកតំណាងរាស្ត្រដូចមានរាយនាម និងហត្ថលេខាខាងក្រោម

សូមជំរាបជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : ស្នើសុំធ្វើការបកស្រាយនិងពិនិត្យធម្មនុញ្ញភាពនៃមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងបកស្រាយមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ។ ។

យោង : - មាត្រា ១៣៦ ថ្មី និងមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជំរាបជូនឯកឧត្តមជ្រាបថា មាត្រា ២៩ វាក្យខណ្ឌទី៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បានចែងថា " *... ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់នោះ ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត* " ។ ផ្អែកតាមខ្លឹមសារខាងលើនេះ មានន័យថា សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជំនួសអ្នកបាត់បង់សមាជិកភាព ដោយទទួលមរណភាព ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់បញ្ចូលឈ្មោះទៅក្នុងបញ្ជីបោះឆ្នោតផ្លូវការ សំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៩ ។

ដោយឡែកមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ចែងថា " *សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួន ទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :*

- *សាមីខ្លួនទទួលមរណភាព*
- *សាមីខ្លួនបាត់បង់សម្បទាជ្លាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច*
- *សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់*
- *សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ*
- *សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាឃុំសង្កាត់តាមលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៨៤ នៃច្បាប់នេះ*
- *ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងមូលត្រូវរំលាយ*
- *សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។*

កាលបើសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ណាមួយ ត្រូវបាត់បង់សមាជិកភាព ត្រូវជ្រើសរើសបេក្ខជន

ដែលមានឈ្មោះបន្ទាប់តាមលេខរៀង ក្នុងបញ្ជីបេក្ខជនជាមួយមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ "។

បើយោងមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងឃុំ-សង្កាត់ ការបាត់បង់សមាជិកភាពក្រុមប្រឹក្សាឃុំ-សង្កាត់ គ្រប់ករណីទាំងអស់ ត្រូវបំពេញជំនួស ដោយបេក្ខជនលេខបន្តបន្ទាប់ក្នុងបញ្ជីបេក្ខជនជាមួយគ្នា ។ ចុះហេតុអ្វីបានជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជំនួសអ្នកបាត់បង់សមាជិកភាព ស្របតាមមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ក្រៅពីទទួលមរណភាព) នៅក្នុងដំណាក់កាលដែល គ.ជ.ប ផ្តល់សុពលភាពដល់បញ្ជីបោះឆ្នោតរួចហើយ មិនត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីបោះឆ្នោត និងបានសិទ្ធិបោះឆ្នោត នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៩ ដូចករណីការផ្លាស់ប្តូរអ្នកបោះឆ្នោតដែលទទួលមរណភាព ដូចមានចែងក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ?

បើសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជំនួសអ្នកបាត់បង់សមាជិកភាពដោយទទួលមរណភាព ទទួលបានសិទ្ធិបោះឆ្នោត ហើយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជំនួសអ្នកបាត់បង់សមាជិកភាពក្នុងករណីផ្សេងៗទៀតមិនទទួលបានសិទ្ធិបោះឆ្នោត តើស្របនឹងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា " ... ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ... " ដែរឬទេ ?

អាស្រ័យដូចបានជំរាបជូនខាងលើ យើងខ្ញុំសូមឯកឧត្តមប្រធានធ្វើការបកស្រាយ និងពិនិត្យធម្មនុញ្ញភាពនៃមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយនឹងបកស្រាយមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដោយអនុគ្រោះ ។

សូមឯកឧត្តមប្រធានទទួលនូវការគោរពដ៏ជ្រាលជ្រៅ អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩

ហត្ថលេខា

តំណាងរាស្ត្រ ១៥រូប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រមច្បាប់ក្បាលធម្មនុញ្ញ

សំណុំរឿង

លេខ : ១៦៧/០០៥/២០០៩

ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩

សេចក្តីសម្រេច

លេខ : ១០៦/០០២/២០០៩ កបច.ច

ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៩

ក្រមច្បាប់ក្បាលធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៤១/០០៣/២០០១ កបច.ច ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០០១
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៩៧/០០២/២០០៨ កបច.ច ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨
- បានឃើញលិខិតគ្មានលេខ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ របស់ក្រុមអ្នកតំណាងរាស្ត្រចំនួន ១៥នាក់ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ និង ពិនិត្យធម្មនុញ្ញភាពមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និង បកស្រាយមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ វេលាម៉ោង ១៦ និង ៥០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់អ្នកតំណាងរាស្ត្រចំនួន ១៥ នាក់ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៩ ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយ និងពិនិត្យធម្មនុញ្ញភាព មាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងបកស្រាយមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ រួមទាំងមាត្រា ២៩ ផង ត្រូវបានប្រកាសថា ស្របទីនរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៩៧/០០២/២០០៨ សជធ.ច ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០០៨ ។ ដូច្នេះ សំណើខាងលើនេះ ត្រូវចាត់ទុកថា ជាសំណើសុំបកស្រាយច្បាប់
- យល់ឃើញថា មាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី១ បានចែងថា " *ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។* " និងវាក្យខ័ណ្ឌទី៤ បានចែងថា " *បទបញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។* "
- យល់ឃើញថា បទបញ្ញត្តិមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពាក់ព័ន្ធតែនឹងបញ្ជីបោះឆ្នោត ពោលគឺបញ្ជីអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែងតែប៉ុណ្ណោះ ។ មាត្រានេះ ចែកជា ៣ វាក្យខ័ណ្ឌ ត្រូវបានបកស្រាយដូចតទៅ ÷

ក/ វាក្យខ័ណ្ឌទី១ បានចែងថា " *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោតក្នុងរយៈពេលយ៉ាងតិចសាមសិបប្រាំ (៣៥) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។* "

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំអាចផ្តល់សុពលភាពបញ្ជីបោះឆ្នោត ក្រោយសាមសិបប្រាំ (៣៥) ថ្ងៃ មុនថ្ងៃបោះឆ្នោតបានទេ ។

ខ/ វាក្យខ័ណ្ឌទី២ បានចែងថា " *បញ្ជីបោះឆ្នោតដែលត្រូវបានផ្តល់សុពលភាពរួចហើយ គឺជាបញ្ជីបោះឆ្នោតជាផ្លូវការ មិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។* "

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ក្នុងពេលដែលបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ បញ្ជីនោះក្លាយជាបញ្ជីបោះឆ្នោតផ្លូវការដែលមិនអាចកែប្រែបានឡើយ លើកលែងតែករណីមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការរួចហើយបានទទួលមរណភាព ។

ត/វាក្យខ័ណ្ឌទី៣ បានចែងថា "*ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវប់ពេញបែបបទ ផ្ទាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេលប្រាំពីរ (០៧) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជ្នូសក្នុងបញ្ជីបោះឆ្នោត ។*"

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្ទូវការហើយ ហើយបានទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវប់ពេញបែបបទធ្វើការផ្ទាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះឱ្យបានរួចស្រេច ហើយផ្ទើទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យបានយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដើម្បីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជ្នូសក្នុងបញ្ជីបោះឆ្នោតផ្ទូវការបាន ។

ចំពោះករណីផ្សេងទៀត មាត្រា ២៩ នេះ មិនអនុញ្ញាតឱ្យធ្វើការផ្ទាស់ប្តូរឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្ទូវការឡើយ ។

- យល់ឃើញថា បទបញ្ញត្តិមាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលចែកជា ២ វាក្យខ័ណ្ឌត្រូវបានបកស្រាយដូចខាងក្រោមនេះ ÷

ក/វាក្យខ័ណ្ឌទី១ បានចែងថា "*សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់បង់សមាជិកភាពរបស់ខ្ទនទៅតាមករណីណាមួយក្នុងចំណោមករណីដូចខាងក្រោម :*

- *សាមីខ្ទនទទួលមរណភាព*
- *សាមីខ្ទនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច*
- *សាមីខ្ទនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់*
- *សាមីខ្ទនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រដ្ឋ ឬ មជ្ឈឹមណាមួយ*
- *សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៨៤ នៃច្បាប់នេះ*
- *ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ*
- *សាមីខ្ទនត្រូវបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្ទនហើយ ។*"

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ត្រូវបាត់បង់សមាជិកភាពរបស់ខ្ទន ក្នុងករណីណាមួយនៃករណីទាំង ៧ ដូចបានរៀបរាប់ខាងលើ ។

ខ/វាក្យខ័ណ្ឌទី២ បានចែងថា "*កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាពត្រូវជ្រើសរើសបេក្ខជនបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជ្នូសដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។*"

បទបញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា ត្រូវបានជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយ មកជ្នូសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបាត់បង់សមាជិកភាព ដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

សម្រេច

មាត្រា ១- បទបញ្ញត្តិនៃមាត្រា ២៩ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ និង មាត្រា ១៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៩

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ជំនួសតា

លេខ : ០០២/១០ រ.ស.គសរ

យើងខ្ញុំជាអ្នកតំណាងរាស្ត្រជូចមានរាយនាម ខិចហត្ថលេខាខាងក្រោម

សូមជំរាបជូន

ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

កម្មវត្ថុ : ស្នើសុំធ្វើការបកស្រាយមាត្រា ១៦ វាក្យខ័ណ្ឌទី៤ នៃច្បាប់កូមិបាល ។

យោង : មាត្រា ១៣៦ ថ្មី និងមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាបជូនឯកឧត្តមថា មាត្រា ១៦ វាក្យខ័ណ្ឌទី៤ នៃច្បាប់កូមិបាល ចែងថា " *ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈ អាចត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ* " ។ ផ្អែកតាមខ្លឹមសារនេះ មានន័យថា ការធ្វើអនុបយោគ ត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក ។ រហូតមកដល់ពេល យើងខ្ញុំពុំទាន់ឃើញមានច្បាប់ស្តីពីអនុបយោគនេះ ត្រូវបានធ្វើឡើងស្របតាមការចង្អុលបង្ហាញត្រង់វាក្យខ័ណ្ឌទី៤ មាត្រា ១៦ នៃច្បាប់កូមិបាលនៅឡើយទេ ប៉ុន្តែយើងខ្ញុំបានកត់សំគាល់ឃើញថា រាជរដ្ឋាភិបាលកម្ពុជា បានសំរេចធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងនីតិបុគ្គលសាធារណៈជាច្រើនសន្ធឹកសន្ធាប់ដោយផ្អែកតែលើព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ជត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈប៉ុណ្ណោះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសូមក្រុមប្រឹក្សាធម្មនុញ្ញធ្វើការបកស្រាយមាត្រា ១៦ វាក្យខ័ណ្ឌទី៤ នៃច្បាប់កូមិបាល ដោយអនុគ្រោះ ។

សូមឯកឧត្តមប្រធានទទួលនូវការគោរពដ៏ជ្រាលជ្រៅ អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០១០

ហត្ថលេខា

តំណាងរាស្ត្រ ១៥រូប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៧២/០០៣/២០១០

ចុះថ្ងៃទី ២៤ ខែ កុម្ភ: ឆ្នាំ២០១០

សេចក្តីសម្រេច

លេខ : ១០៩/០០២/២០១០ កបធ.ច

ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណ:របស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណ:
- បានឃើញលិខិត ០០២/១០ រ.ស.គសរ ចុះថ្ងៃទី ២៣ ខែ កុម្ភ: ឆ្នាំ២០១០ របស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ ១៥ រូប ជូនមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា១៦ វាក្យខ័ណ្ឌទី ៤ នៃច្បាប់ភូមិបាល ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៤ ខែ កុម្ភ: ឆ្នាំ២០១០ វេលាម៉ោង ១០ និង ៣០ នាទី ។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់ឯកឧត្តម លោកជំទាវ អ្នកតំណាងរាស្ត្រ ១៥ រូប ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ មាត្រា ១៦ វាក្យខ័ណ្ឌទី ៤ នៃច្បាប់ភូមិបាល បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ

និង មាត្រា ១៥ ថ្មី មាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីការវៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាចម្មនុញ្ញ ។ សំណើនេះអាចទទួលយកមកពិនិត្យបាន

-យល់ឃើញថា វាក្យខ័ណ្ឌទី ៤ មាត្រា ១៦ នៃច្បាប់ភូមិបាល បានចែងថា " ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ជលប្រយោជន៍សាធារណៈ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ តាមរយៈច្បាប់អនុបយោគ " ។ បទប្បញ្ញត្តិនៃវាក្យខ័ណ្ឌនេះ មានន័យថា កាលណាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋណាមួយ ត្រូវបានឈប់ប្រើប្រាស់ដាជលប្រយោជន៍សាធារណៈតទៅទៀតហើយ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ អាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបាន តាមរយៈច្បាប់អនុបយោគ ។ ពាក្យថា " ច្បាប់អនុបយោគ " គឺជា ច្បាប់ដែលវសាយពីប្រភេទទ្រព្យសម្បត្តិមួយទៅប្រភេទទ្រព្យសម្បត្តិមួយទៀត ដូចជាវសាយពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាដើម ។

សម្រេច

មាត្រា ១- បទប្បញ្ញត្តិ នៃវាក្យខ័ណ្ឌទី ៤ មាត្រា ១៦ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២- សេចក្តីសម្រេចនេះ ច្ងើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាចម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១០

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ : ៨៧៩ រ.ស

សូមគោរពជូន

ឯកឧត្តម ឯក សំអុល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

នៃព្រះរាជាណាចក្រកម្ពុជា

តាមរយៈ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ : ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយច្បាប់ មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ

តបតាមកម្មវត្ថុខាងលើ ក្នុងនាមជាអ្នកតំណាងរាស្ត្រ និងក្នុងនាម**គណបក្សជាតិនិយម** ខ្ញុំសូមអនុញ្ញាត**ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** មេត្តាជួយឲ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយច្បាប់ មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ ដែលបានចែងអំពីគណបក្សនយោបាយអាចប្រកាសរួមបញ្ចូលគ្នា ជាមួយគណបក្សនយោបាយផ្សេងទៀតបាន ។ តើការប្រកាសរួមបញ្ចូលគ្នានេះ ធ្វើឲ្យប៉ះពាល់ដល់អាសនៈ ឬលទ្ធផលបោះឆ្នោតសកល និងអសកលកន្លងមកដែរឬទេ ។

ឧទាហរណ៍ គណបក្សហ៊ុនស៊ុនប៊ិច និងគណបក្សជាតិនិយម ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សតែមួយដោយធ្វើការជ្រើសយកឈ្មោះគណបក្សហ៊ុនស៊ុនប៊ិច ជាគណបក្សដែលបានពីការប្រកាសរួមបញ្ចូលគ្នា ។ តើគណបក្សជាតិនិយមត្រូវបានទទួលរងនូវការបាត់បង់អាសនៈ ឬលទ្ធផលបោះឆ្នោតសកល និងអសកលកន្លងមកដែរឬទេ ។

ដូចគ្នានេះដែរ បើសិនជាគណបក្សហ៊ុនស៊ុនប៊ិច និងគណបក្សជាតិនិយម ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សតែមួយ ដោយធ្វើការជ្រើសរើសយកឈ្មោះគណបក្សថ្មីមួយផ្សេងទៀត ជាគណបក្សដែលបានពីការប្រកាសរួមបញ្ចូលគ្នា ។ តើគណបក្សហ៊ុនស៊ុនប៊ិច និងគណបក្សជាតិនិយមត្រូវបានទទួលរងនូវការរំលាយ ឬបាត់បង់អាសនៈ ឬលទ្ធផលបោះឆ្នោតសកល និងអសកលកន្លងមកដែរឬទេ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជួយឲ្យក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយច្បាប់តាមការស្នើសុំខាងលើ ដោយក្តីអនុគ្រោះ ។ ។

សូម **ឯកឧត្តម** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ២០១០

ហត្ថលេខា

សៅ រ៉ានី

អ្នកតំណាងរាស្ត្រមណ្ឌលព្រៃវែង

និងជាតំណាងគណបក្សជាតិនិយម

បានឃើញ និង បញ្ជូនមក

ឯកឧត្តម ឯក សំអុល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

- ដើម្បីមុខការ -

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១០

ប្រធានរដ្ឋសភា

ហត្ថៈ ៧ខា និង ត្រា

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៧៦/០០៧/២០១០

ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១០

សេចក្តីសម្រេច

លេខ : ១១១/០០៤/២០១០ កប.ច

ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១០

ក្រមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០០៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញលិខិតលេខ ៤៧៨ រ.ស ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ របស់ឯកឧត្តម **សៅ ភិន** តំណាងរាស្ត្រមណ្ឌលត្បូងឃ្មុំ និង ជាតំណាងគណបក្សជាតិនិយម តាមរយៈសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ដោយមានចំណារចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១០ ជូនឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំបកស្រាយច្បាប់មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១០ វេលាម៉ោង ១០ និង ៣០ នាទីព្រឹក

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិកការយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា តំណាងរាស្ត្រមួយរូបបានធ្វើលិខិតមួយ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ ជូនមកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយមាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្ស នយោបាយដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ បានធ្វើឡើងស្របតាមមាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌទី១ មាត្រា ១៤១ ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ចុំ មាត្រា ១៨ ថ្មី វាក្យខ័ណ្ឌទី២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ព្រមទាំងយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាធម្មនុញ្ញ

កន្លងមក សំណើរបស់តំណាងរាស្ត្រមួយរូបតាមរយៈប្រធានរដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលមកពិនិត្យបាន

- យល់ឃើញថា លិខិតរបស់ឯកឧត្តម សៅ ហ៊ីឌ តំណាងរាស្ត្រមណ្ឌលព្រៃវែង និង ជាតំណាងគណបក្សជាតិនិយម សុំឱ្យបកស្រាយបំភ្លឺនូវខ្លឹមសារមាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយដែលបានចែងអំពីគណបក្សនយោបាយ អាចប្រកាសរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេងទៀតបានក្នុងបរិបទនៃសំណួរមួយដែលសួរថា : **តើការប្រកាសរួមបញ្ចូលគ្នានេះ ធ្វើឱ្យប៉ះពាល់ដល់អាសនៈ ឬ លទ្ធផលបោះឆ្នោតសកល និង អសកលកន្លងមកដែរឬទេ ?**
- យល់ឃើញថា មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ ÷

• វាក្យខ័ណ្ឌទី១ ចែងថា " *គណបក្សនយោបាយអាចប្រកាសរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេងទៀតបាន តាមការកំណត់របស់លក្ខន្តិកៈ ។ ក្នុងករណីដែលលក្ខន្តិកៈមិនបានចែង ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាតគណបក្សនយោបាយ* " ។

វាក្យខ័ណ្ឌទី១ នៃមាត្រា ៣៦ នេះ មានន័យថា ច្បាប់អនុញ្ញាតឱ្យគណបក្សនយោបាយ អាចរួមបញ្ចូលគ្នាតាមលក្ខន្តិកៈកំណត់ ឬ បើពុំដូច្នោះទេ តាមសេចក្តីសម្រេចនៃមហាសន្និបាតរបស់គណបក្សនយោបាយនោះ ។

• វាក្យខ័ណ្ឌទី២ ចែងថា " *ក្រសួងមហាផ្ទៃត្រូវលុបឈ្មោះគណបក្សនយោបាយ ដែលបានប្រកាសរួមបញ្ចូលគ្នានោះ ចេញពីបញ្ជីគណបក្សនយោបាយ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីការរួមបញ្ចូលនោះ* " ។

វាក្យខ័ណ្ឌទី២ នៃមាត្រា ៣៦ នេះ មានន័យថា តម្រូវឱ្យគណបក្សនយោបាយដែលប្រកាសរួមបញ្ចូលគ្នាធ្វើលិខិតជូនដំណឹងទៅក្រសួងមហាផ្ទៃ ។ ក្រសួងមហាផ្ទៃក្រោយបានទទួលលិខិតជូនដំណឹងនេះ ត្រូវលុបឈ្មោះគណបក្សនយោបាយនោះចេញពីបញ្ជីគណបក្សនយោបាយ ។

ទោះបីជាមាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយខាងលើនេះ ពុំបានចែងពីផលប៉ះពាល់ដល់អាសនៈ ឬ លទ្ធផលបោះឆ្នោតសកល និង អសកលកន្លងមក ក្រោយពីការប្រកាសរួមបញ្ចូលគ្នានេះក្តី ប៉ុន្តែបញ្ហានឹងកើតមានឡើង ដូចមានចែងនៅក្នុងមាត្រា ១១៨ ថ្មី ចំណុច "ង" នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ " *ក្នុងករណីគណបក្សនយោបាយមួយទទួលបានអាសនៈមួយ ឬ ច្រើននៅក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និង បេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថាជាប់ឆ្នោតរួចហើយ <u>មិនមានសុពលភាព</u> <u>និង</u> <u>មិនមានគុណសម្បត្តិទៅទៀតបានឡើយ</u>* ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលទៅទំនេរនោះក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃ ទៅឱ្យគណបក្សនយោបាយផ្សេង ដែលទទួលបានអាសនៈក្នុងខេត្ត ក្រុង ជាមួយតាមជំហានទាំងឡាយដូចខាងក្រោម ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់អាសនៈ ... ។

ដូច្នេះ យោងតាមមាត្រា ១១៨ ថ្មី ចំណុច "ង" នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីក្រសួងមហាផ្ទៃប្រកាសលុបឈ្មោះគណបក្សនយោបាយដែលប្រកាសរួមបញ្ចូលជាមួយគណបក្សនយោបាយមួយផ្សេងទៀតពីបញ្ជីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏មានភារកិច្ចពិនិត្យ និង អនុវត្តទៅតាមបទប្បញ្ញត្តិមួយចំនួនដូចខាងក្រោម ÷

- មាត្រា ៥៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "*ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬ ព្រោះចាកសមាជិកភាព ដែលកើតមានឡើង ៦ ខែ យ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត ។*"

- មាត្រា ១១៥ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា "*ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែង ឬ ព្រោះចាកសមាជិកភាព ដែលកើតមានឡើងព្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំង ឬ ជ្រើសតាំងសមាជិកនោះ តាមលក្ខខណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។*"

- មាត្រា ៣១ ជំពូកទី៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង ប្រការ ១០ ថ្មី វាក្យខណ្ឌទី២ ប្រការ ១១ ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

- មាត្រា ៣៧ ថ្មី វាក្យខណ្ឌទី២ នៃជំពូកទី៤ មាត្រា ១២០ ថ្មី នៃជំពូកទី៩ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ប្រការ ៨៣ ថ្មី នៃជំពូកទី១៧ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

- មាត្រា ២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

- មាត្រា ១៣ ចំណុច ង មាត្រា ១៦ និង មាត្រា ២២ វាក្យខណ្ឌទី៣ និង វាក្យខណ្ឌទី៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

- មាត្រ ។ ២៦ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

• មាត្រា ២៧ មាត្រា ៥០ ថ្មី (មាត្រា ៥៩ ចាស់) និង **មាត្រា ៥២ ថ្មី (មាត្រា ១០១ ចាស់** កែប្រែ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

- យល់ឃើញថា ប្រព័ន្ធបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា **ជាប្រព័ន្ធសមាមាត្រ** ដូចមានចែងនៅក្នុង ÷

• មាត្រា ៨ ជំពូកទី២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ចែងថា " *ការបោះឆ្នោតត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ...* "

• មាត្រា ៥ វាក្យខ័ណ្ឌទី២ ជំពូកទី២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងថា " *ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមខេត្ត ក្រុងជាមណ្ឌលបោះឆ្នោត ។* "

• មាត្រា ១៣ ផ្នែកទី២ ជំពូកទី២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ចែងថា " **ក-** *ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ ... ។* "

• មាត្រា ៥ ជំពូកទី១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចែងថា " *ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមប្រព័ន្ធសមាមាត្រ ... ។* "

- យល់ឃើញថា ដើម្បីចុះឈ្មោះជាបេក្ខជនឈរឈ្មោះបោះឆ្នោតបាន បុគ្គលម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនគណបក្សនយោបាយមួយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងមហាផ្ទៃ ដូចមានចែងនៅក្នុង ÷

• មាត្រា ១៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ចែងថា " *ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ។*

បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។ "

• មាត្រា ៥០ ថ្មី (មាត្រា ៥៩ ចាស់) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចែងថា " *បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយប៉ុណ្ណោះ ។* "

• មាត្រា ៥២ ថ្មី (មាត្រា ១០១ ចាស់កែប្រែ) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចែងថា " *ពាក្យសុំចុះបញ្ជីបេក្ខជនត្រូវភ្ជាប់មកជាមួយនូវ :*

- សេចក្តីចម្លងលិខិតបញ្ជាក់ពីការចុះបញ្ជីគណបក្សនយោបាយនៃក្រសួងមហាផ្ទៃមួយច្បាប់ ។

... ។

- **យល់ឃើញថា តាមបទប្បញ្ញត្តិមួយចំនួនដូចបានលើកឡើងខាងលើ បញ្ជាក់បានថា បេក្ខជនគណបក្សនយោបាយនីមួយៗ ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនគណបក្សនយោបាយមួយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងមហាផ្ទៃ ។ ដូច្នេះ ប្រសិនជាគណបក្សនយោបាយត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយតាមច្បាប់ស្តីពីគណបក្សនយោបាយ តំណាងរាស្ត្រ និង សមាជិកព្រឹទ្ធសភា ក្នុងតំណែងរបស់គណបក្សនយោបាយនោះ នឹងត្រូវបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា ១២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ប្រការ ៨៣ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា មាត្រា ៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង ប្រការ ១០ ថ្មី វាក្យខ័ណ្ឌទី២ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា**
- **យល់ឃើញថា ដោយសារការបោះឆ្នោតសកល និង អសកលកន្លងមក ត្រូវធ្វើតាមប្រព័ន្ធសមាមាត្រ ដូចបានលើកឡើងក្នុងបទប្បញ្ញត្តិមួយចំនួនខាងលើ នៅពេលគណបក្សនយោបាយដែលមានអាសនៈប្រកាសរួមបញ្ចូលគ្នា ក្នុងករណីណាមួយខាងក្រោមនេះ មានផលប៉ះពាល់ដូចតទៅ ÷**

ករណីទីមួយ :

• ករណីគណបក្សនយោបាយ ក និង គណបក្សនយោបាយ ខ ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សនយោបាយតែមួយ ដោយធ្វើការជ្រើសរើសយកឈ្មោះគណបក្សនយោបាយ ក ជាគណបក្សនយោបាយដែលបានពីការប្រកាសរួមបញ្ចូលគ្នា ។

ករណីនេះ គណបក្សនយោបាយ ខ ត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ។ ដូច្នេះគណបក្សន យាបាយ ខ ត្រូវបានរងការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា រួមទាំងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។

ករណីទីពីរ :

• ផ្ទុយទៅវិញគណបក្សនយោបាយ ក និង គណបក្សនយោបាយ ខ ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សនយោបាយតែមួយដោយធ្វើការជ្រើសរើសយកឈ្មោះគណបក្សនយោបាយ ខ ជាគណបក្សនយោបាយដែលបានពីការប្រកាសរួមបញ្ចូលគ្នា ។

ករណីនេះ គណបក្សនយោបាយ ក ត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ។ ដូច្នេះគណបក្សនយោបាយ ក ត្រូវបានរងការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា រួមទាំងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ។

ករណីទី៥ :

• គណបក្សនយោបាយ **ក** និង គណបក្សនយោបាយ **ខ** ប្រកាសរួមបញ្ចូលគ្នាទៅជាគណបក្សនយោបាយតែមួយដោយបង្កើតគណបក្សនយោបាយថ្មីមួយទៀតឈ្មោះ **គ** ។

ករណីនេះ គណបក្សនយោបាយ **ក** និង **គណបក្សនយោបាយ ខ ត្រូវបានក្រសួងមហាផ្ទៃលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ** ។ ដូច្នេះ គណបក្សនយោបាយទាំងពីរ **ក** និង **ខ** ត្រូវបានរងការបាត់បង់អាសនៈនៅរដ្ឋសភា ព្រឹទ្ធសភា រួមទាំងក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ

- យល់ឃើញថា ទោះក្នុងករណីណាក៏ដោយ **គណបក្សនយោបាយណាមួយដែលបានទទួលអាសនៈមួយ** ឬច្រើន ហើយត្រូវបានក្រសួងមហាផ្ទៃប្រកាសលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និង បេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយនោះ មិនមានសុពលភាព និង មិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

សម្រេច

មាត្រា ១ ៖ មាត្រា ៣៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ ត្រូវបានបកស្រាយដូចមានចែងក្នុងមូលបទខាងលើ ។

មាត្រា ២ ៖ សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០១០ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១០

ប.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៤៩/០៨៧/២០១៧

ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៩២/០៣២/២០១៧ កបធ.ច

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញលិខិតលេខ ៣៨២ ស.ស. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំលើកទី៩ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឲ្យ យោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការ ប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ដែល អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២០ ខែ តុលា ឆ្នាំ២០១៧ វេលាម៉ោង ១១ និង ១០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាក្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុង មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុក ក្រុមប្រឹក្សាខណ្ឌ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុក ក្រុមប្រឹក្សាខណ្ឌ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានពីរមាត្រា និងមាន ខ្លឹមសារដូចខាងក្រោម ÷

មាត្រាមួយ .- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម

លេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ ÷

មាត្រា ១៣.- ស្នូន

មាត្រាពីរ.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ខាងលើនេះ បានធ្វើវិសោធនកម្មដោយបន្ថែមមាត្រា ១៣ ស្នូន ដែលចែងអំពី ការលែងមានសុពលភាព និងលែងមានគុណសម្បត្តិនៃបញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌទាំងអស់ក្នុងអាណត្តិនៃក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយ ការបែងចែកអាសនៈដែលនៅទំនេរ នោះដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន)ថ្ងៃ។ គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត អាចប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹង ជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ។ ការចាត់នីតិវិធីឡើងវិញ ក្នុងករណីពុំមានគណបក្សនយោបាយ ទទួលយកអាសនៈដែលនៅទំនេរដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ជិហានទាំងឡាយនៃការបែងចែកអាសនៈតាមករណីនីមួយៗ ។ ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ)

ថ្ងៃ ក្រោយពីបានទទួលសំណើ។ បែបបទនៃការទទួលពិនិត្យ និងការអនុម័តបេក្ខជនដែលស្នើសុំបន្ថែមនេះ ។ ករណីដែលចាត់ទុកគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈឲ្យនៅទំនេរ និង ការបែងចែកអាសនៈដែលនៅទំនេរដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេរនោះ ។

មាត្រានេះ ស្របតាមស្មារតីកថាខណ្ឌទី១ នៃមាត្រា ៥១ ថ្មី និងមាត្រា ១៥០ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ស្របតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សែវតាំ ហើយមាន

អានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវផ្សព្វ
ផ្សាយក្នុងរាជកិច្ច ។/.

រាជធានី ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ជ.ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

អ៊ុម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



រដ្ឋសភា

ក្រុមប្រឹក្សាធម្មនុញ្ញ
លេខ ៨៤/២០១៧
ថ្ងៃទី ២០/១០/ឆ្នាំ ២០១៧ ម៉ោង ១១:១០
ចូលបញ្ជីធម្មតា ឆ្នាំ ២០១៧

លេខ:៣៨៤.ស.ស.

សូមជម្រាបជូន

ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

សូមជ្រាប ។

កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

យោង: -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិតចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិត **ម៉ែន បញ្ញា** និងឯកឧត្តមបណ្ឌិតជ្ឍ **ជាម យៀប** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៤៩ រូប ។

-លិខិតលេខ ១០៧/១០១៧/ពស/នវ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា **ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ** ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ នាសម័យប្រជុំលើកទី ៩ នីតិកាលទី ៥ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែនាសម័យប្រជុំលើកទី ១១ នីតិកាលទី ៣ នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ ។

អាស្រ័យដោយ ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំ សូមឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានជូនភ្ជាប់មកជាមួយ ជាការប្រញាប់** តាមការគួរ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីស្រឡាញ់រាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន-



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៤៧/០៨៥/២០១៧

ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៩០/០៣០/២០១៧ កបធ.ច

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញលិខិតលេខ ៣៨០ រ.ស. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំលើកទី៩ នីតិកាលទី៥ និង

អាគារស រៃមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ

ព្រឹទ្ធសភា បានពិនិត្យនិងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១១ និង ១០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា មាន ពីរមាត្រា និងមានខ្លឹមសារដូចខាងក្រោម÷

មាត្រាមួយ .-

មាត្រា ៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៦ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ÷

មាត្រា ៣.- ថ្មី

មាត្រាពីរ.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាខាងលើនេះ ត្រូវបានធ្វើវិសោធនកម្មពីរមាត្រាដូចខាងក្រោម ÷

  មាត្រា ៣.- ថ្មី ចែងអំពី "*ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្តង នៅថ្ងៃអាទិត្យ សប្តាហ៍ទី៤ យ៉ាងយូរ មុនដំណាច់ឆ្នាំទី៦ នៃនីតិកាលព្រឹទ្ធសភា លើកលែងតែក្នុងករណីដែលមានចែងក្នុងបទប្បញ្ញត្តិមាត្រា ១០២ ថ្មី នៃរដ្ឋធម្មនុញ្ញ ។*

  កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

  នីតិកាលព្រឹទ្ធសភា ត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង។"

  មាត្រានេះ ស្របតាមស្មារតីមាត្រា ១០១ ថ្មី និងមាត្រា ១០២ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ស្របតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២. សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សព្វផ្សាយ ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានី ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



រដ្ឋសភា



លេខ: ១៤៥ ស.ស.

សូមជម្រាបជូន

ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

សូមជ្រាប ។

កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា ។

យោង: -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិតចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិត **ម៉ែន សញ្ញា** និងឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៤៩ រូប ។

-លិខិតលេខ ១០៥/១០១៧/ពស/នវ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា **ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា** ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ នាសម័យប្រជុំលើកទី ៩ នីតិកាលទី ៥ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែនាសម័យប្រជុំលើកទី ១១ នីតិកាលទី ៣ នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ ។

អាស្រ័យដោយ ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំ សូមឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានដូនគ្នាប់មកជាមួយ ជាការប្រញាប់** តាមការគួរ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីស្រឡាញ់រាប់អានពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន-

ទីស្តីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច:sg@nac.org.kh គេហទំព័រ: www.nac.org.kh



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៤៨/០៨៦/២០១៧

ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៩១/០៣១/២០១៧ កបធ.ច

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញលិខិតលេខ ៣៨១ រ.ស. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំលើកទី៩ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយ

ឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៧ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១១ និង ១០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិនិត្យក្បាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មានពីរមាត្រា និងមានខ្លឹមសារដូចខាងក្រោម ÷

មាត្រាមួយ.-

មាត្រា ២០ និងមាត្រា ២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ÷

មាត្រា ២០.- ថ្មី និង មាត្រា ២១.- ថ្មី

មាត្រាពីរ.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ខាងលើនេះ បានធ្វើវិសោធនកម្មពីរមាត្រាដូចខាងក្រោម ÷

• មាត្រា ២០.- ថ្មី ចែងអំពី ការលែងមានសុពលភាព និងលែងមានគុណសម្បត្តិនៃបញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយ ការបែងចែកអាសនៈដែលនៅទំនេរនោះដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅឲ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងឃុំ សង្កាត់ក្នុងអំឡុងពេលយ៉ាងយូរ ១៤ (ដប់បួន)ថ្ងៃ។ គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត អាចប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរនៅក្នុងឃុំ សង្កាត់ណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងអំឡុងពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ ។ ការចាត់នីតិវិធីឡើងវិញ ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេរដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ជំហានទាំងឡាយនៃការបែងចែកអាសនៈតាមករណីនីមួយៗ ។

មាត្រានេះ ស្របតាមស្មារតីកថាខណ្ឌទី១ នៃមាត្រា ៥១ ថ្មី និងមាត្រា ១៥០ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

• មាត្រា ២១.- ថ្មី រក្សាខ្លឹមសារមាត្រា ២១ ដោយបន្ថែមពាក្យ “ថ្មី” ពីក្រោយពាក្យ “មាត្រា ២០” ។

មាត្រានេះ ស្របតាមស្មារតីកថាខណ្ឌទី១ នៃមាត្រា ៥១ ថ្មី និងមាត្រា ១៥០ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ស្របតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យនិងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២. សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានី ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ឱម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ





ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ ៧៥/២០១៧
ថ្ងៃ ២០/១០/២៣ ម៉ោង ១១:១០
បញ្ជូត ...

រដ្ឋសភា

លេខ:ពាជ ...

សូមជម្រាបជូន

ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

សូមជ្រាប ។

កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ។

យោង: -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិតចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិត **ប៉ែន បញ្ញា** និងឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៤៩ រូប ។

-លិខិតលេខ ១០៦/១០១៧/ពស/នវ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា **ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់** ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ នាសម័យប្រជុំលើកទី ៩ នីតិកាលទី ៥ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែនាសម័យប្រជុំលើកទី ១១ នីតិកាលទី ៣ នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ ។

អាស្រ័យដោយ ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំ សូមឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានជូនភ្ជាប់មកជាមួយ ជាការប្រញ្ញាប់** តាមការគួរ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីស្រឡាញ់រាប់អានរាំពី ខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រនិច:sq@nac.org.kh គេហទំព័រ: www.nac.org.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋាន

លេខ : ១០៥/២០១៧ អ.កបធ.សជណ

អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ

សូមគោរពជូន

ឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា

កម្មវត្ថុ : -សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ១៨៩/០២៩/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧
-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ១៩០/០៣០/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧
-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ១៩១/០៣១/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧
-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ១៩២/០៣២/២០១៧ កបធ.ច ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

យោង : មាត្រា២៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា មេត្តាជ្រាបថា ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំពេញអង្គ នាថ្ងៃអង្គារ ទី២៤ ខែតុលា ឆ្នាំ២០១៧ ដើម្បីពិនិត្យសំណើលេខ ៣៧៩ ស.ស. លេខ ៣៨០ ស.ស. លេខ ៣៨១ ស.ស. និង លេខ ៣៨២ ស.ស. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងបានចេញជាសេចក្តីសម្រេច ដូចមានភ្ជាប់ជូនមកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការមេត្តាជ្រាប និងយកសេចក្តីជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភា ឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ នៃព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាទាំងអស់បានជ្រាបតាមការគួរ។

សូមឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ម៉ែន គីមលី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៤៦/០៨៤/២០១៧

ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៨៩/០២៩/២០១៧ កបធ.ច

ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៣៧៩ រ.ស. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំលើកទី៩ នីតិកាលទី៥ និងព្រឹទ្ធសភា

អាគារស រិមានវដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១ ២៣ ៧២០ ៩១៣. E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh , ប្រអប់សំបុត្រ ២៤៨៣

បានពិនិត្យនិងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលលិខិតខាងលើនេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១១ និង ១០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានពិនិត្យក្បាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង ការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រមានពីរមាត្រា និងមានខ្លឹមសារដូចខាងក្រោម÷

មាត្រាមួយ .- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ÷

មាត្រា ១៣៨.- ស្នង

មាត្រាពីរ.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រខាងលើនេះ បានធ្វើវិសោធនកម្មដោយបន្ថែមមាត្រា ១៣៨ ស្ទួន ដែលចែងអំពី ការលែងមានសុពលភាព និងលែងមានគុណសម្បត្តិនៃបញ្ជីបេក្ខជន និងតំណាងរាស្ត្រនៃគណបក្សនយោបាយក្នុងនីតិកាលនៃរដ្ឋសភា ប្រសិនបើគណបក្សនយោបាយណាមួយប្រកាសបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវរំលាយ ។ ការបែងចែកអាសនៈដែលនៅទំនេរនោះដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ)ថ្ងៃ ទៅឱ្យគណបក្សនយោបាយនានាដែលបានចូលរួមក្នុងការបោះឆ្នោត ក្នុងរាជធានី ខេត្តជាមួយ ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាដែលដឹកនាំរាជរដ្ឋាភិបាល ។ ជំហាននិងរូបមន្តនៃការគណនាបែងចែកអាសនៈ មាន៣ជំហាន ជំហានទី១ កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួល ០១ (មួយ)អាសនៈ ជំហានទី២ កំណត់ចំនួនអាសនៈជាបឋមដែលគណបក្សនយោបាយនីមួយៗបានទទួល និងជំហានទី៣ អាសនៈដែលនៅសល់ ត្រូវបែងចែកដោយមធ្យមភាគខ្ពស់បំផុត ។ ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនតិចជាងអាសនៈនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃក្រោយពីបានទទួលសំណើ។ បែបបទនៃការទទួលពិនិត្យនិងអនុម័តបេក្ខជនដែលស្នើសុំបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រាមួយចំនួននៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ករណីដែលចាត់ទុកគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈឱ្យនៅទំនេរ និងការបែងចែកអាសនៈដែលនៅទំនេរដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេរនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈដែលនៅទំនេរនោះ ឱ្យទៅគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

មាត្រានេះ ស្របតាមស្មារតីកថាខណ្ឌទី១ នៃមាត្រា ៥១ ថ្មី កថាខណ្ឌទី៥ នៃមាត្រា ៧៦ ថ្មី និងមាត្រា ១៤០ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រាពីរ ដែលចែងថា ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ស្របតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំលើកទី១១ នីតិកាលទី៣ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានី ភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ



អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ: ៧៣៧/១៧

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូលថ្ងៃ ទី ២០/១០/២០១៧ ម៉ោង ១១:១០
ឯកសារ ស្នើសុំពិនិត្យច្បាប់

សូមជម្រាបជូន

ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

សូមជ្រាប ។

កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

យោង: -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិតចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិត **ម៉ែន បញ្ញា** និងឯកឧត្តមបណ្ឌិតជ **ជាម យៀប** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៤៩ រូប ។

-លិខិតលេខ ១០៤/១០១៧/ពស/នវ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា **ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៧ នាសម័យប្រជុំលើកទី ៩ នីតិកាលទី ៥ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែនាសម័យប្រជុំលើកទី ១១ នីតិកាលទី ៣ នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧ ។

អាស្រ័យដោយ ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំ សូមឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានជូនភ្ជាប់មកជាមួយ ជាការប្រញាប់** តាមការគួរ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីស្រឡាញ់រាប់អានពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន-

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ : ៧៩/ ២០១៧ អ.កបធ.សជណ

អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ
សូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា

កម្មវត្ថុ ៖ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ១៨៧/០២៧/២០១៧ កបធ.ច ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧។

យោង ៖ មាត្រា២៤ថ្មីនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃអង្គារ ទី២៥ ខែកក្កដា ឆ្នាំ២០១៧ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើ លេខ ២៤៦.រស. ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាស្នើសុំ ក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធន-កម្មច្បាប់ស្តីពីគណបក្សនយោបាយ និងបានចេញជាសេចក្តីសម្រេចដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការមេត្តាជ្រាប និងយកសេចក្តីជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភា ឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ នៃព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាទាំងអស់បានជ្រាបតាមការគួរ។

សូមឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា មេត្តាទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

ម៉េង គឹមលី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៤៤/០៨២/២០១៧

ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៨៧/០២៧/២០១៧ កបធ.ច

ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញលិខិតលេខ ២៤៦.រស. ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់

ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំ លើកទី៨ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ ក្នុងសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ៩:៣០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ៖

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ មាន **ពីរមាត្រា** និងមានខ្លឹមសារដូចខាងក្រោម÷

មាត្រាមួយ.- ច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ÷

-មាត្រា ៦ថ្មី មាត្រា ១១ និងមាត្រា ៤៤ថ្មី ត្រូវបានកែប្រែ និងត្រូវបានបន្ថែមមាត្រា ៤៥ថ្មី (ស្នង) និងមាត្រា ៤៨ថ្មី (ស្នង)។

មាត្រាពីរ.-ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា **មាត្រាមួយ**នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ខាងលើនេះ បានធ្វើការកែប្រែទៅលើ ០៣ មាត្រា និងបន្ថែម ០២ មាត្រា ដូចខាងក្រោម÷

- មាត្រា៦.-ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៦.-ថ្មី (ពីរ) ដោយមានបន្ថែម ៣ ចំណុច គឺចំណុចទី៦ ទី៧ និងទី៨÷

  ចំណុចទី៦-*ប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។*

  ចំណុចទី៧-*យល់ព្រមដោយចំហ ឬដោយតុណ្ហីភាព ឬឃុបឃិតជាមួយទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ឲ្យធ្វើសកម្មភាពណាមួយដើម្បីជាផលប្រយោជន៍នយោបាយ សម្រាប់គណបក្សនយោបាយរបស់ខ្លួន។*

  ចំណុចទី៨-*គាំទ្រ ឬរៀបចំផែនការ ឬឃុបឃិតជាមួយរាល់បុគ្គលដែលធ្វើសកម្មភាពក្នុងគោលបំណងប្រឆាំងនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ដូចមានចែងពីចំណុចទី១ ដល់ចំណុចទី៥ ខាងលើ។*

  មាត្រានេះ ស្របតាមស្មារតីនៃកថាខ័ណ្ឌទី១ នៃមាត្រា ៤១ មាត្រា ៤២ និងមាត្រា ៥២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា ១១.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១១.-ថ្មី ដែលចែងពី "*គ្រប់គណបក្សនយោបាយត្រូវមានឈ្មោះ និងសញ្ញាសម្គាល់តាមការកំណត់ ដូចខាងក្រោម÷*

  ១-ឈ្មោះជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយត្រូវតែខុសគ្នាពីឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយនានា។

២-ឈ្មោះរបស់គណបក្សនយោបាយ មិនត្រូវធ្វើឡើងដោយគ្រាន់តែកែសម្រួលបន្តិចបន្តួចនៅលើឈ្មោះគណបក្សនយោបាយនានា ឬយកឈ្មោះរូបវន្តបុគ្គលមកដាក់ឡើយ។

៣-សញ្ញាសម្គាល់របស់គណបក្សនយោបាយមិនត្រូវចម្លង ឬយកតាមសញ្ញាជាតិ រូបតំណាងឱ្យសាសនា ប្រាសាទអង្គរវត្ត ឬព្រះឆាយាលក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់អង្គ ឬរូបភាពរបស់រូបវន្តបុគ្គលឡើយ។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា ៤៤.-ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៤៤.-ថ្មី (ពីរ) ដែលចែងពី *"ដោយមិនគិតជល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦ ថ្មី (ពីរ) នៃច្បាប់នេះ និងមាត្រា៧ នៃច្បាប់ស្តីពីគណបក្សនយោបាយ តុលាការអាចសម្រេចដូចខាងក្រោម÷*

- ផ្អាកសកម្មភាពគណបក្សនយោបាយនោះមិនលើសពី ៥ (ប្រាំ) ឆ្នាំ

- រំលាយគណបក្សនយោបាយនោះ។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៥.-ថ្មី (ស្នង) ចែងពី *"គណបក្សនយោបាយដែលត្រូវបានសម្រេចផ្អាកសកម្មភាព មិនត្រូវបានអនុញ្ញាតឱ្យចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ។*

ត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងករណីដែលគណបក្សនយោបាយនោះត្រូវបានសម្រេចផ្អាកសកម្មភាព ឬត្រូវបានសម្រេចរំលាយស្របតាមច្បាប់នេះ។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ និងមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៨.-ថ្មី (ស្នង) ចែងពី *"ចំពោះគណបក្សនយោបាយណាដែលមានឈ្មោះ ឬសញ្ញាសម្គាល់របស់គណបក្សនយោបាយជាឈ្មោះ ឬរូបភាពរបស់រូបវន្តបុគ្គល ត្រូវធ្វើការផ្លាស់ប្តូរឈ្មោះ ឬសញ្ញាសម្គាល់ ឱ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា **មាត្រាមួយ** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **មាត្រាពីរ** ដែលចែងថាច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ស្របតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យនិងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ដោយឥតកែប្រែ និងចាត់ទុកជាការប្រញាប់ក្នុងសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ នាថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២. សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ: ២៤៦.រស.

សូមជម្រាបជូន **ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

សូមជ្រាប ។

កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ ។

យោង: -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិតចុះថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិត **ប៉ែន បញ្ញោ** និងឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៤១ រូប ។

-លិខិតលេខ ០៧០/០៧១៧/ពស/នវ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា **ច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ** ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ នាសម័យប្រជុំលើកទី ៨ នីតិកាលទី ៥ ហើយព្រឹទ្ធសភាក៏បានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី ៣ នាថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧ ។

អាស្រ័យដោយហេតុថា ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំ សូមឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានជូនភ្ជាប់មកជាមួយ ជាការប្រញាប់** តាមការគួរ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពី ខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន-

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៤៣/០៨១/២០១៧

ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៨៦/០២៦/២០១៧ កបធ.ច

ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុម-ប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែ មីនា ឆ្នាំ២០១៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ២១៦ រ.ស ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបាន

អនុម័តនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី១០ នីតិកាលទី៣ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង ១៦ និង ២០នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិសាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភានិងព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះ មកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា គឺពីមាត្រា ១ ដល់មាត្រា ៣ ដែលចែងអំពីគោលដៅកំណត់ការរៀបចំបែបបទ និងការប្រព្រឹត្តទៅនៃការចាត់តាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និងមណ្ឌលបោះឆ្នោត ការគ្រប់គ្រងការបោះឆ្នោត ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាត្រូវធ្វើឡើង ០៦ (ប្រាំមួយ) ឆ្នាំម្តង កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី១ នេះស្របតាមមាត្រា ១០១ថ្មី មាត្រា ១០២ថ្មី និង មាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី២ ស្តីពីចំនួនសមាជិកព្រឹទ្ធសភា ប្រព័ន្ធបោះឆ្នោត មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈ មាន ៦មាត្រា គឺពីមាត្រា ៤ ដល់មាត្រា ៩

ដែលចែងអំពីចំនួនសមាជិកព្រឹទ្ធសភា ស្ថាប័នចាត់តាំងនិងជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតត្រូវធ្វើឡើងដោយអសកល មិនចំពោះតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ការបោះឆ្នោតត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រ ការរៀបចំនិងបែងចែក មណ្ឌលបោះឆ្នោត និងការកំណត់ចំនួនអាសនៈនៅក្នុងព្រឹទ្ធសភា។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៦ នៃជំពូកទី២ នេះ ស្របតាមមាត្រា ៩៩ថ្មី មាត្រា ១០០ថ្មី និងមាត្រា ១០១ថ្មី នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៣ ស្តីពីអ្នកបោះឆ្នោត អង្គបោះឆ្នោត បញ្ជីបោះឆ្នោត និង ការិយាល័យបោះឆ្នោត មាន ៣ មាត្រា គឺពីមាត្រា ១០ ដល់មាត្រា ១២ ដែលចែង អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត រយៈពេលនៃការរៀបចំបញ្ជីបោះឆ្នោត និងការផ្តល់ សុពលភាពលើបញ្ជីបោះឆ្នោត លក្ខខណ្ឌនៃអ្នកមានសិទ្ធិបោះឆ្នោត និងការរៀបចំ ការិយាល័យបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៣ នេះ ស្របតាម មាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៤ ស្តីពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ មាន ៣ មាត្រា គឺពីមាត្រា ១៣ ដល់មាត្រា ១៥ ដែល ចែងអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរ ឈ្មោះ ត្រូវអនុវត្តតាមមាត្រា ២៣ ដល់មាត្រា ៣៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើស តាំងតំណាងរាស្ត្រ។ ការកំណត់អាយុរបស់បេក្ខជន បញ្ជីរាយនាមបេក្ខជនពេញសិទ្ធិ និង បម្រុង។ បទបញ្ជា និងនីតិវិធី ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៤ នេះ ស្របតាមមាត្រា ៣៤ថ្មី មាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៥ ស្តីពីការឃោសនាបោះឆ្នោត មាន ៣ មាត្រា គឺពីមាត្រា ១៦ ដល់មាត្រា ១៨ ដែលចែងអំពីគោលបំណងនៃការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយ ទីកន្លែងនៃការឃោសនា។ យុទ្ធនាការឃោសនាមានរយៈពេល ១៤ (ដប់បួន)ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោងមុនថ្ងៃបោះឆ្នោត។ ការឃោសនាបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវ អនុវត្តតាមមាត្រា ៦៨ ៦៩ ៧០ ៧១ កថាខ័ណ្ឌទី២ នៃមាត្រា ៧២ មាត្រា ៧៣ ៧៤

៧៥ ៧៦ ៧៧ ៧៨ ៧៩ ៨០ ៨១ ៨២ ៨៣ ៨៤ ៨៥ ៨៦ ៨៧ ៨៨ ៨៩ ៩០ និងមាត្រា ៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការហែក្បួនក្នុងមណ្ឌលភូមិភាគនីមួយៗអាចធ្វើបានយ៉ាងច្រើន ២ (ពីរ)ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៥ នេះ ស្របតាមមាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៦ ស្តីពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតមាន២មាត្រា គឺមាត្រា១៩និងមាត្រា២០ ដែលចែងអំពីគណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួនដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ។ សិទ្ធិ តួនាទី និងលក្ខខណ្ឌផ្សេងៗក្នុងការស្នើសុំជាភ្នាក់ងារគណបក្សនយោបាយត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ ការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវអនុវត្តតាមមាត្រា ១០ ដល់មាត្រា ២២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៦ នេះ ស្របតាមមាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៧ ស្តីពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត មាន ៤ មាត្រា គឺពីមាត្រា ២១ ដល់មាត្រា ២៤ ដែលចែងអំពីការបោះឆ្នោតត្រូវធ្វើតែ ១ (មួយ)ថ្ងៃ ចាប់ពីម៉ោង ៧:០០ (ប្រាំពីរ)ព្រឹក រហូតដល់ម៉ោង ១៥:០០(ដប់ប្រាំ) លើកលែងតែមានសេចក្តីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវរាប់សន្លឹកឆ្នោតនៅនឹងកន្លែង ក្រោយការប្រកាសបញ្ចប់ការបោះឆ្នោត។ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោតត្រូវបញ្ជូនកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោតនៅក្នុងរាជធានី ខេត្តរបស់ខ្លួនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីបូកសរុបលទ្ធផលតាមភូមិភាគនីមួយៗ។ មាត្រាទាំងឡាយដែលមានចែងក្នុងជំពូកទី៨ អំពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត លើកលែងតែមាត្រា ៩២

១០៣ ១១៦ ១២៣ ១២៦ និងមាត្រា ១២៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។បទប្បញ្ញត្តិក្នុងមាត្រាទាំង ៤ នៃជំពូកទី៧ នេះ ស្របតាមមាត្រា ១០១ថ្មី និងមាត្រា ១៥០ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី៨ ស្តីពីសមត្ថកិច្ចដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោត មាន ៣ មាត្រា គឺពីមាត្រា ២៥ ដល់មាត្រា ២៧ ដែលចែងអំពីសមត្ថកិច្ចក្នុងការសម្រេចលើករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងនីតិវិធីដោះស្រាយវិវាទដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការដោះស្រាយករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ៣ នៃជំពូកទី៨ នេះ ស្របតាមមាត្រា ១០១ថ្មី កថាខ័ណ្ឌទី២ នៃមាត្រា ១៣៦ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី៩ ស្តីពីការបាត់បង់អាសនៈនៃព្រឹទ្ធសភា និងការជ្រើសតាំងសមាជិកជំនួស មាន ២ មាត្រា គឺមាត្រា ២៨ និង មាត្រា ២៩ ដែលចែងអំពីការបោះបង់ចោលអាសនៈរបស់គណបក្សនយោបាយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការបាត់បង់សមាជិកភាពជាសមាជិកព្រឹទ្ធសភា និងការចាត់តាំង ឬជ្រើសតាំង ឬជ្រើសរើសសមាជិកជំនួស។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី៩ នេះ ស្របតាមមាត្រា ១១៥ថ្មី និងមាត្រា ១៥០ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ជំពូកទី១០ ស្តីពីទោសប្បញ្ញត្តិ មាន ១ មាត្រា គឺមាត្រា ៣០ ដែលចែងអំពីជំពូកស្តីពីទោសប្បញ្ញត្តិនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។ បទប្បញ្ញត្តិក្នុងមាត្រា ៣០ នៃជំពូកទី១០ នេះ ស្របតាមកថាខ័ណ្ឌទី២ នៃមាត្រា ៣១ កថាខ័ណ្ឌទី១ នៃមាត្រា ៤១ និងមាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញ

- យល់ឃើញថា ជំពូកទី១១ ស្តីពីអវសានប្បញ្ញត្តិ មាន ២ មាត្រា គឺមាត្រា ៣១ និង មាត្រា ៣២ ដែលចែងអំពីបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជា និរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ។ ច្បាប់នេះត្រូវប្រកាសជាការប្រញាប់។ បទប្បញ្ញត្តិក្នុងមាត្រាទាំង ២ នៃជំពូកទី១១ នេះស្របតាមមាត្រា ៩៣ថ្មី នៃរដ្ឋធម្មនុញ្ញ។
- យល់ឃើញថា ខ្លឹមសារទាំង ១១ ជំពូក ៣២ មាត្រា នៃច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

សម្រេច

មាត្រា ១- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ និង ព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ ដោយឥតកែប្រែក្នុងសម័យប្រជុំ លើកទី១០ នីតិកាលទី៣ នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

អ៊ឹម ឈុនលឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ ៖ ៧៧/២០១៧ អ.កបធ.សជណ

អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ

សូមគោរពជូន

ឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា

កម្មវត្ថុ ៖ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៨៦/០២៦/២០១៧ កបធ.ច ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧។

យោង ៖ មាត្រា២៤ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើលេខ ២១៦ រ.ស ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងបានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងយកសេចក្តីជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភា ឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ នៃព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាទាំងអស់បានជ្រាបតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ ទទួលនូវការរាប់អានដ៏ប្រពៃអំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧

ម៉ែន គីមលី

អាគារស រិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២៦ ០៣១. E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh ,ប្រអប់សំបុត្រ ២៨៣ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
លេខ ៤៥/ ២០១៧
ថ្ងៃ ៣០/ ៦/ ១៧ ម៉ោង ៤ ២០
ហ្ជាត ...

រដ្ឋសភា
-លេខ: ២១៦.រស.

សូមជម្រាបជូន

ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

សូមជ្រាប ។

កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

យោង: -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិតចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៧ របស់ឯកឧត្តម អ៊ុក ប៊ុនឈឿន ឯកឧត្តម យ៉ង សែម ឯកឧត្តម គង់ សារាជ ឯកឧត្តម ជា ដេដ្ឋ និងលោកជំទាវ មាន សំអាន តំណាងក្រុមសមាជិកព្រឹទ្ធសភាហត្ថលេខីចំនួន ២៣ រូប ។

-លិខិតលេខ:០៥៥/០៦១៧/ពស/នវ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា **ច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា** ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៧ នាសម័យប្រជុំលើកទី ៨ នីតិកាលទី ៥ ហើយព្រឹទ្ធសភាក៏បានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំលើកទី ១០ នីតិកាលទី ៣ នាថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៧ ។

អាស្រ័យដោយហេតុថា ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំ សូមឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានជូនភ្ជាប់មកជាមួយ ជាការប្រញ្ញាប់** តាមការគួរ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពី ខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន-

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ : ៣៦/២០១៧ អ.កបធ.សជណ

អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ
សូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា

កម្មវត្ថុ ៖ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ១៨៥/០២៥/២០១៧ កបធ.ច ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧។

យោង ៖ មាត្រា២៤ថ្មីនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃសុក្រ ទី០៣ ខែមីនា ឆ្នាំ២០១៧ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើលេខ ០៧៥ រ.ស ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយនិងបានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការមេត្តាជ្រាប និងយកសេចក្តីជម្រាបជូនសម្តេចប្រធានព្រឹទ្ធសភា ឯកឧត្តមអនុប្រធានទី១ ឯកឧត្តមអនុប្រធានទី២ នៃព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភាទាំងអស់បានជ្រាបតាមការគួរ។

សូមឯកឧត្តមអគ្គលេខាធិការនៃព្រឹទ្ធសភា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧

ម៉ែន គីមលី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ





សូមជម្រាបជូន
ឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

រដ្ឋសភា

សូមជ្រាប ។

-លេខ. ០៧៥.រស.

កម្មវត្ថុ: ការពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ ។

យោង: -មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ

-មាត្រា ១៦ ថ្មី ផ្នែកទី ២ ជំពូកទី ២ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-លិខិត ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** និងឯកឧត្តម **ឈាង ភុន** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៦០ រូប

-លិខិតលេខ ០១៧/០២១៧/ពស/នវ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ របស់ព្រឹទ្ធសភា

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជម្រាបជូន **ឯកឧត្តមប្រធាន** ជ្រាបថា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានទទួលសេចក្តីស្នើរបស់ឯកឧត្តមបណ្ឌិតរដ្ឋ **ជាម យៀប** និងឯកឧត្តម **ឈាង ភុន**តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីចំនួន ៦០ រូប សុំឲ្យរដ្ឋសភាពិនិត្យ និងអនុម័តសេចក្តីស្នើច្បាប់ស្តីពី **វិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ ។**

រដ្ឋសភាអនុម័តយល់ព្រមលើសេចក្តីស្នើ វិសោធនកម្ម ខាងលើដោយទទួលបានចំនួន ៦៦ សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូលនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ ហើយព្រឹទ្ធសភាក៏បានពិនិត្យ និងឲ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់ និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី ៣ នាថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៧ ។

អាស្រ័យដោយហេតុថា ច្បាប់នេះជាច្បាប់រៀបចំអង្គការ ខ្ញុំសូមជូនឯកឧត្តមប្រធានចាត់ **ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ខាងលើនេះ ដែលមានជូនភ្ជាប់មកជាមួយជាការប្រញាប់** តាមការគួរ ។

ខ្ញុំសូម **ឯកឧត្តម** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

រាជធានីភ្នំពេញ ,ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៧

ប្រធានរដ្ឋសភា

សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន

ចម្លងជូន:
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
ដើម្បីជ្រាបជាព័ត៌មាន-

ទីស្នាក់ការរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ៣៤២/០៨០/២០១៧

ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧

សេចក្តីសម្រេច

លេខ : ១៨៥/០២៥/២០១៧ កបធ.ច

ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានឃើញលិខិតលេខ ០៧៥ រ.ស ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យនិងឱ្យយោបល់ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែ ក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ១០:០០ ព្រឹក។

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករបាយការណ៍

ក្រោយពីបានពិភាក្សាគ្រឹះត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ និងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របតាមមាត្រា១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និងការអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយស្របនឹងរដ្ឋធម្មនុញ្ញ
- យល់ឃើញថា ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ មាន **ពីរមាត្រា** និងមានខ្លឹមសារដូចខាងក្រោម÷

មាត្រាមួយ.- ច្បាប់ស្តីពីគណបក្សនយោបាយដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ÷

-ចំណងជើងជំពូកទី៤ ត្រូវបានកែប្រែទៅជាជំពូកទី៤ថ្មី អង្គការនានា និងថ្នាក់ដឹកនាំរបស់គណបក្សនយោបាយ។

-ចំណងជើងជំពូកទី៩ ត្រូវបានកែប្រែទៅជាជំពូកទី៩ថ្មី វិធានការរដ្ឋបាល និងទោសប្បញ្ញត្តិ។ មាត្រា៦ មាត្រា១២ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២៥ មាត្រា២៦ មាត្រា២៩ មាត្រា៣៤ និងមាត្រាទាំងឡាយពីជំពូកទី៩ ដល់ជំពូកទី១១។

មាត្រាពីរ.-ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់

- យល់ឃើញថា មាត្រាមួយនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយខាងលើនេះ បានធ្វើវិសោធនកម្មទៅលើ ២២ មាត្រា ដូចខាងក្រោម÷
  - មាត្រា៦.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៦.-ថ្មី ដោយមានបន្ថែម ២ ចំណុច÷

  " - ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ

  - ធ្វើការញុះញង់ដែលអាចនាំឱ្យមានការបែកបាក់ជាតិ "

  បទប្បញ្ញត្តិដទៃទៀត ត្រូវបានរក្សាខ្លឹមសារដើមដដែល

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា៤១ និងមាត្រា៥២ នៃរដ្ឋធម្មនុញ្ញ
  - មាត្រា១២.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១២.-ថ្មី ដែលចែងពី *"មានតែប្រជាពលរដ្ឋខ្មែរដែលមានអាយុយ៉ាងតិច១៨(ដប់ប្រាំបី)ឆ្នាំ និងមានសិទ្ធិពលរដ្ឋប៉ុណ្ណោះ ដែលអាចចូលជាសមាជិកគណបក្សនយោបាយបាន។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា៣៤ ថ្មី និងមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា១៧.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១៧.-ថ្មី ដោយមានបន្ថែមថ្មី ២ វាក្យខណ្ឌ វាក្យខណ្ឌទី៣ និងទី៤ ដែលចែងពី *"គណបក្សនយោបាយនីមួយៗ ត្រូវរៀបចំឲ្យមានប្រធាន និងអាចមានអនុប្រធានតាមការចាំបាច់។ ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ត្រូវជ្រើសរើសដោយអនុវត្តតាមលក្ខន្តិកៈនៃគណបក្សនយោបាយនីមួយៗ។*

អាណត្តិ ភារកិច្ច ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការដឹកនាំរបស់គណបក្សនយោបាយនីមួយៗ ដូចមានចែងខាងលើនេះ ព្រមទាំងអង្គការដឹកនាំផ្សេងទៀតរបស់គណបក្សនយោបាយត្រូវកំណត់ក្នុងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយ។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា១៨.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១៨.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"ពលរដ្ឋទាំងពីរភេទ ដែលមានសញ្ជាតិខ្មែរពីកំណើត និងមានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ អាចធ្វើជាប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬធ្វើជាសមាសភាពនៃអង្គការដឹកនាំនៃគណបក្សនយោបាយបាន។*

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ មិនត្រូវជាបុគ្គលដែលជាទណ្ឌិតជាប់ទោសជាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសឡើយ។

ប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវបាត់បង់ឋានៈទីរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម÷

- សាមីខ្លួនទទួលមរណភាព។

- សាមីខ្លួនបានសុំលាឈប់ជាលាយលក្ខណ៍អក្សរ។

- សាមីខ្លួនត្រូវបានផ្តន្ទាទោសជាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដោយគ្មានការព្យួរទោសលើកលែងតែទោសនោះត្រូវបានលើកលែងទោសដោយព្រះមហាក្សត្រ។

គណបក្សនយោបាយ ត្រូវចាត់នីតិវិធីដើម្បីជំនួសប្រធានគណបក្សនយោបាយដែលបាត់បង់ឋានៈទី ដូចមានចែងក្នុងកថាខណ្ឌខាងលើ ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប)ថ្ងៃ គិតពីថ្ងៃបាត់បង់ឋានៈទីនោះ។

បទប្បញ្ញត្តិនេះ ក៏ត្រូវយកទៅអនុវត្តផងដែរចំពោះបុគ្គលដែលមានឋានៈទី ឬសិទ្ធិអំណាចប្រហាក់ប្រហែលទៅនឹងប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មា-

ធិការនាយក ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈ-កម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៣៤ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា១៩.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា១៩.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី *"ក្នុងរយៈពេលយ៉ាងយូរ ១៨០ (មួយរយប៊ីតសិប)ថ្ងៃ បន្ទាប់ពីគណបក្សនយោបាយ ត្រូវបាន បង្កើតឡើងស្របតាមមាត្រា៩ នៃច្បាប់នេះ គណបក្សនយោបាយនោះត្រូវស្នើសុំចុះបញ្ជីនៅក្រសួង មហាផ្ទៃ ដើម្បីទទួលបានសុពលភាព និងអាចធ្វើសកម្មភាពបានដោយស្របច្បាប់ក្នុងឋានៈជា នីតិបុគ្គល ដោយត្រូវមានសមាជិកយ៉ាងតិច ៤០០០ (ប្អូនពាន់)នាក់ និងត្រូវបំពេញបែបបទ និង លក្ខខណ្ឌដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។*

គណបក្សនយោបាយដែលមិនទទួលបានការចុះបញ្ជី ស្របតាមបទប្បញ្ញត្តិនៃជំពូកនេះ មិនអាចធ្វើសកម្មភាពនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា២៥.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា២៥.-ថ្មី ដោយកែប្រែពាក្យពី *"ក្រមប្រឹក្សាធម្មនុញ្ញ"* ទៅជា *"តុលាការកំពូល"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា២៦.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា២៦.-ថ្មី ដោយមានបន្ថែមថ្មី២វាក្យខណ្ឌ គឺ វាក្យខណ្ឌទី១ និងទី២ ដែលចែងពី:

"គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ ត្រូវបញ្ជូនទៅក្រសួងមហាផ្ទៃនូវបញ្ជី ឈ្មោះប្រធាន និងអនុប្រធាននៃគណបក្សនយោបាយ ក្នុងករណីដែលមានអនុប្រធាន និងសមាសភាពនៃគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹង គណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណបក្សនយោបាយ ដោយភ្ជាប់មកជាមួយ នូវជីវប្រវត្តិសង្ខេប ដែលមានចិន្ហរបថតទំហំ ០៤ (ប្អូន) គុណនឹង ០៦ (ប្រាំមួយ) ។

ការផ្លាស់ប្តូរប្រធាន ឬអនុប្រធាននៃគណបក្សនយោបាយ ឬសមាសភាពនៃគណៈកម្មាធិការ នាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលនឹងគណៈកម្មាធិការនាយក ឬគណៈកម្មាធិការ អចិន្ត្រៃយ៍នៃគណបក្សនយោបាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយ ភ្ជាប់មកជាមួយនូវជីវប្រវត្តិសង្ខេបរបស់សមាសភាពថ្មី ដែលមានចិន្ហរបថតទំហំ ០៤ (ប្អូន) គុណ នឹង០៦ (ប្រាំមួយ)។

គណបក្សនយោបាយដែលបានចុះបញ្ជីរួចហើយ អាចប្តូរឈ្មោះ សញ្ញាសម្គាល់ ទីស្នាក់ការ កណ្តាល កែប្រែគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ ឬធ្វើវិសោធនកម្មលើលក្ខន្តិក:

បាន ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយខ្លួន។ ក្នុងករណីនេះគណបក្សនយោបាយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារដែលកែប្រែរួចហើយ។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា២៩.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា២៩.-ថ្មី ដោយកែប្រែពាក្យ *"អង្គការក្រៅរដ្ឋាភិបាល"* ទៅជា *"អង្គការមិនមែនរដ្ឋាភិបាល"* ដើម្បីឲ្យស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបន្ថែមមួយវាក្យខណ្ឌ ដែលចែងពី *"គណបក្សនយោបាយត្រូវបានហាមឃាត់មិនឱ្យទទួលវិភាគទាន ទោះតាមរូបភាពណាក៏ដោយពីស្ថាប័នបរទេស ក្រុមហ៊ុនបរទេស ជនបរទេស ឬអង្គការដែលមានប្រភពហិរញ្ញប្បទានពីបរទេស។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ
- មាត្រា៣៤.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៣៤.-ថ្មី ដែលចែងពី *"គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សនយោបាយណាមួយបានឡើយ លើកលែងគណបក្សនោះ ត្រូវបានរំលាយដោយតុលាការ។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ
- មាត្រា៣៨.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៣៨.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី *"គ្រប់គណបក្សនយោបាយទាំងអស់ត្រូវគោរពរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា។*

  ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តខុសទៅនឹងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃអាចចាត់វិធានការដូចខាងក្រោម÷

  - ចេញលិខិតជូនដំណឹងឲ្យគណបក្សនយោបាយនោះ ធ្វើការកែតម្រូវក្នុងរយៈពេលមួយជាកំណត់។

  - ធ្វើការព្រមានជាលាយលក្ខណ៍អក្សរ និងចាត់វិធានការបញ្ឈប់សកម្មភាពខុសច្បាប់ក្នុងករណីចាំបាច់។

  - សម្រេចផ្អាកសកម្មភាពរបស់គណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់។

  - ប្តឹងទៅតុលាការកំពូល ដើម្បីរំលាយគណបក្សនយោបាយនោះ ក្នុងករណីកំហុសមានលក្ខណៈធ្ងន់ធ្ងរ។

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៥២ និង មាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៣៩.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៣៩.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៣៨ ចាស់ ដែលចែងពី *"ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០ (ប្រាំលាន)រៀលដោយក្រសួងមហាផ្ទៃ ចំពោះគណបក្សនយោបាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៣១នៃច្បាប់នេះ។*

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ផាកពិន័យជាប្រាក់ទ្វេមួយជាពីរ ហើយក្រសួងមហាផ្ទៃអាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្ន ក្នុងរយៈពេលមួយជាកំណត់។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤០.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤០.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៣៩ ចាស់ ដែលចែងពី *"គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយក្រសួងមហាផ្ទៃចំនួន ២០ ០០០ ០០០ (ម្ភៃលាន)រៀល។ ក្នុងករណីវិភាគទាន ដែលគណបក្សនយោបាយបានទទួលដោយល្មើសនឹងមាត្រា២៩ថ្មី នៃច្បាប់នេះ មានតម្លៃលើសពី ២០ ០០០ ០០០ (ម្ភៃលាន)រៀល ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃតម្លៃនៃវិភាគទាននោះ។ ក្រសួងមហាផ្ទៃ អាចសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះជាបណ្តោះអាសន្នក្នុងរយៈពេលមួយជាកំណត់។*

ក្នុងករណីនៅតែបន្តប្រព្រឹត្តល្មើសទៀត ត្រូវផាកពិន័យជាប្រាក់ទ្វេមួយជាពីរនៃប្រាក់ពិន័យលើកមុន ហើយក្រសួងមហាផ្ទៃអាចប្តឹងរំលាយគណបក្សនយោបាយនោះទៅតុលាការកំពូល។"

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤១.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤១.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៤០ ចាស់ ដែលចែងពី *"ត្រូវផាកពិន័យជាប្រាក់ចំនួន ៣ ០០០ ០០០ (បីលាន)រៀល ដោយក្រសួងមហាផ្ទៃ ចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៥ និងកថាខណ្ឌទី២ មាត្រា១៥ នៃច្បាប់នេះ។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤២.-ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤២.-ថ្មី ដោយកែប្រែខ្លឹមសារមាត្រា៤១ ចាស់ ដែលចែងពី *"ត្រូវផាកពិន័យជាប្រាក់ចំនួន ១០ ០០០ ០០០ (ដប់លាន)រៀល ដល់ ២០ ០០០ ០០០ (ម្ភៃលាន)រៀល និង/ឬផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ)ខែ ដល់ ០១ (មួយ)ឆ្នាំ ចំពោះជនណាដែលបានប្រព្រឹត្ត..."* និងបានកែសម្រួលរយៈពេលពី ១៨ ខែ មក ១៨០ ថ្ងៃវិញនៅចំណុចទី៣ ព្រមទាំងបន្ថែមមួយចំណុចទៀត គឺចំណុចទី៤ ដែលចែងពី *"នៅតែបន្តធ្វើសកម្មភាពក្នុងនាមគណបក្សនយោបាយខ្លួន ទោះជាមានសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយនោះក៏ដោយ។"*

មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ

- មាត្រា៨៣.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៨៣.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី *"បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ អ្នកមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាទៅតុលាការកំពូលក្នុងអំឡុងពេល ៣០ (សាមសិប)ថ្ងៃ គិតពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ។ ក្នុងអំឡុងពេលនៃការប្តឹងតវ៉ា និងអំឡុងពេលនៃការដោះស្រាយបណ្តឹងតវ៉ា សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ មិនមានអានុភាពអនុវត្តឡើយ លើកលែងតែសេចក្តីសម្រេចផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្តោះអាសន្ន។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី និង មាត្រា ១២៩ ថ្មី នៃរដ្ឋធម្មនុញ្ញ
- មាត្រា៨៤.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៨៤.-ថ្មី ជាមាត្រាតាក់តែងថ្មី ដែលចែងពី *"ដោយមិនទាន់គិតជល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា៦ថ្មី និងមាត្រា៧ នៃច្បាប់នេះ តុលាការអាចសម្រេចដូចខាងក្រោម÷*

  -ផ្អាកសកម្មភាពគណបក្សនយោបាយនោះក្នុងរយៈពេលមិនលើសពី ៥ ឆ្នាំ។

  -រំលាយគណបក្សនយោបាយនោះ។"

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ
- មាត្រា៨៥.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៨៥.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"តុលាការដែលមានសមត្ថកិច្ច ដើម្បីពិនិត្យលើបណ្តឹងនានាដោយអនុវត្តតាមច្បាប់នេះ គឺតុលាការកំពូល។ ដោយឡែកចំពោះមាត្រា៨២ថ្មី នៃច្បាប់នេះ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។*

  តំណាងមហាអយ្យការអមតុលាការកំពូលត្រូវចូលរួមសុំឱ្យមានការគោរពច្បាប់ នៅក្នុងពេលដែលមានបណ្តឹងដាក់ជូនតុលាការកំពូលពិនិត្យ។

  ក្នុងករណីដែលគណបក្សនយោបាយត្រូវបានរំលាយ តុលាការអាចសម្រេចហាមឃាត់ការធ្វើសកម្មភាពនយោបាយរបស់ថ្នាក់ដឹកនាំនៃគណបក្សនយោបាយនោះ សម្រាប់រយៈពេល ០៥ (ប្រាំ)ឆ្នាំបាន។

  តុលាការកំពូលត្រូវសម្រេចសេចក្តីលើអង្គហេតុ និងអង្គច្បាប់ ដោយសភាពេញអង្គ។ សាលដីការបស់តុលាការកំពូលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។"

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ
- មាត្រា៨៦.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៨៦.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"ការអនុវត្តជំពូកនេះ មិនរារាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ

- មាត្រា៤៧.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៧.-ថ្មី ជាមាត្រាតាក់តែងថ្មីដែលចែងពី *"បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថទីទី៨ (នីតិវិធីប្រតិបត្តិ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីត្រាក់ពិន័យបានចូលជាស្ថាពរ។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ
- មាត្រា៤៨.- ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា៤៨.-ថ្មី ជាមាត្រា៤៣ចាស់ដែលចែងពី *"បន្ទាប់ពីច្បាប់នេះចូលជាធរមាន គណបក្សនយោបាយទាំងអស់ដែលត្រូវបានបង្កើត និងបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ត្រូវបន្តសុពលភាព និងអាចធ្វើសកម្មភាពស្របតាមច្បាប់នេះ និងច្បាប់ជាធរមានផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែគណបក្សនយោបាយទាំងនេះ ត្រូវបំពេញសំណុំបែបបទធ្វើនិយ័តកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ យ៉ាងយូរ គិតពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។"*

  មាត្រានេះ ស្របតាមស្មារតីនៃមាត្រា ៤២ នៃរដ្ឋធម្មនុញ្ញ
- មាត្រា៤៩.-ថ្មី ជាមាត្រា៤៤ ចាស់ដែលចែងពី *" បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។"*

  មាត្រានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- មាត្រា៥០.-ថ្មី ជាមាត្រា៤៥ ចាស់ ដែលចែងពី *"ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់។"*

  មាត្រានេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា **មាត្រាមួយ** នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំមានបទប្បបញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា **មាត្រាពីរ** ដែលចែងថាច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា គ្រប់បទប្បញ្ញត្តិទាំងអស់នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំមានបទប្បញ្ញត្តិណាមួយមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

សម្រេច

មាត្រា ១. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ និងព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល ឯកភាពទាំងស្រុងលើទម្រង់និងគតិច្បាប់ដោយឥតកែប្រែក្នុងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

មាត្រា ២. សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្សព្វផ្សាយ ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧

ក្រុមប្រឹក្សាធម្មនុញ្ញ

អ៊ឹម ឈុនលី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៧៨/០០១/២០១១

ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១

សេចក្តីសម្រេច

លេខ : ១១៣/០០១/២០១១ កបធ.ច

ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៦៩ រ.ស ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ២០១១ របស់ឯកឧត្តម **ខួន ញ៉ឹម** ប្រធានរដ្ឋសភាស្តីទី ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២០ ខែមករា ឆ្នាំ២០១១ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១ វេលាម៉ោង ១៥ និង ៤៥ នាទី ។

អាគារស វិមានរដ្ឋមន្ត្រីការពារជាតិ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ: (+៨៥៥) ២៣ ៧២០ ៩១៣ ទូរសារ: (+៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgcc@camnet.com.kh, info@ccc.gov.kh
website: www.ccc.gov.kh. ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ៣

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យ និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ឡន ញ៉ិល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់នេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែង និង អនុម័តច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី១ ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា ដែលចែងអំពីគោលដៅកំណត់ការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា និយមន័យនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី២ ស្តីពីការរៀបចំសមាជ មាន ៦ មាត្រា ចែងអំពីប្រធានសមាជ ទីកន្លែងប្រារព្ធធ្វើសមាជ សមាសភាពគណៈកម្មាធិការសមាជ មុខងាររបស់ប្រធានសមាជ អគ្គលេខាធិការដ្ឋានសមាជ និងបន្ទុកចំណាយសម្រាប់ដំណើរការសមាជ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៣ ស្តីពីការប្រព្រឹត្តទៅនៃសមាជ មាន ៤ មាត្រា ចែងអំពីឥស្សរជនដែលមានសិទ្ធិផ្តួចផ្តើមឱ្យមានការប្រជុំសមាជ ការកោះអញ្ជើញឱ្យចូលរួមប្រជុំសមាជ កូរ៉ុមនៃការប្រជុំសមាជ សំឡេងអនុម័តរបស់សមាជ តម្លៃនៃសេចក្តីសម្រេចរបស់សមាជ ការផ្សព្វផ្សាយ និង ការចុះក្នុងរាជកិច្ច ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ជំពូកទី៤ ស្តីពីអន្តរប្បញ្ញត្តិ មាន ១ មាត្រា ចែងអំពីរយៈពេលនៃការកោះប្រជុំលើកដំបូងរបស់សមាជ ដើម្បីពិនិត្យ និង អនុម័តបទបញ្ជាផ្ទៃក្នុងរបស់សមាជ និង ការអនុវត្តបទបញ្ជាផ្ទៃក្នុងរដ្ឋសភាសម្រាប់ដំណើរការកិច្ចប្រជុំសមាជលើកដំបូង ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

- យល់ឃើញថា ខ្លឹមសារទាំង៤ជំពូក ១៤មាត្រា នៃច្បាប់នេះ ពុំមានបទប្បញ្ញត្តិណាមិនស្របនឹងរដ្ឋធម្មនុញ្ញទេ ។

សម្រេច

មាត្រា ១. ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និង ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និង ព្រឹទ្ធសភាបានពិនិត្យ និង ឱ្យយោបល់ ឯកភាពទាំងស្រុងលើទម្រង់ និង គតិច្បាប់ ដោយឥតកែប្រែ ក្នុងសម័យប្រជុំលើកទី៨ នីតិកាលទី២ នាថ្ងៃទី ២០ ខែ មករា ឆ្នាំ២០១១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២. សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១ ក្នុងកិច្ចប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១១

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ចោះពុម្ពផ្សាយដោយ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

វិមានរដ្ឋចំការមន, មហាវិថីព្រះនរោត្តម, ភ្នំពេញ
ទូរសារ: (៨៥៥-២៣) ២១១ ៤៤៦ / (៨៥៥-២៣) ២១១ ៤៤១
Email: oum_sarith@camnet.com.kh
Website : www.senate.gov.kh